ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត



- អ្នកបកប្រែក៏អាចជាវីរជនដែរ
- ខៀវ សំផន និង នួន ជា ថ្លែងការណ៍

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ១៦៧ ខែវិច្ឆិកា ឆ្នាំ២០១៣

# ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត

លេខ១៦៧ ខែវិច្ឆិកា ឆ្នាំ២០១៣

## មាតិកា

◆ អ្នកបកប្រែក៏អាចជាវីរជនដែរ ........................................ ១

**ផ្នែកឯកសារ**

◆ បទទទ្ទេសនាមរបស់សមមិត្តតំណាងអគ្គការបក្ស ........................................ ២

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆ ត្រូវការយុត្តិធម៌ មិនមែនថ្នាំព្យាបាលទេ ........................................ ១១

◆ ខៀវ សំផន ថ្លែងការណ៍ ........................................ ១៥

◆ នួន ជា ៖ មិនបានជម្លៀសប្រជាជនដោយបង្ខំទេ ........................................ ១៧

◆ នារីស្រែអំបិលរកយុត្តិធម៌ជូនឪពុក ........................................ ៣០

**ផ្នែកច្បាប់**

◆ កម្មវិធីវិទ្យុសហគមន៍របស់មជ្ឈមណ្ឌល ........................................ ៣៣

◆ ការរៀបចំសំណង ការប្រឈមមុខរបស់ដើមបណ្តឹងរដ្ឋប្បវេណី ........................................ ៣៧

◆ ការស្វែងយល់អំពីគេហទំព័រឃ្លាំមើល ........................................ ៤៣

**វេទិកាពិភាក្សាសាធារណៈ**

◆ អង្គជំនុំជម្រះសាលាដំបូងសម្រេចទទួលយកកំណត់ហេតុ ........................................ ៤៤

**ទំព័រស្រាវជ្រាវរកគ្រួសារ**

◆ ទណ្ឌិតផ្ទៃល្អៅ ........................................ ៤៧

◆ គ្រួសាររបស់ឪពុកខ្ញុំពីឆ្នាំ១៩៧៥ - ១៩៧៩ ........................................ ៥៣

◆ គំនិតក្មេងជំនាន់ក្រោយមួយរូបទាក់ទងនឹងសាលាក្តីខ្មែរក្រហម ........................................ ៥៧

◆ ម្តាយខ្ញុំចាំមិនភ្លេចសម័យបីឆ្នាំ ប្រាំបីខែ ម្ភៃថ្ងៃ ........................................ ៦១




ខៀវ សំផន កំពុងថ្លែងសុន្ទរកថាក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ

**រក្សាសិទ្ធិ**

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ០២៩១ពម.៩៩
ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

រូបថតឯកសារៈ មជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

**ស្នេរលេខនេះ ៖** គ្រីស្ទីន ប័រគ័រលី, លី សុខឃាង, រ៉េនឌល ឌីហ្វាល់កូ, ម៉ែន ពិចិត្រ, លន់ ដាលីន, អាន ហាញឌល, ឆាយ ស៊ូឆាត្រ, យ៉ាន់ នីកូឡា, ម៉ៅ ច័ន្ទដាលី, ស្រីនាថ ភូល **អ្នកនិពន្ធនិងស្រាវជ្រាវ ៖** ទាវ សារៈមុនិន្ទ, ស៊ិន សុធីតា **អ្នកបកប្រែ ៖** នង ច័ន្ទមល្លិកា និង ភួង ច័ន្ទប្រណិត **និពន្ធនាយកទូទៅ ៖** ឆាំង យុ និង ញាណ សុជាតិ **ជំនួយការនិពន្ធនាយក ៖** សោម ប៊ុនថន **ក្រាហ្វិកកុំព្យូទ័រ ៖** សោម ប៊ុនថន **គ្រប់គ្រងការចែកផ្សាយ ៖** ឆេង វើង Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiatribunal.org, www.cambodiasri.org

# អ្នកបកប្រែក៏អាចជាវីរជនដែរ

បុគ្គលជាច្រើនបាននឹងកំពុងដើរតួនាទីយ៉ាងសំខាន់ក្នុងការបង្កើតនិងធ្វើឲ្យមានឡើងវិញនូវពិភពលោករបស់យើងហើយខ្ញុំសូមយកឱកាសនេះដើម្បីទាញការចាប់អារម្មណ៍ចំពោះការចូលរួមចំណែករបស់បុគ្គលចំនួនបួនរូប ។ ថ្មីៗនេះ តុលាការយុត្តិធម៌អន្តរជាតិបានចេញសេចក្តីសម្រេចស្តីពីជម្លោះតំបន់ក្បែរប្រាសាទព្រះវិហារ ។ សេចក្តីសម្រេចនេះបានត្រូវបោះពុម្ព និងផ្សព្វផ្សាយយ៉ាងទូលំទូលាយតាមរយៈប្រព័ន្ធអ៊ីធឺណែតនៅជុំវិញពិភពលោក ។ ប៉ុន្តែ សម្រាប់កម្ពុជា មានពលរដ្ឋជាច្រើននាក់អាចនឹងពុំយល់ឬស្តាប់ឮសេចក្តីសម្រេចរបស់តុលាការយុត្តិធម៌អន្តរជាតិមួយនេះ ប្រសិនបើពុំមានការបកប្រែពីសំណាក់អ្នកបកប្រែបួនរូបតាមរយៈទូរទស្សន៍បណ្តាញព័ត៌មានកម្ពុជា (ស៊ី.អិន.ស៊ី) ។ នេះពុំមែនជាការចូលរួមចំណែកតូចតាចនោះទេ ។

អ្នកបកប្រែទាំងអស់នេះបានដើរតួយ៉ាងសំខាន់នៅក្នុងកិច្ចប្រឹងប្រែងជាសាកលដើម្បីធ្វើយ៉ាងណាឲ្យមានការទទួលបានព័ត៌មាន ។ ច្បាប់មានសារប្រយោជន៍ លុះត្រាណាតែប្រជាជនអាចយល់ពីអត្ថន័យនៃច្បាប់នោះ ។ សិទ្ធិមនុស្សអាចនឹងត្រូវបានលើកកម្ពស់ដរាបណាវាត្រូវយកមកអនុវត្ត ដោយប្រើប្រាស់តាមរបៀបភាសាសាមញ្ញ ហើយដំណើងអន្តរជាតិនឹងអាចធ្វើឲ្យប្រជាជនចាប់អារម្មណ៍បាននៅពេលណាដំណើងនោះត្រូវបានបកប្រែជាភាសាសម្រាប់ប្រជាជនសាមញ្ញដែលអាចយល់បាន ។



ប្រាសាទព្រះវិហារ

ប្រសិនជាពុំមានអ្នកបកប្រែទាំងបួនរូបនេះទេ ប្រជាជនកម្ពុជាជាច្រើន ទោះបីជាមិនលើសលប់ក៏ដោយ នឹងពុំមានឱកាសដើម្បីយល់ដឹងលម្អិតអំពីសេចក្តីសម្រេចស្តីពីប្រាសាទព្រះវិហារដែលជាសេចក្តីសម្រេចមួយមានអត្ថន័យយ៉ាងជ្រាលជ្រៅបំផុតសម្រាប់អធិបតេយ្យកម្ពុជា និងមនោសញ្ចេតនានៃប្រជាជនកម្ពុជាចំពោះអត្តសញ្ញាណរបស់ជាតិខ្លួនឡើយ ។ អ្នកបកប្រែទាំងបួនរូបបានផ្តល់ជូនប្រជាជនកម្ពុជានូវឱកាសមួយដើម្បីធ្វើជាសាក្សីនៃប្រវត្តិសាស្ត្រដែលពុំមែនជាឱកាសសម្រាប់នរណាម្នាក់ឡើយ ។

ប្រសិនបើទាញយកវាំងននចេញ គេនឹងអាចមើលស្គាល់ថា អ្នកបកប្រែទាំងបួនរូបគឺជាបុគ្គលិកនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានជួបប្រទះបញ្ហាវិបត្តិ និងភាពចម្រូងចម្រាសជាច្រើន ប៉ុន្តែចំណុចដែលសំខាន់គឺថា យើងអាចទាញយកឱកាសដើម្បីធ្វើជាគុណសម្បត្តិលុបលាងចំណុចមិនល្អទាំងនោះបាន ។ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានផ្តល់នូវការបណ្តុះបណ្តាល និងបទពិសោធន៍យ៉ាងសំខាន់ចំពោះប្រជាជនកម្ពុជា ហើយតាមរយៈបទពិសោធន៍ទាំងនេះ អ្នកបកប្រែទាំងបួនរូបអាចសម្រេចបានការបកប្រែមួយដែលមានលក្ខណៈជាប្រវត្តិសាស្ត្រយ៉ាងស្ទាត់ជំនាញនិងពោរពេញដោយទំនុកចិត្ត ។

នៅកន្លែងដែលមនុស្សទូទៅតែងផ្តល់កិត្តិនាមថាជាកន្លែងយុត្តិធម៌អន្តរជាតិបុគ្គលម្នាក់ៗគឺចាប់អារម្មណ៍លើកិច្ចការរបស់ចៅក្រម មេធាវី និងមន្ត្រីច្បាប់ដែលចូលរួមក្នុងការលើកកម្ពស់ឲ្យមាននីតិរដ្ឋប៉ុន្តែយើងពុំគួរមើលរំលងបុគ្គលិកទាំងអស់ដែលបានបម្រើការក្នុងតួនាទីយ៉ាងសំខាន់ដើម្បីស្វែងរកយុត្តិធម៌និងការលើកស្ទួយពិភពលោករបស់យើងទាំងអស់គ្នាឡើយ ។

**ឆាំង យុ**

# បទឧទ្ទេសនាមរបស់សមមិត្តតំណាងអង្គការបក្សក្នុងឱកាសបុណ្យខួបទី៩នៃកំណើតកងទ័ពបដិវត្តន៍កម្ពុជាដ៏អង់អាចក្លាហាន និងខ្លាំងពូកែមហាអស្ចារ្យ

*“ដកស្រង់ចេញពីសៀវភៅ យុវជន និងយុវនារីបដិវត្តន៍ លេខ៥ ខែឧសភា ឆ្នាំ១៩៧៦”*

**(តចប់)**

***ឃ) តទៅនេះគឺមានបញ្ហាមួយទៀត គឺបញ្ហាទប់ទល់កម្ចាត់សង្គ្រាមចារកម្មរបស់ខ្មាំងនៅក្នុងសង្គ្រាមប្រជាជនរបស់យើង ៖*** ក្នុងសង្គ្រាមប្រជាជនរបស់យើង គឺខ្មាំងវាវាយយើង មិនមែនតែយោធាទេ គឺវាវាយយើងខាងចារកម្ម ។ វាវាយយើងខាងចារកម្ម គឺវាយយើងជាយុទ្ធសាស្ត្រ វាយដោយលបលួចចូលក្នុងកងទ័ពយើង វាយដោយលបលួចចូលក្នុងប្រជាជនយើង ចូលក្នុងជួរយើង ដើម្បីបំផុសនូវមតិឃោសនាផ្សេងៗ ធ្វើម៉េចឲ្យកងទ័ពយើងច្របូកច្របល់ ឲ្យសមរភូមិយើងច្របូកច្របល់ ហើយវាធ្វើសកម្មភាពខ្លាំងណាស់នៅឆ្នាំ៧៣ ។ ឆ្នាំ៧៣ វាធ្វើខ្លាំង ឆ្នាំ៧៤ វាធ្វើខ្លាំង ។ វាធ្វើខ្លាំងណាស់ ។ សមរភូមិមុខក៏វាធ្វើខ្លាំង សមរភូមិក្រោយក៏វាធ្វើខ្លាំង ។ ខ្ញុំគ្រាន់តែលើកឧទាហរណ៍ខ្លះទេ ។ សមរភូមិ



*ប៉ុល ពត អំឡុងពេលជួបពិភាក្សាជាមួយគណៈប្រតិភូបរទេសក្នុងរបបកម្ពុជាប្រជាធិបតេយ្យ*

ខ្លះ យើងត្រូវឈ្នះ១០០ភាគរយ ទៅជាមិនឈ្នះ ហើយសមរភូមិខ្លះ យើងឈ្នះទៅ ហើយ ទៅជាខ្មាំងដណ្ដើមវិញបាន ។ ខ្មាំងមិនខ្លាំងទេ ក៏ប៉ុន្ដែ មកពីវាមានរនុកក្នុង វាមានចារកម្មទាក់ទងដោយទូរស័ព្ទអាកាសគេអូ ។ ក្នាក់ងាររវាងនិយាយជាមួយយើងផង និយាយជាមួយខ្មាំងផង ។ នៅកន្លែងណាក៏មានបញ្ហានេះ ស្គាល់បញ្ហានេះ ។ ដូច្នោះ ផែនការខ្លះរបស់យើងខ្មាំងដឹង ។ ខ្ញុំយកឧទាហរណ៍ខ្លះ ដើម្បីជម្រាប ។ ផ្លូវលេខ៥ ពីព្រែកព្នៅទៅកំពង់លួង យើងរៀបចំដោយខ្មាំងដឹង ។ ពេលរៀបចំឆ្លងទន្លេសាបមកវាយ បញ្ជាការសមរភូមិរាយការណ៍មកថ្នាក់លើថា ឥឡូវខ្មាំងដឹងហើយ ខ្មាំងដឹងខ្លួន វាប្រុងប្រៀបទប់ទល់យើង តើវាយឬមិនវាយ ។ ប៉ុន្ដែ ខាងលើថា ត្រូវវាយដាច់ខាត ព្រោះផែនការមិនមែនវាយតែផ្លូវលេខ៥ទេ គឺវាយទូទាំងប្រទេស ។ បើវាយមិនឈ្នះ ក៏ភ្ជាប់ជើងខ្មាំង នៅលើផ្លូវលេខ៥នេះដែរ ។ ខ្មាំងដឹងមុន ដោយមានសមាសភាពលបលួចចូលមកក្នុងកងទ័ពយើង ។ ម្នាក់ពីរនាក់ទេ ។ ក្រោយមក យើងរកឃើញ ។ នេះជាឧទាហរណ៍មួយ ។ ឧទាហរណ៍មានច្រើនណាស់ ។ វាយព្រៃវែងពីឆ្នាំ៧៤ ។ យើងវាយជុំវិញភ្នំពេញហើយ វាយផ្លូវលេខ១ហើយ យើងត្រៀមរៀបចំវាយផ្ដាច់ព្រៃវែងនៅរដូវវស្សា ។ ផែនការតាមគណៈអចិន្ត្រៃយ៍ភាគរាយការណ៍មកខាងលើថា វាវាយដាច់១០០ភាគរយ ។ ប្រៀបធៀបកម្លាំងខ្មាំងនិងយើង យើងវាយដាច់១០០ភាគរយ ព្រោះព្រៃវែងឯកោយូរឆ្នាំមកហើយ គ្មានអីជួយទាំងអស់ ។ ប៉ុន្ដែ វាដឹងផែនការមុន វារៀបចំមុន ។ កងណាទៅមុខព្រួញណា កងណាត្រូវវាយមុខព្រួញណា វាដឹងកងខ្លាំង កងខ្សោយរបស់យើង វាទប់តាមនឹង ។ ដូច្នេះ យើងវាយមិនឈ្នះ មិនមែនមកពីបញ្ហាទ័ពទេ មកបញ្ហាខ្មាំងដឹងសកម្មភាពមុន ។ ដឹងមុនដោយសារអី ដោយសារចារកម្ម ។ ខ្ញុំលើកជាឧទាហរណ៍ខ្លះយ៉ាងនេះ ។ ដូច្នេះ បានជាយើងលើកវិធានការទប់ទល់ចារកម្មនៅក្នុងឆ្នាំ១៩៧៤នេះដាច់ខាត ។ មានវិធានការដាច់ខាត ។

វិធានការទី១ គឺបិទទ្វារបក្សទាំងមូលមិនពង្រីកបក្សទៀតទេ ចាប់ពីពាក់កណ្ដាល៧៤ ។ ទន្ទឹមនេះ មិនឲ្យពង្រីកអង្គការស្នូលជាថ្មីទៀតទេ ចាប់ពីពាក់កណ្ដាល៧៤ ។ លើកលែងតែកងទ័ព ។ នៅក្នុងកងទ័ព បក្សសម្រេចថាឲ្យពង្រីកបានពីព្រោះកងទ័ពពលីកម្មច្រើន បក្ខជនពលីកម្មច្រើនកម្មាភិបាល ពលីកម្មច្រើន ។ ត្រូវបង្កើនបក្ខជននេះ មកទទួលខុសត្រូវដឹកនាំ ក៏ប៉ុន្ដែ ដើម្បីទប់ទល់កុំឲ្យខ្មាំងវាបញ្ចូលគ្នាវាបាន យើងសម្រេចថា ក្នុងកងទ័ពបញ្ចូលអង្គការស្នូលបានបញ្ចូលបក្សបាន លុះត្រាតែ សាខាអនុសេនាធំយល់ព្រម គណៈកម្មាធិការបក្ស វរៈសេនាតូចយល់ព្រម គណៈកម្មាធិការបក្ស វរៈសេនាធំយល់ព្រម និងគណៈកម្មាធិការបក្សកងពលយល់ព្រម ។ ត្រូវ៤ថ្នាក់យល់ព្រម ។ មិនដូចពីមុន សាខា យល់ព្រម វរៈសេនាតូចអនុម័តទេ ។ ពីមុន ចូលបានធូរណាស់ បានជាយើងលើកលក្ខណៈសម្បត្តិចូលបក្សទាល់តែ៤ថ្នាក់យ៉ាងនេះ ដើម្បីទប់ទល់កុំឲ្យខ្មាំងជ្រៀតចូលបានទៅក្នុងកងទ័ព ។ មិនមែនគ្រាន់តែសាខាពិនិត្យទេ គឺរហូតកងពលពិនិត្យ បើខុស វាខុសតិច ។ មិនមែនមិនខុសសោះទេ ប៉ុន្ដែខុសតិច ។ ត្រូវភាគច្រើន ។ ដូច្នេះ យើងបិទទ្វារ ហើយយើងមានវិធានការតឹងរឹងពាក់កណ្ដាល៧៤ ។ ឯក្រៅពីកងទ័ព អត់ឲ្យចូលទេ ពីព្រោះខ្មាំងវាយយើង មិនមែនវាយតែក្នុងកងទ័ពទេ វាយក្នុងមូលដ្ឋាន វាយក្នុងរដ្ឋអំណាច វាយចូលក្នុងឈ្លប វាយចូលក្នុងសិល្បៈចូលទៅមន្ទីរពេទ្យ ចូលទៅអង្គភាពទាំងអស់ ហើយវាវាយយើង ។ ដូច្នោះ យើងមានវិធានការទប់ទល់ហ្មត់ចត់ បិទទ្វារពីពាក់កណ្ដាល៧៤មក ។ វិធានការនេះ តាមបក្សយើងពិនិត្យមានប្រសិទ្ធភាពទប់ទល់ខ្មាំងពី៧០ទៅ៨០ភាគរយ ។ យើងទប់ទល់សកម្មភាពខ្មាំងមិនឲ្យចូលមកផ្ទៃក្នុងយើងបានពី៧០ទៅ៨០ភាគរយ ។ ពីមុនវាចូលតាមចិត្ត ។ ឥឡូវពីពាក់កណ្ដាល៧៤មក ដែលយើងមានវិធានការយ៉ាងនេះ យើងទប់ទល់បានពី៧០ទៅ៨០ភាគរយ ។ ដូច្នោះកម្លាំងវាខ្សោយ កម្លាំងវាត្រូវចូល១០០ វាចូលបាន២០ ។ បើកម្លាំងវាតែ២០ វាធ្វើសកម្មភាពអុកយើងមិនបាន បន្ទំរស់នៅក្នុងកងទ័ពរស់នៅសមរភូមិខាងក្រោយមិនបានទេ ។ ដូច្នោះវិធានការរបស់យើងពី៧៤ មិនមែនដោះស្រាយបញ្ហាចារកម្មរបស់ខ្មាំងនេះបានទាំងអស់ទេ ក៏ប៉ុន្ដែ បានភាគច្រើនទប់ទល់ឲ្យវាចូលបានកម្រិតតិច ហើយយើងប្រើប្រាស់កម្លាំងយើងបានជាអតិបរមា ។ អាស្រ័យដោយវិធានការយ៉ាងនេះហើយ បានជាកងទ័ពយើងខ្លាំងនៅចុងឆ្នាំ៧៤ និងដើម៧៥ ។ សមរភូមិខាងក្រោយរបស់យើងក៏ខ្លាំងក្នុងចុង៧៤ និងដើម៧៥ ។ យើងវាយខ្មាំងបានទាន់ពេលវេលា ។ បញ្ហានេះជាបញ្ហាពិសោធន៍មួយធំណាស់ ជាពិសោធន៍មួយធំនៅក្នុងសកលលោក ។ សមមិត្តនៅកងទ័ពក្ដីឬក្រៅកងទ័ពក្ដីត្រូវ

ក្តាប់បញ្ហានេះ បច្ចុប្បន្នក៏ដូចអនាគត ។

ខ្មាំងវាយតាមសង្គ្រាមចារកម្មជាបញ្ហាពិសពុលណាស់ ។ វាយចំមុខជាបញ្ហាម្យ៉ាង តែបើវាយជាសម្ងាត់ ជាការលំបាក ។

នៅក្នុងប្រទេសជាច្រើន ខ្មាំងបញ្ចូលភ្នាក់ងារវាទៅក្នុងជួរបក្សបាន ។ ដូច្នោះ ទៅជាបក្សពីរ រហូតដល់បក្សបី ។ កងទ័ពក៏បំបែកគ្នាជាពីរ ជាបី ។ វាឲ្យឈ្មោះផ្សេងៗ ទៅ ។

ខ្មាំងវាធ្វើសកម្មភាពខ្លាំង តែបើបក្សឯកភាពគ្នា មានវិធានការហ្មត់ចត់ ខ្មាំងចូលមិនចុះ ។ បក្សយើងនៅតែបក្សមួយ ។ កងទ័ពយើងនៅតែកងទ័ពមួយ ។ ចក្រពត្តិក៏ចូលមិនបាន ខ្មាំងណាក៏ចូលមិនបាន ។

ពេលយើងបើកវាយសមរភូមិភ្នំពេញផ្តាច់ព្រ័ត្រ យើងរក្សាការសម្ងាត់បាន ។ ខ្មាំងអត់ដឹង វាប៉ាន់ប្រមាណកម្លាំងយើងមិនបាន វាទប់ទល់យើងមិនបាន ។

ដូច្នោះ បើយើងមិនកម្ចាត់ចារកម្មបានទាន់ពេលវេលាទេ យើងមិនរំដោះបានថ្ងៃ១៧មេសា ទេ ។ បក្សទាំងមូល កងទ័ពទាំងមូល ត្រូវដកពិសោធន៍ ហើយក្តាប់ពិសោធនេះ ។ ពេលកន្លងមកក៏ដូចបច្ចុប្បន្ន និងទៅអនាគត ។ ខ្មាំងនៅតែបន្តវាយយើង ។ សង្គ្រាមទល់មុខក៏ជាការតស៊ូវណ្ណៈមួយ ។ យើងត្រូវបន្តប្រយុទ្ធតទៅទៀត ។ យើងត្រូវមានកងទ័ពតទៅទៀត យើងត្រូវពង្រឹងនិងពង្រីកកងទ័ពតទៅទៀត ។ សង្គ្រាមនៅមានជាប្រចាំ មិនទាន់អស់ទេ អាចជាសង្គ្រាមតូច ធំ តំបន់ ឬសកលលោក ។ យើងត្រូវត្រៀមជាមុន ហើយត្រៀមសំខាន់គឺទស្សនៈ គោលជំហរម្ចាស់ការជាមុន ។

◆ មាគ៌ាប្រយុទ្ធមួយចំនួន

មាគ៌ាប្រយុទ្ធទី១របស់យើង គឺវាយឈ្លប និងវាយសម្បូរបែប ដោយយកឈ្លបជាមូលដ្ឋាន ហើយយកសម្បូរបែបដើម្បីសម្រេច ។ ជាមាគ៌ាប្រយុទ្ធរបស់បក្សយើងក្នុងសង្គ្រាមប្រជាជន ។ ធ្វើសង្គ្រាមប្រជាជនដើម្បីឈ្នះ ត្រូវប្រយុទ្ធពីរយ៉ាង ៖ វាយធំ ដោយកងសម្បូរបែប ក៏ត្រូវមាន ប៉ុន្តែ វាយតូច ដោយកងឈ្លប ក៏ត្រូវមាន ។ ប៉ុន្តែ វាយសម្បូរបែប និងវាយឈ្លបមានតួនាទីខុសគ្នា ។



យោធាខ្មែរក្រហមធ្វើដំណើរទៅកាន់សមរភូមិនៅមុំទំនប់កប់ស្រូវ ជាយក្រុងភ្នំពេញ ក្នុងអំឡុងចុងឆ្នាំ១៩៧៤ ឬដើមឆ្នាំ១៩៧៥

វាយឈ្លបគឺវាយបានរាល់ថ្ងៃ ប្រៀបដូចដញ្ញាត់ត្រី ។ នរណាក៏ដញ្ញាត់ត្រី ។ នរណាក៏ដញ្ញាត់បានដាក់ពីស ជាក្រឹម ។ ក្នុងសង្គ្រាម បក្សបានលើកថា បើយើងវាយឈ្លបទូទាំងប្រទេសមួយក្រុម ឈ្លបវាយខ្មាំងឲ្យរបួសម្នាក់ និងស្លាប់មួយនាក់ក្នុងមួយថ្ងៃ ។ បើមាន១០០០ក្រុម ៥០០០ក្រុម តើមួយថ្ងៃកម្ទេចខ្មាំងបានប៉ុន្មាននាក់? ច្រើនណាស់ ។ នេះជាសង្គ្រាមប្រជាជន ធ្វើឲ្យខ្មាំងហេវហត់ អស់កម្លាំង បាត់ស្មារតី ឲ្យខ្មាំងច្របូកច្របល់ ។

ប៉ុន្តែ សង្គ្រាមឈ្លបសម្រេចជ័យជម្នះមិនបានទេ កម្ទេចខ្មាំងមិនបានទេ ត្រូវធ្វើសង្គ្រាមសម្បូរបែបទៀត ត្រូវប្រើកម្លាំងសម្បូរបែប ដើម្បីកម្ទេចខ្មាំងរាប់រយ រាប់ពាន់ រាប់ម៉ឺន បានខ្មាំងវាបរាជ័យទាំងស្រុងបាន ។

ត្រង់នេះហើយ ពាក្យស្លោកដែលថា ធ្វើសង្គ្រាមប្រជាជនដោយអនុវត្តមាគ៌ាប្រយុទ្ធ ធ្វើសង្គ្រាមឈ្លបផង សង្គ្រាមសម្បូរបែបផង ដោយយកសង្គ្រាមឈ្លបជាមូលដ្ឋាន សម្បូរបែបដើម្បីកម្ទេច ។

សមមិត្តដឹកនាំសង្គ្រាមតទៅទៀត ក៏ត្រូវអនុវត្តមាគ៌ានេះ ។ ដូច្នេះ បានជាយើងរៀបចំអាវុធ ទៅតាមនេះដែរ ។ រៀបចំអាវុធសម្បូរបែប ក៏រៀបចំ រៀបចំអាវុធឈ្លប ក៏រៀបចំឈ្លបនេះ គឺឈ្លបអង្គភាពផង ឈ្លបប្រជាជនបំពាក់អាវុធផង ។

នៅក្នុងសង្គ្រាមផ្ទៃក្នុង១៩៦៨-៦៩ យើងគ្មានអាវុធទេ ។ ប៉ុន្តែ នៅក្នុងភូមិឃុំ ចុងកាត់ មាត់ញក តើមានទាហានប៉ុន្មាន ។ មិនច្រើនទេ ។ មួយឃុំជួនណាមានពីរបីនាក់ តើប៉ុណ្ណឹង ឈ្លបយើងទៅវាយវាបានទេ? វាយបាន ។ ដៃទទេ ក៏វាយបាន ។ ដំបងក៏វាយបាន ។ ផ្គាក់ក៏វាយបាន ដណ្តើមកាំភ្លើងពីខ្មាំងបានទៀត ។ ចាប់ទាហាន ចាប់ប្រធានភូមិ រឹបយករដ្ឋអំណាចភូមិថ្មី ចាត់តាំងឈ្លបថ្មីទៀត ។ នេះជាមាគ៌ាសង្គ្រាមប្រជាជនត្រឹមត្រូវ ។ បើមិនអ៊ីចឹងទេគិតថា ដើម្បីធ្វើសង្គ្រាមរំដោះជាតិ ត្រូវទៅពឹងពាក់ប្រទេសនេះ ប្រទេសនោះអត់បានទេ ។

អនុវត្តសង្គ្រាមឈ្លប ប្រើអាវុធអីក៏បានដែរ ។ អនុវត្តមាគ៌ាសង្គ្រាមយ៉ាងនេះ គឺខ្លាំងណាស់ ។ ឧទាហរណ៍ ខេត្តរតនគិរី មាន៣៤ឃុំ ។ ថ្ងៃ៣០ខែ០៣ យើងផ្ទុះអាវុធ ខែ៤ យើងរំដោះ៣២ឃុំ ។ ខ្មាំងមាននៅតែ២ឃុំ ។ វាយរបៀបដៃទទេ យកកម្លាំងហិង្សារបស់ប្រជាជនទៅវាយខ្មាំងដោយដៃទទេ រឹបយកអាវុធពីខ្មាំង ។

ដូច្នោះ សង្គ្រាមឈ្លបជាសង្គ្រាមមូលដ្ឋាន ជារូបភាពប្រយុទ្ធជាមូលដ្ឋានរបស់យើង ។ វាយឈ្លប រាល់ពេល រាល់វេលារួមផ្សំនឹងសង្គ្រាមសម្បូរបែប ខ្មាំងទប់ទល់មិនបានទេ ។ សក្តិសិទ្ធិណាស់ក្នុងសង្គ្រាមរបស់យើង ។ យើងអនុវត្តបានយ៉ាងនេះត្រឹមត្រូវ ។ វាយយ៉ាងនេះបានសក្តិសិទ្ធិ ។ ជាវិទ្យាសាស្ត្រសង្គ្រាមខ្ពស់ណាស់ ។ វិទ្យាសាស្ត្រ ដើម្បីវិភាគខ្មាំងនិងយើងឲ្យច្បាស់លាស់ ដើម្បីរៀបចំ យុទ្ធសាស្ត្រ យុទ្ធវិធីវាយ ។ បើវាយយ៉ាងនេះ យើងដណ្តើមរដ្ឋអំណាចភូមិ ឃុំបាន ។ ខ្មាំងគ្មានកម្លាំងមកដណ្តើមយើងវិញបានទាំងអស់ទេពិសេស ភូមិឃុំនៅចុងកាត់មាត់ញក ។ នេះជាយុទ្ធសាស្ត្រ ជាពិសោធថ្មីថ្មោងនៅក្នុងសកលលោក ។

ឯពិសោធន៍ប្រទេសខ្លះកន្លងមក គេវាយតែទីតាំង ។ ទីតាំងខ្មាំងអនុសេនាតូច អនុសេនាធំ ដើម្បីវាយទីតាំងវា មួយអនុសេនាតូចយើងមួយអនុសេនាធំពិបាកវាយវា ។ យើងមួយអនុសេនាធំ ទៅវាយវាមួយអនុសេនាតូច ក្នុងទីតាំងរបស់វា ក្នុង១០ភាគ មានលទ្ធភាពឈ្នះវា តែមួយភាគទេ ។ ដូច្នេះ យកខ្សែរាយរបស់យើងទៅវាយវាខ្លាំង ។

ឯយើង យើងមិនវាយទីតាំងទេ ។ យើងវាយភូមិ បើវាយភូមិហើយ ទីតាំងវាមួយអនុសេនាតូច ពីរអនុសេនាតូច មួយអនុសេនាធំ បើយើងដណ្តើមបានបួនប្រាំឃុំហើយវារត់ឯង ។ ចាំរៀបចំវាយវា ក្រៅទីតាំង ។ យើងវាយរបៀបយ៉ាងនេះបានខ្លាំង ។

មាគ៌ាប្រយុទ្ធទី២ វាយឲ្យខ្លាំងក្លាជាបន្តបន្ទាប់ ទាំងប្រាំងទាំងវស្សា ទាំងយប់ ទាំងថ្ងៃ ដើម្បីកុំឲ្យខ្មាំងដកដង្ហើមបាន ៖ មតិខ្លះអាចចោទថា ដើម្បីវាយដូច្នេះបាន ទាល់តែមានកងទ័ពច្រើន មានអាវុធច្រើន ផ្លាស់គ្នាវាយ ។ តែបើកងទ័ពយើងមិនច្រើន អាវុធយើងមិនច្រើន យើងផ្លាស់គ្នាវាយ ទាំងថ្ងៃ ទាំងយប់ ទាំងប្រាំង ទាំងវស្សាមិនបានទេ ។ ចោទបញ្ហានេះ ។

តែយើងមិនដោះស្រាយយ៉ាងនេះទេ ។ យើងអនុវត្តមាគ៌ាប្រយុទ្ធរបស់យើង ។ ឈ្លបយើងវាយអត់ហត់ទេ ។ ដើរយាមតាមផង លបមើលក្រឹត្យក្រមខ្មាំងផង វាយខ្មាំងផង ។ វាយឲ្យខ្មាំងរបួសមួយ របួសពីរ ត្រឡប់មកផ្ទះវិញ ។ ខ្មាំងលោះព្រលឹងរាល់ថ្ងៃ ។ ត្រឡប់មកផ្ទះវិញច្រូតស្រូវ បង្កបង្កើនផលធម្មតា បំប៉នកម្លាំងទៀត ។ ដូច្នោះ ឈ្លបសុទិដ្ឋិនិយមណាស់ ។ អត់មានបញ្ហាអីទេ

ហើយ ពិសេសឈ្លបនៅចុងកាត់មាត់ញក ជាវណ្ណៈមូលដ្ឋាន ។ ខោខ្លីមួយ ផ្កាក់មួយ វាយខ្មាំងបាន ។ កន្លែងខ្លះប្រើស្នា កន្លែងខ្លះប្រើធ្នូ ដោយជ័រឆក់ ។ ទៅដល់កន្លែងណាផ្គត់ផ្គង់កន្លែងនោះ ។ ជីកក្តាម រកម្ហូប ខបត្តម្ភខ្លួនឯង ឯករាជ្យ ម្ចាស់ការ ខ្លួនទីពឹងខ្លួនកម្រិតខ្ពស់បំផុត ។ ដូច្នោះ អ្នកណាក៏វាយបានដែរ ។ កសិករក្រ កសិករកណ្តាលថ្នាក់ក្រោម វាយពូកែណាស់ ។ ដឹងច្រកល្ហកទាំងអស់ ។ គេរីករាយណាស់ ។ គេរីករាយនឹងទៅវាយ ។ មកវិញគេរីករាយនឹងរាយការណ៍ ។ ដូច្នេះ អត់គិតពីរឿងគ្មានកាំភ្លើង អត់គិតពីរឿងគ្មានគ្រាប់ អត់គិតពីរឿងគ្មានស្បៀងអីទេ ។ គេរស់នៅធម្មតាគេទៅវាយខ្មាំងធម្មតា ។ គេវាយយ៉ាងនេះ ទាំងយប់ ទាំងថ្ងៃ វាយបាន ។

ឯកងទ័ពស្រួចរបស់យើង ក៏ដូច្នេះដែរ ។ ក្នុងសង្គ្រាម៥ឆ្នាំយើងវាយយ៉ាងនេះ គឺក្នុងរដូវប្រាំង យើងរៀបចំវាយជាយុទ្ធសាស្ត្រ ។ តាមមុខព្រួញធំៗ ក្នុងរដូវប្រាំង យើងវាយខ្មាំងជាដែនការដើម្បីរកម្ទេចកម្លាំងខ្មាំង ។ ប៉ុន្តែខែវស្សាយើងថយ ។ ដកកម្លាំងមួយចំនួនមកបំប៉ន រៀនសូត្រ តែទុកកម្លាំងដើម្បីវាយឈ្លបតទៅទៀត ។ ខ្មាំងមិនដឹងថា យើងដកថយមកបំប៉នកម្លាំងទេ ។ វាទប់ទល់យើងជាប់ ។ កន្លែងណា ក៏យើងអនុវត្តមាគ៌ាយ៉ាងនេះដែរ ។ ដូច្នេះ ប្រាំងក៏វាយបាន វស្សាក៏វាយបាន ។ យើងបំប៉នកម្លាំងបានផង វាយខ្មាំងបានជាប់ផង ។ ខ្មាំងប៉ាន់ប្រមាណកម្លាំងយើងមិន ។ ជាយើងមានកម្លាំងប៉ុន្មានម៉ឺន ប៉ុន្មានសែនទេ បានជាវាយវាយ៉ាងនេះ ។ មកពីយើងអនុវត្តមាគ៌ាត្រូវ ។ គ្រាន់តែឃើញយ៉ាងនេះ យើងឃើញថា យើងខ្លាំង ។

មាគ៌ាប្រយុទ្ធទី៣ វាយពង្រិចពង្រិល និងបង្ហត់បង្ហេវខ្មាំង ដើម្បីបង្កឱកាសកម្ទេចខ្មាំង ៖ ដើម្បីឲ្យខ្មាំងហត់ហេវ យើងវាយឈ្លបឲ្យតែយូរទៅ ដល់ខ្មាំងហត់ហេវ យើងប្រមូលកម្លាំងតំបន់ប្លុកម្លាំងស្រួចទៅកម្ទេចវា ។

ដូច្នេះ ចៀសវាងកុំប្រមូលកម្លាំងទៅវាយកម្លាំងថ្មីរបស់ខ្មាំង ។ បើខ្មាំងវាកំពុងពេញកម្លាំងវា យើងទៅវាយប្រមូលផ្តុំយើងចំណាយកម្លាំងច្រើនណាស់ ។ វិធីវាយរបស់យើង យើងបង្ហត់វាសិន ។ ធ្វើឲ្យវាហត់ ដោយវាយឈ្លបជាបន្តបន្ទាប់ ។ វាហត់មួយរយៈហើយ សឹមយកកម្លាំងធំទៅវាយវា ។ បើវាយយ៉ាងនេះលទ្ធភាពឈ្នះ៨០ភាគរយ ។

ដូច្នេះបានជាបក្សថា បើខ្មាំងបុកខ្លាំង កុំវាយទល់ជ្រួក ។ បើវាបុកខ្លាំងហើយ វាលូតកាន់តែឆ្ងាយ ក្បាលវាខ្លាំង តែកន្ទុយវាខ្សោយ ។ យើងកុំទល់ជ្រួក យើងវាយកន្ទុយ និងពីចំហៀង ។ យើងកុំទប់ក្បាលវា យើងមកវាយកន្លែងដែលវាខ្សោយ ដើម្បីពង្រិចពង្រិលវា បង្កឱកាសកម្ទេចវា ។

ទី៤ វាយតូច វាយធំ វាយមធ្យម វាយពីមុខ វាយពីក្រោយ វាយពីចំហៀង វាយពីកន្ទុយ វាយពិសេស វាយសង្គ្រប់ វាយកាត់ជាកង់ៗ វាយក្នុងបរិវេណខ្មាំង វាយក្រៅបរិវេណខ្មាំង ៖ យើងលើកទិសយ៉ាងនេះ កុំឲ្យទាល់សុញ ។ វាយយ៉ាងណាបាន យើងវាយយ៉ាងនោះ ។ យើងស្ថិតក្នុងសភាពម្ចាស់ការគំនិតផ្តើមជាប់ ។ យើងអត់សុញទេ យើងរស់រវើក ។

តាមពិសោធន៍រៀនសូត្រ ឆ្នាំ១៩៧៣ និង១៩៧៤ កងទ័ពយើងជឿជាក់ថា ដាច់ខាតយើង វាយឈ្នះ ។ ស្នៀតយើងច្រើនណាស់ ។ ជួនណាប្រើ១ ជួនណាប្រើ២ ឬប្រើ៣ រួមផ្សំគ្នា ។ តែចៀសវាង កុំវាយទល់ជ្រួក ។ យើងគេចទៅវាយពីឆ្អឹងជំនី និងពីកន្ទុយខ្មាំងវិញ ។ វាយយ៉ាងនេះ យើងមានប្រៀបខ្មាំងចូលមកមិនបានទេ វាចូលមកយើងវាយកាត់វា ។ ដូច្នោះ យើងគំនិតផ្តើមជាប់ ។ ខ្មាំងរត់តាមយើង មិនមែនយើងរត់តាមខ្មាំងទេ ។

ឧទាហរណ៍ វាយកាត់ជាកង់ៗ នៅផ្លូវលេខ៥ ។ ដំបូងយើងវាយខាងលិចកំពង់ឆ្នាំង ។ ខ្មាំងប្រមូលកម្លាំងទៅបុកយើង ។ យើងលើកទ័ពមកវាយវានៅខាងត្បូងកំពង់ឆ្នាំងវិញ កាត់វាជាកង់ៗ ។ ដូច្នោះ ខ្មាំងរត់តាមយើង ។ យើងធ្វើឲ្យវារត់តាមយើង ។ ខ្មាំងខ្លាំងទៅជាខ្សោយ ។ នៅបូព៌ា នៅផ្លូវលេខ១ នៅខាងកើតភ្នំពេញ ក៏ដូច្នោះដែរ ។ ឆ្នាំ១៩៧៣ នៅតាមផ្លូវលេខ៣ ក៏យើងវាយកាត់កង់ៗ ឯកោខ្មាំងនៅត្រាំខ្នារ និងនៅស្រង់ ឲ្យវាទៅជាកម្លាំងងាប់ ។ ដល់យើងឯកោវាហើយ វាទាក់ទងភ្នំពេញ និងកំពង់កន្ទួតមិនបានទេ យើងវាយរំដោះវាតែម្តង យើងវាយកាត់ជាកង់ៗ ធ្វើឲ្យកម្លាំងខ្មាំង ជាច្រើនកប់ចោលទទេ ។

ពិសោធន៍របស់កងទ័ពបដិវត្តន៍យើងមានច្រើនណាស់ នៅតែចងក្រង ដើម្បីរៀនសូត្រទេ ។

ទី៥ វាយដោយប្រើទាំងអាវុធបុរាណ ទាំងអាវុធសម័យទាំងអាវុធពាក់កណ្តាលសម័យ រួមផ្សំគ្នាទាំងអស់ ៖ ធម្មតាខ្មាំងប្រើកាំភ្លើងធំ និងរថក្រោះ ។ វាប្រើកាំភ្លើងធំមុន ទើបឲ្យថ្មើរជើង

ចូលទៅ យើងដាក់ចម្រូង ថ្មើរជើងវាចូលមកត្រូវចម្រូងយើង ។ ដូច្នោះ វាឲ្យរថក្រោះទៅមុន ទើបថ្មើរជើង ដើរមកតាមក្រោយ តែរថក្រោះ បើអត់ថ្មើរជើង វាមើលមិនឃើញអស់ ។ យើងប្រើបេ៤០កម្ទេច វារត់មកក្រោយ ជាន់ថ្មើរជើងគ្នាវាវិញ ។ ដូច្នោះ ចម្រូង និងបេ៤០ រួមផ្សំគ្នា ។

ទាំងអស់នេះ យើងគ្រាន់តែរំឭកខ្លះៗ នូវមាគ៌ាសង្គ្រាមប្រជាជនរបស់យើង ។ ថ្ងៃក្រោយ យើងត្រូវរំឭកថែមទៀត ។

## ៤) អំពីភារកិច្ច បន្តពង្រឹងពង្រីក បន្តកសាងកងទ័ពបដិវត្តន៍របស់បក្សយើងតទៅទៀត

កងទ័ពបដិវត្តន៍កម្ពុជាយើងបានកកើតឡើងដល់ថ្ងៃនេះ បានសាកល្បងក្នុងចលនាតស៊ូបដិវត្តន៍ ច្រើនលើកច្រើនគ្រា ដ៏យូរលង់ អនុវត្តហិង្សាបដិវត្តន៍ក្នុងសភាពបត់បែនស្មុគស្មាញ ធ្វើសង្គ្រាមឈ្លប ក្នុងក្របខណ្ឌនៃសង្គ្រាមផ្ទៃក្នុងតឹងតែង ហើយធ្វើសង្គ្រាមរំដោះជាតិ រំដោះប្រជាជន៥ឆ្នាំ ក្នុងសភាពអង់អាចក្លាហាន ពុះពារការលំបាកគ្រប់បែបយ៉ាងទាំងអស់ ហើយរហូតដណ្តើមបានមហាជ័យជម្នះ ថ្ងៃ១៧ មេសា ១៩៧៥ ។ កងទ័ពនេះជាកងទ័ពដែលមានគុណភាពខ្ពស់ ខាងនយោបាយ ខាងសតិអារម្មណ៍ និងខាងចាត់តាំង ។ ក្តាប់ជាប់ និងអនុវត្តបានល្អ នូវមាគ៌ាយោធារបស់បក្ស នូវសង្គ្រាម ប្រជាជនរបស់បក្ស នូវមាគ៌ាប្រយុទ្ធរបស់បក្ស ទើបដណ្តើមបានមហាជ័យជម្នះយ៉ាងនេះ ។ កងទ័ពយើងជាកងទ័ពមួយដែលល្អក្នុងកងទ័ពដែលល្អបំផុតនៅក្នុងសកលលោក ទាំងនយោបាយ ទាំងសតិអារម្មណ៍ ទាំងចាត់តាំង ទាំងបច្ចេកទេសប្រយុទ្ធ ។ រហូតដល់ថ្ងៃនេះ កងទ័ពនេះ មានគុណភាពយ៉ាងនេះ យើងមិនបំផ្លើស យើងមិនពន្លើសនូវគុណភាពនេះទេ នេះជាការពិត ។

យកភ័ស្តុតាង២មកនិយាយដើម្បីបញ្ជាក់ ។ ភ័ស្តុតាងមួយគឺវាយឈ្នះចក្រពត្តិអាមេរិក និងបរិវារមុនបង្អស់ក្នុងសកលលោក ហើយក្នុងប្រវត្តិសាស្ត្រសកលលោកទាំងមូល ដែលមិនដែលមានកងទ័ពណាឈ្នះចក្រពត្តិអាមេរិកយ៉ាងនេះ ។ យើងវាយឈ្នះមុនគេបំផុត ។ នេះជាភស័ស្តុតាង មួយបញ្ជាក់ច្បាស់ ។

ភ័ស្តុតាងមានច្រើន តែខ្ញុំយកតែភ័ស្តុតាងខ្លះ មកបញ្ជាក់ ។



យោធាខ្មែរក្រហមកំពុងឆែកពិនិត្យកប៉ាល់ទឹករបស់ទាហាន លន់ នល់

ភ័ស្តុតាងមួយទៀត គឺភ័ស្តុតាងក្រោយសង្គ្រាម កងទ័ពនេះបំពេញ ភារកិច្ចការពារប្រទេសក៏បានល្អ ហើយរួមកសាងប្រទេស ក៏បានល្អ ក៏បានសកម្មក្លៀវក្លា បង្កបង្កើនផលឧបត្ថម្ភខ្លួនបានជាអតិបរមា ។ លៃលកពេលវេលារបស់ខ្លួន ក្រៅពីកិច្ចការពារប្រទេស បង្កបង្កើន ផលបានជាអតិបរមា ហើយខ្ញុំសូមជម្រាបថា កងទ័ពភូមិភាគខ្លះ បានផ្តល់ស្រូវ ផ្តល់អង្ករជូនរដ្ឋនាំទៅលក់ក្រៅប្រទេសទៀតផង ។ តាមខ្ញុំចាំ ប្រហែល៤ម៉ឺនតោន អង្ករ រួមទូទាំងប្រទេស ភូមិភាគនេះ ប៉ុណ្ណេះ ភូមិភាគនោះប៉ុណ្ណោះ ។ នេះគឺបក្សមិនឲ្យកងទ័ពធ្វើតែបង្កបង្កើនផលទេ គឺយកការងារការពារប្រទេស ជាស្នូល ជាមូលដ្ឋាន ឯការកសាងប្រទេស ការបង្កបង្កើនផលដើម្បី ឧបត្ថម្ភខ្លួន ជាការ សំខាន់បន្ទាប់ ។ យើងធ្វើដើម្បីលត់ដំកងទ័ពយើង ។ កងទ័ពយើង ចេះច្បាំងផង កងទ័ពយើងចេះបង្កបង្កើនផលផង ។ កងទ័ពនេះ ច្បាំងយ៉ាងម៉េច ក៏មិនចាញ់គេដែរ ច្បាំងយ៉ាងណាក៏ឈ្នះដែរ ពីព្រោះចេះច្បាំង ចេះរកស្បៀង ហើយកងទ័ពទៅធ្វើការងារមូលដ្ឋាន វិញក៏បានល្អដែរ ។

យកភ័ស្តុតាងទាំង២នេះ បញ្ជាក់ឃើញថា កងទ័ពយើងមាន គុណភាពខ្ពស់ណាស់ ប្រៀបធៀបនឹងកងទ័ពនៅក្នុងសកលលោក ទាំងមូល ។ ក៏ប៉ុន្តែ តើភារកិច្ចរបស់កងទ័ពយើងត្រូវចប់ប៉ុណ្ណឹង ឬ ត្រូវបន្តទៅទៀត ។ គុណភាពរបស់កងទ័ពយើងបានដល់នេះហើយ យើងត្រូវបញ្ចប់ត្រឹមនេះ ឬតទៅទៀត ។ យើងត្រូវមានមោទកភាព យើងត្រូវពេញចិត្តពេញថ្លើមនឹងគុណភាពរបស់កងទ័ពយើង រហូត ដល់ថ្ងៃនេះ ។ ប៉ុន្តែ យើងក៏ត្រូវខិតខំបន្តកសាង ពង្រឹងពង្រីកកងទ័ព យើងតទៅទៀតឲ្យមានគុណភាពកាន់តែល្អ ទាំងកិច្ចការពារប្រទេស មានគុណភាពល្អ ទាំងរួមកសាងប្រទេសក្នុងក្របខណ្ឌនៃបដិវត្តន៍ សង្គមនិយម និងការកសាងសង្គមនិយមរបស់យើង ហើយដើម្បី ឲ្យកងទ័ពយើងមានគុណភាពកាន់តែល្អថែមទៀតយើងត្រូវធ្វើយ៉ាងម៉េច? បក្សយើងទាំងមូល កងទ័ពយើងទាំងមូល ក៏ដូចជាប្រជាជន យើងទាំងមូល ត្រូវយកចិត្តទុកដាក់កសាងបក្ស ខាងនយោបាយ ខាងសតិអារម្មណ៍ ខាងចាត់តាំងតទៅទៀត ។ កន្លងមក កងទ័ពយើង មានគុណភាពខ្ពស់ល្អដូចបានជម្រាបអម្បាញ់មិញ មកពីនយោបាយ ល្អ សតិអារម្មណ៍ល្អ ចាត់តាំងល្អ មានគុណសម្បត្តិជាមូលដ្ឋាន ។ គុណវិបត្តិក៏មានដែរ មិនមែនថាមិនមានទេ ប៉ុន្តែ គុណសម្បត្តិជា មូលដ្ឋានបានជាដណ្តើមបានជ័យជម្នះក្នុងសង្គ្រាម ហើយដណ្តើម បានជ័យជម្នះក្រោយសង្គ្រាម ។ ប៉ុន្តែ ឥឡូវត្រូវបន្តពង្រឹងពង្រីក នូវជំហរនយោបាយតទៅទៀត ពង្រឹងពង្រីកនូវការចាត់តាំងកងទ័ពនេះ ឲ្យកាន់តែល្អថែមទៀត ។

ការកសាងខាងនយោបាយ សតិអារម្មណ៍ ខ្លឹមសាររបស់វា គឺការកសាងខាងជំហរបដិវត្តន៍ សង្គមនិយមរបស់យើង របស់បក្ស យើង បច្ចុប្បន្ននេះ ។ យើងយកចិត្តទុកដាក់កសាងខាងនយោបាយ ឲ្យល្អ សតិអារម្មណ៍ឲ្យល្អ ពីព្រោះជាកត្តាកំណត់ ជាមូលដ្ឋាន ឲ្យកងទ័ព យើងខាងនយោបាយ និងខាងសតិអារម្មណ៍ស្អាត ។ ស្អាតនេះគឺស្អាត ក្នុងន័យក្តាប់មាគ៌ារបស់បក្ស ឯកភាពមាគ៌ារបស់បក្ស ជ្រួតជ្រាប មាគ៌ារបស់បក្សក្នុងន័យអនុវត្តមាគ៌ានយោបាយ ជាមាគ៌ាសេដ្ឋកិច្ច ជាមាគ៌ាយោធា ជាមាគ៌ាគ្រប់បែប គ្រប់យ៉ាងរបស់បក្ស ក្នុងក្របខណ្ឌនៃបដិវត្តន៍សង្គមនិយម និងការកសាងសង្គមនិយមនេះ ។

បញ្ហានេះ សមមិត្តនៅក្នុងកងទ័ពក្តី នៅក្រៅកងទ័ពក្តី សុទ្ធតែ បានរៀនអស់ហើយ ពីបដិវត្តន៍សង្គមនិយម ហើយក្នុងមីទ្ទិញ យើងជាបន្តបន្ទាប់មក តែងនិយាយអំពីបដិវត្តន៍សង្គមនិយមនេះ យ៉ាងម៉េច ។ ក្នុងពេលនេះ ខ្ញុំសូមបញ្ជាក់ថា យើងយកចិត្តទុកដាក់ ពង្រឹងពង្រីក បន្តធ្វើបដិវត្តន៍សង្គមនិយម ដើម្បីការពារប្រទេស បានល្អ ដើម្បីកសាងប្រទេសបានល្អ ដើម្បីលើកតម្កើង នូវកិត្តិយស របស់ជាតិ យើងបានល្អ កិត្តិយសកងទ័ពយើង កិត្តិយសរបស់បក្ស យើង បដិវត្តន៍យើងបានល្អ ។ មិនមែនធ្វើបដិវត្តន៍សង្គមនិយម ដោយហេតុផលអ្វីផ្សេង ក្រៅពីនេះទេ ។ បើយើងធ្វើបដិវត្តន៍សង្គមនិយមបានល្អ នៅក្នុងកងទ័ព ក៏ដូចជាក្រៅកងទ័ព ការពារប្រទេស ធានាអះអាងណាស់ គ្មានមារសត្រូវណាមកចូលចុះទេ ហើយបើ កងទ័ពយើងស្អាតខាងនយោបាយ ខាងសតិអារម្មណ៍ខាងចាត់តាំង ហើយ គឺជាកំពែងដែក ស្អីក៏ចូលមិនចុះដែរ ព្រោះយើងត្រូវការ ការពារប្រទេសយើង ការពារបដិវត្តន៍យើង ការពារលទ្ធផលបដិវត្តន៍ យើង កុំឲ្យវាខូចខាតទៅវិញ ហើយជាភារកិច្ចរបស់យើង ជាភារកិច្ច របស់ជំនាន់យើង ដែលបានបំពេញភារកិច្ចរំដោះប្រទេសទាំង ស្រុង រំដោះប្រជាជនទាំងស្រុងហើយ ។ ត្រូវជំនាន់យើងមាន ភារកិច្ចការពារលទ្ធផលបដិវត្តន៍ និងការពារប្រទេសឲ្យបានល្អ ថែមទៀត ។ ដូច្នោះ ដូចបានជម្រាបពីពេលមុនហើយ គ្មាននរណា

មានកិត្តិយសជាងជំនាន់យើងទេ ។ ជំនាន់យើងបានរំដោះប្រទេស បានរំដោះប្រជាជនទាំងស្រុង ហើយជំនាន់យើងនេះ មានភារកិច្ចការពារប្រទេសឲ្យបានការពារបដិវត្តន៍ឲ្យបានលើកតម្កើងកិត្តិយសរបស់ជាតិឲ្យខ្ពង់ខ្ពស់ឡើង ។ កិត្តិយសរបស់ជាតិដែលធ្លាប់តែគេញាំញី គេជិះជាន់រាប់ពាន់ឆ្នាំមកហើយ យើងត្រូវថែរក្សា ត្រូវពង្រឹងពង្រីកវា គ្មានអ្នកណាទៀតទេ ។ យើងប្រគល់ភារកិច្ចនេះឲ្យអ្នកណា? មានតែជំនាន់យើង ។ ជំនាន់យើងធ្វើល្អ បានជំនាន់ក្រោយធ្វើបានល្អ ទៀត ។ ប៉ុន្តែ បើជំនាន់យើងធ្វើមិនបានល្អ ជំនាន់ក្រោយរឹតតែធ្វើមិនបានល្អ ។ ជំនាន់យើងធ្វើល្អ ពូជធាហ្នឹង វាល្អ ។ បើជំនាន់យើងមិនល្អ ពូជធាទៅថ្ងៃក្រោយក៏មិនល្អ ។ និយាយជាសាមញ្ញ គឺយ៉ាងនេះ ។ ដូច្នោះ ជាកិត្តិយសណាស់ មិនងាយនរណាមានវាសនា មានឱកាសក្នុងជីវិតរបស់ខ្លួនមករំដោះប្រទេស មកការពារប្រជាជន ដូចជំនាន់យើងទេ ។ ដូច្នោះ កុំឲ្យខាតពេលវេលាកុំឲ្យខាតឱកាសនេះ មួយថ្ងៃក៏កុំឲ្យខាត មួយខែក៏កុំឲ្យខាត ។ នេះម្យ៉ាង ។

ម្យ៉ាងទៀត ជាពិសោធន៍មក យើងរំដោះប្រទេសបានល្អ ហើយធ្វើបដិវត្តន៍សង្គមនិយមបានល្អ កសាងប្រទេស ក៏បានល្អ ។ កសាងប្រទេសរបស់យើងសព្វថ្ងៃនេះ ដូចបានជម្រាប ឆ្នាំ១៩៧៧ យើងបានហូបរបបហូប មួយចំនួនបាន៣០គីឡូ ១ខែ មួយចំនួនបាន២៥គីឡូ ១ខែ មួយចំនួនបាន២០គីឡូ ១ខែ មួយចំនួនបាន១៥គីឡូ ១ខែ ។ តិចជាងគេត្រឹម១០គីឡូ ។ របបនេះ គឺគ្រប់គ្រាន់តាមយើងលៃគ្រប់ពេញទី គឺខ្ពស់ណាស់ ។

ពិតមែនហើយ យើងនៅស្មៀកពាក់ខ្វះខាត តែរបបយើងខ្ពស់ណាស់ ។ មួយទៀតឈឺថ្កាត់ ក៏ថយច្រើន ។ នេះមកពីជីវភាពប្រជាជនឡើង ។

ដូច្នោះ សារសំខាន់នៃបដិវត្តន៍សង្គមនិយម និងការកសាងសង្គមនិយម និងការកសាងសង្គមនិយម មានទិសដៅកសាងប្រទេសបានល្អ ការពារប្រទេសបានល្អ និងដោះស្រាយជីវភាពប្រជាជនបានឆាប់រហ័ស ។ យើងត្រូវការប្រជាជនពី១៥ ទៅ២០លាន ទើបគ្រប់គ្រាន់នឹងដីយើង ។ ដើម្បីឲ្យប្រជាជនកើនបានឆាប់ ទាល់តែជីវភាពឡើង សុខភាពល្អ ដូច្នេះ មានតែបង្កបង្កើនផលឲ្យបានរហ័ស ។ លុយដែលបានមកពីការនាំផលិតផលទៅបរទេស គឺដើម្បីពង្រីកកសិកម្ម ពង្រីកឧស្សាហកម្ម និងបម្រើជីវភាពប្រជាជន ។ គ្មានធ្វើអ្វីក្រៅពីនេះទេ ។

ខ្លាំងវាតែងឃោសនាថា យើងធ្វើបដិវត្តន៍សង្គមនិយមដើម្បីអត់ ។ ការពិតដូចជាលទ្ធផលឆ្នាំនេះ ជាភ័ស្តុតាងស្រាប់ យើងធ្វើបដិវត្តន៍សង្គមនិយម ដើម្បីប្រជាជន កម្មករ កសិករយើងបានគ្រប់គ្រាន់ ឈានទៅសម្បូរសប្បាយ ។ ធ្វើបដិវត្តន៍សង្គមនិយម កសាងសង្គមនិយម ដើម្បីកសាងប្រទេស ដោះស្រាយជីវភាពប្រជាជនឲ្យបានរហ័ស ។

ឧទាហរណ៍ បើឆ្នាំនេះ យើងនាំអង្ករចេញបានច្រើន លុយបានមក យើងទិញថ្នាំកម្ចាត់គ្រុនចាញ់ ហើយទិញម៉ាស៊ីន ដើម្បីជួយកម្លាំងពលកម្មប្រជាជនយើង ។ ម្យ៉ាងទៀត បើក្នុង៣ ឬ៤ឆ្នាំនេះ យើងកម្ចាត់គ្រុនចាញ់បានអស់នៅកម្ពុជា គឺជាជ័យជម្នះធំសម្បើមណាស់ ព្រោះជំងឺគ្រុនចាញ់រាប់សតវត្សរ៍មកហើយ ។

ឧទាហរណ៍ យើងត្រូវដោះស្រាយផ្ទះសម្បែងប្រជាជនឲ្យបាន ត្រូវតែយកចិត្តទុកដាក់ធ្វើក្នុង២ ឬ៣ឆ្នាំខាងមុខនេះ ។ ដូច្នោះ យើងត្រូវតែធ្វើបដិវត្តន៍សង្គមនិយម ។ សមូហភាពបានលឿនបានខ្លាំង ។

គ្មាននរណាធ្វើម្ចាស់ទេ គឺយើងធ្វើម្ចាស់ ។ ដូច្នេះ ការពារប្រទេសក៏យើង កសាងប្រទេសក៏យើង ។ លើកតម្កើងជីវភាពប្រជាជនក៏យើង ។ បើធ្វើបានលឿនក៏យើងធ្វើមិនបានក៏យើង ។ ដើម្បីឲ្យបានលឿន ទាល់តែធ្វើបដិវត្តន៍សង្គមនិយមឲ្យបានល្អ ។ បើធ្វើបដិវត្តន៍សង្គមនិយមមិនបានល្អ មិនលឿនទេ ។

ឯបញ្ហាចាត់តាំងត្រូវយកចិត្តទុកដាក់ពង្រឹង និងពង្រីក ហើយសម្រិតសម្រាំងឲ្យកងទ័ពយើង ស្អាតបរិសុទ្ធ តាមមាគ៌ារបស់បក្ស ។ កងទ័ពខ្លាំង គឺកងទ័ពស្អាត ។ ឲ្យតែស្អាត ចំនួនតិច ក៏ខ្លាំងដែរ ។ បើមួយក្រុមស្អាត វាយខ្លាំង មួយអនុសេនាធំដែលមិនស្អាត ។ ដើម្បីឲ្យកងទ័ពស្អាត មានតែអប់រំទេ ។ កងទ័ពយើង ជាកងទ័ពល្អ ។ តែឲ្យយល់ជ្រួតជ្រាបមាគ៌ាបក្សគ្រប់ផ្នែកនៅមិនទាន់យល់គ្រប់ផ្នែកទេ ។ នៅទស្សនៈនេះ ទស្សនៈនោះ នៅខ្វះខាតជាធម្មតា ។ ដូច្នេះ ត្រូវអប់រំជាបន្តបន្ទាប់ ។

នៅក្នុងនេះ ខ្ញុំចង់លើកបញ្ហាមួយ ដែលត្រូវបញ្ជាក់ដែរ គឺបញ្ហាទស្សនៈនយោបាយ ។ មិនមែនសម្រាប់តែកងទ័ពទេ គឺទាំងកងទ័ព ទាំងបក្ស ។ ទស្សនៈនយោបាយឲ្យជ្រះស្រឡះ ទស្សនៈ

នយោបាយឲ្យច្បាស់លាស់ទស្សនៈនយោបាយឲ្យភ្លឺស្វាង ។ សមមិត្តយើងម្នាក់ៗ ពិសេសកងទ័ព ត្រូវមានទស្សនៈនយោបាយអំពីយើងឲ្យច្បាស់ ។ អំពីយើង គឺអំពីកម្ពុជាប្រជាធិបតេយ្យយើងឲ្យច្បាស់ ។ មានអីជាចំណុចខ្លាំង មានអីជាចំណុចខ្សោយ ។ ត្រូវយល់ខ្លួនឯងឲ្យច្បាស់ ។ ទន្ទឹមនឹងនេះត្រូវយល់អំពីខ្មាំងឲ្យច្បាស់ តើវាមានអីខ្លះជាចំណុចខ្លាំង មានអីខ្លះជាចំណុចខ្សោយ ។ ខ្មាំងជិត ខ្មាំងឆ្ងាយ តើវាមានចំណុចអីខ្លាំង វាមានចំណុចអីខ្សោយឲ្យច្បាស់ ក្នុងរយៈកាលមួយៗ ។ បក្សដឹកនាំត្រូវយល់ ។ បក្សនៅក្នុងកងទ័ពត្រូវយល់ ។

ធម្មតា ខ្មាំងវាតែងផ្សព្វផ្សាយនូវទស្សនៈថា យើងខ្សោយ ឬប្រទេសតូច ប្រជាជនតិចក្រ គ្មានកម្លាំងអីទប់ទល់វាបានទេ ។ ឲ្យយើងយល់អ៊ីចឹង ។ ដូច្នេះហើយ បានជាវាធ្លាក់ទៅក្នុងពាក្យខុសខ្លះថា “ពងមាន់ទៅជល់នឹងថ្ម មិនបានទេ” ។ ឲ្យយើងរឹតតែភ័ន្តប្រទ្បំខាងទស្សនៈនយោបាយទៅទៀត ។ ឲ្យយើងយល់ថា ខ្មាំងខ្លាំង យើងខ្សោយ ។ ព្រមជាមួយនេះ ភ្នាក់ងារខ្មាំងខ្លះ វាផ្សាយពីឥទ្ធិពលខ្មាំងថា វាខ្លាំងអីចេះ ថាវាខ្លាំងអីចុះ ធ្វើម៉េចបន្ទាប់បន្ថុះកងទ័ពយើង ប្រជាជនយើងឲ្យខ្លាចវា ។ បញ្ហានេះ ត្រូវចាប់អារម្មណ៍ ។ ពីមុន ក៏វាធ្វើ ។ បច្ចុប្បន្នក៏វាធ្វើ ។ ថ្ងៃក្រោយក៏វាធ្វើ ហើយបើវាធ្វើអ៊ីចឹងបាន វាវាយតែបន្តិច ក៏មិនហ៊ានវាយវា វាវាយច្រើន ក៏រឹតតែមិនហ៊ានវាយវាទៀត ពីព្រោះសតិអារម្មណ៍ វាបន្ទាប់បានហើយ ។ បញ្ហានេះ មានភារៈសំខាន់ណាស់ ជាទស្សនៈវិភាគចំណុចខ្លាំង ចំណុចខ្សោយរបស់ខ្មាំង និងយើង ។ តាមពិត យើងវាយឈ្នះចក្រពត្តិអាមេរិកដែលជាមេក្លោងចក្រពត្តិក្នុងលោក ។ យើងត្រូវឃើញច្បាស់មានទស្សនៈឲ្យច្បាស់ចំពោះកម្លាំងយើង និងកម្លាំងខ្មាំង កុំឲ្យវាបំផុសឃោសនាបាន វាយគោលជំហរយើងបាន ។ វារកល្បិចសំដៅវាយគោលជំហរយើង ។ បើយើងមានទស្សនៈច្បាស់ យើងអត់ខ្លាចខ្មាំងទេ ។ យើងហ៊ានវាយ អត់អីក៏យើងវាយ ។ កន្លងមក យើងវាយតាំងពីបាតដៃទទេដូចបានជម្រាបមកហើយ ។

យើងត្រូវពង្រឹងទស្សនៈយើងតទៅទៀត ។ ឃើញចំណុចខ្លាំង និងចំណុចខ្សោយរបស់ខ្មាំង ។ ឃើញចំណុចខ្លាំង និងចំណុចខ្សោយរបស់យើង ។ ឥឡូវយើងមានកងទ័ព មានកងពល តែបើនយោបាយ សតិអារម្មណ៍មិនល្អ កងទ័ពនេះទៅជាខ្សោយ ទៅជាខ្លាត់ខ្លាយ ទៅជារយើករយាក ។ ឧបមាថា បើអាមេរិកមកទៀត តើយើងហ៊ានវាយវាឬទេ? យើងធ្លាប់វាយវាហើយ ។ អាវុធអីក៏វាប្រើ អត់តែបរមាណូ ។ ជាមួយយើង វាមិនហ៊ានប្រើបរមាណូទេ ។ យើងអត់ខ្លាចទេ ។ យើងធ្លាប់ស្គាល់វា វាយវារឹតតែខ្លាំងជាងមុន ។ បើវិភាគអាមេរិកយ៉ាងនេះហើយ ខ្មាំងណាក៏ដោយ ឲ្យតែហ៊ានឈ្លានពានយើង យើងហ៊ានវាយ ។

ចំណុចខ្លាំងរបស់យើងគឺប្រជាជនអង់អាចណាស់ ។ បើបក្សដឹកនាំត្រូវគឺខ្លាំងក្លាណាស់ ។ តែបើបក្សដឹកនាំមិនត្រូវ គឺប្រជាជនមិនខបត្តម្ភបក្សទេ ។ ក្នុងឱកាសនេះ យើងនិយាយពីកងទ័ព តែតាមពិត យើងនិយាយពីកសាងបក្ស ។

សរុបមកវិញ គឺត្រូវបន្តកសាងកងទ័ពយើងឲ្យមានគុណភាពកាន់តែខ្ពស់ឡើង ។ បរទេសគេវាយតម្លៃយើងខ្ពស់ណាស់ ។ មើលចុះកងទ័ពយើង គ្មានសក្តិ គ្មានយស គ្មានប្រាក់ខែ លះបង់ដើម្បីវណ្ណៈ ដើម្បីបដិវត្តន៍ ។ បង្កបង្កើនផលខបត្តម្ភខ្លួនដើម្បីសម្រាលទម្ងន់ប្រជាជន ។ ទន្ទឹមនេះ ការពារប្រទេសបានជាអតិបរមា ។ គេស្ញប់ស្ញែងណាស់ ។ គេចង់រៀនសូត្រតាមកងទ័ពយើង ។ គុណភាពនេះខ្ពស់ណាស់ បើប្រៀបធៀបនៅលើសកលលោក ។ ក៏ប៉ុន្តែត្រូវបន្តលើកគុណនេះតទៅទៀត ។ ឥឡូវនេះ ជាគំរូហើយ តែត្រូវបន្តធ្វើគំរូតទៅទៀត ។

## រឿងរ៉ាវពិតដើម្បីប្រវត្តិសាស្ត្រ

មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថា ប្រជាជនកម្ពុជាគ្រប់រូបដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហមបាន និងកំពុងសរសេរអត្ថបទឬសៀវភៅអំពីរឿងរ៉ាវពិតផ្ទាល់ខ្លួន ហើយនឹងផ្ញើមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមអាសយដ្ឋានខាងក្រោម ÷

ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ ភ្នំពេញ

ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទលេខ: (៨៥៥) (២៣) ២១១ ៨៧៥

ទូរស័ព្ទលេខ: (៨៥៥) (១៦) ៨៧៦ ៦៩២

ទូរសារលេខ: (៨៥៥) (២៣) ២១០ ៣៥៨

Email: truthsocheat@dccam.org

Home page: www.dccam.org

# ត្រូវការយុត្តិធម៌ មិនមែនថ្នាំព្យាបាលទេ

ដំណើរការនីតិវិធីប្រឆាំងទៅនឹងមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម បានចំណាយរយៈពេល២១២ថ្ងៃ ។ ទន្ទឹមនឹងនេះ ពេលសំខាន់ខិតចូលមកដល់ គឺថ្ងៃសម្រេចបញ្ចប់ការដេញដោល ។ ភាគីនីមួយៗ រួមមាន ភាគីដើមបណ្តឹងរដ្ឋប្បវេណី អង្គជំនុំជម្រះ មេធាវីការពារក្តី ព្រមទាំងជនជាប់ចោទត្រូវបានអនុញ្ញាតឲ្យចូលរួមក្នុងការបញ្ចប់សវនាការសំណុំរឿង០០២វគ្គ១ ។ តាមវចនានុក្រម Black's Law ការបញ្ចប់នូវការសួរដេញដោលមានន័យថា "រាល់សេចក្តីសម្រេចចុងក្រោយរបស់មេធាវីត្រូវបញ្ជូនទៅកាន់ចៅក្រមមុនពេលការពិភាក្សាចាប់ផ្តើម ដែលមានន័យថា មេធាវីត្រូវស្នើសុំចៅក្រមពិចារណាលើភ័ស្តុតាងនិងដាក់សំណុំរឿងតាមផ្លូវច្បាប់គាំទ្រកូនក្តីរបស់ខ្លួន" ។ សេចក្តីសម្រេចត្រូវអនុលោមទៅតាមការវិនិច្ឆ័យយ៉ាងល្អិតល្អន់លើភ័ស្តុតាងពិរុទ្ធភាពទាំងខាងក្នុង និងក្រៅដែលបញ្ជូនមកពីភាគីដែលបានរៀបរាប់ដូចខាងលើ ។ ជនជាប់ចោទនិងមេធាវីការពារក្តីរបស់ខ្លួនមានលទ្ធភាពយ៉ាងមុតមាំលើកយកនូវសិទ្ធិរបស់កូនក្តីខ្លួនក្នុងពេលចុងក្រោយ ។

សាធារណជនទូទៅ រួមមាន អ្នកភូមិចំនួន១៥០នាក់ មកពីខេត្តតាកែវ ខេត្តកំពង់ស្ពឺ និងខេត្តកំពង់ឆ្នាំង ក្រោមការសម្របសម្រួលរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា មកចូលរួមតាមដានដំណើរការកាត់ក្តីដោយភាពស្ងៀមស្ងាត់ ។ អត្ថបទនេះនឹងសង្កត់ធ្ងន់លើការចូលរួមស្តាប់សវនាការកាលពីខែតុលាកន្លងទៅ ។ បន្ថែមពីនេះទៀត អត្ថបទនេះនឹងធ្វើការឆ្លុះបញ្ចាំងទូទៅលើការស្តាប់និងសារសំខាន់នៃភាពយុត្តិធម៌សម្រាប់អ្នកដែលស្លាប់អំឡុងរបបកម្ពុជាប្រជាធិបតេយ្យ(ឆ្នាំ១៩៧៥-១៩៧៩) ការរំពឹងទុករបស់អ្នកចូលរួមទៅលើសេចក្តីសម្រេចចុងក្រោយនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា រួមទាំងទស្សនៈបន្ថែមទៀតចំពោះការស្វែងរកនូវសំណង ។

**ការសង្កត់ធ្ងន់ ចំពោះការស្តាប់សវនាការ នៅថ្ងៃទី "១៦ ខែ តុលា"**

សវនាការថ្ងៃទី១៦ ខែតុលា ផ្តោតលើប្រធានបទមួយចំនួន ចាប់ពីការជម្លៀសដោយបង្ខំ ការបង្ខំឲ្យរៀបការ រហូតទៅដល់សំណង តាមរយៈការសាងសង់ជាសារមន្ទីរនៃការចងចាំ បូជនីយដ្ឋាន ការបង្រៀនអំពីប្រវត្តិសាស្ត្រខ្មែរក្រហម ការតាំងពិព័រណ៍ជាអចិន្ត្រៃយ៍ជាដើម ។ ក្រុមសហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណីផ្លាស់ប្តូរវេនគ្នាអានអត្ថបទដ៏វែងពីសំណុំឯកសារសរសេរ ។

**ការជម្លៀសដោយបង្ខំ**

សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណីចាត់ទុកការជម្លៀសប្រជាជនពីកន្លែងមួយទៅកន្លែងមួយថាជាសហកម្មខក្រិដ្ឋកម្មរួមដែលសំដៅលើជនជាប់ចោទ នួន ជា អតីតអនុលេខាបក្សកុម្មុយនីស្តកម្ពុជាក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និង ខៀវ សំផន អតីតប្រមុខរដ្ឋកម្ពុជាប្រជាធិបតេយ្យ ។ គោលនយោបាយនិងផែនការត្រូវបានអនុវត្តដោយកម្លាំងប្រជាជនដែលត្រូវបានជម្លៀសដោយបង្ខំដើម្បីឈានដល់ការសម្រេចគោលដៅបដិវត្តន៍ ហើយនឹងបញ្ជាក់ថា សហករណ៍និងកន្លែងដែលត្រូវបានសាងសង់ទាំងអស់ត្រូវបានប្រព្រឹត្តទៅដោយឯករាជ្យនិងមានលំនឹងភាពសេដ្ឋកិច្ចនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ការពិតដែលគួរឲ្យកត់សម្គាល់មួយទៀតគឺការជម្លៀសដោយបង្ខំ មានគោលដៅដើម្បីក្តោបក្តាប់ទីក្រុងទាំងមូល ការពារដល់អ្នកបដិវត្តន៍ និងធានាថា គ្មានសត្រូវណាម្នាក់ត្រូវគេចខ្លួនរួចនោះឡើយ ។

ការជម្លៀសដំបូងធ្វើឡើងនៅទីក្រុងភ្នំពេញទៅកាន់ទីជនបទផ្សេងៗក្នុងប្រទេសកម្ពុជា ហើយបន្ទាប់មកទៀត ទើបចាប់ផ្តើមជម្លៀសពីតំបន់ជនបទមួយទៅតំបន់មួយផ្សេងទៀត ។ នួន ជា បានអះអាងអំពីការជម្លៀសដោយបង្ខំនៅទីក្រុងភ្នំពេញ ។ លទ្ធផលដែលអាក្រក់នៃការជម្លៀសនោះគឺការមិនយកចិត្តទុកដាក់ ឬការធ្វេសប្រហែសនៃបដិវត្តន៍ខ្មែរក្រហមដែលបានធ្វើឲ្យប្រជាជនរងទុក្ខវេទនា ។ ដោយសារតែឆ្លងកាត់នូវហេតុការណ៍តក់ស្លុតផ្ទាល់ទើបបានជាភាគីដើមបណ្តឹងរដ្ឋប្បវេណីជាច្រើនរូបបានចូលរួមនៅក្នុងសំណុំរឿង០០២/០១ ដើម្បីបញ្ជាក់ពីទំហំដ៏ធំសម្បើមនៃ

ខក្រិដ្ឋកម្មដ៏ធ្ងន់ធ្ងរនេះ ។ អ្នកដែលត្រូវបានជម្លៀសភាគច្រើនមិនបានដឹងពីផែនការជម្លៀស ដែលការជម្លៀសជាទូទៅធ្វើឡើងក្រោយពីខែកក្កដា និងខែសីហា ក្នុងឆ្នាំ១៩៧៥ និងឆ្នាំ១៩៧៧ ។ ការជម្លៀសដោយបង្ខំមានលក្ខណៈដូចគ្នាទៅនឹងការអនុវត្តផែនការ ហើយគ្មានមនុស្សធម៌ទេ ។ ជនភៀសខ្លួនដើរដោយថ្មើរជើងក្នុងចម្ងាយរាប់សិបយោជន៍ មិនមានចំណីអាហារ ថ្នាំពេទ្យ ទីជម្រក ឬមួយក៏អាហារូបត្ថម្ភផ្សេងៗត្រូវបានផ្តល់ឲ្យឡើយ ។ ជាឧទាហរណ៍ ជនភៀសខ្លួនត្រូវបង្ខំឲ្យឡើងជិះរថភ្លើងនិងមិនត្រូវបានយកចិត្តទុកដាក់ ជាហេតុនាំឲ្យប្រជាជនជួបការលំបាកដល់ស្លាប់ក៏មាន ។

"ប្រជាជនថ្មី" ឬហៅថា "អ្នក១៧មេសា" ត្រូវបានចាត់ទុកថាជាសត្រូវ ទន្ទឹមនឹង "អ្នកមូលដ្ឋាន" ទទួលការអត់ឱនច្រើនជាង ។ សមាជិកគ្រួសារនៃប្រជាជនថ្មីត្រូវបានបែងចែកទៅតាមមូលដ្ឋានផ្សេងៗគ្នា ។ ដូចគ្នានេះដែរ ខ្មែរក្រហមមានបំណងកាត់បន្ថយរបបអាហាររបស់ប្រជាជននៅក្នុងទម្រង់ជាការដាក់ពិន័យដល់អ្នកទាំងនោះ ។

ក្រុមសហមេធាវីនាំមុខ ដើមបណ្តឹងរដ្ឋប្បវេណីរំពឹងទុកថាការរកយុត្តិធម៌សម្រាប់ជនរងគ្រោះនឹងនាំមកនូវការកាត់ទោសជាប្រវត្តិសាស្ត្រ ។ ក្រុមទាំងនេះសង្ឃឹមថានឹងយកតួនាទីរបស់ខ្លួនជាដើមទុនដើម្បីទាមទារនូវការទទួលស្គាល់ឲ្យបានទូលំទូលាយថានេះគឺជាការចាំបាច់បំផុតសម្រាប់ដំណើរការផ្សះផ្សាចំពោះប្រទេសកម្ពុជា ។ ក្រុមសហមេធាវីនិយាយម្តងហើយម្តងទៀតថា កន្លងផុតប្រមាណ៣០ឆ្នាំមកនេះ ដើមបណ្តឹងរដ្ឋប្បវេណីជាច្រើនរូបមិនទាន់បានរួចផុតពីជំងឺវិបត្តិផ្លូវសតិអារម្មណ៍នៅឡើយទេ ។ ទោះបីជាមានការប្រថុយប្រថានដល់សុខភាពចំពោះប្រជាជនដែលជាអតីតជនរងគ្រោះក៏ដោយ ដើមបណ្តឹងរដ្ឋប្បវេណីរាប់ពាន់នាក់ត្រូវបានជ្រើសរើសឲ្យចូលរួម ។ ដើមបណ្តឹងរដ្ឋប្បវេណីផ្តល់នូវព័ត៌មានជាច្រើនដែលជួយដល់ដំណើរការអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាក្នុងការកសាងសំណុំរឿងជាផ្លូវការ ។



ប្រជាជនរស់នៅជាយក្រុងភ្នំពេញកំពុងភៀសខ្លួនចេញពីលំនៅដ្ឋានដើម្បីទៅរកកន្លែងសុវត្ថិភាពក្រោយពេលយោធាខ្មែរក្រហមវាយប្រហារលំនៅដ្ឋានរបស់ខ្លួន

## ការជម្លៀសដោយបង្ខំ និងសំណងជួសជុលការខូចខាត

ក្រុមសហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណីក៏សង្កត់ធ្ងន់ដែរថា ការរៀបការដោយបង្ខំគឺជាទង្វើអមនុស្សធម៌ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដាក់ទោសមកលើប្រជាជនកម្ពុជា ។ របបនេះ ឬអង្គការដើរតួជាឪពុកម្តាយ ទៅកាន់ប្រជាជនគ្រប់រូបដែលត្រូវបានគេរៀបចំឲ្យរៀបការ ។ ក្រុមសហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណីបានលើកពីបញ្ហានេះឡើងដោយចាត់ទុកថានេះក៏ជាគោលដៅមួយរបស់អង្គការដើម្បីរក្សានូវកំណើនប្រជាជន ។ ទោះបីជាយ៉ាងនេះក៏ដោយ ទង្វើនេះត្រូវបានចាត់ទុកក្នុងទម្រង់ល្មើសទៅលើសិទ្ធិនិងរឿងផ្ទាល់ខ្លួនរបស់បុគ្គលម្នាក់ៗដែលជាមុខសញ្ញានៃការរើសអើសពូជសាសន៍ ។ សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណីលើកពីចំណុចមួយចំនួនទៀតគឺ ការមិនមានការអនុញ្ញាតឲ្យរៀបការរវាងប្រជាជនមូលដ្ឋាននិងប្រជាជនថ្មី ។ ទីពីរ ព្រះសង្ឃត្រូវបង្ខំឲ្យលាចាកពីសិក្ខាបទ ហើយបង្ខំឲ្យរៀបការដែលបំពានទៅនឹងគោលការណ៍របស់ពុទ្ធសាសនា ។ ទីបី ការបង្ខំរៀបការរវាងជនជាតិខ្មែរនិងចាម ដោយមិនមានការយោគយល់ខាងផ្នែកសាសនាពីបុគ្គលម្នាក់ៗ ។ នឹងមានការដាក់ទណ្ឌកម្មប្រសិនបើមាននរណាម្នាក់ដែលតម្រូវឲ្យរៀបការ ហើយនោះតែបែជាបដិសេធ ។ ដូចដែលសកម្មភាពទាំងនេះត្រូវបានអនុវត្តនៅក្នុងប្រទេសកម្ពុជា ហើយប៉ះពាល់ដល់ជនជាតិកម្ពុជាផ្ទាល់និងជនជាតិភាគតិចទាំងអស់ ទើបបានជាសហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណីយល់ឃើញថា នេះគឺជាគោលនយោបាយផ្ទាល់របស់របបកម្ពុជាប្រជាធិបតេយ្យ ។ នៅខណៈនេះ សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីផ្សារភ្ជាប់គោលការណ៍នេះទៅនឹងមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមមានទំនួលខុសត្រូវដឹកនាំឲ្យអនុវត្តនូវគោលការនេះ ។ ការអានអត្ថបទនៃការបិទបញ្ចប់ការសាកសួរដេញដោលពេញមួយថ្ងៃដោយសហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណីបញ្ចប់ទៅជាមួយនឹងលិខិតស្នើសុំសំណងជួសជុលមួយចំនួនធំទៅកាន់អ្នកដែលរស់រានមានជីវិតក្រោយរបបខ្មែរក្រហម ជាពិសេសដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងករណីសំណុំរឿង០០២/០១ ។

## ការយល់ឃើញរបស់អ្នកចូលរួមលើការស្តាប់សវនាការ

អ្នកភូមិចំនួន១៥០នាក់ត្រូវបានជ្រើសរើសឲ្យមកចូលរួមស្តាប់ការបិទការសួរដេញដោលរបស់ក្រុមសហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី ។ ក្រុមមេធាវីពិតជាមានការលំបាកក្នុងការរកឲ្យឃើញតថភាពឆ្លុះបញ្ចាំងថា របបខ្មែរក្រហមបណ្តាលឲ្យមានការឈឺចាប់ដល់ប្រជាជនកម្ពុជា ។ អ្នកភូមិឈ្មោះ គុណ ឈឿន អាយុ៦៣ឆ្នាំ មកពីខេត្តកំពង់ស្ពឺ និងលោក មើយ ចាយ វ័យ៦៣ឆ្នាំមកពីខេត្តតាកែវពិតជាយកចិត្តទុកដាក់តាមដានរាល់ចំណុចដែលលើកឡើងដោយក្រុមសហមេធាវី ។ ទាក់ទងនិងការជម្លៀសប្រជាជន ឈឿន និយាយខ្សាវៗដោយយល់ស្របទៅនិងអ្វីដែលសហមេធាវីនាំមុខបាននិយាយនៅក្នុងបន្ទប់សវនាការ ព្រោះគាត់ធ្លាប់ជួបប្រទះដោយផ្ទាល់នូវលក្ខខណ្ឌយ៉ាប់យ៉ឺននៃការរស់នៅ និងការស្លាប់របស់ប្រជាជនថ្មីប្រសិនបើធ្វើការប្រៀបធៀបទៅនឹងប្រជាជនមូលដ្ឋាន ។ ចាយ ក៏ជាជនរងគ្រោះម្នាក់ដែលបានរៀបការដោយបង្ខំរៀបចំឡើងដោយខ្មែរក្រហម ។ គាត់គ្មានសិទ្ធិក្នុងការបដិសេធមិនព្រមរៀបការនោះទេ ។ ទោះជាយ៉ាងនេះក៏ដោយ ចំណងមិត្តភាពក្រុមគ្រួសាររបស់គាត់នៅតែបន្តរហូតមកដល់សព្វថ្ងៃនេះ ។ គាត់មានកូនប្រាំបីនាក់ និងចៅជប់ប្រាំមួយនាក់ ។ ទោះបីជាប្រធានបទនៃការរៀបការដោយបង្ខំត្រូវបានបើកចំហក្នុងការតស៊ូមតិដើម្បីរកឲ្យឃើញថា តើចំណងគ្រួសារនឹងនៅស្ថិតស្ថេរ ដូចជាពាក្យថា («គូព្រេងន័យសាមញ្ញថា គូកំណត់») ឬ («ជាគូកម្មន័យសាមញ្ញថាគូមានកម្ម») យ៉ាងណាក៏ដោយ ជាទូទៅសកម្មភាពនេះគឺមិនអាចទទួលយកបាននោះទេ តាមផ្លូវច្បាប់និងសីលធម៌ ហើយអាចចាត់ទុកជាការបំពានសិទ្ធិរបស់បុគ្គលនីមួយៗយ៉ាងធ្ងន់ធ្ងរ ការគំរាមកំហែងដល់ជីវិតទោសប្រហារជីវិតបើបដិសេធទៅការរៀបចំរបស់អង្គការ ។ ឡែម ហួត អាយុ៦៥ឆ្នាំមកពីខេត្តកំពង់ឆ្នាំងទទួលស្គាល់ថា ការបង្ខំឲ្យរៀបការរាប់ពាន់នាក់ត្រូវបានរៀបចំឡើងនៅភូមិរបស់គាត់កាលពីរបបខ្មែរក្រហម ។ កញ្ញា ប៉ែន សោភា មកពីខេត្តកំពង់ឆ្នាំងបានអះអាងថា ឪពុកម្តាយរបស់គាត់ក៏រៀបការជិនាន់ខ្មែរក្រហមដែរ ។

## ការស្វែងរកយុត្តិធម៌នៅក្នុងការតស៊ូមតិ

ការបិទបញ្ចប់ការសាកសួរដេញដោលក្នុងករណី០០២/០១ប្រាប់ឲ្យដឹងជាមុនថា ការនាំមកនូវយុត្តិធម៌ទៅកាន់ជនរងគ្រោះនឹងមិនយូរជាងពាក់កណ្តាលឆ្នាំ២០១៤នោះទេ ។ អ្នកតំណាងប្រាំរូប

ក្នុងចំណោមអ្នកភូមិ១៥០រូបត្រូវបានអញ្ជើញឲ្យចូលរួមសហការជាមួយនឹងគម្រោងឃ្លាំមើលយុត្តិធម៌របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជឿជាក់ថា យុត្តិធម៌គឺពិតជាសំខាន់ណាស់សម្រាប់រូបគាត់សម្រាប់ក្មេងៗជំនាន់ក្រោយ និងប្រទេសជាតិទាំងមូល ។ នៅពេលដែលសួរថាតើវាសំខាន់យ៉ាងណាដែរ អ្នកទាំងអស់បានបង្ហាញពីគំនិតរួមទាមទារសំណងដូចដែលអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបាននឹងកំពុងធ្វើការសរុប ។ ហួត នឹង ឈឿន ពោលថា យុត្តិធម៌នឹងនាំមកនូវការធូរស្រាល ថ្វីត្បិតតែជួបនឹងបញ្ហាប្រឈមជាច្រើនក៏ដោយដូចជា ភាពខ្សត់ខ្សោយនៃហិរញ្ញវត្ថុ ការរីកវរនៃប្រាក់ខែ ការមិនយល់ស្របចំពោះការចោទប្រកាន់ចំពោះអ្នកដែលមានអំណាច ការចោទប្រកាន់អំពីការលូកដៃរបស់រាជរដ្ឋាភិបាលក្នុងកិច្ចការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ការលាលែងពីតំណែងរបស់ចៅក្រម ព្រះរាជអាជ្ញា និងបុគ្គលិកដទៃទៀត ការស្លាប់របស់ អៀង សារី ភាពមិនប្រក្រតីរបស់ អៀង ធីរិទ្ធ ដែលមិនអនុញ្ញាតឲ្យចូលរួមក្នុងការជំនុំជម្រះបាន ។ ខណៈពេលមើយ ចាយ ជឿជាក់ថាកម្មវិធីសំណងជួលជុលសម្រាប់អ្នកដែលរស់រានមានជីវិតក្រោយរបបខ្មែរក្រហមពិតជាផ្តល់ជូននូវទំហំកិច្ចខិតខំប្រឹងប្រែងដ៏ធំធេងសម្រាប់ផ្សះផ្សានោះ ប៉ែន សោភា មិនបានជឿជាក់ទៅលើកម្មវិធីនេះទេ ។ គាត់និយាយថា ការកាត់ក្តីមេដឹកនាំខ្មែរក្រហមកំពុងដំណើរការ តែមេដឹកនាំទាំងនោះព្យាយាមបដិសេធ ពោរពេញដោយល្បិចកលដោយបដិសេធមិនទទួលស្គាល់បទឧក្រិដ្ឋកម្មធ្ងន់ធ្ងរដែលបានកើតឡើងចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ រហូតដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ ហើយតាំងខ្លួនជាអ្នកដែលគ្មានកំហុស មិនដឹងរឿងរ៉ាវដែលបានកើតឡើង និងជាអ្នកស្នេហាជាតិទៅវិញ ។

ផ្ទុយទៅវិញ ឡាយ យល់ឃើញថា ការជំនុំជម្រះគួរធ្វើឡើងចំពោះតែ «មេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម និងអ្នកដែលទទួលខុសត្រូវខ្ពស់បំផុតប៉ុណ្ណោះ ។ គាត់ប្រាប់ថា ទោះបីជាជនជាប់ចោទម្នាក់ក្នុងចំណោមអ្នកផ្សេងទៀតបានស្លាប់ក៏ដោយ គោលបំណងសំខាន់គឺថារបបនេះត្រូវតែតបស្នងដល់អ្នកដែលបានស្លាប់ ។ សម្រាប់គាត់ ការដែលនាំជនជាប់ចោទទាំងអស់នោះដាក់គុកមិនសំខាន់ទេ តែអ្វីដែលសំខាន់គឺថា ប្រជាជនកម្ពុជានិងប្រជាជនទាំងអស់លើពិភពលោកទទួលស្គាល់តថភាពនៃរបបដ៏ព្រៃផ្សៃនេះដែលខ្មែរក្រហមបានធ្វើមកលើប្រជាជនស្លូតត្រង់ ។

នៅពេលចុងបញ្ចប់នៃករណីសំណុំរឿង០០២/០១ អ្នកចូលរួមប្រាំនាក់ដែលត្រូវបានសម្ភាសន៍មានមតិពីរផ្សេងគ្នា ។ មតិទីមួយគឺថាគួរតែមានការដាក់ទណ្ឌកម្មឲ្យសមរម្យទៅនឹងអ្វីដែលជនជាប់ចោទបានធ្វើ ។ ជាទូទៅ ប្រជាជនចង់ឃើញអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាកាត់ទោសប្រហារជីវិតចំពោះជនជាប់ចោទ ទោះបីជាការកាត់ទោសរបៀបនេះមិនអាចធ្វើសាច់ញាតិរបស់ខ្លួនដែលស្លាប់ទៅរស់ឡើងវិញក៏ដោយ ។ មតិទីពីរគឺបដិសេធមិនផ្តល់យោបល់អ្វីទាំងអស់ តែទុកតួនាទីនេះឲ្យអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាធ្វើការសម្រេចខ្លួនឯងអាស្រ័យតាមច្បាប់ ។

## សរុបសេចក្តី

ការបញ្ចប់ការសួរដេញដោលផ្អែកទៅលើព្រឹត្តការណ៍សោកសៅជាច្រើន ដូចជា ការជម្លៀសដោយបង្ខំ ការរៀបការដោយបង្ខំ និងសកម្មភាពអមនុស្សធម៌ផ្សេងៗទៀត ដែលបានកើតឡើងក្នុងរបបខ្មែរក្រហមចន្លោះពីថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៧ មករា ឆ្នាំ១៩៧៩ ។ មានការរំពឹងទុកថា ការកាត់ទោសជនជាប់ចោទដែលនៅសល់ពីររូបទៀត នឹងមានផ្តល់យុត្តិធម៌សម្រាប់ប្រជាជនកម្ពុជា ។ ដូចអ្វីដែលបានរំពឹងទុក អ្នកភូមិ១៥០រូប ដែលបានអញ្ជើញមកចូលរួមសង្ឃឹមថានិងទទួលបានយុត្តិធម៌ ។ ជារឿងធម្មតាទេ យើងតែងតែព្យថា យុត្តិធម៌និងនាំមកនូវភាពធូរស្រាលក្នុងអារម្មណ៍ ។ នេះគឺជាគំរូសម្រាប់ប្រជាជនកម្ពុជានិងប្រទេសជាតិទាំងមូល ។ យុត្តិធម៌តាមរយៈការជំនុំជម្រះនឹងរឹតតែបញ្ជាក់អំពីសោកនាដកម្មនៃរបបខ្មែរក្រហមនេះដល់ប្រជាជនកម្ពុជា ។ របបខ្មែរក្រហមបានបន្សល់ទុកកេរដំណែលមិនអាចបំភ្លេច ។ អ្នកប្រព្រឹត្តិខុសនឹងមិនអាចរត់គេខ្លួនពីយុត្តិធម៌បាននោះទេ ។ កម្មវិធីគម្រោងសំណងជួសជុលនឹងផ្តល់នូវភាពវិជ្ជមានបន្ថែមទៀតដល់កិច្ចប្រឹងប្រែងផ្សះផ្សាដែលប្រជាជនកម្ពុជាបានធ្វើភ្លាមៗបន្ទាប់ពីការដួលរលំនៃរបបខ្មែរក្រហមក្នុងខែមករា ឆ្នាំ១៩៧៩ ។

**លី សុខឃាង**

# ខៀវ សំផន ថ្លែងការណ៍

ជនជាប់ចោទ ខៀវ សំផន ធ្វើសេចក្តីថ្លែងការណ៍នៅសាលាក្តីខ្មែរក្រហម នៅថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៣



រូបថត៖ អ.វ.ត.ក

សូមថ្វាយបង្គំព្រះសង្ឃគ្រប់ព្រះអង្គដែលគង់នៅតាមវត្តអារាមនានាទូទាំងប្រទេស ។ សូមគោរពបងប្អូនជនរួមជាតិទាំងអស់ជាទីស្នេហា ។ សូមគោរពដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ ។ សូមគោរពលោកប្រធាន សូមគោរពលោក លោកស្រីចៅក្រមទាំងអស់ ។ សូមគោរព លោកមេធាវី អស់លោក លោកស្រីមេធាវីទាំងអស់ ។ សូមគោរពសហព្រះរាជអាជ្ញា ។

ក្នុងរយៈប៉ុន្មានថ្ងៃកន្លងមកនេះ ខ្ញុំបានស្តាប់ច្បាស់អំពីអត្ថាធិប្បាយ... អន្តរាគមន៍របស់ភាគីនានា ហើយជាពិសេស អន្តរាគមរបស់អ្នកដែលបន្ទោសខ្ញុំថា ខ្ញុំបាននិយាយតិចតួចពេកក្នុងរឿងក្តីរបស់ខ្ញុំនេះ ។ ក៏ប៉ុន្តែ ព្រមជាមួយគ្នាដដែលនេះ អ្នកដដែលនេះបានប្រើប្រាស់អ្វីដែលខ្ញុំបាននិយាយបន្តិចបន្តួចនោះមកចោទលើរូបខ្ញុំទៅវិញ ។ ហេតុនេះ បើទោះជាខ្ញុំនិយាយពន្យល់ដោយបដិសេធមិនព្រមទទួលការចោទប្រកាន់របស់អស់លោក ក៏អស់លោកនៅតែបន្ទោសខ្ញុំ តែបើខ្ញុំនៅស្ងៀម ក៏អស់លោកនៅតែចោទប្រកាន់ខ្ញុំដដែល ។

ខ្ញុំមិនដែលប្រាថ្នាឬក៏បានសម្រេចជម្លៀសប្រជាជនអ្វីទាល់តែសោះ ហើយខ្ញុំក៏មិនដែលប្រាថ្នាឬសម្រេចឲ្យមានការកាប់សម្លាប់អ្វីទាល់តែសោះ ។ ជំនឿគោលនយោបាយរបស់ខ្ញុំ អ្វីដែលខ្ញុំបានខិតខំធ្វើសកម្មភាពជាហូរហែរកន្លងមកនេះគឺដើម្បីការពារអ្នកទន់ខ្សោយ គឺដើម្បីឲ្យគេគោរពនូវសិទ្ធិជាមូលដ្ឋានរបស់ពួកគេ ហើយដើម្បីជាតិយើង កម្ពុជាយើងមានភាពរឹងមាំនិងឯករាជ្យបរិបូរណ៍ ។

បាទ! ពិតណាស់ ភាពអយុត្តិធម៌ក្នុងសង្គមធ្វើឲ្យខ្ញុំមិនពេញចិត្តទាល់តែសោះ តែវាមិនដល់ថ្នាក់ថាខ្ញុំចង់ឲ្យអ្នកដទៃទទួលភាពអយុត្តិធម៌វិញនោះឡើយ ។ ឧត្តមគតិរបស់ខ្ញុំគឺជាតិឯករាជ្យភាពនិងប្រជាជនរស់នៅបានធូរធារ និងសម្បូរសប្បាយនិងទទួលបាននូវកិត្តិយសនិងសេចក្តីថ្លៃថ្នូររបស់ខ្លួនដូចគេឯងឡើងវិញ ។ ក៏ប៉ុន្តែ ពេលដែលខ្ញុំបានឮអ្វីដែលចោទប្រកាន់ដល់រូបខ្ញុំនិងរបៀបនៃការចោទប្រកាន់នៅទីនេះ ហើយពេលដែលខ្ញុំមើលឃើញថា អ្នកដែលនឹងត្រូវចូលរួមសម្រេចលើរឿងក្តីរបស់ខ្ញុំនេះបានបដិសេធមិនព្រមពិចារណាដល់សភាពការណ៍ជាក់ស្តែងនៅសម័យកាលនោះដោយមើលមកខ្ញុំថា ខ្ញុំជាព្រាយបិសាចនោះ ខ្ញុំលែងចង់និយាយស្តីអីទៀតហើយ ។

បាទ! កាលពីសម័យរដ្ឋប្រហាររបស់លោកសេនាប្រមុខ លន់ នល់ ខ្ញុំប្រាថ្នាចង់ឲ្យខ្មែរក្រហមនិងសម្តេច សីហនុ ទទួលបានជ័យជម្នះក្នុងសង្គ្រាម ហើយខ្ញុំបានចូលរួមជាមួយពួកគេ ។ ក្រោយពីការលាលែងរបស់ សម្តេច សីហនុ ពីតំណែងប្រមុខរដ្ឋនៅឆ្នាំ១៩៧៦ ខ្ញុំបានជឿថា មានការកសាងប្រទេសឲ្យបានរីកចម្រើន ។ អស់លោកអ្នកទាំងអស់គ្នាដែលនៅទីនេះ អស់លោកហាក់ដូចជាជឿជាក់ថាខ្ញុំខុសព្រោះអស់លោកទាំងអស់គ្នាជឿថា ខ្ញុំគួរតែបានប្រមាណមើលឃើញអំពីអ្វីដែលបានកើតឡើងនៅក្រោយថ្ងៃទី១៧

មេសា ឆ្នាំ១៩៧៥ ហើយខ្ញុំគួរតែឈប់ចូលរួម ឬក៏រត់គេចខ្លួនចេញពីរបបកម្ពុជាប្រជាធិបតេយ្យ ។ ដោយសារតែខ្ញុំនៅបន្តទៅទៀត លោកក៏ចោទថា ខ្ញុំជាពិរុទ្ធជន បើទោះជាខ្ញុំអាចនិយាយបកស្រាយ និងព្យាយាមពន្យល់យ៉ាងណាក៏ដោយ ។ តាមអស់លោក ខ្ញុំគួរតែទុកឲ្យ លន់ នល់ បន្តសកម្មភាពរបស់គេ ខ្ញុំមិនគប្បីតបតនឹងសកម្មភាពរបស់ លន់ នល់ ឡើយ ឬក៏នៅពេលទទួលបានជ័យជម្នះលើសង្គ្រាម លន់ នល់ និងពួកអាមេរិកហើយ ខ្ញុំត្រូវតែដឹងជាមុនថា នយោបាយ និងឧត្តមគតិរបស់ខ្ញុំនឹងមិនត្រូវបានអនុវត្តន៍នោះទេតែវានឹងត្រូវបង្វែរតាមទិសផ្ទុយពីនេះទៅវិញ ។

ដោយខ្មែរក្រហមដែលគេមានអំណាច គេបានអនុវត្តន៍វិធានការតឹងរឹងនោះ ។ ខ្ញុំមិនបានឃើញរឿងរ៉ាវដែលអាចកើតឡើងនៅថ្ងៃក្រោយនោះទេ ហើយខ្ញុំក៏មិនមានអំណាចអ្វីដាក់កំហិតឲ្យគេកែប្រែនោះដែរ ។ អ្នកខ្លះថាខ្ញុំជាជនកំសាក ឯខ្ញុំ ខ្ញុំមិនមែនជាអ្នកមានអំណាចអ្វី ហើយខ្ញុំក៏មិនខ្វល់អ្វីពីរឿងអត់អំណាចនេះដែរ ។ នេះប្រហែលជាទោសកំហុសរបស់ខ្ញុំ ព្រោះថាក្នុងពេលតៗមក ខ្ញុំក៏ស្ថិតនៅក្បែរៗអ្នកមានអំណាចផងដែរ តែខ្ញុំមិនអំណាចដូចគេនោះទេ តែអស់លោកជឿជាក់ថា ខ្ញុំមានអំណាច ដូច្នេះហើយបានជាថ្ងៃនេះ ខ្ញុំត្រូវបានគេចាប់ខ្លួនយកមកកន្លែងនេះ ។ នៅថ្ងៃនេះ វាងាយស្រួលណាស់ដែលនិយាយថា ខ្ញុំគួរតែដឹងរឿងរ៉ាវទាំងអស់យល់រឿងរ៉ាវទាំងអស់ ហើយដូច្នេះ ខ្ញុំអាចកែប្រែសភាពការណ៍បានទាំងអស់ ។ តើទាំងអស់គ្នាយល់ថាខ្ញុំមិនបានព្យាយាមរកយល់ឬ? តើទាំងអស់គ្នាពិតជាយល់ឃើញថា នេះជាអ្វីដែលខ្ញុំចង់បានសម្រាប់ប្រជាជនរបស់ខ្ញុំឬ? កាលពីនៅយុវវ័យ ខ្ញុំបានខិតខំទៅតាមលទ្ធភាពនិងមធ្យោបាយរបស់ខ្ញុំ ក្នុងគោលបំណងចង់កែប្រែរបបអយុត្តិធម៌ ក្រោយមកខ្ញុំក៏ត្រូវបង្ខំចិត្តរត់គេចខ្លួន ខ្ញុំបានរួចជីវិតដោយសារតែខ្ញុំរត់ចូលព្រៃ ។ បន្ទាប់មកទៀត នៅពេលដែលខ្ញុំគិតថា មានមនុស្សគេអាចបំពេញកិច្ចការបានប្រសើរជាងខ្ញុំដើម្បីផលប្រយោជន៍ប្រជាជន និងជាតិរបស់ខ្ញុំ ខ្ញុំក៏ប្រាថ្នាចង់ឲ្យអ្នកទាំងនោះទទួលបានជ័យជម្នះ ហើយខ្ញុំក៏បានផ្តល់ដល់ពួកគេនូវការខិតខំប្រឹងប្រែងដ៏តិចតួចស្តួចស្តើងតាមលទ្ធភាពដែលខ្ញុំអាចធ្វើទៅបានពីព្រោះ ខ្ញុំជឿជាក់ទៅលើគម្រោងបដិវត្តន៍របស់គេនោះថា នឹងនាំឲ្យសង្គមបានប្រសើរជាងមុន ជាតិខ្ញុំបានរស់គង់វង្ស ទោះណាប្រទេសខ្ញុំត្រូវទទួលរងគ្រោះដោយសង្គ្រាមមហាវិនាសសកម្មហើយត្រូវបានបំផ្លិចបំផ្លាញខ្ទេចខ្ទីរហូតដល់នាំឲ្យមានគ្រោះអាសន្នទុរ្ភិក្សថែមទៀតផងក៏ដោយ ។

ផ្ទុយស្រឡះពីការដែលបានលើកឡើងនៅក្នុងសវនាការនេះ ខ្ញុំមិនដែលបានចូលរួមធ្វើផែនការដែលនាំបង្កឲ្យមានទុក្ខវេទនាទាល់តែសោះ គឺមិនដែលទាល់តែសោះ មិនដែលទាល់តែសោះ ។ ដូចដែលខ្ញុំបានព្យាយាមនិយាយជម្រាបទៅដើមបណ្តឹងរដ្ឋប្បវេណីដែលបានឡើងមកនិយាយនៅក្នុងសវនាការនេះដូច្នោះដែរ គឺថា ខ្ញុំមិនដែលគិតថា ចង់ឲ្យរឿងទាំងនេះកើតឡើងទាល់តែសោះ នេះគឺជារឿងតែមួយគត់ដែលខ្ញុំអាចនិយាយនៅថ្ងៃនេះ ។ នេះជាការពិត ប៉ុន្តែគ្មាននរណាចង់ស្តាប់ខ្ញុំឡើយ ។ នៅចំពោះមុខការមិនរវល់អើពើដល់ការខិតខំពន្យល់របស់ខ្ញុំចំពោះមុខលក្ខខណ្ឌដំណើរការនៅតុលាការនេះ ខ្ញុំមានអារម្មណ៍ថា ទោះបីខ្ញុំខំនិយាយពន្យល់យ៉ាងណាក៏ដោយ ក៏គេនៅតែមិនយកចិត្តទុកដាក់ស្តាប់ខ្ញុំឡើយ ។ ផ្ទុយទៅវិញ ខ្ញុំមានអារម្មណ៍ថា ពេលណាខ្ញុំនិយាយ គេរឹងតែចងកំហឹងនឹងខ្ញុំកាន់តែខ្លាំងឡើងទៅទៀត ។ ដូច្នេះ ខ្ញុំគិតថា ខ្ញុំមិនបាច់ឆោតល្ងង់ទៅនិយាយពន្យល់អ្នកមិនដែលចង់ស្តាប់ខ្ញុំនោះទេ ។ ខ្លួនខ្ញុំ ក៏ខ្ញុំសោកស្តាយណាស់ដែរ ដោយខំជឿយ៉ាងខ្លាំងពីដំបូងថា តុលាការនេះអាចជាឱកាសសម្រាប់រូបខ្ញុំក្នុងការពន្យល់ ក៏ប៉ុន្តែគ្រប់គ្នាចង់បានតែម្យ៉ាងគត់ពីខ្ញុំ គឺការសារភាពសុទ្ធសាធទៅតាមអ្វីដែលគេចោទមកលើខ្ញុំ ឯការចោទប្រកាន់នេះទៀត ក៏ជាការចោទប្រកាន់លើអំពើដែលខ្ញុំមិនបានប្រព្រឹត្តទាល់តែសោះ ។ ដោយហេតុថា ខ្ញុំមិនបានដឹងព្រឹត្តិការណ៍ដែលកើតឡើងជាបន្តបន្ទាប់ណាមួយ ខ្ញុំគ្មានហេតុផលអ្វីទៅលន់តួចំពោះការបង្ខំដាច់ណាត់មកលើខ្ញុំនេះដែរ ។ ខ្ញុំយល់ថា ការនៅស្ងៀមមិននិយាយស្តីរបស់ខ្ញុំវាស្របនឹងកិត្តិយស និងសេចក្តីថ្លៃថ្នូររបស់ខ្ញុំជាង ។ ហើយខ្ញុំទុកលទ្ធភាពជូនអស់លោកលោកស្រីចៅក្រមវិនិច្ឆ័យរូបខ្ញុំទៅចុះ ។ មេធាវីទាំងអស់របស់ខ្ញុំ និងក្រុមការងាររបស់ខ្ញុំបានការពារខ្ញុំយ៉ាងរឹងមាំ យ៉ាងខ្លាំងក្លា និងប្រកបដោយការជឿជាក់ ហើយខ្ញុំសូមអរគុណដល់អ្នកទាំងអស់គ្នាទោះបីលទ្ធផលវាទៅជាយ៉ាងណាក៏ដោយ ។

ខ្ញុំសង្ឃឹមជឿជាក់ថា ទោះជាយ៉ាងណាក្តី អស់លោក-លោកស្រីនឹងស្វែងរកយុត្តិធម៌ ។

សូមអរគុណ ។

# នួន ជា : មិនបានជម្លៀសប្រជាជនដោយបង្ខំទេ

## នួន ជា ថ្លែងទៅកាន់សាលាក្តីខ្មែរក្រហមកាលពីថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៣

សូមក្រាបថ្វាយបង្គំព្រះថេរានុថេរៈដែលគង់នៅទីនេះនិងនៅគ្រប់វត្ត ។ សូមគោរពបងប្អូនជនរួមជាតិជាទីស្នេហា ។ សូមគោរពតុលាការ ។ មកដល់ពេលនេះ សវនាការបានប្រព្រឹត្តទៅអស់រយៈពេលជាងពីរឆ្នាំមកហើយដើម្បីសម្រេចអំពីជោគវាសនារបស់ខ្ញុំក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ មកដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ ។ ក្នុងអំឡុងពេលនេះ គឺជាចន្លោះពេលមួយដែលទាក់ទងនឹងការបំពេញការងារស្ទើរតែមួយជីវិតរបស់ខ្ញុំ ក្នុងបុព្វហេតុបម្រើប្រទេសជាតិ និងប្រជាជនជាទីស្នេហារបស់ខ្ញុំផងដែរ ។

ទាក់ទងទៅនឹងសវនាការនេះ បើទោះបីជាខ្ញុំមិនបានចូលរួមដោយផ្ទាល់ដោយសារសុខភាពរបស់ខ្ញុំមិនសូវល្អក្តី ក៏ខ្ញុំបានតាមដានស្តាប់ដោយយកចិត្តទុកដាក់នូវការបង្ហាញភ័ស្តុតាងរបស់សហព្រះរាជអាជ្ញាជាតិនិងអន្តរជាតិ និងការសួរដេញដោលសាក្សីទាំងឡាយនៅពេលសវនាការពីបន្ទប់ឃុំឃាំងនៅក្រោមសាលជំនុំជម្រះជាបន្តបន្ទាប់ ។ តាមរយៈសវនាការនេះ បានបញ្ជាក់យ៉ាងច្បាស់ថា ខ្ញុំមិនមានការជាប់ពាក់ព័ន្ធក្នុងការប្រព្រឹត្តបទល្មើសដូចលោកលោកស្រីសហព្រះរាជអាជ្ញាចោទប្រកាន់នោះទេ ។ និយាយឲ្យខ្លីទៅ គឺខ្ញុំមិនមានទោសអ្វីទាក់ទងនឹងការចោទប្រកាន់ដូចដែលបានលើកឡើងនោះទេ ។ សូមគោរពតុលាការ! នៅពេលខ្ញុំនិយាយបែបនេះ ប្រហែលជាអាចមានអ្នកខ្លះដែលមិនទាន់បានយល់អំពីច្បាប់



នួន ជា នៅក្នុងបន្ទប់សវនាការក្នុងខែតុលា ឆ្នាំ២០១៣ ។ (រូបថតៈ អ.វ.ត.ក)

ឬមានគំនិតលម្អៀង អាចសើចចំអកឡកឡឺយឲ្យខ្ញុំ ។ តែនេះមិនមែនជាអ្វីទេ នៅពេលខ្ញុំជម្រាបជូននៅពេលបន្តិចទៀតនេះ ទើបអស់លោកបានដឹងច្បាស់ថា អ្វីដែលខ្ញុំនិយាយគឺសុទ្ធសឹងតែជាការពិត ។ តាមផ្លូវច្បាប់ គោលបំណងនៃការបង្កើតតុលាការនេះគឺមានទិសដៅ និងតួនាទីដើម្បីស្វែងរកការពិត និងយុត្តិធម៌ឲ្យខ្ញុំ និងជនរងគ្រោះតាមរយៈភស្តុតាងរឹងមាំ ស្របច្បាប់ និងអាចឲ្យជឿបាន ។ ផ្ទុយទៅវិញ មកដល់ពេលនេះ លោក លោកស្រីសហព្រះរាជអាជ្ញាមិនមានភស្តុតាងគ្រប់គ្រាន់ដើម្បីបំពេញធាតុផ្សំបទល្មើសដែលបានចោទប្រកាន់ដាក់បន្ទុកមកលើរូបខ្ញុំ ហើយសិទ្ធិស្របច្បាប់របស់ខ្ញុំមួយចំនួនក៏មិនបានធានាត្រឹមត្រូវនៅក្នុងតុលាការនេះផងដែរ ។ ដូចជាសិទ្ធិទទួលបានការកាត់សេចក្តីឲ្យបានឆាប់រហ័ស សិទ្ធិទទួលបានការការពារតាមផ្លូវច្បាប់ សិទ្ធិទទួលបានការកាត់ក្តីប្រកបដោយយុត្តិធម៌ និងសិទ្ធិផ្សេងៗទៀតដែលធានាដោយច្បាប់ជាតិនិងអន្តរជាតិ ។ ម្យ៉ាងវិញទៀត ចំណុចសង្ស័យជាច្រើន ទាក់ទងនឹងភស្តុតាងក៏មិនទាន់បានលាតត្រដាងឲ្យបានច្បាស់លាស់នៅចំពោះមុខតុលាការ ដូចជា ឯកសារដើម និងសក្ខីកម្មរបស់សាក្សីសំខាន់ៗដែលជួយដល់ខ្ញុំ ។ ដូចលោក លោកស្រីចៅក្រមបានជ្រាបស្រាប់ហើយ ចំណុចទាំងអស់នេះ លោកមេធាវីរបស់ខ្ញុំបានបញ្ជាក់ជូនអង្គសវនាការយ៉ាងច្បាស់ និងមានមូលដ្ឋានច្បាប់ត្រឹមត្រូវរួចមកហើយ ។ តែទោះជាយ៉ាងនេះក្តី រូបខ្ញុំផ្ទាល់សូមបញ្ជាក់បន្ថែមនូវចំណុចសំខាន់ៗមួយចំនួនទៀតសម្រាប់ជាមូលដ្ឋានផ្តល់ជូនលោកលោកស្រីចៅក្រមជ្រាបឲ្យកាន់តែច្បាស់ចំពោះភាពគ្មានទោស និងសុចរិតភាពរបស់ខ្ញុំពាក់ព័ន្ធនឹងបទចោទប្រកាន់មកលើខ្ញុំ ។ ខ្ញុំសម្អាងបែបនេះដោយផ្អែកលើមូលដ្ឋានបីយ៉ាងសំខាន់គឺ៖

## ក) ការគ្មានអំណាចគ្រប់គ្រង និង គ្មានអំណាចទប់ស្កាត់

សូមគោរពតុលាការ និងបងប្អូនជនរួមជាតិជាទីស្នេហា! កាលពីថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០១៣កន្លងទៅនេះ ខ្ញុំបានជម្រាបជូនអង្គសវនាការម្តងរួចមកហើយថា ខ្ញុំមិនមានអំណាចអ្វីនិងមិនជាប់ពាក់ព័ន្ធទៅនឹងការប្រព្រឹត្តបទល្មើសដែលកើតមានឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនោះទេ ។ ជាថ្មីម្តងទៀត ខ្ញុំសូមបញ្ជាក់ថា នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ខ្ញុំមានតួនាទីតែបីប៉ុណ្ណោះគឺ៖

### ក.១) ជាអនុលេខាបក្សកុម្មុយនីស្តកម្ពុជា

នៅក្នុងមុខដំណែងនេះ ខ្ញុំមានតួនាទីជាអ្នកឃោសនាអប់រំអំពីគោលនយោបាយនៅក្នុងជួរសមាជិកបក្ស ។ ចំពោះខ្លឹមសារនៃការឃោសនាអប់រំ ខ្ញុំមិនដែលឃោសនាអប់រំឲ្យសមាជិកបក្សប្រព្រឹត្តអំពើអាក្រក់ ដូចជាប្រើអំណាចអាជ្ញា ឬមានអកប្បកិរិយាមិនល្អចំពោះប្រជាជននោះទេ ។ ខ្ញុំបានអប់រំឲ្យសមាជិកបក្សកុម្មុយនីស្តកម្ពុជាចេះគោរពប្រជាជន ស្រឡាញ់ប្រជាជន បម្រើប្រជាជននិងប្រទេសជាតិរបស់ខ្លួន ។ ខ្ញុំមិនដែលអប់រំ ឬណែនាំសមាជិកបក្សកុម្មុយនីស្តកម្ពុជាណាម្នាក់ឲ្យធ្វើបាប កាប់សម្លាប់ អត់អាហារប្រជាជន ឬប្រល័យពូជសាសន៍ណាម្តងទេ ។ ខ្ញុំតែងតែលើកយកគោលការណ៍សំខាន់ៗរបស់បក្សកុម្មុយនីស្តកម្ពុជាមកបង្រៀន និងអប់រំដល់សមាជិកបក្ស និងកងទ័ពប្រជាជនបដិវត្តន៍កម្ពុជាក្នុងទិសដៅធ្វើយ៉ាងណាឲ្យសមាជិកបក្ស និងកងទ័ពប្រជាជនបដិវត្តន៍កម្ពុជាទាំងអស់អនុវត្តការងារ និងបម្រើប្រជាជនឲ្យបានល្អប្រសើរ ។ ជាពិសេស ខ្ញុំបានលើកយកគោលការណ៍ដែលមានចែងនៅក្នុងមាត្រា២នៃលក្ខន្តិកៈរបស់បក្សកុម្មុយនីស្តកម្ពុជាដើម្បីអប់រំឲ្យសមាជិកបក្សទាំងអស់យល់ជ្រួតជ្រាបកាន់តែច្បាស់អំពីភារកិច្ចរបស់សមាជិកបក្សក្នុងការចូលរួមក្នុងសកម្មភាពសង្គម ។ មាត្រា ២ នៃលក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជាចែងថា«បក្ខជនគ្រប់រូបសុទ្ធតែមានភារកិច្ចដូចតទៅ៖

ក) ភារកិច្ចក្នុងមហាជនគឺ ឃោសនា អប់រំមហាជនអំពីនយោបាយ សតិអារម្មណ៍ចាត់តាំងរបស់បក្ស ហើយប្រឡូកចុះជិតស្និទ្ធជាមួយមហាជន កម្មករ កសិករ ក្នុងសហជីព សហករណ៍ និងកងទ័ពបដិវត្តន៍ ។ ត្រូវទទួលខុសត្រូវខ្ពស់ចំពោះមហាជន បម្រើមហាជនអស់ពីចិត្តពីថ្លើម និងគ្មានលក្ខខណ្ឌ ។ រាបសារនឹងមហាជនហើយខំរៀនសូត្រពីមហាជន ។

ខ) បំផុសបំផុលចលនាមហាជន ពិសេសមហាជនកម្មករ កសិករ ក្នុងសហជីព សហករណ៍ និងកងទ័ពបដិវត្តន៍ឲ្យក្តៅគគុក និងជាប់ជានិច្ចក្នុងកិច្ចការពារប្រទេសនិងកសាងប្រទេសកម្ពុជាប្រជាធិបតេយ្យ តាមទិសដៅបដិវត្តន៍សង្គមនិយម និងការកសាងសង្គមនិយម ។

ក.២) ភារកិច្ចផ្ទៃក្នុងគឺ :

ក) ខិតខំថែរក្សា ពង្រឹងពង្រីកសាមគ្គីភាពផ្ទៃក្នុងបក្សឲ្យបានល្អជាប់ជានិច្ចជាប់ខាត ។ ផ្អែកលើគោលការណ៍នេះ វាបញ្ជាក់យ៉ាងច្បាស់ថា បក្សកុម្មុយនីស្តកម្ពុជាមានបំណងឲ្យសមាជិករបស់ខ្លួនមានស្មារតីទទួលខុសត្រូវខ្ពស់ចុះជាប់ជាមួយប្រជាជន ធ្វើល្អជាមួយប្រជាជន យកចិត្តទុកដាក់ជាមួយប្រជាជន និងរៀនសូត្រពីប្រជាជន ។ ជាពិសេស លើកទឹកចិត្តកងទ័ពបដិវត្តន៍ប្រជាជនកម្ពុជា និងប្រជាជនឲ្យមានគំនិតស្នេហាជាតិ និងការពារមាតុភូមិ ។ ទន្ទឹមនឹងនេះខ្ញុំ តែងតែអប់រំឲ្យសមាជិកបក្សទាំងអស់កុំប្រើអំណាចអាជ្ញា កុំស្រី កុំស្រា កុំពុករលួយ និងកុំលែងល្បែងស៊ីសង ។ល ។ ជាពិសេសឲ្យចេះសាមគ្គីគ្នា ទាំងក្នុងជួរបក្ស និងមហាជន ។

អ្វីៗដែលខ្ញុំបានលើកឡើងខាងលើនេះ គឺជាឧទាហរណ៍មួយដែលបញ្ជាក់ពីកិច្ចការរបស់ខ្ញុំបានធ្វើក្នុងតួនាទីជាអនុលេខាបក្សកុម្មុយនីស្តកម្ពុជានៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ និយាយឲ្យខ្លីទៅ អ្វីដែលខ្ញុំបានអប់រំ និងបង្រៀនដល់សមាជិកបក្ស និងកងទ័ពនោះគឺជាការបណ្តុះពុទ្ធិឲ្យសមាជិកបក្សនិងកងទ័ពប្រជាជនបដិវត្តន៍កម្ពុជាត្រូវមានឆន្ទៈស្នេហាជាតិ ការពារជាតិ និងស្រឡាញ់ប្រជាជន និងសាមគ្គីភាពផ្ទៃក្នុងល្អក្នុងទិសដៅការពារនិងកសាងប្រទេសជាតិមួយឲ្យបានរីកចម្រើនរុងរឿង និងឯករាជ្យពិតប្រាកដ ហើយមិនអនុញ្ញាតឲ្យប្រទេសណាមួយ ធំក្តី តូចក្តី ជិតក្តី ឆ្ងាយក្តី ឈ្លានពាន និងធ្វើអាណានិគមមកលើប្រទេសកម្ពុជាបានជាដាច់ខាត ។

ការកម្ចាត់ខ្មាំងឈ្លានពាន វាជាតួនាទីរបស់កងទ័ពប្រជាជនបដិវត្តន៍កម្ពុជាក្នុងការការពារជាតិមាតុភូមិ ។ រួមជាមួយនេះ ការពង្រឹងសន្តិសុខ និងស្ថេរភាពនយោបាយផ្ទៃក្នុង ត្រូវអនុវត្តឲ្យបានល្អប្រសើរ ទើបបដិវត្តន៍មានការរីកចម្រើនរុងរឿង ។ តាមទស្សនៈទូទៅ ប្រការនេះវាមិនខុសគ្នាទៅនឹងថ្នាក់ដឹកនាំគ្រប់ប្រទេសទាំងអស់នៅលើពិភពលោក ដែលត្រូវតែមានតួនាទីបែបនេះដើម្បីការពារសន្តិសុខនិងប្រទេសជាតិរបស់ខ្លួន ។ ប្រទេសនានានៅលើពិភពលោកតែងតែមានច្បាប់ដើម្បីបម្រើនយោបាយនិងគ្រប់គ្រងប្រទេសរបស់គេ ។ ប្រសិនបើជនណាម្នាក់រំលោភច្បាប់ ជននោះនឹងត្រូវទទួលទោសតាមច្បាប់នៃប្រទេសនោះ ។

**ក.២) ជាអនុប្រធានគណៈកម្មាធិការទំនាក់ទំនងជាមួយគណបក្សពលករវៀតណាម (បច្ចុប្បន្នបក្សកុម្មុយនីស្តវៀតណាម)**

ចំពោះកិច្ចការទំនាក់ទំនងជាមួយប្រទេសនិងប្រជាជនវៀតណាម គឺមានមកជាយូរយារណាស់មកហើយ ។ តែចាប់តាំងពីមានចលនា និងការកកើតបក្សកុម្មុយនីស្តកម្ពុជា ការទំនាក់ទំនងជាមួយវៀតណាម កាន់តែបានពង្រឹងថែមទៀត ដោយមានការចាត់តាំងជាគណៈកម្មាធិការទំនាក់ទំនងជាមួយវៀតណាម តាំងពីថ្នាក់មជ្ឈិមរហូតដល់ថ្នាក់ភូមិភាគ ។ គណៈកម្មាធិការទំនាក់ទំនងជាមួយវៀតណាមថ្នាក់មជ្ឈិមមាន ប៉ុល ពត ជាប្រធាន ហើយខ្ញុំជាអនុប្រធានគណៈកម្មាធិការនេះ ។ តែដោយ ប៉ុល ពត មានកិច្ចការច្រើន ដូច្នោះហើយ គណៈអចិន្ត្រៃយ៍បក្សកុម្មុយនីស្តកម្ពុជាបានតែងតាំងខ្ញុំជាអនុប្រធានឲ្យទទួលខុសត្រូវកិច្ចការនេះជំនួស ប៉ុល ពត ។ នៅក្នុងឱកាសនោះហើយដែលខ្ញុំបានជួបប្រជុំជាមួយបក្សកុម្មុយនីស្តវៀតណាមជាញឹកញាប់ ។ ចាប់តាំងពីខ្ញុំទទួលកិច្ចការនេះ ខ្ញុំបានដឹងពីកលល្បិច និងកិច្ចការសម្ងាត់ជាច្រើនរបស់ប្រទេសវៀតណាម ដែលមានមកលើប្រទេសកម្ពុជាយើង ។ ខ្ញុំចាំបានថា នៅពេលខ្ញុំចូលបម្រើចលនាបក្សកុម្មុយនីស្តកម្ពុជានៅឆ្នាំ១៩៥០ គឺមានវត្តមានកងទ័ពវៀតណាម (វៀតកុង) នៅទូទាំងប្រទេសកម្ពុជារួចជាស្រេចទៅហើយ ។ សមាសភាពនេះបានបង្កប់ខ្លួននៅក្នុងចលនាបក្សកុម្មុយនីស្តកម្ពុជា ទាំងនៅក្នុងជួរកងទ័ពប្រជាជនបដិវត្តន៍កម្ពុជា ក្នុងថ្នាក់ដឹកនាំស៊ីវិលកម្ពុជា និងក្នុងប្រជាជនកម្ពុជា ។ ខ្ញុំចាំបានថា នៅពេលបក្សកុម្មុយនីស្តកម្ពុជាត្រូវបានបង្កើតឡើងជាលើកដំបូង គឺមិនទាន់មានការិយាល័យឬទីបញ្ជាការរបស់ខ្លួនទេ ។ បក្សកុម្មុយនីស្តកម្ពុជា ស្ថិតនៅក្រោមការគ្រប់គ្រង និងដឹកនាំរបស់បក្សកុម្មុយនីស្តវៀតណាមទាំងស្រុង ។ តែនៅឆ្នាំ១៩៦៤ ប៉ុល ពត បានរំដោះបក្សចេញពីការគ្រប់គ្រងចាត់ចែងពីវៀតណាម ។ ប៉ុល ពត និងសមាជិកមជ្ឈិមបក្សមួយចំនួនបានទៅកសាងមូលដ្ឋានបង្អែករបស់ខ្លួនដែលមានឈ្មោះថា “មន្ទីរ១០០” ។ ក្រោយមកមន្ទីរនេះបានចល័តទៅខេត្តរតនៈគិរី ។ ពេលនោះ ការិយាល័យនោះមិនទាន់មានសេរីភាពពេញលេញទេ ។ វៀតណាមដែលមានមូលដ្ឋានសឹកនៅភូមិភាគ៥នៃប្រទេសវៀតណាមបានខំរកគ្រប់វិធីដើម្បីក្តោបក្តាប់បក្សកុម្មុយនីស្តកម្ពុជាគ្រប់ពេលវេលា ទាំងផ្នែកនយោបាយ សេដ្ឋកិច្ច និងយោធា ។

នៅទសវត្សរ៍ឆ្នាំ១៩៦០ វៀតណាមខាងជើងបានប្រើ

ប្រាស់ប្រទេសកម្ពុជាធ្វើជាមូលដ្ឋានសឹក ដើម្បីវាយប្រយុទ្ធជាមួយវៀតណាមខាងត្បូង (ធីវគី) ។ នៅពេលជាមួយគ្នានេះដែរ ចលនាបក្សកុម្មុយនីស្តកម្ពុជាបានរីកដុះដាលយ៉ាងរហ័សបន្ទាប់ពីមានព្រឹត្តិការណ៍រដ្ឋប្រហារទម្លាក់សម្តេចព្រះនរោត្តម សីហនុ ចេញពីដំណែងនៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ដែលធ្វើឡើងដោយចក្រពត្តិអាមេរិក និងបនក្បត់ជាតិ លន់ នល់, សិរីមតៈ និង សឺង ង៉ុកថាញ់ ។ នៅពេលនេះហើយ កងទ័ពប្រជាជនបដិវត្តន៍កម្ពុជាត្រូវបានបង្កើតឡើង ហើយរីកចម្រើនធំធាត់យ៉ាងឆាប់រហ័ស ។ នៅពេលនោះដែរ វៀតណាមបានជ្រើសរើសខ្មែរមួយចំនួនប្រហែលបីពាន់នាក់ ឲ្យទៅរៀនសូត្រ និងទទួលការបំពាក់បំប៉ន ទាំងផ្នែកបច្ចេកទេសនយោបាយ និងសតិអារម្មណ៍នៅប្រទេសវៀតណាមខាងជើង ។ នៅពេលពួកគេត្រឡប់មកប្រទេសកម្ពុជាវិញនៅពាក់កណ្តាលឆ្នាំ១៩៧៣ អ្នកទាំងនោះត្រូវបានចាត់តាំងឲ្យបម្រើការងារនៅក្នុងជួរបក្សនិងកងទ័ពប្រជាជនបដិវត្តន៍កម្ពុជា ។

និយាយជារួម វៀតណាមខំប្រើគ្រប់ល្បិចកលដើម្បីគ្រប់គ្រងចលនាបក្សកុម្មុយនីស្តកម្ពុជា ទាំងផ្នែកយោធា នយោបាយ សេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ល ។ តែទោះជាយ៉ាងនេះក្តី អ្នកដឹកនាំបក្សកុម្មុយនីស្តកម្ពុជាបានមើលឃើញថា បក្សកុម្មុយនីស្តវៀតណាម ធ្វើបែបនេះ គឺមិនសមស្របទៅនឹងគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជានោះទេ ។ នៅដើមឆ្នាំ១៩៧៣ ដោយការខិតខំតស៊ូរើបម្រាស់រំដោះខ្លួនរបស់បក្សកុម្មុយនីស្តកម្ពុជា ដែលមានសមមិត្ត ប៉ុល ពត ជាលេខាបក្ស និងដោយសង្គ្រាមនៅវៀតណាមខាងត្បូងកាន់តែប្រយុទ្ធសន្ធោសន្ធៅ កងទ័ពវៀតណាមបានបង្ខំចិត្តបន្ធូរដៃគ្រប់គ្រងកងកម្លាំងប្រដាប់អាវុធ និងរដ្ឋអំណាចកម្ពុជា ហើយដកខ្លួនទៅប្រយុទ្ធជាមួយវៀតណាមខាងត្បូង ។ ពេលនោះហើយជាឱកាសមួយធ្វើឲ្យកងទ័ពប្រជាជនបដិវត្តន៍កម្ពុជា និងបក្សកុម្មុយនីស្តកម្ពុជាកាន់តែមានឯករាជ្យភាព និងកម្លាំង រឹងមាំបន្ថែមទៀត ។ ខណៈនោះ បក្សកុម្មុយនីស្តកម្ពុជាក្រោមការខិតខំរបស់មជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា ដែលមានសមមិត្ត ប៉ុល ពត ជាលេខាបក្ស បានអនុវត្តនូវគោលការណ៍ឯករាជ្យម្ចាស់ការ ខ្លួនទីពឹងខ្លួន និងខ្លួនសម្រេចវាសនាជាតិខ្លួនដោយខ្លួនឯង ។

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ កងទ័ពប្រជាជនបដិវត្តន៍កម្ពុជាបានជ័យជម្នះលើរបប លន់ នល់ ហើយប្រហែលជាពីរអាទិត្យក្រោយមក វៀតណាមខាងត្បូងក៏ត្រូវបានរំដោះផងដែរ ។ ទាក់ទងនឹងមហាជ័យជម្នះនេះគឺប្រជាជនកម្ពុជានិងកងទ័ពប្រជាជនបដិវត្តន៍កម្ពុជាបានវាយរំដោះទីក្រុងភ្នំពេញដោយខ្លួនឯង ហើយបក្ស និងកងទ័ពប្រជាជនបដិវត្តន៍កម្ពុជាមានឯករាជ្យពេញលេញក្នុងការគ្រប់គ្រងប្រទេសរបស់ខ្លួន ។ បើទោះជាបក្សកុម្មុយនីស្តវៀតណាមប្រកាសថា កងទ័ពវៀតណាមបានដកឬឈប់គ្រប់គ្រងដោយផ្ទាល់លើចលនាបក្សកុម្មុយនីស្តកម្ពុជានៅក្នុងឆ្នាំ១៩៧៣យ៉ាងណាក៏ដោយ តែការពិត កងកម្លាំងវៀតណាម និងភ្នាក់ងារសម្ងាត់របស់វៀតណាមជាច្រើនដែលបានជ្រៀតចូលក្នុងជួរបក្ស និងកងទ័ពប្រជាជនបដិវត្តន៍កម្ពុជាជាយូរមកហើយ នៅតាមមូលដ្ឋាននានាទូទាំងប្រទេសកម្ពុជា មិនបានត្រឡប់ទៅប្រទេសវៀតណាមវិញទេ ។ ពួកគេបាននៅធ្វើការតាមរូបភាពចំហរខ្លះនិងសម្ងាត់ខ្លះជាមួយអនិកជនវៀតណាម និងប្រជាជនកម្ពុជា ។ ប្រការនេះ ដំបូងឡើយយើងពុំបានយល់ដឹងស៊ីជម្រៅចំពោះកលល្បិចរបស់វៀតណាមនោះទេ ។ ក្រោយមកយើងបាន ដឹងច្បាស់ពីឧបាយកលទាំងនោះតាមរយៈភ័ស្តុតាងបួនយ៉ាងគឺ៖ ១) មានរបាយការណ៍ថា ប្រជាជនកម្ពុជា ត្រូវបានគេបង្អត់បាយ និងធ្វើការជាទម្ងន់នៅតាមមូលដ្ឋាន ២) ប្រជាជនកម្ពុជាត្រូវបានគេសម្លាប់ ៣) កម្មាភិបាលថ្នាក់ក្រោមមិនបានរាយការណ៍អំពីស្ថានភាពទាំងអស់នោះជូនថ្នាក់លើ និង ៤) កងទ័ពរបស់យើងមួយចំនួនបានបង្កអរិភាព និងចុះចូលជាមួយវៀតណាម ជាពិសេសនៅភូមិភាគបូព៌ា ។ ទាំងអស់នោះហើយបង្ហាញយ៉ាងច្បាស់ថា វៀតណាមបានបង្កប់ភ្នាក់ងារសម្ងាត់របស់គេនៅក្នុងជួរបក្ស និងកងទ័ពប្រជាជនបដិវត្តន៍កម្ពុជា ក្នុងគោលបំណងបំផ្លិចបំផ្លាញបដិវត្តន៍កម្ពុជា សម្លាប់ប្រជាជន និងលេបយកទឹកដីនៃប្រទេសកម្ពុជា ដែលវៀតណាមមានមហិច្ឆតាជាយូរមកហើយ ។ ជាក់ស្តែងណាស់ នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ វៀតណាមបានឈ្លានពានប្រទេសកម្ពុជា នៅពេលដែលវៀតណាមបានកម្ទេចមូលដ្ឋានគ្រឹះរបស់បដិវត្តន៍កម្ពុជានៅតាមមូលដ្ឋានស្ទើរតែទាំងអស់ តាមរយៈការបង្អត់អាហារ ការកាប់សម្លាប់ប្រជាជន និងការបង្កើតឲ្យមានភាពមិនទុកចិត្តនៅក្នុងបក្សកុម្មុយនីស្តកម្ពុជា ។ ប្រទេសវៀតណាមបានគ្រប់គ្រងប្រទេសកម្ពុជាចាប់តាំងពីឆ្នាំ១៩៧៩ រហូតដល់ឆ្នាំ១៩៩១

នៅពេលប្រទេសកម្ពុជាមានកិច្ចព្រមព្រៀងទីក្រុងប៉ារីសនៅថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ ។ អំពើបង្អត់អាហារ និងការកាប់សម្លាប់ប្រជាជនកម្ពុជាទាំងអស់នោះ វាផ្ទុយស្រឡះពីទស្សនៈនិងគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ។ ផ្អែកលើមូលដ្ឋាននេះ ខ្ញុំសន្និដ្ឋានបានថា អំពើទាំងអស់នោះគឺជាអំពើរបស់បក្សកុម្មុយនីស្តវៀតណាមយ៉ាងពិតប្រាកដ ។

ខ្ញុំ និងបក្សកុម្មុយនីស្តកម្ពុជាមានការឈឺចាប់ណាស់នៅពេលដែលខ្ញុំ និងបក្សកុម្មុយនីស្តកម្ពុជាបានដឹងថា បក្សកុម្មុយនីស្តកម្ពុជាចាញ់ល្បិចកលវៀតណាម ដែលធ្វើឲ្យប្រជាពលរដ្ឋខ្លួនស្លាប់ ហើយប្រទេសជាតិធ្លាក់ចូលទៅក្នុងភាពអន្តរាយបែបនេះ ។ តែវាហាក់ដូចជាហួសពេល ក្នុងការស្តារឡើងវិញទៅហើយ ។ នៅពេលប្រទេសវៀតណាមឈ្លានពានប្រទេសកម្ពុជា កិច្ចការទូតរវាងប្រទេសទាំងពីរត្រូវបានកាត់ផ្តាច់ ។ កិច្ចការការពារជាតិ និងការបញ្ជាកម្លាំងប្រយុទ្ធបានធ្លាក់ទាំងស្រុងទៅលើ សុន សេន ដែលជារដ្ឋមន្ត្រីនៃក្រសួងការពារជាតិរបស់កម្ពុជាប្រជាធិបតេយ្យ ។ ពេលនោះហើយ ដែលតួនាទីរបស់ខ្ញុំក្នុងគណៈកម្មាធិការទំនាក់ទំនងជាមួយគណបក្សពលករវៀតណាម (គណបក្សកុម្មុយនីស្តវៀតណាម) ត្រូវបានបញ្ចប់ទាំងស្រុង ។

### ក.៣) ជាប្រធានសភាតំណាងប្រជាជនកម្ពុជា

គោរពតុលាការ! ក្រោយពេលរំដោះនៅថ្ងៃ១៧ មេសា ១៩៧៥ ខ្ញុំត្រូវបានជ្រើសឲ្យធ្វើជាប្រធានសភាតំណាងប្រជាជនកម្ពុជា ។ តាមផ្លូវច្បាប់ នៅក្នុងតួនាទីនេះ ខ្ញុំទទួលខុសត្រូវក្នុងការអនុម័តច្បាប់ ។ នៅពេលនោះ ដោយសារប្រទេសកម្ពុជាទើបតែចប់សង្គ្រាម ហើយក៏មានសង្គ្រាមបន្តជាមួយវៀតណាមទៀតនោះ ក្នុងរយៈពេលខ្លីបែបនេះ យើងមិនមានពេលវេលាគ្រប់គ្រាន់ដើម្បីធ្វើច្បាប់ច្រើននោះទេ ។ ម្យ៉ាងវិញទៀត ដោយសារប្រទេសជាតិស្ថិតនៅក្នុងស្ថានភាពបែបនេះកិច្ចការច្បាប់គឺមិនមែនជាកិច្ចការជាអទិភាពនោះដែរ ។ តាមទ្រឹស្តីនៃរបបកុម្មុយនីស្ត ការដឹកនាំប្រទេសនៃរបបកម្ពុជាប្រជាធិបតេយ្យ ក៏ដូចជាប្រទេសកុម្មុយនីស្តផ្សេងៗទៀតដែរ គឺមានបក្សដឹកនាំនិងរដ្ឋគ្រប់គ្រងប្រទេស ។ ក្នុងន័យនេះ បក្សផ្តល់ជាគោលការណ៍សម្រាប់ដឹកនាំ ចំណែករដ្ឋវិញ គឺសំដៅទៅលើរដ្ឋាភិបាល ឬនីតិប្រតិបត្តិ ដែលជាអ្នកមានអំណាចគ្រប់គ្រងប្រទេសទាំងមូល ។ និយាយឲ្យចំទៅ មានតែរដ្ឋាភិបាលទេដែលមានអំណាចពេញលេញក្នុងការបញ្ជា ឬអនុវត្តរាល់សកម្មភាពការងារទាំងឡាយក្នុងការគ្រប់គ្រងប្រទេស ។ នៅក្នុងសម័យកាលនោះ បើទោះបីជាមានការបែងចែកអំណាចជាបីគឺ នីតិប្រតិបត្តិ នីតិបញ្ញត្តិ និងអំណាចតុលាការដោយផ្អែកលើគោលការណ៍ដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យយ៉ាងណាក៏ដោយ ក៏វាគ្រាន់តែជានិមិត្តរូបប៉ុណ្ណោះ ។ ស្ថាប័ននីតិបញ្ញត្តិ និងតុលាការមិនបានដំណើរការពេញលេញទេ ។ ជាក់ស្តែង មានតែនីតិប្រតិបត្តិទេដែលបានដំណើរការងារពេញលេញ ហើយ ប៉ុល ពត បានទទួលតំណែងជានាយករដ្ឋមន្ត្រី ។ ដូច្នេះហើយ ប៉ុល ពត មានអំណាចជារួមក្នុងការដឹកនាំ និងគ្រប់គ្រងប្រទេសទាំងនៅក្នុងជួរបក្ស និងនៅក្នុងរដ្ឋាភិបាល ដោយសារគាត់ជាលេខាបក្ស និងជានាយករដ្ឋមន្ត្រី ។ នៅក្នុងតួនាទីនេះ គ្មាននរណាម្នាក់អាចជំនួសគាត់បានឡើយ ។ ផ្អែកលើមូលដ្ឋាននេះបញ្ជាក់យ៉ាងច្បាស់ថា ខ្ញុំមិនមានអំណាចអ្វីបន្តិចក្នុងការគ្រប់



ទីតាំងរបស់សភាតំណាងប្រជាជនកម្ពុជា ក្នុងរបបកម្ពុជាប្រជាធិបតេយ្យដែល នួន ជា ជាប្រធាន ។

គ្រង និងប្រតិបត្តិការងារនៃនីតិប្រតិបត្តិឡើយ ។

### ក.៤) ការចោទប្រកាន់ចំពោះមុខតំណែងផ្សេងៗទៀត

ខ្ញុំសូមបញ្ជាក់ថា ក្រៅពីតួនាទីខាងលើ ខ្ញុំមិនដែលបានទទួលតួនាទីអ្វីទៀតទេ ។ ខ្ញុំមានចម្ងល់យ៉ាងខ្លាំងចំពោះការលើកឡើងរបស់លោក លោកស្រីសហព្រះរាជអាជ្ញាថា ខ្ញុំធ្លាប់ធ្វើជានាយករដ្ឋមន្ត្រីស្តីទី ជាសមាជិកគណៈកម្មាធិការយោធាមជ្ឈិម និងមានការជាប់ពាក់ព័ន្ធទៅនឹងការគ្រប់គ្រងមន្ទីរស-២១ ។ ការចោទប្រកាន់បែបនេះ បើទោះជាមានចេតនាឬអចេតនាក៏ដោយ វាជាការនិយាយខុសពីការពិតទាំងស្រុង ហើយពុំមានភ័ស្តុតាងជាក់លាក់ផងដែរ ។ ប៉ុល ពត គាត់មានឧបនាយករដ្ឋមន្ត្រីរបស់គាត់គឺលោក អៀង សារី លោក សុន សេន និងលោក វន វេត ។ ដូចនេះ វាគ្មានហេតុផលអ្វីដែល ប៉ុល ពត តែងតាំងខ្ញុំឲ្យធ្វើជានាយករដ្ឋមន្ត្រីស្តីទី ក្រៅពីឧបនាយករដ្ឋមន្ត្រីរបស់គាត់នោះទេ ។ ជាការពិតណាស់ គាត់មិនអាចតែងតាំងខ្ញុំឲ្យធ្វើជានាយករដ្ឋមន្ត្រីស្តីទីនៅពេលគាត់អវត្តមានពីប្រទេសនោះទេ ពីព្រោះខ្ញុំមិនមែនតួនាទីណាមួយក្នុងអំណាចនីតិប្រតិបត្តិទាល់តែសោះ ។ ប្រសិនបើគាត់ធ្វើបែបនេះ វាជាអំពើខុសច្បាប់របស់បក្ស ។

ចំពោះការចោទថា ខ្ញុំធ្វើជាសមាជិកគណៈកម្មាធិការយោធាមជ្ឈិម និងជាប់ទាក់ទងទៅនឹងការគ្រប់គ្រងមន្ទីរស-២១ នោះក៏ជារឿងមិនពិតដែរ ។ ជាការពិតណាស់ ខ្ញុំ មិនដែលបានធ្វើកិច្ចការទាំងនេះទេ កិច្ចការទាំងអស់នោះ លោក សុន សេន ជាអ្នកគ្រប់គ្រងផ្ទាល់ ។ ខ្ញុំមិនដែលបានជួប មិនដែលគ្រប់គ្រង ឬមិនបានបញ្ជា ឌុច ឲ្យធ្វើបាប ឬសម្លាប់មនុស្សនោះទេ ។ អស់លោកគួរតែជ្រាបហើយ សារជាតិជាទាហាន ឬសន្តិសុខ គឺមិនដែលស្តាប់អ្នកណាក្រៅពីមេបញ្ជាការផ្ទាល់របស់ខ្លួននោះទេ ។ ដូច្នេះ គ្មានហេតុផលអ្វីដែល ឌុច ស្តាប់ខ្ញុំនោះទេ ។ និយាយដោយត្រង់ទៅ ខ្ញុំទើបតែឮឈ្មោះ ឌុច នៅក្រោយឆ្នាំ១៩៧៩ តែប៉ុណ្ណោះ ។ សម្តីរបស់ ឌុច ដែលបានចោទខ្ញុំថា បានគ្រប់គ្រងមន្ទីរស-២១ នោះ គឺគាត់គ្រាន់តែចង់គេចពីការទទួលខុសត្រូវចំពោះអ្វីដែលបានកើតឡើងនៅមន្ទីរស-២១ និងមានបំណងចង់ឲ្យខ្ញុំទទួលទោសអស់មួយជីវិតដូចគាត់ដែរ ដោយសារ សុន សេន បានស្លាប់ហើយ ឌុច ត្រូវបានតុលាការផ្តន្ទាទោសអស់មួយជីវិតទៅហើយ ។ មនុស្សដែលស្ថិតនៅក្នុងស្ថានភាពបែបនេះ មិនដែលនិយាយការពិតនោះទេ ដោយសារគាត់មានកំហឹងពេញខ្លួន និងអស់សង្ឃឹមក្នុងជីវិត ។ នេះគឺជាហេតុផលជាក់លាក់ដែលគាត់ឆ្លើយទម្លាក់កំហុសមកលើខ្ញុំ ។

និយាយជារួមចំណុចទាំងនេះ មេធាវីរបស់ខ្ញុំបានបញ្ជាក់ជូនលោក លោកស្រីចៅក្រមច្បាស់លាស់រួចមកហើយថា ខ្ញុំមិនបានបំពេញកិច្ចការនេះទាល់តែសោះ ហើយក៏គ្មានឯកសារណាមួយជាក់លាក់បញ្ជាក់ពីរឿងនេះដែរ ។ ផ្អែកលើមូលដ្ឋានទាំងអស់នេះ បានបញ្ជាក់យ៉ាងច្បាស់ថា ខ្ញុំគ្មានអំណាច និងមិនមានតួនាទីគ្រប់គ្រងផ្ទាល់លើកងកម្លាំង ឬរដ្ឋអំណាចមូលដ្ឋានទាល់តែសោះ ។ ដូច្នេះ តើមានហេតុផលអ្វីដែលខ្ញុំអាចបញ្ជា បញ្ចុះបញ្ចូល ឬទប់ស្កាត់មិនឲ្យជនល្មើសប្រព្រឹត្តបទល្មើសបាននៅក្នុងសម័យនោះ? សូមលោក លោកស្រី ចៅក្រមពិចារណា!

ខ្ញុំសូមអះអាងយ៉ាងឧឡារិកថា អ្វីដែលខ្ញុំបានចូលរួមនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនោះ គឺមានបំណងចង់រំដោះប្រទេសជាតិពីអាណានិគមនិយមបារាំង និងការពារទឹកដី ការឈ្លានពានពីប្រទេសជិតខាង ដែលពួកគេមានបំណងចង់លេបយកតាំងពីយូរយារណាស់មកហើយនោះទេ ។ ខ្ញុំស្រឡាញ់ប្រជាជនខ្ញុំ ខ្ញុំមិនមានបំណង និងចេតនាណាមួយធ្វើបាប កាប់សម្លាប់ ឬប្រល័យពូជសាសន៍ឯងនោះទាល់តែសោះ ។

### ខ) ការគ្មានភ័ស្តុតាងគ្រប់គ្រាន់នៅក្នុងបទចោទ

#### ខ.១) ការសម្លាប់អតីតទាហាន លន់ នល់ នៅទួលពោធិ៍ជ្រៃ

ករណីនេះខ្ញុំសូមបញ្ជាក់ដោយស្មោះត្រង់ថា ខ្ញុំមិនដែលបានដឹងថាអតីតទាហាន លន់ នល់ ត្រូវបានគេសម្លាប់នៅទួលពោធិ៍ជ្រៃ ខេត្តនោះទេ ។ ក្រោយពេលរំដោះថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ បើតាមខ្ញុំដឹង បក្សកុម្មុយនីស្តកម្ពុជាមិនដែលបានបង្កើតគោលនយោបាយឲ្យកងកម្លាំងរបស់ខ្លួនកាប់សម្លាប់អតីតទាហាន លន់ នល់ ឬប្រជាជនទេ ។ គោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាចំពោះឈ្លើយសឹក គឺសណ្តោស ប្រណី និងលើកលែងទោស ពីព្រោះអ្នកទាំងនោះត្រូវគេចាប់បង្ខំមកឲ្យធ្វើទាហានសម្រាប់មកប្រយុទ្ធស្លាប់ជំនួសគេ ហើយពួកគេជាកូនចៅរបស់ប្រជាជននៅក្នុងមូលដ្ឋានរំដោះរបស់បក្សកុម្មុយនីស្តកម្ពុជា ។ ជាគោលការណ៍ ការធ្វើបដិវត្តន៍គឺប្រមូលកម្លាំង ។ បើយើងសម្លាប់អ្នកទាំងនោះដូចការចោទប្រកាន់

គឺខុសពីមាគ៌ារបស់បក្សកុម្មុយនីស្តកម្ពុជា ហើយរុញច្រានឪពុកម្តាយ បងប្អូនរបស់ពួកគេឲ្យទៅនៅជាមួយខ្មាំង បន្ថែមកម្លាំងឲ្យខ្មាំង ឬឲ្យគេងាកមកប្រឆាំងជាមួយបក្សកុម្មុយនីស្តកម្ពុជាវិញទេ ។ តែទោះជាមានការកាប់សម្លាប់អតីតទាហាន លន់ នល់ ពិតមែនក៏នេះគឺជាការសម្រេចចិត្តរបស់មន្ត្រីថ្នាក់ក្រោម ដែលបានប្រព្រឹត្តអំពើខុសឆ្គង ធ្វើតាមទំនើងចិត្តរបស់ខ្លួន ឬប្រហែលជាមានបំណងសងសឹក និងការគុំគួនគ្នានៅពេលធ្វើសង្គ្រាម ។ ទាក់ទងនឹងករណីនេះមានសាក្សីមួយចំនួនបានមកផ្តល់សក្ខីកម្មនៅចំពោះមុខសវនាការថា ទាហានខ្មែរក្រហមប្រមូលអតីតទាហាន លន់ នល់ មកជួបប្រជុំនៅសាលាខេត្តពោធិ៍សាត់ប្រហែលជាមួយអាទិត្យក្រោយថ្ងៃរំដោះ ១៧ មេសា ១៩៧៥ ។ សាក្សីទាំងនោះផ្តល់សក្ខីផ្ទុយគ្នា សូម្បីតែចម្លើយរបស់គាត់ទៅចៅក្រមស៊ើបសួរ និងនៅសវនាការ ក៏ខុសគ្នាដែរ ។ ដូចជាសាក្សីឈ្មោះ លឹម សាត បានផ្តល់ចម្លើយទៅចៅក្រមស៊ើបសួរថា ទាហាន លន់ នល់ ដែលចូលរួមប្រជុំនៅសាលាខេត្តពោធិ៍សាត់ និងក្រោយមកត្រូវយកទៅសម្លាប់មានចំនួនប្រហែលបីពាន់នាក់ ។ អ្នកទាំងនោះត្រូវបានដឹកតាមឡានចំនួន២០ទៅ៣០ឡាន ហើយក្នុងមួយឡានដាក់មនុស្សប្រហែល៣០នាក់ ។ នៅពេលសវនាការ សាក្សី លឹម សាត ឆ្លើយថា ទាហាន លន់ នល់ នោះមានចំនួនពីរពាន់នាក់ ខ្វះបន្តិចបន្តួចប៉ុណ្ណោះ ដឹកតាមឡានពី១០ទៅ១៥ឡាន ។ សាក្សីឈ្មោះ អ៊ុង ឆាត់ បានឆ្លើយនៅក្នុងសវនាការថា ទាហាន លន់ នល់ ដែលប្រជុំនៅសាលាខេត្តពោធិ៍សាត់មានចំនួន២០០នាក់ ក្រោយមកថាមានចំនួនពី១០០ទៅ១៥០នាក់ទៅវិញ ហើយខ្សែវីដេអូរបស់ ថេត សម្បត្តិ ដែលមានចំណងជើងថា «មួយថ្ងៃនៅទួលពោធិ៍ជ្រៃ» មានសាក្សីថា ទាហាន លន់ នល់ ដែលត្រូវយកទៅសម្លាប់នោះមានចំនួនប្រហែលមួយម៉ឺននាក់ ។ លើសពីនេះ មានសាក្សីខ្លះទៀតឆ្លើយថា គេបានលួចចូលទៅមើល ហើយឃើញខ្មោចនៅពេញវាលដោយគ្មានសម្លៀកបំពាក់យោធា ឬសាកាដូយោធាទេ ។ តែសាក្សីខ្លះអះអាងថា មានសាកាដូនៅទីនោះច្រើនណាស់ ។ សូមសាធារណជន លោក លោកស្រី ចៅក្រមនិងដាក់ចម្ងល់បន្តិចមើល! នៅក្នុងស្ថានភាពគ្រោះថ្នាក់បែបនេះ តើមានហេតុផលអ្វីដែលប្រជាជនទាំងនោះប្រថុយនឹងគ្រោះថ្នាក់ដល់ជីវិតសុខចិត្តលួចចូលទៅមើលសាកសពទាំងនោះ ។ ប្រសិនបើមានសម្លាប់មនុស្សមែននោះ ខ្ញុំជឿថាកន្លែងនោះជាតំបន់គ្រោះថ្នាក់ មនុស្សយើងធម្មតាមិនហានទៅទីនោះទេ ។ នៅពេលចៅក្រមស្តាប់ចម្លើយសាក្សីទាំងនោះ តើសាក្សីទាំងអស់នោះគួរជឿ និងយកជាសក្ខីកម្មត្រឹមត្រូវបានឬទេ? ចម្លើយគឺថា មិនអាចឲ្យជឿ និងយកជាការណ៍បាននោះទេ ដោយសារសក្ខីកម្មរបស់សាក្សីទាំងអស់នោះពោរពេញទៅដោយចំណុចមន្ទិលសង្ស័យ និងភូតកុហក ។ ខ្ញុំសួរថា នៅពេលនោះ ក្នុងនាមជាអ្នកដឹកនាំម្នាក់ តើមានពេលវេលាឯណាសម្រាប់គិតគូរពីបញ្ហានេះ? ពួកយើងមានកិច្ចការរួមសំខាន់ៗ និងបន្ទាន់ជាច្រើននៅទីក្រុងភ្នំពេញ ជាពិសេសនៅអំឡុងពេល២ឬ៣ខែដំបូង ។ បញ្ហាសំខាន់គឺដោះស្រាយជីវភាពរបស់ប្រជាជន និងការពារជាតិឲ្យផុតពីការប៉ុនប៉ងគ្រប់គ្រងពីបក្សកុម្មុយនីស្តវៀតណាម និងពីគូរបដិបក្ខ ។

លើសពីនេះទៀត ខ្ញុំសូមឆ្លើយតបចំពោះការចោទប្រកាន់របស់សហព្រះរាជអាជ្ញា ដែលថា បក្សកុម្មុយនីស្តកម្ពុជាបានប្រើប្រាស់ហិង្សាបដិវត្តន៍តាំងពីមុនឆ្នាំ១៩៧៥ ។ ការអះអាងនេះវាហាក់ដូចជាមើលព្រឹត្តិការណ៍ប្រទេសកម្ពុជាតែជ្រុងម្ខាង ឯជ្រុងម្ខាងទៀត ធ្វើជាមិនដឹង និងឃើញ ឬធ្វើមិនឮ ។ បើនិយាយភាសានៅក្នុងតុលាការវិញ គេថា យុត្តិធម៌សម្រាប់តែអ្នកឈ្នះ ។ សូមកុំភ្លេចថា មុនពេលសម្រេចចិត្តតស៊ូ ដោយអាវុធក្នុងបុព្វហេតុរំដោះប្រទេសជាតិ សមាជិកបក្សកុម្មុយនីស្តកម្ពុជា និងប្រជាជនជាច្រើនរូបត្រូវបានគេលួចសម្លាប់ ចាប់ខ្លួន ធ្វើទារុណកម្មដោយគ្មានហេតុផលនិងបាត់ខ្លួនជារៀងរាល់ថ្ងៃ ។ ព្រឹត្តិការណ៍នោះ ប្រជាពលរដ្ឋគ្រប់រូបគួរតែនៅចងចាំនៅឡើយ ។ អំពើហិង្សាទាំងនោះ បានកើតមានគ្រប់ជំនាន់ក្នុងសង្គមខ្មែរ ហើយជនរងគ្រោះនៃព្រឹត្តិការណ៍ទាំងនោះ សុទ្ធសឹងជាកសិករក្រីក្រ និងជនស្លូតត្រង់ ។

ខ្ញុំសូមចាប់ផ្តើមពីសម័យអាណានិគមនិយមបារាំង ។ បារាំងបានធ្វើអាណានិគមមកលើប្រទេសកម្ពុជាអស់រយៈពេលជិតមួយសតវត្សរ៍ ។ អ្នកកាន់អំណាចនាសម័យនោះបានប្រើហិង្សា ដោយតាមចាប់ខ្លួន និងកាប់សម្លាប់ប្រជាជនកសិករ ដែលគ្មានអាវុធ នៅភូមិក្រាំងលាវ ក្នុងខេត្តកំពង់ឆ្នាំង ដែលពួកគាត់ពុំមានលទ្ធភាពបង់ពន្ធដារ ត្រូវបង្ខំចិត្តតវ៉ា និងទាមទារយុត្តិធម៌ ។ ចុងក្រោយ អ្នកចាញ់គឺកសិករក្រីក្រ ហើយភូមិរបស់ពួកគាត់ ត្រូវបានគេប្តូរឈ្មោះទៅជាភូមិតិរច្ឆាន ។ តើនេះមិនមែនជាហិង្សាទេឬ?

នៅសម័យសង្គមរាស្ត្រនិយម ពួកអ្នកមានអំណាច បានទៅឈូសឆាយ ដុះសម្បែង ស្រែចម្ការរបស់កសិករនៅសំឡូត ។ល ។ ពួកគេបានរំលោភបំពានយកដីពីប្រជាកសិករដែលធ្លាប់បានរស់នៅទីនោះតកូន តចៅរាប់ជំនាន់មកហើយនោះ ។ នៅពេលដែលប្រជាជនតវ៉ាដើម្បីការពារទ្រព្យសម្បត្តិរបស់ពួកគាត់ ទាហានបានបាញ់សម្លាប់ប្រជាជនដែលគ្មានអាវុធយ៉ាងរង្គាល ទាំងក្មេង ទាំងចាស់ ទាំងប្រុស ទាំងស្រី ។ ឈឺចាប់ជាងនេះ ពួកគេតាមកាប់សម្លាប់ប្រជាជនជាច្រើនទៀត ដែលហេតុធ្វើឲ្យប្រជាជនមានការភ័យខ្លាច និងរត់ចូលព្រៃ ។ តែអ្នកមានអំណាចបានចោទប្រកាន់ប្រជាជន ម្ចាស់ទឹក ម្ចាស់ដីទាំងនោះថា ជាខ្មែរក្រហម ។ តើនេះមិនមែនជាការបង្កើតហិង្សា និងធ្វើឲ្យឈឺចាប់ទេឬ?

នៅក្នុងសម័យ លន់ នល់ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់សហរដ្ឋអាមេរិក ពួកទាហាន លន់ នល់ បានរំលោភស្ត្រី ប្លន់យកទ្រព្យសម្បត្តិ កាប់សម្លាប់ប្រជាជននៅគ្រប់ទីកន្លែង និងកាត់ក្បាលមនុស្សដោតតាមរបងផ្ទះ ដោយគ្រាន់តែសង្ស័យថា ប្រឆាំងនឹងរបបរបស់ខ្លួន និងយកលេសថា ប្រជាជនរងគ្រោះទាំងនោះជាខ្មែរក្រហម ។ មិនតែប៉ុណ្ណោះ ពួក លន់ នល់ បានប្រព្រឹត្តិជាប្រព័ន្ធនូវអំពើរំលោភស្ត្រីភេទ ប្លន់ទ្រព្យសម្បត្តិ ជម្លៀសដោយហិង្សាចេញពីផ្ទះសម្បែង កាប់សម្លាប់យ៉ាងរង្គាលលើអនិកជនវៀតណាមនៅគ្រប់ទីកន្លែង ។ លើសពីនេះ អាមេរិកផ្ទាល់ បានទម្លាក់គ្រាប់បែកជាច្រើនតោន មកលើភូមិករ ផ្ទះសម្បែង វត្តអារាម ស្រែចម្ការរបស់កសិករកម្ពុជា សម្លាប់ជនស៊ីវិល មានទាំងកុមារ មនុស្សចាស់ជរា ស្ត្រីមានផ្ទៃពោះ និងជនពិការ អស់រាប់ម៉ឺននាក់ ។ តើនេះមិនមែនជាឧក្រិដ្ឋកម្មសង្គ្រាម ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទេឬ?

នៅក្នុងឆ្នាំ១៩៧៩ វៀតណាមបានចូលឈ្លានពាន និងកាន់កាប់ប្រទេសកម្ពុជា ហើយនៅឆ្នាំបន្តបន្ទាប់មក ពួកគេបានបាញ់ផ្លោងដាក់ជំរំជនភៀសខ្លួននៅតាមព្រំដែនកម្ពុជា-ថៃ ធ្វើឲ្យឆេះលំនៅដ្ឋាន ទ្រព្យសម្បត្តិ បាត់បង់ជីវិតមនុស្សរាប់សិបនាក់ក្នុងនោះមានទាំងកុមារ ស្ត្រីភេទ មនុស្សចាស់ជរា និងជនពិការផងដែរ ។ លើសពីនេះ ពួកគេបានរៀបចំ «ផែនការក-៥» ដោយចាប់បង្ខំប្រជាជនស៊ីវិលឲ្យចូលព្រៃ ជញ្ជូនគ្រាប់រំសេវ ជីកលេណដ្ឋាន ដើម្បីការពារអំណាចដែលបានមកពីការឈ្លានពាន ដែលបណ្តាលឲ្យប្រជាជនស្លាប់អស់រាប់ម៉ឺននាក់ ។ តើទាំងនេះមិនមែនជាឧក្រិដ្ឋកម្មទេឬ? មិនមែនជាផែនការសម្លាប់មនុស្សទេឬ?

នៅក្នុងឆ្នាំ១៩៩៧ គេបានប្រយុទ្ធគ្នាក្នុងទីក្រុងភ្នំពេញ ដើម្បីដណ្តើមអំណាចគ្នា បណ្តាលឲ្យឆេះផ្ទះសម្បែង ទ្រព្យសម្បត្តិរបស់ប្រជាជន ស្លាប់ជនស៊ីវិល ហើយឈ្លើយសឹកមួយចំនួនរបស់ទាហានហ៊ុនស៊ិនប៉ិច ត្រូវបានគេបាញ់សម្លាប់ក្រោយពេលពួកគេចុះចាញ់ ។ ឧទាហរណ៍ លោក ហូ សុក ត្រូវបានគេសម្លាប់នៅក្នុងបរិវេណក្រសួងមហាផ្ទៃនៅពេលចាប់បានជាចំណាប់ខ្មាំង ។ តើនេះមិនមែនជាហិង្សាឬបទល្មើសឧក្រិដ្ឋទេឬ? តើព្រឹត្តិការណ៍ទាំងអស់ដែលខ្ញុំបានលើកឡើងនេះមិនមែនជាហិង្សា ឬឧក្រិដ្ឋកម្មជាអំពើអមនុស្សធម៌ទេឬ?

ទាំងអស់នេះអាចជាសក្ខីភាព អាចជាសក្ខីភាពមួយសម្រាប់ធ្វើការប្រៀបធៀបទៅនឹងស្ថានភាពនៃបក្សកុម្មុយនីស្តកម្ពុជា ។ ប្រសិនបើចោទប្រកាន់ថា មុនឆ្នាំ១៩៧៥ បក្សកុម្មុយនីស្តកម្ពុជាបានប្រើហិង្សា ចុះហេតុអ្វីសហព្រះរាជអាជ្ញាមិនព្រមផ្តល់សច្ចភាពបន្តិចបន្តួច ដោយគ្រាន់តែលើកពីអំពើខ្លះស្រាលៗ ដែលភាគីម្ខាងទៀតបានប្រព្រឹត្តមកលើប្រជាជនកម្ពុជា ។ ខ្ញុំមើលឃើញថា សហព្រះរាជអាជ្ញាបានខិតខំលើកយកការកាប់សម្លាប់គ្នាទៅវិញទៅមកក្នុងដំណាក់កាលធ្វើសង្គ្រាម មកភ្ជាប់ជាមួយព្រឹត្តិការណ៍កាប់សម្លាប់ក្រោយបញ្ចប់សង្គ្រាមភ្លាម ដើម្បីបង្ហាញអង្គជំនុំជម្រះថា នេះជាផែនការធ្វើឡើងជាប្រព័ន្ធរបស់បក្សកុម្មុយនីស្តកម្ពុជា ។ ការភ្ជាប់ស្ថានភាពបែបនេះ មិនយុត្តិធម៌ទេ ដោយហេតុផល បើចាត់ទុកការកាប់សម្លាប់គ្នាក្នុងពេលធ្វើសង្គ្រាមថា ជាផែនការធ្វើឡើងជាប្រព័ន្ធ ហេតុអ្វីមិនចោទប្រកាន់លើគូបដិបក្ខម្ខាងទៀតនៃសង្គ្រាមផងទៅ? ជាការពិតណាស់ បក្សកុម្មុយនីស្តកម្ពុជាបានធ្វើផែនការធ្វើសង្គ្រាម ដើម្បីរំដោះប្រទេសជាតិពីភាពអន្តរាយ ។ យុទ្ធសាស្ត្រប្រយុទ្ធសម្រាប់សត្រូវ ពិតជាត្រូវបានប្រើប្រាស់ ដើម្បីទទួលបានជ័យជម្នះ ។ ការធ្វើបែបនេះ ខ្ញុំគិតថា វាមិនមែនជាការខុសច្បាប់ទេ ។ ប្រជាជននៃប្រទេសជាច្រើននៅលើពិភពលោកបានវាយប្រយុទ្ធគ្នាប្រឆាំងនឹងរដ្ឋាភិបាលរបស់ខ្លួនសម្រាប់បុព្វហេតុអ្វីមួយដែលគេគិតថា អ្វីដែលកើតឡើងមកលើពួកគេ ជាការមិនត្រឹមត្រូវ និងទាមទារឲ្យមានការផ្លាស់ប្តូរ ។ ជាពិសេស ការទាមទារសិទ្ធិស្វ័យ

សម្រេចទៅលើជោគវាសនាប្រទេសជាតិខ្លួន ។ ខ្ញុំសូមផ្ដល់ឧទាហរណ៍ខ្លះៗ ដូចជា ប្រទេសសិរីលង្ការ ប្រទេសស៊ីរី ប្រទេសលីប៊ី ប្រទេសវៀតណាម និងប្រទេសអ៊ីរ៉ាក់ ។ល ។ ប្រទេសទាំងអស់នោះសុទ្ធតែធ្លាប់ប្រយុទ្ធគ្នា ។ នៅពេលប្រយុទ្ធបែបនេះ ក្រុមមនុស្សទាំងនោះសុទ្ធសឹងតែមានផែនការ ដើម្បីកម្ទេចសត្រូវរបស់ខ្លួនទៅវិញទៅមក ។ ប្រសិនបើតុលាការចាត់ទុកថា ការធ្វើផែនការប្រយុទ្ធនៅពេលធ្វើសង្គ្រាមរបស់ភាគីដើម្បីទទួលជ័យជម្នះ ជាចេតនាប្រព្រឹត្តិបទល្មើស ដូចលោក លោកស្រីសហព្រះរាជអាជ្ញាចោទប្រកាន់មែននោះ ម៉្លេះសមមេដឹកនាំនៃប្រទេសទាំងអស់នោះ មិនថា រាជរដ្ឋាភិបាល ឬក្រុមប្រឆាំងទេ ត្រូវតែយកមកកាត់ទោសដូចគ្នា ជាពិសេស សហរដ្ឋអាមេរិក វៀតណាម រួមទាំងមេដឹកនាំខ្មែរដទៃទៀតផង ។ កុំយកតែខ្លួនក្រពើមកកាត់ទោស តែក្បាល និងកន្ទុយទុកនៅដោយឡែករួចពីសំណាញ់ច្បាប់ ។ នេះជារឿងអយុត្តិធម៌ណាស់ចំពោះរូបខ្ញុំ ។ ខ្ញុំសូមឲ្យលោក លោកស្រីចៅក្រមញែកឲ្យដាច់ពីគ្នារវាងផែនការវាយរំដោះទឹកដី ទៅនឹងផែនការសម្លាប់មនុស្សនៅក្រោយសង្គ្រាម ។ ចំណុចទាំងពីរនេះ មានភាពខុសគ្នាស្រឡះ ផែនការប្រយុទ្ធគ្នា ឬកម្ទេចសត្រូវ ត្រូវបានបញ្ចប់នៅពេលបញ្ចប់សង្គ្រាម ។ ចំណែកចេតនាសម្លាប់មនុស្ស វាជាដំណាក់កាលថ្មីនៃអ្នកកាន់អំណាចនៅពេលដែលពួកគេបានទទួលមុខដំណែងក្នុងការគ្រប់គ្រងប្រទេស ។ ម្យ៉ាងវិញទៀត ខ្ញុំចាំបានថា តុលាការនេះបានកំណត់វិសាលភាពនៃការកាត់ទោសចំពោះតែអំពើទាំងឡាយណាដែលកើតឡើងក្នុងចន្លោះថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ មករា ឆ្នាំ១៩៧៩ ប៉ុណ្ណោះ ។ បើទោះជាខ្ញុំមិនចេះច្បាប់ក៏ដោយ ក៏ខ្ញុំយល់ថា ការអះអាងរបស់លោក លោកស្រីសហព្រះរាជអាជ្ញាអំពីសកម្មភាពរបស់ខ្ញុំនៅមុនថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ពិតជាអំណះអំណាងខុសច្បាប់ និងគ្មានតម្លៃតាមផ្លូវច្បាប់ ។ ជារួម ការលើកឡើងរបស់លោក លោកស្រីសហព្រះរាជអាជ្ញា ពីអំពើហិង្សាបដិវត្តន៍នៅមុនថ្ងៃរំដោះ១៧ មេសា ឆ្នាំ១៩៧៥ ដើម្បីធ្វើជាមូលដ្ឋានច្បាប់សម្រាប់បង្គ្រប់ធាតុផ្សំនៃបទល្មើសក្នុងគោលបំណងដាក់ទោសចំពោះរូបខ្ញុំនោះ គឺពិតជាមិនត្រឹមត្រូវទេ ។ សូមលោក លោកស្រីចៅក្រមបដិសេធចោលចំពោះការអះអាងនេះ ។

### ១.២) ការជម្លៀសប្រជាជន

ដូចខ្ញុំបានជម្រាបជូនអង្គសវនាការរួចមកហើយកាលពីប៉ុន្មានឆ្នាំមុននេះ ក្រោយថ្ងៃរំដោះថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ប្រជាជនទាំងអស់ដែលបានរស់នៅក្នុងទីក្រុងនានា ត្រូវបានជម្លៀសចេញពីទីក្រុងពិតមែន ។ តែការជម្លៀសនេះ មិនមែនជាការជម្លៀសដោយបង្ខំនោះទេ ។ មានហេតុផលពីរយ៉ាងដែលថ្នាក់ដឹកនាំបានបង្ខំចិត្តខ្លួនឯង ធ្វើសេចក្ដីសម្រេចបែបនេះ ។

**ហេតុផលទី១:** គឺដោយសារមានការភ័យខ្លាចការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិកមកលើទីក្រុងក្រោយរដ្ឋាភិបាល លន់ នល់ បានទទួលបរាជ័យ ។ ចំណុចនេះ វាជាមូលហេតុដែលធ្វើឲ្យថ្នាក់ដឹកនាំ និងប្រជាពលរដ្ឋខ្មែរជឿបានថា នឹងមានយន្តហោះអាមេរិកមកទម្លាក់គ្រាប់បែកនៅប្រទេសកម្ពុជាជាថ្មីទៀតនៅតាមក្រុងនានា ជាពិសេសនៅទីក្រុងភ្នំពេញ ព្រោះសហរដ្ឋអាមេរិកធ្លាប់ទម្លាក់គ្រាប់បែកមកលើប្រទេសកម្ពុជាជាច្រើនគោនកន្លងមកហើយ ។

**ហេតុផលទី២:** គឺថា ប្រទេសកម្ពុជាបានឆ្លងកាត់សង្គ្រាមអស់រយៈពេលជាងប្រាំឆ្នាំមកហើយ ។ តាមរយៈសង្គ្រាមនេះ ប្រទេសកម្ពុជាបានជួបប្រទះបញ្ហាប្រឈមជាច្រើន រួមទាំងស្បៀងអាហារផងដែរ ។ ករណីស្បៀងអាហារ វាជាបញ្ហាមួយសំខាន់ដែលត្រូវដោះស្រាយជាបន្ទាន់ ព្រោះវាទាក់ទងនឹងអាយុជីវិតរបស់ប្រជាជន ។ នៅពេលនោះ ប្រទេសកម្ពុជាក៏មិនមានជំនួយពីបរទេសដែរ ។ ស្ថិតនៅក្នុងកាលៈទេសៈបន្ទាន់បែបនេះ បានជាថ្នាក់ដឹកនាំរបស់បក្សកុម្មុយនីស្តកម្ពុជា បានរៀបចំផែនការជម្លៀសប្រជាជនឲ្យទៅតាមតំបន់ និងខេត្តណាដែលមានធនធាន សេដ្ឋកិច្ច ស្រូវ អង្ករ អាចចិញ្ចឹមប្រជាជនបាន និងទាមទារឲ្យប្រជាជនចូលរួមក្នុងការបង្កបង្កើនផលដោយខ្លួនឯង សម្រាប់ផ្គត់ផ្គង់ជីវភាពរស់នៅនិងកសាងប្រទេសជាតិ ។ ទាក់ទងនឹងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ គណៈអចិន្ត្រៃយ៍បានសម្រេចឲ្យមជ្ឈិមបក្សកោះប្រជុំដើម្បីរៀបចំផែនការជម្លៀស ។ គ្រប់លេខាភូមិភាគដែលជាសមាជិកគណៈមជ្ឈិមបក្សបានចូលរួមកិច្ចប្រជុំនេះ ។ ពេលនោះខ្ញុំចាំបានថា គ្រាន់តែភូមិភាគពាយ័ព្យបានធានាទទួលយកប្រជាជនចំនួន១លាន៥សែននាក់ ហើយភូមិភាគបូព៌ា ភូមិភាគនិរតី និងភូមិភាគកណ្ដាល បានធានាទទួលយកប្រជាជនដែលនៅសេសសល់ ។ ក្នុងផែនការនោះ គឺឲ្យភូមិភាគនីមួយៗ មានស្វ័យភាពក្នុងការជួយសម្រួលគ្នាទៅវិញទៅមកទាក់ទងនឹងការជម្លៀស

នេះ និងត្រូវណែនាំដល់សហករណ៍ឲ្យខិតខំដោះស្រាយជីវភាពប្រជាជនដែលបានជម្លៀសចេញពីទីក្រុងភ្នំពេញ ហើយកុំឲ្យមានការរើសអើងចំពោះប្រជាជនទាំងនោះផងដែរ ។

ទោះជាមានហេតុផលទាំងពីរនេះក្តី ការជម្លៀសប្រជាជននៅពេលនោះ ធ្វើឡើងតាមការស្ម័គ្រចិត្ត ដោយគ្មានការបង្ខិតបង្ខំគ្មានប្រើអំពើហិង្សា ឬសម្លាប់ប្រជាជននោះទេ ។ ប្រការនេះត្រូវបានអនុវត្តតាមរយៈការពន្យល់ប្រជាជនឲ្យបានដឹងច្បាស់ពីស្ថានភាពគ្រោះថ្នាក់នៃការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិកមកលើទីក្រុង និងតម្រូវការចាំបាច់នៃការដោះស្រាយជីវភាព និងកសាងប្រទេសដោយខ្លួនឯង ។ នៅពេលនោះ ប្រជាជនបានយល់ពីស្ថានភាពគ្រោះថ្នាក់ និងតម្រូវការចាំបាច់របស់ប្រទេសជាតិ ជាពិសេសប្រជាជនបានគាំទ្រនិងស្រឡាញ់បដិវត្តន៍ ។ ដូច្នេះហើយប្រជាជនបានចាកចេញពីទីក្រុងជាបណ្តើរៗតាមការអំពាវនាវ និងការពន្យល់របស់បក្សកុម្មុយនីស្តកម្ពុជា ។ ទាក់ទងនឹងចំណុចនេះ ខ្ញុំសូមបំភ្លឺចំពោះការចោទប្រកាន់របស់សហព្រះរាជអាជ្ញា ។ លោក លោកស្រីសហព្រះរាជអាជ្ញាបានចោទប្រកាន់ចំពោះការហ៊ុំព័ទ្ធទីក្រុងភ្នំពេញ ដែលបណ្តាលឲ្យមានវិបត្តិស្បៀងអាហារ និងការបាញ់ផ្លោងចូលក្នុងទីក្រុងទីតាំងជាមូលដ្ឋានបង្អែករបស់ លន់ នល់ ក្នុងទីក្រុងភ្នំពេញ ដែលធ្វើឡើងដោយបក្សកុម្មុយនីស្តកម្ពុជាថា នេះជាអំពើអមនុស្សធម៌ ។ ចុះសហព្រះរាជអាជ្ញាធ្លាប់បានគិតទេថា ពួក លន់ នល់ បានបាញ់ផ្លោងដោយកាំភ្លើងធំដែលសហរដ្ឋអាមេរិកផ្តល់ឲ្យអស់រាប់លានគ្រាប់ និងការទម្លាក់គ្រាប់បែកពីសំណាក់សហរដ្ឋអាមេរិកច្រើនជាងកន្លះលានតោន បំផ្លាញផ្ទះសម្បែង វត្តអារាម ទ្រព្យសម្បត្តិ ស្រែចម្ការ សត្វពាហនៈ របស់ប្រជាជន ។ ជាពិសេស បណ្តាលឲ្យស្លាប់មនុស្សរាប់សិបម៉ឺននាក់ មានទាំងចាស់ជរា ទាំងកុមារ ទាំងស្ត្រីភេទ តើនេះមិនមែនជាអំពើអមនុស្សធម៌ ឬជាឧក្រិដ្ឋកម្មទេឬ? គ្រាប់បែករបស់សហរដ្ឋអាមេរិកដែលបានទម្លាក់មកលើប្រទេសកម្ពុជាមានចំនួនច្រើនជាងបីដងនៃគ្រាប់បែកដែលសហរដ្ឋអាមេរិកបានទម្លាក់លើប្រទេសជប៉ុនក្នុងសង្គ្រាមលោកលើកទី២ ។

លើសពីនេះ បក្សកុម្មុយនីស្តកម្ពុជាមិនបានចាត់ទុកប្រជាជនដែលរស់នៅក្នុងទីក្រុងភ្នំពេញ ជាខ្មាំងដូចការចោទប្រកាន់របស់សហព្រះរាជអាជ្ញាទេ ។ ផ្ទុយទៅវិញ ប្រជាជនដែលរស់នៅក្នុងទីក្រុងភ្នំពេញទាំងនេះ ភាគច្រើនជាកម្មករ កសិករ អនុធន បញ្ញាជន និងបុគ្គលស្នេហាជាតិ ដែលបក្សកុម្មុយនីស្តកម្ពុជា ត្រូវប្រមូល និងចាត់ទុកជាកម្លាំងមួយដ៏សំខាន់ដើម្បីចូលរួមធ្វើបដិវត្តន៍ ។

ចំពោះករណីដែលលោក លោកស្រីសហព្រះរាជអាជ្ញាលើកឡើងអំពីកម្ពុជាប្រជាធិបតេយ្យជារដ្ឋទាសករ ។ នេះវាជារឿងមួយមិនអាចទទួលយកបានទេ ។ ខ្ញុំសូមជម្រាបជូនបងប្អូនជនរួមជាតិថា បក្សកុម្មុយនីស្តកម្ពុជាមិនមែនតស៊ូរំដោះប្រទេសកម្ពុជា ក្នុងគោលបំណងដាក់ប្រជាជនកម្ពុជាជាទាសករ ដូចការចោទប្រកាន់របស់សហព្រះរាជអាជ្ញាទេ ។ ផ្ទុយទៅវិញ បក្សកុម្មុយនីស្តកម្ពុជាបានរំដោះប្រជាជនកម្ពុជាពីទាសភាព ។ យើងទាំងអស់គ្នាគួរតែបានដឹងរួចមកហើយថា នៅមុនថ្ងៃរំដោះ១៧ មេសា ឆ្នាំ១៩៧៥ ប្រជាកសិករកម្ពុជាភាគច្រើនមានភាពក្រីក្រ ខ្វះមុខ ខ្វះក្រោយ និងជួបប្រទះការលំបាកយ៉ាងខ្លាំងនៅក្នុងជីវភាពរស់នៅរបស់ពួកគេ ។ រដ្ឋអំណាច លន់ នល់ មិនបានផ្តល់សេវាកម្មសាធារណៈ និងគិតគូរពីសុខមាលភាពសង្គមដល់ប្រជាជនក្រីក្រនោះទេ ។ អំពើពុករលួយ និងភាពអយុត្តិធម៌បានចាក់ឫសយ៉ាងជ្រៅនៅក្នុងសង្គមកម្ពុជា ។ ដោយសារហេតុផលនេះ ប្រជាកសិករកាន់តែក្រទៅៗ ពួកគាត់តែងតែខ្ចីបុលពីនាយទុនដើម្បីទ្រទ្រង់ជីវភាព ព្យាបាលជំងឺ ឬបង់ពន្ធដា ។ នៅពេលនោះហើយពួកនាយទុនបានឆ្លៀតពេលដែលប្រជាជនមានទុកលំបាក បានធ្វើទុក្ខបុកម្នេញ និងទារការប្រាក់គាត់តាមទំនើងចិត្ត រហូតដល់យកការប្រាក់ចំនួន៥០ភាគរយក្នុងមួយខែក៏មាន ។ ដោយការប្រាក់ខ្ពស់ហួសហេតុ នាំឲ្យប្រជាជនទាំងនោះគ្មានលទ្ធភាពសងបំណុល ហើយត្រូវបានម្ចាស់បំណុលរឹបអូសយកដីស្រែ ចម្ការ និងផ្ទះសម្បែងអស់ ។ នៅពេលអស់ដីស្រែ ចម្ការ និង ផ្ទះសម្បែង ប្រជាជនទាំងនោះត្រូវបង្ខំចិត្តស៊ីឈ្នួលគេ ឬត្រូវបានចាប់បង្ខំឲ្យធ្វើជាខ្ញុំកញ្ជះគេ ដើម្បីកាត់បំណុលដែលសងមិនចេះអស់នេះ ។ មានករណីជាច្រើនដែលពួកគាត់ត្រូវបង្ខំចិត្តលក់កូនឲ្យធ្វើជាខ្ញុំគេ តកូន តចៅ រហូតខ្លួនមិនរួចហើយក្លាយជាទាសកររបស់គេ ដោយលក់កម្លាំងដូរបាយតែមួយចំអែតក្រពះតែប៉ុណ្ណោះ ។ ការកេងប្រវ័ញ្ច និងភាពក្រីក្ររកទីបំផុតគ្មានរបស់ប្រជាកសិករនេះ ជាបុព្វហេតុមួយក្នុងបុព្វហេតុជាច្រើនទៀតដែលបក្សកុម្មុយនីស្តកម្ពុជារំដោះប្រទេសជាតិ និងប្រជាជនចេញពីទាសភាព ។ ការកេងប្រវ័ញ្ច ការជិះជាន់ និងការឈ្លានពាន

របស់បរទេស ដោយយកសាងប្រទេសកម្ពុជាមួយដែលប្រជាជនរស់នៅដោយស្មើភាព និងប្រជាជនជាម្ចាស់ប្រទេសពិតប្រាកដក្នុងគោលជំហរឯករាជ្យ ម្ចាស់ការ ខ្លួនទីពឹងខ្លួន ហើយខ្លួនសម្រេចលើជោគវាសនាជាតិខ្លួនដោយខ្លួនឯង ។ គ្មានគោលនយោបាយ ឬផែនការរបស់បក្សកុម្មុយនីស្តកម្ពុជាណាមួយដែលកំណត់ឲ្យដាក់ប្រជាជនជាទាសករ តាមរយៈ ការបង្អត់អាហារ ការបង្ខំឲ្យធ្វើការ ឬការសម្លាប់ឡើយ ។ ផ្ទុយទៅវិញ នៅពាក់កណ្តាលឆ្នាំ១៩៧៦ គណៈអចិន្ត្រៃយ៍បក្សកុម្មុយនីស្តកម្ពុជា បានរៀបចំ និងអនុម័តគម្រោងផែនការបួនឆ្នាំសម្រាប់កសាងសង្គមនិយមគ្រប់ផ្នែក ។ មាគ៌ា និងគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា គឺលើកស្ទួយកម្រិតជីវភាពរបស់ប្រជាជនកម្ពុជា ។ ផែនការនេះបានកំណត់ថា របបអាហាររបស់ប្រជាជនម្នាក់ៗ ចំនួន១៣ថាំងឬ១៣រយ ១២គីឡូក្រាមស្រូវក្នុងមួយឆ្នាំ ។ ដូច្នេះ ប្រជាជនហូបគ្រប់គ្រាន់សម្រាប់ពីបីពេលទៅបួនពេលក្នុងមួយថ្ងៃ ។ ចំពោះម្ហូប គឺពីរមុខ មានសម្លទឹក និងសម្លគោក ។ លើសពីនេះ បានសម្រេចបន្ថែមលើរបបអាហារ នូវចំណីនិងបង្អែមផ្សេងៗ ដោយផ្តល់ឲ្យបីថ្ងៃម្តងក្នុងឆ្នាំ១៩៧៧ ។ ពីរថ្ងៃម្តងៗក្នុងឆ្នាំ១៩៧៨ ហើយមួយថ្ងៃម្តង ចាប់ពីឆ្នាំ១៩៧៩តទៅ ។ ចំពោះការងារវិញគឺឲ្យប្រជាជនធ្វើការងារប្រាំបីម៉ោងក្នុងមួយថ្ងៃ និងឲ្យឈប់សម្រាកបីថ្ងៃក្នុងមួយខែ ។ នារីមានផ្ទៃពោះ និងឆ្លងទន្លេឲ្យឈប់សម្រាកពីរខែ ។ អ្នកជំងឺឲ្យឈប់សម្រាកតាមជាក់ស្តែង ។ លើសពីនេះ យើងបានរៀបចំបង្កើនគ្រឿងចក្រឲ្យកាន់តែច្រើន សម្រាប់សម្រាលទម្ងន់ការងារដោយកម្លាំងកាយផ្ទាល់របស់ប្រជាជន ។ នេះបង្ហាញថា គោលជំហរបក្សកុម្មុយនីស្តកម្ពុជា មិនបានបង្ខំឲ្យប្រជាជនធ្វើការយ៉ាងធ្ងន់ធ្ងរនោះឡើយ ។ ខ្ញុំនៅចាំបានថា មានថ្ងៃមួយ ខ្ញុំបានធ្វើដំណើរទៅកាន់ខេត្តសៀមរាប កាត់តាមខេត្តកំពង់ធំ នៅពេលយប់ ។ ខ្ញុំបានឃើញប្រជាជនដើរទៅកាន់វាលស្រែ ពេលខ្ញុំសួរកម្មាភិបាលគ្រប់គ្រងមូលដ្ឋាននោះ គេឆ្លើយប្រាប់ខ្ញុំថា ប្រជាជនមានស្មារតីប្តេជ្ញាចិត្តខ្ពស់ ស្ម័គ្រចិត្តធ្វើការបន្ថែម ។ ក្រោយឆ្នាំ១៩៧៩ ទើបខ្ញុំបានដឹងថា កម្មាភិបាលមូលដ្ឋាននោះបានកុហកខ្ញុំ ។ លើសពីនេះ យើងបានគ្រោងការចំណាយសម្រាប់ថ្នាំពេទ្យរយៈពេលបួនឆ្នាំ សរុប៣៥លាន ២សែន ៧ម៉ឺនដុល្លារ ។ សម្រាប់សម្លៀកបំពាក់រយៈពេលបួនឆ្នាំ សរុប៦៦លាន ២សែន ៧ម៉ឺនដុល្លារ ។ សម្រាប់ផ្ទះសម្បែង អនាម័យ វប្បធម៌ រយៈពេលបួនឆ្នាំ សរុប៨០លាន ២សែន និង៣ម៉ឺនដុល្លារ ។ បក្សកុម្មុយនីស្តកម្ពុជាបានដាក់ចេញនូវផែនការនេះយ៉ាងជាក់លាក់ និងច្បាស់លាស់ សម្រាប់ឲ្យភូមិភាគ និងតំបន់ស្វយ័តនីមួយៗអនុវត្ត ។

ចំពោះការកាប់សម្លាប់ ក៏មិនមែនជាផែនការ ឬគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាដែរ ។ បក្សកុម្មុយនីស្តកម្ពុជាមានផែនការបង្កើនប្រជាជន មិនមែនកាត់បន្ថយចំនួនប្រជាជននោះឡើយ ។ ប៉ុន្តែគួរឲ្យសោកស្តាយដែលភូមិភាគ និងតំបន់ស្វយ័តខ្លះមិនបានអនុវត្តតាមការសម្រេចរបស់គណៈអចិន្ត្រៃយ៍ ។ មកដល់ពេលនេះ ខ្ញុំអាចសរុប និងឆ្លើយតបនឹងចម្ងល់របស់តុលាការ និងជាពិសេសជនរួមជាតិរបស់ខ្ញុំឲ្យបានជ្រាបថា វិនាសកម្មដែលបានកើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យដោយសារមូលហេតុដូចខាងក្រោម ៖

**ទី១)** អ្នកដឹកនាំរបស់បក្សកុម្មុយនីស្តកម្ពុជាជ្រើសរើសកម្មាភិបាលមួយចំនួនខុស ដោយអ្នកខ្លះក្បត់ អ្នកខ្លះក្តាប់មិនបានពីមាគ៌ារបស់បក្ស ហើយអ្នកដឹកនាំរវល់តែកិច្ចការនៅទីក្រុងភ្នំពេញ មិនសូវបានចុះទៅតាមសហករណ៍ឲ្យបានជាប់លាប់ ។

**ទី២)** មានមេដឹកនាំភូមិភាគ តំបន់ស្វយ័ត និងកម្មាភិបាលមួយចំនួន ជាភ្នាក់ងារបង្កប់របស់វៀតណាម និងអាមេរិកដែលក្បត់បដិវត្តន៍ ។ ពួកគេបានធ្វើសកម្មភាពបំផ្លិចបំផ្លាញចលនាបក្សកុម្មុយនីស្តកម្ពុជា ប្រជាជនកម្ពុជា និងប្រទេសកម្ពុជា ។ ពួកមិនបានធ្វើតាមផែនការ និងគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាទេ ។ បែរជានាំគ្នាកាប់សម្លាប់ និងធ្វើបាបប្រជាជន ដោយការបង្អត់អាហារ ការបង្ខំឲ្យធ្វើការហួសកម្លាំងតាមទំនើងចិត្តរបស់ខ្លួន ហើយលាក់បាំង និងរាយការណ៍ភូតកុហកមកកមជ្ឈិមបក្ស ។ ពួកគេធ្វើគ្រប់វិធីដើម្បីធ្វើឲ្យប្រជាជនមានសតិអារម្មណ៍ថ្នាំងថ្នាក់ងាកមកប្រឆាំងនឹងបដិវត្តន៍ បណ្តាលឲ្យបក្សកុម្មុយនីស្តកម្ពុជាចុះខ្សោយ ហើយសត្រូវបរទេសយកលេសថាមករំដោះប្រជាជនកម្ពុជា ដើម្បីឲ្យការឈ្លានពានរបស់គេក្លាយជាអំពើស្របច្បាប់ ។ ជាក់ស្តែង មេភូមិភាគបូព៌ាបានបង្អត់បាយប្រជាជន តែបែរជាលួចដឹកស្រូវចេញទៅ ប្រទេសវៀតណាមទៅវិញ ។ ក្រុមនេះអាចចាត់ទុកថា ជាពួកដុតឲ្យខ្លោច រោចឲ្យឆៅ ។ ពួកដុតឲ្យខ្លោចគឺពួកធ្វើឲ្យលើសហួសហេតុពីគោលនយោបាយរបស់

បក្សកុម្មុយនីស្តកម្ពុជា ។ ពួកវោចឲ្យនៅ គឺពួកគេមិនធ្វើអ្វីទាំងអស់ មិនខ្វល់អ្វីទាំងអស់ ហើយកម្មាភិបាលថ្នាក់ក្រោមធ្វើតាមអំពើចិត្ត ។

**ទី៣)** មានកម្មាភិបាលភូមិភាគ តំបន់ស្វយ័ត ស្រុក និងសហករណ៍មួយចំនួនធំក្តាប់មិនបានពីមាគ៌ា ផែនការ និងគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ។ ក្រុមនេះមិនបានរាយការណ៍ពីការលំបាក និងការខ្វះខាតរបស់ប្រជាជន ឬបើបានជារាយការណ៍វិញ គេរាយការណ៍បំផ្លើសពីភាពជោគជ័យក្នុងការដឹកនាំមូលដ្ឋានរបស់ខ្លួន មកមជ្ឈិមបក្ស ជាថ្នូរនឹងស្នាដៃ ។ ដើម្បីឲ្យបានសម្រេចដូចរបាយការណ៍ ពួកគេបានបង្ខិតបង្ខំឲ្យប្រជាជនឲ្យធ្វើការហួសកម្លាំង កាត់បន្ថយរបបអាហារ និងកាប់សម្លាប់តាមតែចិត្តរបស់ខ្លួន ។

សរុបមក បក្សកុម្មុយនីស្តកម្ពុជាមានហេតុផលច្បាស់លាស់ចំពោះការជម្លៀសប្រជាជន ក្នុងគោលដៅដើម្បីធានានូវសុវត្ថិភាពរបស់ប្រជាជន និងរំដោះប្រជាជនចេញពីទាសភាព និងអំពើអយុត្តិធម៌ ។ វាមិនមែនជាការដាក់ប្រជាជនជាទាសករនោះទេ ។

**ក) ភាពយុត្តិធម៌នៅពេលកាត់សេចក្តីនេះ**

គោរពតុលាការ! តាមការសង្កេតរបស់ខ្ញុំនៅក្នុងសវនាការនេះ សិទ្ធិជាមូលដ្ឋានមួយចំនួនរបស់ខ្ញុំត្រូវបានរំលោភបំពាន ។ តាមពិតទៅខ្ញុំមិនគួរនិយាយថា ការកាត់សេចក្តីនេះមានភាពអយុត្តិធម៌នោះទេ ពីព្រោះខ្ញុំកំពុងតែសុំតុលាការជួយរកយុត្តិធម៌ឲ្យខ្ញុំ ។ ប្រសិនបើចៅក្រមខឹងខ្ញុំ ដោយសារតែខ្ញុំរិះគន់នោះ ភាពអយុត្តិធម៌ពិតជាកើតមានឡើងចំពោះខ្ញុំជាមិនខាន ។ តែបើខ្ញុំមិននិយាយអំពីការរំលោភបំពាននោះទេ ឱកាសនៃការរកយុត្តិធម៌ឲ្យខ្ញុំនោះ វារិតតែគ្មានទាល់តែសោះ ពីព្រោះសិទ្ធិទាំងអស់នោះ ជាមូលដ្ឋានគ្រឹះនៃការរកយុត្តិធម៌ឲ្យខ្ញុំ ។ ទាក់ទងនឹងករណីនេះ ខ្ញុំបានតាមដាន និងសង្កេតដោយយកចិត្តទុកដាក់បំផុត ហើយឃើញថា មានសិទ្ធិច្រើនណាស់ត្រូវបានរំលោភបំពាន ។

**ក) ភាពមិនស្មើគ្នានៃការប្រមូលភ័ស្តុតាង៖** នៅពេលដំណើរការរឿងក្តី មេធាវីរបស់ខ្ញុំ មិនត្រូវបានអនុញ្ញាតឲ្យចុះស៊ើបអង្កេតដើម្បីប្រមូលភ័ស្តុតាងយកមកការពារខ្ញុំនោះទេ ។ ចំណែកសហព្រះរាជអាជ្ញាវិញ មានឱកាសគ្រប់គ្រាន់ក្នុងការស៊ើបអង្កេត សួរសាក្សីតាំងពីដំបូង ។ ចំពោះមេធាវីការពារខ្ញុំវិញ មិនត្រូវបានអនុញ្ញាតឲ្យស្វែងរកសាក្សីផ្សេងក្រៅពីបញ្ជីសាក្សីដែលចៅក្រមស៊ើបអង្កេតផ្តល់ឲ្យនោះទេ ។ ការធ្វើបែបនេះ វាហាក់ដូចជាចងដៃមេធាវី និងកម្រិតសិទ្ធិមេធាវីរបស់ខ្ញុំ ក្នុងការប្រមូលភ័ស្តុតាងមកការពារខ្ញុំ ហើយផ្តល់ឱកាសឲ្យភាគីម្ខាងទៀតវ៉ៃខ្ញុំតាមចិត្ត ។ នេះធ្វើឲ្យប៉ះពាល់យ៉ាងខ្លាំងដល់ការការពាររបស់មេធាវី និងផលប្រយោជន៍ស្របច្បាប់របស់ខ្ញុំ ។

**២) មិនបានកោះហៅសាក្សីសំខាន់មកបំភ្លឺនៅចំពោះមុខតុលាការ៖**

ករណីនេះ មេធាវីរបស់ខ្ញុំបានស្នើសុំជាច្រើនដងឲ្យតុលាការកោះហៅសាក្សីសំខាន់ៗមួយចំនួនឲ្យចូលមកបំភ្លឺនៅចំពោះមុខតុលាការ ដូចជាសាក្សីអគ្គចរិក និងសាក្សីទាក់ទងនឹងការសម្លាប់ទាហាន លន់ នល់ នៅទួលពោធិ៍ជ្រៃ ។ តែតុលាការបានបដិសេធ ។ ការសម្រេចនេះ បានធ្វើឲ្យប៉ះពាល់ដល់ការស្វែងរកការពិត និងត្រឹមត្រូវចំពោះរឿងក្តី ។

**៣) មានភាពលម្អៀងក្នុងការសាកសួរសាក្សីនៅចំពោះមុខតុលាការ៖**

ការសួរសាក្សីជាផ្នែកមួយដ៏សំខាន់សម្រាប់ស្វែងរកការពិត និងភាពមិនច្បាស់លាស់របស់សាក្សី ដែលផ្អែកលើលទ្ធផលនៃសក្ខីកម្មនេះ ចៅក្រមអាចសម្រេចក្តីប្រកបដោយយុត្តិធម៌ ។ ចំពោះសវនាការនេះ ខ្ញុំមើលឃើញថា ចៅក្រមមិនបានពិចារណាឲ្យបានដិតដល់អំពីបញ្ហានេះទេ ។ នៅពេលព្រះរាជអាជ្ញាសួរសាក្សី ចៅក្រមតែងតែផ្តល់ឱកាសឲ្យព្រះរាជអាជ្ញាសួររហូតកម្រនឹងមានការរំខានណាស់ បើទោះជាមានការជំទាស់ពីមេធាវីការពារក៏ដោយ ។ ចំពោះមេធាវីការពារវិញ មិនមានឱកាសដូចនេះទេ ។ មេធាវីការពារត្រូវបានរំខានគ្រប់ពេលវេលាតាមការជំទាស់របស់សហព្រះរាជអាជ្ញា ហើយចៅក្រម តែងតែផ្តល់ឲ្យព្រះរាជអាជ្ញាធ្វើបែបនេះ ។ មានពេលខ្លះនៅពេលមេធាវីការពារធ្វើការតវ៉ា ក៏មានការព្រមានពីប្រធានសវនាការជាដើម ។ ដោយមើលឃើញពីភាពអយុត្តិបែបនេះ ទាំងរូបខ្ញុំក៏ដូចជាលោក ខៀវ សំផន បានសម្រេចចិត្តឈប់ផ្តល់សក្ខីកម្មជូនតុលាការ ពីព្រោះយើងយល់ថា បើទោះជាយើងផ្តល់ចម្លើយជូនចៅក្រម ក៏វាមិនមានន័យអ្វីដែរ ដោយហេតុថាចៅក្រមមានភាពលម្អៀង ហើយអ្វីដែលអនុវត្តនៅចំពោះមុខតុលាការនោះ វាគ្រាន់តែជាការបង្គ្រប់នីតិវិធី ឬបំពេញទម្រង់ឲ្យល្អមើលតែប៉ុណ្ណោះ ។

សរុបសេចក្តីមក ដោយផ្អែកលើមូលដ្ឋានទាំងបីដែលខ្ញុំបានបញ្ជាក់ជូនខាងលើនេះ វាបានឆ្លុះបញ្ចាំងយ៉ាងច្បាស់ថា ខ្ញុំមិនបានធ្វើផែនការប្រព្រឹត្តបទល្មើស ខ្ញុំមិនបានជួយឧបត្ថម្ភ ឬលើកទឹកចិត្តឲ្យ

ជនណាម្នាក់ឲ្យប្រព្រឹត្តបទល្មើស ។ បើទោះជាខ្ញុំមានតួនាទីជាអនុលេខាបក្សកុម្មុយនីស្តកម្ពុជា និងជាប្រធានសភាតំណាងប្រជាជនកម្ពុជា ខ្ញុំមិនបានដឹងអំពីការប្រព្រឹត្តបទល្មើសនៅតាមមូលដ្ឋាននោះទេ ។ ទើបតែនៅជិតចុងបញ្ចប់នៃរបបកម្ពុជាប្រជាធិបតេយ្យ ទើបខ្ញុំបានដឹងអំពីអំពើក្បត់របស់មេដឹកនាំនៅតាមភូមិភាគ តំបន់ មូលដ្ឋានខ្លះដែលមានបំណងបំផ្លាញចលនាបក្សកុម្មុយនីស្តកម្ពុជា ហើយនៅពេលនោះ ខ្ញុំពិតជាគ្មានអំណាចក្នុងការទប់ស្កាត់អំពើក្បត់ទាំងនោះបានឡើយ ពីព្រោះខ្ញុំពុំមានតួនាទីគ្រប់គ្រងផ្ទាល់លើកងកម្លាំងយោធា ឬរដ្ឋអំណាចមូលដ្ឋានទាល់តែសោះ ។ ប្រសិនបើក្នុងរបបកម្ពុជាប្រជាធិបតេយ្យខ្ញុំពិតជាមានអំណាចដឹកនាំ ឬបានប្រព្រឹត្តដូចការចោទប្រកាន់នៅពេលនេះ ប្រាកដជាតុលាការដែលបង្កើតឡើងដោយរបបសាធារណរដ្ឋប្រជាមានិតកម្ពុជាក្នុងឆ្នាំ១៩៧៥ ពិតជាកាត់ទោសខ្ញុំដូចជា ប៉ុល ពត និង អៀង សារី ទៅហើយ ពីព្រោះពេលនោះភស្តុតាងនៃឧក្រិដ្ឋកម្មនៅបន្សល់ទុកថ្មីៗ នៅឡើយមិនបាច់រង់ចាំពេល៣៨ឆ្នាំដើម្បីកាត់ទោសខ្ញុំទេ ។ តែដោយសារដឹងថាខ្ញុំគ្មានអំណាចអ្វី និងមិនបានប្រព្រឹត្ត ។ ទោះបីជាយ៉ាងណា ខ្ញុំនៅតែសម្តែងនូវការសោកស្តាយជាទីបំផុត និងសូមទទួលខុសត្រូវផ្នែកសីលធម៌ចំពោះជនរងគ្រោះទាំងអស់ និងប្រជាជនកម្ពុជាទាំងមូលដែលបានទទួលរងគ្រោះក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ជាការពិតសម្រាប់ប្រវត្តិសាស្ត្រ ទាំងគោលនយោបាយ ទាំងមាគ៌ា និងទាំងផែនការរបស់ចលនាបក្សកុម្មុយនីស្តកម្ពុជាបានបង្កើតឡើងក្នុងគោលបំណងតែមួយគត់គឺរំដោះប្រទេសជាតិនិងប្រជាជនឲ្យរួចផុតពីអាណានិគមនិម ចក្រព័ត្តិនិយម និងការជិះជាន់កេងប្រវ័ញ្ចភាពក្រីក្ររកទីបំផុតគ្មានការជ្រៀតជ្រែក និងការឈ្លានពានពីប្រទេសជិតខាងពិសេសពីប្រទេសវៀតណាម ។ បក្សកុម្មុយនីស្តកម្ពុជាមានគោលនយោបាយជាក់លាក់ គ្មានការភូតភរ គឺកសាងប្រទេសមួយស្មើភាពគ្នា និងប្រជាជនជាម្ចាស់ប្រទេសពិតប្រាកដក្នុងគោលជំហរឯករាជ្យ ម្ចាស់ការ ខ្លួនទីពឹងខ្លួន ហើយខ្លួនសម្រេចលើជោគវាសនាជាតិខ្លួនដោយខ្លួនឯង ។ ចលនាបក្សកុម្មុយនីស្តកម្ពុជាបង្កើតឡើង មិនមែនដើម្បីកាប់សម្លាប់ប្រជាជននិងបំផ្លាញប្រទេសជាតិនោះឡើយ ។ ខ្ញុំពិតជាមានការសោកស្តាយចំពោះការលះបង់សឹងតែមួយជីវិតរបស់ខ្ញុំក្នុងបក្សកុម្មុយនីស្តកម្ពុជា ។ មនសិការរបស់ខ្ញុំ សេចក្តីសង្ឃឹមរបស់ខ្ញុំ និងសេចក្តីប្រាថ្នារបស់ខ្ញុំត្រូវបានបំផ្លាញដោយពួកក្បត់ចលនា ដែលធ្វើឲ្យប្រជាជនរបស់ខ្ញុំត្រូវបានកាប់សម្លាប់ និងរងទុក្ខវេទនា ។ ប្រទេសជាតិរបស់ខ្ញុំត្រូវបែកបាក់ ។ ទោះបីជាសោកវិនាសកម្មនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យបង្កឡើងដោយជនក្បត់ចលនាក៏ដោយ ក៏ក្នុងនាមខ្ញុំជាអនុលេខាបក្សកុម្មុយនីស្តកម្ពុជាដែលមានភារកិច្ចឃោសនាអប់រំពីគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ខ្ញុំសូមសុំទោសជាសាធារណៈចំពោះជនរងគ្រោះ ក្រុមគ្រួសារជនរងគ្រោះ និងប្រជាជនកម្ពុជាទាំងមូល ហើយនៅតែប្រកាន់ជំហរទទួលខុសត្រូវលើផ្នែកសីលធម៌ចំពោះការគ្រប់គ្រងមិនបានដិតដល់និងមិនបានគ្រប់ជ្រុងជ្រោយរបស់បក្សកុម្មុយនីស្តកម្ពុជា ។ ខ្ញុំសូមគោរពវិញ្ញាណក្ខន្ធដល់ប្រជាជនដែលរងគ្រោះដោយគ្រប់យថាហេតុទាំងអស់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។

សរុបឲ្យខ្លីតាមពន្លឺនៃសវនាការនេះ ខ្ញុំឃើញច្បាស់ថា យុត្តិធម៌អាចប្រែប្រួលទៅតាមកាលៈទេសៈ តែសច្ចៈធម៌ជាអមតៈធម៌មិនប្រែប្រួលជាដាច់ខាត ។ ពពកខ្មៅមិនអាចបិទបាំងពន្លឺព្រះអាទិត្យបានទេ ។ យ៉ាងណាមិញ មនុស្សអគតិ អសីលធម៌ មិនអាចភូតភរកុហក និងបិទបាំងភ្នែកប្រជាជន និងមហាជនមិនឲ្យមើលឃើញនូវសច្ចធម៌នៃការតស៊ូដ៏អង់អាចក្លាហានរបស់ប្រជាជនកម្ពុជា និងការឧបត្ថម្ភគាំទ្ររបស់ប្រជាជនស្នេហាសន្តិភាព និងយុត្តិធម៌លើសកលលោកបានឡើយ ។ អាស្រ័យហេតុនេះ ដោយផ្អែកលើភស្តុតាង និងហេតុផលទាំងអស់ខាងលើនេះ និងជាពិសេសសេចក្តីសន្និដ្ឋានរបស់មេធាវីខ្ញុំ ខ្ញុំសំណូមពរតុលាការមេត្តាសម្រេចឲ្យខ្ញុំបានរួចផុតពីបទចោទប្រកាន់ក្នុងសំណុំរឿងនេះ និងសូមដោះលែងខ្ញុំឲ្យមានសេរីភាពវិញទៅតាមផ្លូវច្បាប់ ។ សូមអរគុណ! សូមអរគុណលោកប្រធាន! ។

## អានទស្សនាវដ្តីតាមគេហទំព័រ

ទស្សនាវដ្តីស្វែងរកការពិតទាំងអស់ត្រូវបានផ្សព្វផ្សាយតាមគេហទំព័ររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ អ្នកអានអាចរកបានតាមៈ http://d.dccam.org/Projects/Magazines/Magazine_Searching.htm . ព័ត៌មានបន្ថែម សូមទាក់ទង ញាណ សុជាតិ ទូរស័ព្ទលេខ ០១៦ ៨៧៦ ៦៩២ ឬ ០២៣ ២១១ ៨៧៥ ។

# នារីស្រែអំបិលរកយុត្តិធម៌ជូនឪពុក

អង្គុយនៅក្បែរច្រកចូលសាលសវនាការកាត់ទោសមេដឹកនាំខ្មែរក្រហមជាមួយនឹងសម្លៀកបំពាក់សំពត់ឆ្នូត និងអាវពណ៌ផ្កាឈូក ចាន់ រីម បានរៀបរាប់ថា គាត់មានអាយុ៥៣ឆ្នាំ មកពីស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ។ រីម មានឪពុកឈ្មោះ ចាន់ (ស្លាប់) និងម្តាយឈ្មោះ ជុំ សៀម ។ រីម មានបងប្អូនប្រាំពីរនាក់ (ប្រុសពីរនាក់ និង ស្រីប្រាំនាក់) ។



ចាន់ រីម

កាលពីតូច រីម មិនបានរៀនច្រើនទេ ដោយសារក្រុមគ្រួសាររបស់គាត់មានជីវភាពខ្វះខាត ។ នៅពេលរដ្ឋប្រហារទម្លាក់សម្តេច នរោត្តម សីហនុ ឆ្នាំ១៩៧០ ក្រុមគ្រួសាររបស់ រីម មានការភ័យខ្លាចយ៉ាងខ្លាំង ដោយសារមានការទម្លាក់គ្រាប់បែកបេ-៥២ ជាច្រើនគ្រាប់មកលើភូមិរបស់គាត់ ។ ការទម្លាក់គ្រាប់បែកនៅពេលនោះបានបណ្តាលឲ្យអ្នកមួយចំនួនបានស្លាប់បាត់បង់ជីវិត ហើយខ្លះទៀតបានរងរបួសដោយសារបំណែកគ្រាប់បែក ។ លើសពីនេះទៅទៀត គោ ក្របី និងផ្ទះសម្បែងត្រូវបានរងការបំផ្លាញស្ទើរតែទាំងអស់ ។

ក្រោយមក ដោយសារការភ័យខ្លាច ឪពុកម្តាយរបស់ រីម បានចាកចេញពីភូមិកំណើតទៅរស់នៅកន្លែងផ្សេងដើម្បីគេចចេញពីការទម្លាក់គ្រាប់ ។ នៅពេលមានការទម្លាក់គ្រាប់បែកម្តងៗ រីម និងគ្រួសារតែងតែរត់ទៅពួននៅក្នុងលេណដ្ឋានដែលស្ថិតនៅក្បែរភ្នំស្រួច ជាមួយនឹងអ្នកភូមិផ្សេងទៀត ។

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ នៅពេលដែលយោធាខ្មែរក្រហមចូលរំដោះទីក្រុងភ្នំពេញទាំងស្រុង ខ្មែរក្រហមបានជម្លៀស រីម ទៅកាន់ភូមិផ្សេងនៅក្នុងខេត្តកំពង់ស្ពឺ ។ រីម នៅចាំបានថា ឪពុកម្តាយរបស់គាត់បានចាកចេញពីផ្ទះដោយមានតែសម្លៀកបំពាក់មួយកំប្លេនៅជាប់នឹងខ្លួននិងអង្ករពីរកំប៉ុងប៉ុណ្ណោះ ។ ក្រោយមក ខ្មែរក្រហមបានបង្ខំឲ្យឪពុកគាត់ធ្វើការជាទម្ងន់រហូតបណ្តាលឲ្យឪពុកគាត់ស្លាប់ ដោយសារបាក់កម្លាំង និងខ្វះអាហារបរិភោគ ។ រីម បាននិយាយថា «ទើបតែជួបមុខឪពុកម្តងប៉ុណ្ណោះ ឪពុកក៏ស្លាប់ចោល» ចំណែកម្តាយ រីម ត្រូវបានអង្គការបែងចែកឲ្យទៅរស់នៅកន្លែងផ្សេងពីគ្នា ។

នៅឆ្នាំ១៩៧៦ រីម ត្រូវបានខ្មែរក្រហមចាត់តាំងឲ្យមកខេត្តកំពត ដោយធ្វើដំណើរតាមផ្លូវជាតិលេខ៣ ។ នៅទីនោះអង្គការបញ្ជូន រីម ទៅនៅសហករណ៍មួយ ដោយប្រើគាត់ឲ្យធ្វើបាយឲ្យកងចល័ត ។ ក្រោយមក អង្គការបានចាត់តាំងគាត់ឲ្យទៅធ្វើស្រែអំបិល ។

រីម នៅចាំបានថា នៅរដូវប្រាំង អង្គការបានចាត់តាំងមនុស្សនៅក្នុងក្រុមរបស់គាត់ដប់នាក់ឲ្យធ្វើអំបិលដែលពេលនោះស្ថិតនៅក្រោមការគ្រប់គ្រងរបស់ឈ្មោះ សារឿន ។ មុនដំបូង រីម ត្រូវរែកដី និងជីកប្រឡាយដើម្បីបង្ហូរទឹកចូលស្រែ ហើយប្រសិនបើគាត់ធ្វើមិនទាន់តាមពេលវេលាកំណត់ អង្គការនឹងហៅទៅកសាង ។

ក្រោយពីជីកប្រឡាយរួច ទើបកងភ្ជួរ ចាប់ផ្តើមភ្ជួររាស់ស្រែអំបិលហើយ រីម និងនារីនៅក្នុងកងដែលស្លៀកពាក់ខោអាវខ្មៅ បាននាំគ្នាបុកដីបង្ហាប់ដោយចលនាដើរថយក្រោយ ព្រមទាំងនាំគ្នាច្រៀងចម្រៀង «កងឈ្លបនារីស្រែអំបិល សែនក្លាហាន» ។ នៅពេលរៀបចំស្រែអំបិលរួច រីម និងកងនារីត្រូវបូមទឹកសមុទ្រពីព្រែកកំពត (ម្តុំកំពង់នង់) បញ្ចូលទៅក្នុងស្រែ ដែលមានបែងចែកជាលេខរៀងស្រែ គឺស្រែលេខ១ ស្រែលេខ២ ស្រែលេខ៣ និងស្រែបន្តបន្ទាប់ទៀត ។ បន្ទាប់ពីបញ្ចូលទឹកទៅក្នុងស្រែបាន

មួយរយៈ ទើប រីម និងកងនារីចាប់ផ្តើមអូសរនាស់កៀរយកអំបិល ។ ចំណែកគុណភាពអំបិល អង្គការបានធ្វើពិសោធន៍ទឹកអំបិលដោយកំណត់លេខ២១អំបិលល្អរហូតដល់លេខ៣១ អំបិលមិនសូវល្អ ។ រីម និងសមាជិកក្រុមបានច្រកអំបិលដែលប្រមូលបាន រួចលើកដាក់ឡានដឹកយកទៅដាក់នៅក្នុងឃ្លាំងដែលមានទីតាំងនៅក្បាលរមាស ។

ក្រៅពីការងារ រីម ធ្វើបង្គីជូនអង្គការឲ្យបានចំនួន៥០បង្គីក្នុងមួយក្រុម ប្រសិនបើធ្វើមិនបាន អង្គការនឹងកាត់របបអាហារ ។ លើសពីនោះ រីម ត្រូវបានអង្គការបង្ខំឲ្យជីកប្រឡាយដែលមានប្រវែងប្រមាណជា៥០០បន្ថែមទៀត ។ រសៀលថ្ងៃមួយ អង្គការបានហៅសមាជិកក្នុងកងរបស់ រីម ម្នាក់ឈ្មោះ ផាន់ណា ទៅកសាងក្រោយមកបាត់ឈ្មោះនេះរហូត ។

នៅឆ្នាំ១៩៧៩ នៅពេលដែលកងទ័ពវៀតណាមវាយចូលមក អង្គការបំពាក់កាំភ្លើងឲ្យ រីម និងកងនារីស្រែអំបិលទាំងអស់ ។ ប៉ុន្តែដោយសារភ័យខ្លាចកងទ័ពវៀតណាមសម្លាប់ រីម និងកងនារីទាំងអស់បាននាំគ្នារត់សំដៅទៅខេត្តពោធិ៍សាត់ ។ ពេល រីម រត់មកដល់ស្រុកភ្នំក្រវ៉ាញ គាត់ក៏ទម្លាក់អាវុធចោល ។

រីម រស់នៅស្រុកភ្នំក្រវ៉ាញបានមួយរយៈ ក៏វិលត្រឡប់មករស់នៅស្រុកកំណើតរបស់គាត់វិញ ដោយគាត់បានចំណាយពេលធ្វើដំណើរអស់រយៈពេលជាងមួយខែ ។ រីម បានបន្តថា ពេលមកដល់ស្រុកកំណើត សមាជិកក្រុមគ្រួសាររបស់គាត់បានស្លាប់បាត់បង់ជីវិតអស់ជាច្រើន ។ គាត់បានខិតខំចាប់ផ្តើមកសាងជីវិតសាជាថ្មី និងរស់នៅជាមួយម្តាយរហូតមកដល់សព្វថ្ងៃនេះ ។

ចុងក្រោយ រីម សំណូមពរឲ្យតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមដែលគាត់បានមកចូលរួមស្តាប់នៅពេលនេះ កាត់ទោសជនដៃដល់ឲ្យបានឆាប់រហ័ស ដើម្បីស្វែងរកយុត្តិធម៌ជូនឪពុករបស់គាត់ ក៏ដូចជាប្រជាជនប្រមាណជិតពីរលាននាក់ដែលបានបាត់បង់ជីវិត ។ ម្យ៉ាងទៀត ដើម្បីឲ្យក្មេងជំនាន់ក្រោយជៀសវាងការយកគំរូអាក្រក់តាមមេដឹកនាំខ្មែរក្រហមទាំងនោះ ។

**សិុន សុធីតា**



នារីស្រែអំបិលកំពុងធ្វើការនៅការដ្ឋានស្រែអំបិល ក្នុងខេត្តកំពត ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

# ការិយាល័យព័ត៌មានសាធារណៈ

«ការិយាល័យព័ត៌មានសាធារណៈ» របស់មជ្ឈមណ្ឌលឯកសារកម្ពុជា បានបើកបម្រើជូននិស្សិត អ្នកស្រាវជ្រាវ បុគ្គលិករាជការ និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍ចង់យល់ដឹងអំពីប្រវត្តិសាស្ត្ររបបកម្ពុជាប្រជាធិបតេយ្យ និងព្រឹត្តិការណ៍វិវឌ្ឍន៍របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហម ។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំ និងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត ។ ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រាំប្រភេទ ។ ប្រភេទឯកសារទីមួយគឺឯកសារជាក្រដាសសន្លឹកដែលមានចំនួនជិតមួយលានទំព័រ ។ ប្រភេទឯកសារទីពីរគឺជាបទសម្ភាសន៍ដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសន៍ជាមួយជនរងគ្រោះនិងអតីតកម្មាភិបាលខ្មែរក្រហម ។ ប្រភេទឯកសារទីបីគឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម ។ ប្រភេទឯកសារទីបួនគឺជាឯកសារទាក់ទងទៅនឹងការធ្វើផែនទីរណ្តៅសាកសព និងទីតាំងសម្លាប់របស់ខ្មែរក្រហម និងឯកសារប្រភេទទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហមនិងសម័យក្រោយមកទៀត ។

តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចអាននឹងស្រាវជ្រាវឯកសារទាំងនេះបាន ។ ឯកសារខ្លះទៀតរួមមាន ៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាព កំណត់ហេតុរបស់បក្ស ទូរលេខឆ្លើយឆ្លង ព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្លិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍ ។

ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ៦៦ មហាវិថីព្រះសីហនុ ខាងកើតវិមានឯករាជ្យ ។ ការិយាល័យរបស់យើងបើកជូនសាធារណជនពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង៨ដល់ម៉ោង១២ និងពេលរសៀលពីម៉ោង២ដល់ម៉ោង៥ ។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង ជា ផល្លា តាមរយៈ ទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ឬអ៊ីម៉ែល *truthphalla.c@dccam.org* ។





















# សិទ្ធិទទួលបានអាហារគ្រប់គ្រាន់

## សំឡេងយុត្តិធម៌ ៖ អំពីប្រល័យពូជសាសន៍ និងការអត់ឃ្លាននៅក្នុងរបបខ្មែរក្រហម

*កម្មវិធីវិទ្យុសហគមន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា (វគ្គទី៩)*

ការផ្សាយនៅក្នុងវគ្គមុនៗ យើងបានលើកឡើងអំពីបញ្ហាផ្សេងៗដែលពាក់ព័ន្ធនឹងការអត់ឃ្លាន គ្រោះទុរ្ភិក្ស និងច្បាប់ឧក្រិដ្ឋកម្មអន្តរជាតិ ។ ដោយឡែក នៅក្នុងការផ្សាយវគ្គទី៩នេះ យើងខ្ញុំផ្តោតទៅលើច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងបញ្ហាពាក់ព័ន្ធផ្សេងៗ ។

### តើច្បាប់សិទ្ធិមនុស្សអន្តរជាតិគឺជាអ្វី?

ពាក្យថា “សិទ្ធិមនុស្ស” ត្រូវបានយកមកប្រើប្រាស់នៅក្នុងស្ថានភាព និងបរិបទផ្សេងៗគ្នា ។ ជាឧទាហរណ៍ នៅពេលដែលមានរឿងរ៉ាវអ្វីមួយកើតឡើងទៅលើបុគ្គលណាម្នាក់ ដែលទង្វើនោះត្រូវបានមើលឃើញថាមិនមានភាពត្រឹមត្រូវ ឬយុត្តិធម៌ ជនដែលទទួលរង ឬអង្គភាពផ្សេងៗដែលពាក់ព័ន្ធ ដូចជាអង្គការក្រៅរដ្ឋាភិបាលជាដើម តែងតែនិយាយថា ទង្វើនោះគឺជាការរំលោភសិទ្ធិមនុស្ស ។ ភាពអយុត្តិធម៌បែបនេះនៅតែបន្តកើតឡើងជាប្រចាំនៅទូទាំងសកលលោក ក៏ដូចជានៅប្រទេសកម្ពុជាដូច្នេះដែរ ។ នៅក្នុងកាលៈទេសៈមួយចំនួន ពាក្យ “សិទ្ធិមនុស្ស” ត្រូវបានអ្នកនយោបាយប្រើដើម្បីបញ្ឈរវាក់ពីបុព្វហេតុជាក់លាក់ណាមួយ ។



អ្នកភូមិកំពុងសម្រាកក្រោមម្លប់ឈើក្រោយពីធ្វើការងាររួចក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

ការប្រើប្រាស់ពាក្យ "សិទ្ធិមនុស្ស" ដោយឡែកៗពីគ្នា បានឆ្លុះបញ្ចាំងឲ្យឃើញពីភាពស្មុគស្មាញនៃច្បាប់ដែលត្រូវបានយកមកប្រើប្រាស់ដើម្បីបង្កើតច្បាប់សិទ្ធិមនុស្សអន្តរជាតិ ។ បើតាមផ្លូវច្បាប់ ច្បាប់សិទ្ធិមនុស្ស គឺសំដៅដល់ "សេចក្តីថ្លៃថ្នូរ" មូលដ្ឋានរបស់បុគ្គលគ្រប់រូបដែលបុគ្គលម្នាក់ៗទទួលបានការការពារប្រកបដោយសីលធម៌ និងសមធម៌ ។ ប៉ុន្តែ ការកំណត់លក្ខណៈសម្បត្តិឲ្យបានត្រឹមត្រូវ និងជាក់លាក់ ត្រូវតែធ្វើឡើងដើម្បីការពារសេចក្តីថ្លៃថ្នូររបស់មនុស្ស ដែលនេះគឺជាដំណើរការមួយមានការលំបាក និងលក្ខណៈស្មុគស្មាញ ។ សម្រាប់បុគ្គលមួយចំនួន ការទទួលបានការអប់រំដែលធ្វើឲ្យជីវិតប្រកបទៅដោយសេចក្តីថ្លៃថ្នូរ គឺជាបញ្ហាចម្បង ។ ចំណែកឯបុគ្គលដទៃទៀត យល់ឃើញថា បញ្ហាចម្បងគឺការទទួលបានប្រាក់បៀវត្សរ៍ខ្ពស់សម្រាប់ផ្គត់ផ្គង់ខ្លួនឯង និងក្រុមគ្រួសារ ។ នៅក្នុងករណីខ្លះទៀត មនុស្សមួយចំនួនយល់ឃើញថា បញ្ហាចម្បង គឺការទទួលបានអាហារមិនគ្រប់គ្រាន់ ដែលអាចធ្វើឲ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូរ និងសុខុមាលភាពរបស់បុគ្គលទាំងនោះ ។

ដោយផ្អែកទៅលើវិសាលភាពនៃច្បាប់សិទ្ធិមនុស្សអន្តរជាតិ ច្បាប់នេះត្រូវបានបង្កើតឡើងពីប្រភព និងប្រភេទច្បាប់ផ្សេងៗគ្នាជាច្រើន ។ ច្បាប់ស្តីពីសិទ្ធិមនុស្ស អាចមានចែងនៅក្នុងសន្ធិសញ្ញាអន្តរជាតិ និងឯកសារមួយចំនួន រួមមាន សេចក្តីថ្លែងការណ៍ជាសកលស្តីអំពីសិទ្ធិមនុស្សជាដើម ។ ច្បាប់ស្តីអំពីសិទ្ធិមនុស្សក៏មានចែងនៅក្នុងរបាយការណ៍ និងសេចក្តីថ្លែងការណ៍ផ្សេងៗ ដែលបានបោះពុម្ពផ្សាយដោយអង្គការសហប្រជាជាតិនិងអង្គការផ្សេងៗ ។

## សិទ្ធិក្នុងការទទួលបានអាហារគ្រប់គ្រាន់

សិទ្ធិក្នុងការទទួលបានអាហារគ្រប់គ្រាន់ ត្រូវបានលើកឡើងនៅក្នុងសេចក្តីថ្លែងការណ៍ជាសកលស្តីអំពីសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ នៅឆ្នាំ១៩៤៨ ដែលបានចែងថា "មនុស្សគ្រប់រូបមានសិទ្ធិទទួលបានលក្ខខណ្ឌរស់នៅសមរម្យ ទាំងសុខុមាលភាព និងសុវត្ថិភាពផ្ទាល់ខ្លួន និងក្រុមគ្រួសារ ដោយក្នុងនោះរាប់បញ្ចូលទាំងចំណីអាហារ" ។ សិទ្ធិនេះមានចែងយ៉ាងលម្អិតនៅក្នុងអនុសញ្ញា អន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ដែលជាឯកសារស្តីពីសិទ្ធិមនុស្សដ៏សំខាន់មួយរបស់អង្គការសហប្រជាជាតិ ។

សិទ្ធិក្នុងការទទួលបានអាហារគ្រប់គ្រាន់ក៏ត្រូវបានគាំទ្រដោយច្បាប់ផ្សេងៗ រួមមាន អនុសញ្ញាអន្តរជាតិស្តីអំពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ អនុសញ្ញាស្តីអំពីការលុបបំបាត់ការរើសអើងស្ត្រី និងអនុសញ្ញាស្តីអំពីសិទ្ធិកុមារជាដើម ។ មិនតែប៉ុណ្ណោះ សិទ្ធិក្នុងការទទួលបានអាហារគ្រប់គ្រាន់ក៏ត្រូវបានចាត់ចូលជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ ។ សិទ្ធិក្នុងការទទួលបានអាហារគ្រប់គ្រាន់ មានចែងនៅក្នុងមាត្រា១១ នៃអនុសញ្ញាអន្តរជាតិស្តីអំពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដែលតម្រូវឲ្យប្រទេសដែលជាហត្ថលេខីទាំងអស់ "ទទួលស្គាល់សិទ្ធិរបស់បុគ្គលគ្រប់រូបក្នុងការទទួលបានលក្ខខណ្ឌរស់នៅសមរម្យផ្ទាល់ខ្លួន និងក្រុមគ្រួសារ ដោយរាប់បញ្ចូលទាំងការទទួលបានអាហារគ្រប់គ្រាន់ និងសិទ្ធិជាមូលដ្ឋានក្នុងការរួចផុតពីភាពអត់ឃ្លាន ។" ជាសរុប សិទ្ធិក្នុងការទទួលបានអាហារគ្រប់គ្រាន់ ត្រូវបានបង្កើតឡើងចេញពីសិទ្ធិពីរផ្សេងគ្នា ទីមួយ ៈ សិទ្ធិជាទូទៅក្នុងការទទួលបានអាហារគ្រប់គ្រាន់ ក្រោមទម្រង់ជាសន្តិសុខស្បៀងអាហារជាមូលដ្ឋាន និងទីពីរ ៈ សិទ្ធិជាមូលដ្ឋានក្នុងការរួចផុតពីភាពអត់ឃ្លាន ។

យោងតាមគោលការណ៍ច្បាប់ស្តីអំពីសិទ្ធិមនុស្ស ប្រទេសហត្ថលេខីនៃអនុសញ្ញាអន្តរជាតិស្តីអំពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ មានកាតព្វកិច្ចក្នុងការធានាឲ្យបានថា សិទ្ធិជាមូលដ្ឋានក្នុងការរួចផុតពីភាពអត់ឃ្លានត្រូវបានអនុវត្ត ។ មិនតែប៉ុណ្ណោះ ប្រទេសហត្ថលេខីទាំងអស់ ត្រូវតែបំពេញសកម្មភាពផ្សេងៗមួយចំនួនក្នុងការសម្រេចឲ្យបាននូវគោលដៅរយៈពេលវែងនៃការធានាសន្តិសុខស្បៀងអាហារសម្រាប់ប្រជាជននៅក្នុងប្រទេសរបស់ខ្លួនដើម្បីចូលរួមបញ្ឈប់បញ្ហាកង្វះស្បៀងអាហារ នៅទូទាំងសកលលោក ។ សិទ្ធិជាមូលដ្ឋាននៃការរួចផុតពីភាពអត់ឃ្លាន មិនអាចត្រូវបានមិនអើពើនោះទេ បើទោះបីជាស្ថិតក្នុងស្ថានភាពគ្រោះធម្មជាតិឬគ្រោះមហន្តរាយផ្សេងៗក៏ដោយ ។

ការធានាទៅលើសិទ្ធិជាមូលដ្ឋានក្នុងការរួចផុតពីភាពអត់ឃ្លាន មិនមែនត្រឹមតែជាការផ្តល់អាហារក្នុងកម្រិតអប្បបរិមាដើម្បីរស់តែប៉ុណ្ណោះទេ ។ អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិទៅលើសិទ្ធិទទួលបានអាហារគ្រប់គ្រាន់បានលើកឡើងអំពីចំណុចសំខាន់ក្នុងការធានានូវសិទ្ធិក្នុងការទទួលបានអាហារគ្រប់គ្រាន់ថា ៈ

*បុគ្គលគ្រប់រូបត្រូវបានធានាថា មានសិទ្ធិក្នុងការចិញ្ចឹមខ្លួនឯង មិនត្រឹមតែអាចទទួលបានអាហារនោះទេ ថែមទាំងមានសិទ្ធិក្នុងការស្វែងរកផលិតប្រដាប់ផលិតស្បៀងអាហារដោយខ្លួនឯង និងមានសិទ្ធិក្នុងការទិញចំណីអាហារដែលខ្លួនត្រូវការ ។*

គណៈកម្មាធិការនៃអង្គការសហប្រជាជាតិស្តីអំពីសិទ្ធិ សង្គម និងវប្បធម៌ បានលើកឡើងថា "សិទ្ធិក្នុងការទទួលបានអាហារគ្រប់គ្រាន់សំដៅទៅលើ" ចំណីអាហារត្រូវតែអាចរកបានទាំងបរិមាណ និងគុណភាព ដើម្បីធានាថាបុគ្គលគ្រប់រូបទទួលបានចំណីអាហារគ្រប់គ្រាន់ ។ មិនតែប៉ុណ្ណោះ ចំណីអាហារទាំងនោះត្រូវតែឆ្លើយតបទៅនឹងអ្វីដែលជាវប្បធម៌របស់ប្រជាពលរដ្ឋ ហើយត្រូវធានាថាការទទួលបានចំណីអាហារគ្រប់គ្រាន់មិនបានប៉ះពាល់សិទ្ធិដទៃទៀត ។

ដូច្នេះ តម្រូវការចាំបាច់ក្នុងការអនុវត្តសិទ្ធិទទួលបានអាហារគ្រប់គ្រាន់ តម្រូវឲ្យរដ្ឋាភិបាលនៃប្រទេសហត្ថលេខី ចាត់វិធានការជាបន្ទាន់ដើម្បីធានាថា ប្រជាពលរដ្ឋរបស់ខ្លួនអាចទទួលបានអាហារគ្រប់គ្រាន់សម្រាប់ផ្គត់ផ្គង់តម្រូវការរបស់ខ្លួនព្រមទាំងចាត់វិធានការជាបន្តបន្ទាប់ដើម្បីពង្រឹងការផ្គត់ផ្គង់ចំណីអាហារទាំងក្នុងស្រុក និងក្រៅស្រុក ។

បើយោងតាមអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រសិនបើប្រទេសណាមួយ "មិនអាចធានាថា ប្រជាជនខ្លួនអាចទទួលបានការផ្គត់ផ្គង់ចំណីអាហារក្នុងកម្រិតអប្បបរិមាដើម្បីជៀសផុតពីការអត់ឃ្លាន" ប្រទេសនោះនឹងត្រូវបានចាត់ទុកថាបានរំលោភទៅលើសិទ្ធិក្នុងការទទួលបានអាហារគ្រប់គ្រាន់ ។ ជាងនេះទៅទៀត ប្រទេសមួយអាចប្រកែកចំពោះការចោទប្រកាន់នេះបាន ប្រសិនបើ "ប្រទេសនោះជួបប្រទះនូវបញ្ហាកង្វះធនធានដែលមិនអាចផ្គត់ផ្គង់ចំណីអាហារបានគ្រប់គ្រាន់ដោយខ្លួនឯង ។ មិនតែប៉ុណ្ណោះ រដ្ឋាភិបាលនៃប្រទេសនោះបានប្រើប្រាស់រាល់ធនធាន ដែលខ្លួនមានដើម្បីបំពេញកាតព្វកិច្ចរបស់ខ្លួនដោយអស់ពីសមត្ថភាព ។"

## ***សិទ្ធិទទួលបានអាហារគ្រប់គ្រាន់នៅប្រទេសកម្ពុជា និង***



កុមារពីរនាក់កំពុងចាប់ត្រីក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

## កេរដំណែលរបស់ខ្មែរក្រហម

ខណៈដែលសិទ្ធិក្នុងការទទួលបានអាហារគ្រប់គ្រាន់ត្រូវបានយកមកពិនិត្យពិច័យក្នុងបរិបទនៃការអត់ឃ្លានដែលបានកើតមានឡើងក្នុងរបបខ្មែរក្រហម វាបានបញ្ជាក់យ៉ាងច្បាស់ថា រដ្ឋាភិបាលខ្មែរក្រហម ពិតជាបរាជ័យក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួនដើម្បីធានាថា ប្រជាពលរដ្ឋរបស់ខ្លួនរួចផុតពីការអត់ឃ្លាន ។ បើទោះបីជាប្រទេសកម្ពុជាមិនមែនជាប្រទេសហត្ថលេខីនៃអនុសញ្ញាអន្តរជាតិស្តីអំពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ រហូតដល់ឆ្នាំ១៩៩២ក៏ដោយ សិទ្ធិជាមូលដ្ឋានរបស់ប្រជាពលរដ្ឋក្នុងការទទួលបានលក្ខខណ្ឌរស់នៅសមរម្យត្រូវបានចែងយ៉ាងច្បាស់នៅក្នុងសេចក្តីថ្លែងការណ៍ជាសាកលស្តីអំពីសិទ្ធិមនុស្សដែលបានបង្ហាញថា ខ្មែរក្រហមពិតជាបានរំលោភសេចក្តីថ្លែងការណ៍នេះចន្លោះពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ក្នុងរូបភាពផ្សេងៗជាច្រើន ដោយរួមមានការបង្កើតឲ្យមានលក្ខខណ្ឌនៃការអត់ឃ្លានរីករាលដាលនៅទូទាំងប្រទេស ។

ប្រសិនបើខ្មែរក្រហមបានចុះហត្ថលេខាលើអនុសញ្ញាអន្តរជាតិស្តីអំពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដែលបានព្រាងឡើងនៅក្នុងឆ្នាំ១៩៦៦ នោះខ្មែរក្រហមនឹងរំលោភបំពានទៅលើកាតព្វកិច្ចរបស់ខ្លួនទៅលើអនុសញ្ញានោះ ។ ជាបឋមខ្មែរក្រហមមិនអាចយកលេសមិនផ្តល់អាហារគ្រប់គ្រាន់ឬក្នុងចំនួនអប្បបរមាទៅឲ្យប្រជាពលរដ្ឋនោះទេ បើទោះបីជាស្ថានភាពកង្វះស្បៀងអាហារបានបន្សល់មកពីរបប លន់ នល់ ក៏ដោយ ។ មិនតែប៉ុណ្ណោះ ខ្មែរក្រហមក៏មិនអាចយកកត្តាគ្រោះធម្មជាតិមកធ្វើជាលេសថា ខ្លួនមិនអាចបំពេញតម្រូវការចំណីអាហាររបស់ប្រជាពលរដ្ឋបាននោះទេ ។ ជាងនេះទៅទៀត ប្រសិនបើប្រទេសមួយចង់ធ្វើការបដិសេធថា ខ្លួនមិនមានធនធានគ្រប់គ្រាន់ដើម្បីផ្គត់ផ្គង់ចំណីអាហារគ្រប់គ្រាន់ដល់ប្រជាជន លុះត្រាតែរដ្ឋាភិបាលនៃប្រទេសនោះអាចបង្ហាញឲ្យឃើញថា ខ្លួនពិតជាបានខិតខំប្រឹងប្រែងប្រើប្រាស់ធនធានទាំងអស់ដែលមានដើម្បីចិញ្ចឹមប្រជាពលរដ្ឋរបស់ខ្លួន ។ ហេតុដូច្នេះ ខ្មែរក្រហមមិនអាចបដិសេធបានទេថា ខ្លួនបានចំណាយធនធានដែលមានទាំងអស់ដើម្បីផ្គត់ផ្គង់ដល់ប្រជាពលរដ្ឋ ។ ផ្ទុយទៅវិញ ខ្មែរក្រហមបានធ្វើការនាំចេញផលិតផលស្បៀងយ៉ាងច្រើន នៅក្នុងអំឡុងពេលនៃការកាន់អំណាចរបស់ខ្លួន បើទោះបីជាស្ថានភាពនៃការអត់ឃ្លានបានរាលដាលនៅគ្រប់ទីកន្លែងក៏ដោយ ។

ជាសរុប ខ្មែរក្រហមពិតជាបរាជ័យក្នុងការបំពេញកាតព្វកិច្ចក្នុងការគោរពសិទ្ធិមនុស្ស ដោយរាប់បញ្ចូលទាំងកាតព្វកិច្ចក្នុងការធានាឲ្យបានថា ប្រជាជនខ្លួនអាចទទួលបានអាហារគ្រប់គ្រាន់ ដើម្បីរស់រានមានជីវិត ។ ដូចដែលបានលើកឡើងនៅក្នុងវគ្គមុនៗនៃកម្មវិធីវិទ្យុនេះរួចមកហើយ ការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើសិទ្ធិទទួលបានអាហារគ្រប់គ្រាន់របស់ប្រជាជនស៊ីវិលនៅក្នុងរបបខ្មែរក្រហម ហាក់ដូចជាបានរួចផុតពីការចោទប្រកាន់ទាក់ទងទៅនឹងការរំលោភសិទ្ធិមនុស្ស ហើយបែរជាត្រូវចោទពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិទៅវិញ ។

ជាចុងបញ្ចប់ យើងសង្កេតឃើញថាកេរដំណែលដែលបានបន្សល់ទុកពីការអត់ឃ្លានដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហម នៅតែបន្តកើតមាននៅក្នុងសង្គមកម្ពុជានាពេលបច្ចុប្បន្ន ។ ប្រជាជនកម្ពុជាភាគច្រើននៅតែត្រូវប្រឈមនឹងបញ្ហាកង្វះអាហារ សម្រាប់ផ្គត់ផ្គង់ខ្លួនឯង និងក្រុមគ្រួសារ ។ ជាលទ្ធផល សិទ្ធិក្នុងការទទួលបានអាហារគ្រប់គ្រាន់នៅតែមិនទាន់សម្រេចបាននៅក្នុងប្រទេសកម្ពុជានៅឡើយ បើទោះបីជាប្រទេសកម្ពុជាបានចុះហត្ថលេខាលើអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ជាង ២០ឆ្នាំរួចមកហើយ ពោលគឺនៅក្នុងឆ្នាំ១៩៩២ ។ ថ្វីបើប្រទេសកម្ពុជាបានខិតខំប្រឹងប្រែងដោះស្រាយបញ្ហាមួយចំនួនទាក់ទងទៅនឹងសិទ្ធិក្នុងការទទួលបានអាហារគ្រប់គ្រាន់ក៏ដោយ ក៏នៅមានប្រជាជនជាច្រើននាក់នៅតែប្រឈមនឹងបញ្ហាកង្វះស្បៀងអាហារដដែល ។ កង្វះខាតនៃសន្តិសុខក្នុងការធានាថា ប្រជាជនទាំងអស់ទទួលបានអាហារគ្រប់គ្រាន់ដែលជាសិទ្ធិជាមូលដ្ឋានសម្រាប់រស់រានមានជីវិតបានបង្ហាញថា កេរដំណែលពីរបបខ្មែរក្រហមពិតជាបានប៉ះពាល់ដល់សង្គមកម្ពុជាបច្ចុប្បន្ន ។ ទោះបីជាយ៉ាងនេះក្តី តាមរយៈកិច្ចខិតខំប្រឹងប្រែងក្នុងការធ្វើកំណែទម្រង់ និងការស្វែងរកយុត្តិធម៌ ចំពោះរបួសពីអតីតកាល ប្រទេសកម្ពុជានឹងអាចទទួលបានស្ថេរភាព និងសន្តិសុខស្បៀងអាហារនាពេលអនាគតមិនខាន ។

**រ៉ែនឌុល ដីហ្វាល់កូ, ម៉ែន ពិចិត្រ និង លន់ ដាលីន**

# ការរៀបចំសំណង ការប្រឈមរបស់ ដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០២

អត្ថបទនេះនឹងស្វែងយល់អំពីលទ្ធភាពរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាក្នុងការផ្តល់សំណងនោះក្នុងសំណុំរឿង០០២ ។ អត្ថបទនេះ នឹងផ្តោតលើ “ប្រសិទ្ធភាព” ឬតម្រូវការចំពោះគម្រោងសំណង ដែលជំរុញឲ្យតុលាការចេញសេចក្តីសម្រេចដែលមានលក្ខណៈបង្គាប់បញ្ជា ។ ក្នុងសំណុំរឿង០០១ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានលើកឡើងអំពីប្រសិទ្ធភាពម្តងហើយម្តងទៀត ឧទាហរណ៍ កង្វះថវិកាសម្រាប់គម្រោងផ្តល់សំណងជនរងគ្រោះ ឬគម្រោងនោះ ទាមទារឲ្យមានការត្រួតពិនិត្យនិងការគ្រប់គ្រងមានលក្ខណៈស្មុគស្មាញ ប្រសិនបើសេចក្តីសម្រេចលើកហេតុផល មិនព្រមចេញសេចក្តីសម្រេចផ្តល់សំណង ។ ប្រសិទ្ធភាពគឺជាក្តីបារម្ភដ៏ចម្បងរបស់សាលាក្តីខ្មែរក្រហម ពីព្រោះសាលាក្តីនេះ ខ្វះអំណាចគ្រប់គ្រាន់ក្នុងការជំរុញឲ្យមានការផ្តល់សំណង ។

ការកែប្រែវិធានផ្ទៃក្នុងរបស់សាលាក្តីខ្មែរក្រហម និងសេចក្តីសម្រេចក្នុងការផ្តល់សំណងរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិក្នុងសំណុំរឿង ថូម៉ាស លូបានហ្កាឌីឡូ ឆ្នាំ២០១២ គួរតែផ្តល់ឲ្យសាលាក្តីខ្មែរក្រហមនូវទស្សនៈក្នុងការផ្តល់សំណងនៅក្នុងសំណុំរឿង០០២ ។ ទោះបីជាតុលាការប្រហែលជាមានជម្រើសច្រើនយ៉ាងណាក៏ដោយ ការផ្តល់សំណងពិតប្រាកដនឹងផ្អែកលើការបង្កើតឲ្យមានយន្តការទទួលខុសត្រូវ ដើម្បីពិនិត្យមើលដំណើរការផ្តល់សំណង ។ យន្តការនោះគួរតែធានាឲ្យមានការអនុលោមតាមច្បាប់របស់តុលាការនៅក្នុងការអនុវត្តគម្រោងផ្តល់សំណងនោះ បន្ទាប់ពីសំណុំរឿងត្រូវបានបញ្ចប់ ឬបន្ទាប់ពីអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបញ្ឈប់ដំណើរការរបស់ខ្លួន ។

ក្នុងអាណត្តិរបស់ខ្លួន តុលាការពិសេសដែលធានាឲ្យមានការត្រួតពិនិត្យគ្រប់ជ្រុងជ្រោយលើការផ្តល់សំណងក្នុងអំឡុងពេលអនុវត្តការផ្តល់សំណងនោះអាចជាការប្រឈមមួយក្នុងចំណោមការប្រឈមដ៏សំខាន់ដែលអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាជួបប្រទះ ។

អត្ថបទនេះចែកចេញជាបីផ្នែក ។ ផ្នែកទីមួយនៃអត្ថបទនេះនឹងវិភាគលើក្របខ័ណ្ឌច្បាប់សម្រាប់ការផ្តល់សំណងក្នុងសំណុំរឿង០០២ ។ អត្ថបទនេះនឹងផ្តោតលើលក្ខណៈនៃការផ្តល់សំណងដែលអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានបង្កើតឡើងដែលជាផលប៉ះពាល់នៃការសម្រេចចិត្តជាចម្បងរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិមកលើសំណងសម្រាប់គំហើញក្នុងសំណុំរឿង០០២របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងការកែប្រែវិធានផ្ទៃក្នុងស្តីពីការផ្តល់សំណង ជាពិសេសការបន្តអាណត្តិរបស់អង្គភាពគាំពារជនរងគ្រោះនិងសមត្ថភាពក្នុងការផ្តល់សំណង ។ ការកែប្រែវិធានផ្ទៃក្នុងបានធ្វើឲ្យលក្ខខណ្ឌក្នុងការផ្តល់សំណងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមានលក្ខណៈស្របទៅនឹងលក្ខខណ្ឌផ្តល់សំណងរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ។

ផ្នែកទីពីរនៃអត្ថបទនេះនឹងពិពណ៌នាអំពីតម្រូវការ “ប្រសិទ្ធភាព” របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ អត្ថបទនេះនឹងប្រៀបធៀបនីតិវិធីរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាក្នុងសំណុំរឿង០០១ ទៅនឹងនីតិវិធីរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិលើសំណុំរឿង ថូម៉ាស់ លូបានហ្កាឌីឡូ ។ អត្ថបទនេះនឹងបង្ហាញថា ការតម្រូវឲ្យមានយន្តការ “ប្រសិទ្ធភាព” របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា គឺជាការបំបែកចេញពីការអនុវត្តក្របខណ្ឌអន្តរជាតិ ហើយតម្រូវការផ្នែកហិរញ្ញវត្ថុមិនគួរជាកត្តាកំណត់នៅពេលដែលខ្លួនសម្រេចចិត្តថាតើត្រូវចេញសេចក្តីសម្រេចផ្តល់សំណងសមូហភាពឬយ៉ាងណា ។ អត្ថបទនេះនឹងទាញយកយុត្តិសាស្ត្ររបស់តុលាការសិទ្ធិមនុស្សក្នុងតំបន់និងការអនុវត្តរបស់គណៈកម្មាធិការស្វែងរកការពិតនិងការផ្សះផ្សា ។

ផ្នែកទីបីនៃអត្ថបទនេះនឹងធ្វើសេចក្តីសន្និដ្ឋានដោយស្វែងយល់អំពីយន្តការគ្រប់គ្រងដែលអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការ

កម្ពុជាអាចបង្កើតឡើងដើម្បីត្រួតពិនិត្យមើលការផ្តល់សំណងក្នុងសំណុំរឿង០០២ ។ តើហេតុអ្វីបានជាការបង្កើតយន្តការនោះនឹងផ្តល់ឲ្យអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាកាន់តែមានឱកាសដើម្បីបញ្ចប់អាណត្តិក្នុងការផ្តល់សំណងរបស់ខ្លួន?

## ១) ប្រវត្តិ

ការផ្តល់សំណងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាក្នុងសំណុំរឿង០០១ត្រូវបានកម្រិត ។ ក្នុងការបដិសេធទៅនឹងសំណើ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានផ្តោតលើភាពខ្វះខាតរបស់ចុងចោទ ដែលជាកង្វះខាតភាពជាក់លាក់នៃសំណើផ្តល់សំណង និងការកំណត់ផ្នែកយុត្តិសាស្ត្ររបស់តុលាការ ។ តាមរយៈសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល តុលាការមានការព្រួយបារម្ភចំពោះការទាមទារឲ្យមានការផ្តល់សំណងប្រកបដោយប្រសិទ្ធភាព ។ នៅពេលដែលអង្គជំនុំជម្រះតុលាការកំពូលជឿថាសំណើឲ្យមានការផ្តល់សំណងមានលក្ខណៈច្បាស់លាស់ មានលក្ខណៈជាសមូហភាព និងជាសំណងផ្លូវចិត្ត ។ អង្គជំនុំជម្រះនឹងទទួលស្គាល់សំណើនោះថាជា »ទម្រង់នៃការផ្តល់សំណងដ៏ត្រឹមត្រូវ» ហើយខ្លួននឹងជំរុញឲ្យម្ចាស់ជំនួយជាតិ និង អន្តរជាតិជួយសម្របសម្រួលដល់ការផ្តល់សំណងទាំងនោះ ។

តុលាការបានចេញសេចក្តីសម្រេចលើការផ្តល់សំណងត្រឹមតែការប្រមូលនិងការផ្សព្វផ្សាយសេចក្តីថ្លែងការណ៍សុំទោស និងការទទួលស្គាល់ការទទួលខុសត្រូវរបស់ កាំង ហ្គេចអ៊ាវ ហៅ ឌុច នៅលើគេហទំព័ររបស់អង្គជំនុំជម្រះវិសាមញ្ញ រួមមានឈ្មោះរបស់ជនរងគ្រោះ និងសាច់ញាតិ ដែលបានបាត់បង់ជីវិតរបស់ជនរងគ្រោះទាំងនោះ ។

ខែវិច្ឆិកា ឆ្នាំ២០១១ អង្គជំនុំជម្រះសាលាដំបូងបានចាប់ផ្តើមសំណុំរឿង០០២ ។ សំណុំរឿង០០២មានលក្ខណៈស្មុគស្មាញជាងសំណុំរឿង០០១ ដោយមានក្រុមមេធាវីការពារក្តីជាច្រើននាក់ ហើយឧក្រិដ្ឋកម្មជាច្រើនត្រូវបានប្រព្រឹត្តឡើងនៅពាសពេញប្រទេស ។ សំណុំរឿង០០២ត្រូវបានបំបែកទៅជាការជំនុំជម្រះជាច្រើនដំណាក់កាល ។ សំណុំរឿង០០២/០១ នៅតែស្ថិតនៅក្នុងដំណាក់កាលដំបូង ហើយមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណីនឹងប្រឈមមុខនឹងឧបសគ្គផ្លូវច្បាប់មួយចំនួនមុនពេលដែលដាក់សំណើស្នើសុំសំណងចុងក្រោយ នៅពេលបញ្ចប់ការជំនុំជម្រះក្តីរបស់អង្គជំនុំជម្រះសាលាដំបូង ។ ជនរងគ្រោះ៤០០០នាក់បានដាក់ពាក្យចូលរួមក្នុងនាមជាដើមបណ្តឹងរដ្ឋប្បវេណី ។ អំឡុងពេលសវនាការបឋមក្នុងសំណុំរឿង០០១ ដើមបណ្តឹងរដ្ឋប្បវេណីបានបង្ហាញអំពីគម្រោងនៃការស្នើសុំសំណងរបស់ខ្លួន ។ សវនាការបានធ្វើឡើងមុនពេលដែលដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានអនុញ្ញាតឲ្យទទួលបានព័ត៌មានអំពីសំណុំរឿង ហើយមុនពេលចេញសេចក្តីសម្រេចខទ្ទរណ៍ក្នុងសំណុំរឿង០០១ ដែលមានព័ត៌មានសំខាន់ដល់ការផ្តល់សំណង ។ ដោយផ្អែកលើការប្រឹក្សាយោបល់ជាមួយនឹងដើមបណ្តឹងរដ្ឋប្បវេណី សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណីបានបង្ហាញអំពីការផ្តល់សំណងបួនបែប រួមមាន ក) ការរំឭក និងការបងចាំ ខ) ការស្តារនីតិសម្បទា និងការគាំពារសុខភាព គ) ការចងក្រងឯកសារ និងការអប់រំ ឃ) គម្រោងផ្សេងៗទៀត ។ សវនាការលើកទី២ ខែតុលា ឆ្នាំ២០១១ សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីបានពិពណ៌នាអំពីដំណើរការនៃការផ្តល់សំណងហើយបាននិយាយអំពីចេតនារបស់ខ្លួនដើម្បីបង្កើតថវិកាដែលអាចរៀបចំវិភាគទានដើម្បីជួយផ្តល់សំណងផ្នែកហិរញ្ញវត្ថុ បន្ទាប់ពីអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានបញ្ឈប់ការងាររបស់ខ្លួន ។

## ២) ក្របខ័ណ្ឌគតិយុត្តិ និងនីតិវិធី

ក) អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានកំណត់រចនាសម្ព័ន្ធក្នុងការផ្តល់សំណងដោយឡែក ដែលឆកចេញពីការអនុវត្តរបស់កម្ពុជា និងអន្តរជាតិ

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា គឺជាផ្នែកមួយនៃប្រព័ន្ធតុលាការកម្ពុជា ។ ក្នុងនាមជាតុលាការកូនកាត់ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានប្រើប្រាស់ច្បាប់ព្រហ្មទណ្ឌកម្ពុជា និងនីតិវិធីព្រហ្មទណ្ឌដែលកើតចេញមកពីទំនៀមទម្លាប់ច្បាប់រដ្ឋប្បវេណីរបស់ប្រទេសបារាំង ថែមទាំងបញ្ចូលច្បាប់ប្រទេសកម្ពុជាឲ្យស្របជាមួយនឹងច្បាប់អន្តរជាតិ ។ ដោយអនុលោមតាមច្បាប់របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា តុលាការមានយុត្តាធិការលើមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ និងអ្នកដែលទទួលខុសត្រូវបំផុតលើឧក្រិដ្ឋកម្ម និងការរំលោភបំពានធ្ងន់ធ្ងរលើក្រមព្រហ្មទណ្ឌរបស់ប្រទេសកម្ពុជា ទម្លាប់ច្បាប់

មនុស្សធម៌អន្តរជាតិ និងអនុសញ្ញាអន្តរជាតិដែលទទួលស្គាល់ដោយប្រទេសកម្ពុជា ដែលប្រព្រឹត្តឡើងនៅចន្លោះពីថ្ងៃទី១៧ ខែមេសា ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ ។

ទន្ទឹមពេលដែលមាត្រា៣៩ នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានអនុញ្ញាតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបង្គាប់បញ្ជារឹបអូសទ្រព្យសម្បត្តិខុសច្បាប់របស់ជនជាប់ចោទ ។ ទ្រព្យសម្បត្តិនេះត្រូវប្រគល់ត្រឡប់ជូនទៅរដ្ឋវិញ ។ សិទ្ធិក្នុងការទាមទារសំណងមិនត្រូវបានបញ្ចូលក្នុងច្បាប់របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាឡើយ ប៉ុន្តែត្រូវបានដាក់បញ្ចូលក្នុងកម្រងដំបូងនៃវិធានផ្ទៃក្នុងដែលបានអនុម័តនៅខែឧសភាឆ្នាំ២០០៧ ។ វិធាននេះត្រូវបានធ្វើវិសោធនកម្មជាច្រើនដង ហើយវិសោធនកម្មសំខាន់ជាច្រើនត្រូវបានធ្វើឡើងចំពោះក្របខ័ណ្ឌផ្តល់សំណង មុនសំណុំរឿង០០២ ។

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមានឱកាសក្នុងការបង្កើត និងការកែប្រែការផ្តល់សំណង ប៉ុន្តែវិធានផ្ទៃក្នុងបានកំណត់ការផ្តល់សំណងត្រឹមតែជាសំណងសមូហភាព និងផ្លូវចិត្ត ។ នៅក្នុងសំណុំរឿង០០១ អង្គជំនុំជម្រះតុលាការកំពូលបានផ្តល់និយមន័យសម្រាប់សំណងជាសមូហភាព និងផ្លូវចិត្ត ។ សំណងសមូហភាព មិនបានដាក់បញ្ចូលសំណងផ្ទាល់ខ្លួនឡើយ ហើយគាំទ្រមធ្យោបាយ ដែលផ្តល់ប្រយោជន៍ដល់ជនរងគ្រោះជាច្រើនតាមដែលអាចធ្វើទៅបាន ហើយបានដាក់បញ្ចូលជនរងគ្រោះដែលមិនបានចូលរួមក្នុងសំណុំរឿងក្នុងនាមជាដើមបណ្តឹងរដ្ឋប្បវេណី ។

សំណងផ្លូវចិត្តគឺជាសំណងដែលមានបំណងប៉ះប៉ូវការខូចខាតផ្លូវចិត្តជាជាងការខូចខាតផ្នែកសម្ភារ ។ ឧទាហរណ៍ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាលើកឡើងថា សំណើសុំឲ្យមានការផ្តល់សំណងសម្រាប់ការសាងសង់បូជនីយដ្ឋានមិនឆ្លើយតបដោយផ្ទាល់ទៅនឹងអត្ថន័យនៃសំណងសមូហភាព និងផ្លូវចិត្ត ។ ទាំងសំណងសមូហភាព ទាំងសំណងផ្លូវចិត្ត ទាមទារឲ្យមានការអនុវត្តផ្នែកថវិកា ហើយបង្ហាញអំពីអត្ថប្រយោជន៍របស់បុគ្គលចំពោះសមូហភាព ដរាបណាសំណងសម្រាប់ជនរងគ្រោះគឺជាសំណងសមូហភាព ។ ឧទាហរណ៍ អង្គជំនុំជម្រះតុលាការកំពូលបានកំណត់ថា សំណើឲ្យមានសំណងសម្រាប់ជំនួយផ្លូវចិត្ត និងផ្នែកវេជ្ជសាស្ត្រ ដែលបានលើកឡើងក្នុងសំណុំរឿង០០១ បានទទួលបរាជ័យក្រោមពាក្យថា "សំណងសមូហភាព និងផ្លូវចិត្ត" ។

ដោយអនុលោមតាមវិធាន២៣ស្ទួន៤ នៃវិធានផ្ទៃក្នុងដែលបានធ្វើវិសោធនកម្ម សំណងសមូហភាព និងសំណងផ្លូវចិត្តគឺជាវិធានការទាំងឡាយ ក) ដែលទទួលស្គាល់នូវការខូចខាតដែលដើមបណ្តឹងរដ្ឋប្បវេណីទទួលរងដោយសារការប្រព្រឹត្តនូវបទឧក្រិដ្ឋរបស់ជនជាប់ចោទដែលត្រូវបានផ្តន្ទាទោស ហើយខ) ផ្តល់ផលប្រយោជន៍ដល់ដើមបណ្តឹង រដ្ឋប្បវេណីដែលលើកឡើងការខូចខាតនេះ ។ និយមន័យនៃពាក្យសំណងសមូហភាពនិងផ្លូវចិត្តដែលចែងក្នុងវិធានផ្ទៃក្នុងដែលបានធ្វើវិសោធនកម្មត្រូវតែអនុវត្តដោយតុលាការក្នុងសំណុំរឿង០០២ ។

វិធានរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាលើការផ្តល់សំណងមានលក្ខណៈខុសគ្នាពីនីតិវិធីព្រហ្មទណ្ឌកម្ពុជា ។ ក្នុងច្បាប់ព្រហ្មទណ្ឌប្រទេសកម្ពុជា វិសាលភាពរបស់ដើមបណ្តឹងរដ្ឋប្បវេណីមានកម្រិតធំជាងវិសាលភាពរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ក្នុងសំណុំរឿងព្រហ្មទណ្ឌក្នុងតុលាការកម្ពុជាអាចផ្តល់មធ្យោបាយច្រើនជាងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា រួមមានសំណងខូចខាត ការប្រគល់ទ្រព្យសម្បត្តិ ឬការស្តារទ្រព្យសម្បត្តិដែលត្រូវបានបំផ្លាញ ។ ជាធម្មតា តុលាការព្រហ្មទណ្ឌបានបង្គាប់ឲ្យជនជាប់ចោទផ្តល់សំណងថវិកាដល់ជនរងគ្រោះ ។ ទោះបីជាយ៉ាងណាក៏ដោយ សំណងផ្លូវចិត្ត និងសំណងសមូហភាពរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមានបំណងបម្រើជានិមិត្តរូប ជាជាងមុខងារជាសំណងទំនៀមទម្លាប់ ។

ដើមបណ្តឹងរដ្ឋប្បវេណីអាចទាមទារសំណងពីក្រុមទទួលខុសត្រូវក្នុងប្រព័ន្ធតុលាការកម្ពុជា ទន្ទឹមពេលដែលជនរងគ្រោះគ្រាន់តែអាចប្រឆាំងទៅនឹងជនជាប់ចោទប៉ុណ្ណោះ នៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ដោយអនុលោមតាមច្បាប់កម្ពុជា ទង្វើរបស់ដើមបណ្តឹងរដ្ឋប្បវេណីអាចបន្ត ប្រសិនបើជនជាប់ចោទស្លាប់ដោយមានបុព្វការីជនរបស់ជនជាប់ចោទទទួលខុសត្រូវចំពោះសំណង ។ នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ទង្វើដើមបណ្តឹងរដ្ឋប្បវេណីអាចបញ្ចប់នៅពេលដែលជនជាប់ចោទ

ស្លាប់ ។ ចុងបញ្ចប់ ទន្ទឹមពេលដែលភាគីដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងតុលាការព្រហ្មទណ្ឌកម្ពុជាអាចធ្វើការទាមទារដោយឡែកនៅក្នុងតុលាការស៊ីវិល ភាគីដើមបណ្តឹងរដ្ឋប្បវេណីនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមិនអាចប្រើសកម្មភាពជាដើមបណ្តឹងរដ្ឋប្បវេណីដោយផ្អែកលើសវនាការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានៅក្នុងតុលាការស៊ីវិលកម្ពុជាឡើយ ។ ទោះបីជាយ៉ាងណាក៏ដោយសម្រាប់ទង្វើមួយចំនួនការដកចេញពីច្បាប់កម្ពុជាបានជួយជនរងគ្រោះ ដោយសារនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ទង្វើដើមបណ្តឹងរដ្ឋប្បវេណីមិនត្រូវបានកំណត់ដោយលក្ខន្តិកៈ នៅក្នុងក្រមរដ្ឋប្បវេណីនៅក្នុងប្រទេសកម្ពុជា ហើយដោយសារសិទ្ធិទទួលបានសំណងត្រូវបានសម្រេចដោយផ្អែកលើសមធម៌ ។

មាត្រា៣៣នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានចែងថា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាត្រូវតែប្រតិបត្តិស្របតាមវិធាននីតិវិធីដែលចូលជាធរមានដោយអនុលោមតាមច្បាប់ប្រទេសកម្ពុជា ។ ប៉ុន្តែបទដ្ឋានអន្តរជាតិអាចត្រូវបានមើលឃើញថាជាការចង្អុលបង្ហាញដល់កិច្ចការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាទាក់ទងទៅនឹងថាតើបទដ្ឋានទាំងនេះត្រូវបានដាក់បញ្ចូលក្នុងច្បាប់ក្នុងស្រុក ឬយ៉ាងណា ។ ដូច្នេះហើយ ការយល់ស្របផ្នែកអន្តរជាតិនិងយុត្តិសាស្ត្រស្តីពីសំណងអាចមានហើយគួរតែបន្តបង្ហាញដល់កិច្ចការងាររបស់តុលាការ ។

សិទ្ធិក្នុងការទទួលបានសំណងត្រូវបានបង្កើតឡើងនៅក្នុងឯកសារច្បាប់អន្តរជាតិជាច្រើន ។ ក្នុងសំណុំរឿង០០១ អង្គជំនុំជម្រះតុលាការកំពូលបានទទួលស្គាល់ថា ប្រភពអន្តរជាតិជាច្រើនទទួលស្គាល់សិទ្ធិរបស់ជនរងគ្រោះក្នុងការទទួលបានដំណោះស្រាយ ។ អង្គជំនុំជម្រះតុលាការកំពូលបានកត់សម្គាល់ថា សិទ្ធិក្នុងការទទួលបានដំណោះស្រាយ ត្រូវបានរកឃើញនៅក្នុងច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងច្បាប់ឧក្រិដ្ឋកម្មអន្តរជាតិ ។ តុលាការបានលើកឡើងអំពីមាត្រា៧៥នៃលក្ខន្តិកៈនៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិ និងមាត្រា២៥នៃលក្ខន្តិកៈនៃតុលាការពិសេសរបស់ប្រទេសលីបង់ ។ គោលការណ៍មូលដ្ឋានរបស់អង្គការសហប្រជាជាតិមានបំណងកំណត់នូវយន្តការសម្រាប់ការអនុវត្តកាតព្វកិច្ចរដ្ឋច្បាប់ដែលមានស្រាប់ជាជាងកំណត់នូវកាតព្វកិច្ចថ្មី ។ គោលការណ៍ជាមូលដ្ឋានរបស់អង្គការសហប្រជាជាតិផ្តល់ឲ្យជនរងគ្រោះនូវការទទួលបានយុត្តិធម៌ និងសំណងគ្រប់គ្រាន់មានប្រសិទ្ធភាពនិងឆាប់រហ័សចំពោះការទទួលរងការខូចខាត ហើយអាចទទួលបានព័ត៌មានពាក់ព័ន្ធទាក់ទងនឹងអំពើហិង្សានិងយន្តការផ្តល់សំណង ។ គោលការណ៍ជាមូលដ្ឋានរបស់អង្គការសហប្រជាជាតិបន្តកំណត់ និងគូសបញ្ជាក់ការផ្តល់សំណងប្រាំប្រភេទ រួមមានការប្រគល់ឲ្យមកវិញ ការប៉ះប៉ូវ ការស្តារនិតិសម្បទា ការពេញចិត្ត និងការធានាមិនឲ្យមានសាជាថ្មី។ តុលាការព្រហ្មទណ្ឌអន្តរជាតិបានពឹងផ្អែកយ៉ាងខ្លាំងលើគោលការណ៍ជាមូលដ្ឋានរបស់អង្គការសហប្រជាជាតិនៅពេលដែលខ្លួនបង្កើតគោលការណ៍ផ្ទាល់របស់ខ្លួនស្តីពីការផ្តល់សំណងនៅឡូបាហ្កា ។

អង្គជំនុំជម្រះតុលាការកំពូលបានធ្វើសេចក្តីសម្រេចផ្តល់សំណងដោយផ្អែកលើធនធានអន្តរជាតិ ដោយលើកឡើងពីសេចក្តីសម្រេចរបស់តុលាការយុត្តិធម៌អន្តរជាតិអចិន្ត្រៃយ៍ដល់សេចក្តីសម្រេចរបស់តុលាការសិទ្ធិមនុស្សក្នុងតំបន់ រួមមានតុលាការសិទ្ធិមនុស្សអន្តរអាមេរិក និងតុលាការសិទ្ធិមនុស្សអឺរ៉ុបនៅក្នុងសំណុំរឿងអន្តរជាតិ ។

ទោះបីជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះតុលាការកំពូលក្នុងសំណុំរឿង០០១ បានកត់សម្គាល់ឃើញថា ប្រភពជំនួយអន្តរជាតិត្រូវបានកំណត់ដោយសារវិធានផ្ទៃក្នុងបានរៀបរាប់អំពីវិធីសាស្ត្រក្នុងការផ្តល់សំណងដែលត្រូវបានដាក់បញ្ចូលក្នុងយន្តការនិងអាណត្តិដោយឡែករបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ឧទាហរណ៍ តុលាការមានការប្រុងប្រយ័ត្នក្នុងការបែងចែកអាណត្តិក្នុងការផ្តល់សំណងរបស់ខ្លួនទៅនឹងអាណត្តិរបស់តុលាការសិទ្ធិមនុស្សអន្តរអាមេរិក និងអង្គភាពសិទ្ធិមនុស្សក្នុងតំបន់ផ្សេងដោយកត់សំគាល់ថា អង្គភាពទាំងនោះអាចបម្រើជាមុខងារជាអាជ្ញាធរក្នុងការបញ្ចុះបញ្ចូលតែប៉ុណ្ណោះ ។ អង្គជំនុំជម្រះតុលាការកំពូលបានដំណើរការដោយប្រុងប្រយ័ត្នដោយសម្អាងលើតុលាការអន្តរជាតិដែលមិនមានយុត្តិសាស្ត្រលើឧក្រិដ្ឋកម្ម ដោយសារតុលាការទាំងនេះផ្តោតលើការរំលោភលើកាតព្វកិច្ចរបស់រដ្ឋជាជាងបុគ្គលក្នុងការគាំទ្រសិទ្ធិមនុស្ស ។ ដូច្នេះហើយ តុលាការសិទ្ធិមនុស្ស

ក្នុងតំបន់មានគោលនយោបាយ និងក្របខណ្ឌច្បាប់ផ្នែកបច្ចេកទេសខុសពីអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ តុលាការបានដាស់តឿនការបែងចែកតម្រូវការដូចគ្នាសម្រាប់ការទាមទារសំណងផ្នែករដ្ឋបាល ។

*១) សេចក្តីសម្រេចចម្បងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាស្តីពីការផ្តល់សំណង គួរតែជាអំណាចជំរុញដល់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាលើការសម្រេចចិត្តក្នុងការផ្តល់សំណងលើកក្រោយ ជាពិសេសដោយសារសំណុំរឿងឡូបាហ្គា មានលក្ខណៈស្រប ជាពិសេសទៅនឹងសំណុំរឿង០០២របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានាពេលបច្ចុប្បន្ន ។*

សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលបានធ្វើឡើងមុនសេចក្តីសម្រេចដំបូងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាស្តីពីការផ្តល់សំណង ។ អង្គជំនុំជម្រះតុលាការព្រហ្មទណ្ឌអន្តរជាតិបានចេញសេចក្តីសម្រេចចោទប្រកាន់ដំបូងរបស់ខ្លួនក្នុងសំណុំរឿង ថូម៉ាស ឌីឡូបានហ្គា ដោយរកឃើញថាឡូបានហ្គា ជាប់បទល្មើសឧក្រិដ្ឋកម្មសង្គ្រាម នៅក្នុងសាធារណរដ្ឋប្រជាមានិតកុងហ្គោ ។ នៅក្នុងសេចក្តីសម្រេចទី២របស់ខ្លួននៅក្នុងសំណុំរឿងនោះ អង្គជំនុំជម្រះសាលាដំបូងបានកាត់ទោសឲ្យឡូបានហ្គា ជាប់ពន្ធនាគារ១៤ឆ្នាំ ។ សេចក្តីសម្រេចលើកទី៣របស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ក្នុងសំណុំរឿង ឡូបានហ្គា ដែលបានចេញសេចក្តីសម្រេចនៅខែសីហា ឆ្នាំ២០១២ គឺជាសេចក្តីសម្រេចដ៏សំខាន់ដំបូងរបស់តុលាការលើការផ្តល់សំណង ។

សេចក្តីសម្រេចលើការផ្តល់សំណងរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិក្នុងសំណុំរឿង ឡូបានហ្គា មានលក្ខណៈស្រដៀងគ្នាយ៉ាងសំខាន់ទៅនឹងសំណុំរឿង០០២របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ក្នុងនាមជាតុលាការព្រហ្មទណ្ឌអន្តរជាតិ តុលាការព្រហ្មទណ្ឌអន្តរជាតិដូចគ្នាទៅនឹងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមិនមានយុត្តាធិការលើរដ្ឋ ហើយមិនអាចចេញដីកាបង្គាប់ឲ្យរដ្ឋផ្តល់សំណងឡើយ ។ ដូចគ្នាទៅនឹងយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា លក្ខន្តិកៈទីក្រុងរ៉ូមរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ មានឥទ្ធិពលលើការផ្តល់សំណង ហើយកត់សម្គាល់ថា ការផ្តល់សំណង រួមមានការប្រគល់ឲ្យវិញការប៉ះប៉ូវ និងការស្តារនិតិសម្បទា អាចត្រូវបានធ្វើឡើងប្រឆាំងទៅនឹងជនជាប់ចោទ ហើយតាមរយៈមូលនិធិសំណងជនរងគ្រោះ ។

ឡូបានហ្គា ដូចគ្នាទៅនឹងចុងចោទនៅក្នុងសំណុំរឿង០០២ដែរ គឺជាមនុស្សមិនសូវមានទ្រព្យធនទេ ។ ខុសគ្នាពីអង្គភាពគាំពារជនរងគ្រោះរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មូលនិធិសំណងជនរងគ្រោះគឺជាយន្តការណ៍មួយសម្រាប់ការផ្តល់សំណងផ្នែកខាងក្រៅ ហើយមូលនិធិសំណងជនរងគ្រោះមានលក្ខណៈដូចគ្នាទៅនឹងអង្គភាពគាំពារជនរងគ្រោះ ត្រង់ថាមិនមានថវិកាគ្រប់គ្រាន់ ។ ទន្ទឹមពេលដែលអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានឹងរំលាយចោលបន្ទាប់បញ្ចប់កិច្ចដំណើរនីតិវិធីតុលាការព្រហ្មទណ្ឌអន្តរជាតិមានអាណត្តិជាអចិន្ត្រៃយ៍ ។ សំណុំរឿងឡូបានហ្គា មិនបានផ្តល់អំណាច ដែលគួរប្រតិបត្តិសម្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាឡើយ ។ ប៉ុន្តែសំណុំរឿងរបស់ ឡូបានហ្គា គួរតែផ្តល់ការចង្អុលបង្ហាញរបស់អន្តរជាតិដ៏សំខាន់សម្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាទាក់ទងទៅនឹងសំណងក្នុងសំណុំរឿង០០២ ។

សេចក្តីសម្រេចរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិក្នុងសំណុំរឿង ឡូបានហ្គា មិនបានចេញនូវការបង្គាប់ឲ្យមានការផ្តល់សំណងនោះឡើយ ។ លក្ខន្តិកៈទីក្រុងរ៉ូមមិនមែនការលម្អិតច្រើនស្តីពីថាតើសំណងត្រូវធ្វើឡើង អនុវត្ត និងត្រួតពិនិត្យដោយរបៀបណា ។ ផ្ទុយទៅវិញ អង្គជំនុំជម្រះក្នុងតុលាការព្រហ្មទណ្ឌអន្តរជាតិដែលបានប្រើប្រាស់អំណាចរបស់ខ្លួនដោយអនុលោមតាមមាត្រា៧៥(១) បានគូសបញ្ជាក់អំពីគោលការណ៍ និងនីតិវិធីក្នុងការផ្តល់សំណងជនរងគ្រោះ ក្រោមលក្ខន្តិកៈទីក្រុងរ៉ូម ដោយផ្តល់នូវការចង្អុលបង្ហាញក្រៅពីលក្ខន្តិកៈទីក្រុងរ៉ូមចំពោះថាតើតុលាការនឹងចេញសេចក្តីសម្រេចលើការផ្តល់សំណងដោយរបៀបណា ។ ដោយយល់ដឹងអំពីលក្ខណៈនៃសំណុំរឿងអង្គជំនុំជម្រះសាលាដំបូងបានធ្វើសេចក្តីសម្រេច២ភាគ៣ដែលមានឯកសារ៩៤ទំព័រដើមផ្តោតលើការផ្តល់សំណងសម្រាប់ការពិព័ណ៌នាលើសំណើរបស់ក្រុមការពារក្តីព្រះរាជអាជ្ញា មេធាវីជនរងគ្រោះ អង្គភាពអង្គការសហប្រជាជាតិ និងអង្គការក្រៅរដ្ឋាភិបាល ។ ដោយមានការសម្រេចជាឯកច្ឆ័ន្ទ អង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា សំណងគួរតែត្រូវបាន

ធ្វើឡើងក្នុងទ្រង់ទ្រាយធំ ហើយខ្លួនក៏រកឃើញថាសំណងក្នុងទ្រង់ទ្រាយធំបំផុតតាមដែលអាចធ្វើទៅរួចគួរតែត្រូវបានធ្វើសេចក្តីសម្រេច ។

ក្នុងសំណុំរឿងឡូបានហ្កា អង្គជំនុំជម្រះសាលាដំបូងបានទទួលស្គាល់សិទ្ធិក្នុងការទទួលបានសំណងថាជាសិទ្ធិមនុស្សជាមូលដ្ឋានដ៏សំខាន់ ។ អង្គជំនុំជម្រះសាលាដំបូងបានលើកឡើងសេចក្តីប្រកាសសិទ្ធិមនុស្សជាសាកល កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ សន្ធិសញ្ញាស្តីពីការលុបបំបាត់ចោលការរើសអើងពូជសាសន៍គ្រប់ទម្រង់ និងធម្មនុញ្ញ និងសន្ធិសញ្ញាសិទ្ធិមនុស្សក្នុងតំបន់ ។

តុលាការបានកត់សម្គាល់ថា ខ្លួនបានយកគោលការណ៍មូលដ្ឋានរបស់អង្គការសហប្រជាជាតិសេចក្តីប្រកាសគោលការមូលដ្ឋានក្នុងការស្វែងរកយុត្តិធម៌ឲ្យជនរងគ្រោះនៃអំពើឧក្រិដ្ឋកម្ម និងការរំលោភបំពានអំណាច និងផ្នែកជាប់ពាក់ព័ន្ធដទៃដែលជាលិខិតូបករណ៍អន្តរជាតិដែលមិនជាប់ជាកាតព្វកិច្ចស្តីពីការផ្តល់សំណងក្នុងការបង្កើតគោលការណ៍ផ្តល់សំណង ដែលបានកំណត់នៅក្នុងសំណុំរឿងឡូបានហ្កា ។ ក្រៅពីនេះ មិនដូចគ្នាទៅនឹងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា តុលាការព្រហ្មទណ្ឌអន្តរជាតិបានកត់សម្គាល់អំពីការរួមចំណែកយ៉ាងច្រើនរបស់ តុលាការសិទ្ធិមនុស្សក្នុងតំបន់ក្នុងការជួយឲ្យសិទ្ធិបុគ្គលទទួលបានការដោះស្រាយប្រកបដោយប្រសិទ្ធិភាពនិងការទទួលបានសំណង ។

ដូច្នេះហើយ ជាជាងការព្យាយាមញែកចេញពីអង្គភាពទាំងនេះ តុលាការព្រហ្មទណ្ឌអន្តរជាតិបានកត់សំគាល់ថា ខ្លួនបានពិចារណាលើយុត្តាធិការនៃតុលការសិទ្ធិមនុស្សក្នុងតំបន់ យន្តការនិងការអនុវត្តរបស់អន្តរជាតិលើការផ្តល់សំណង ។ តុលាការព្រហ្មទណ្ឌអន្តរជាតិបានផ្អែកលើយុត្តាធិការរបស់តុលាការសិទ្ធិមនុស្សក្នុងតំបន់ក្នុងការជួយកំណត់នូវវិសាលភាពនៃជនរងគ្រោះ ដោយផ្ទាល់ ឬដោយប្រយោលក្នុងការទទួលបានសំណង ព្រមទាំងបង្កើតនូវទម្រង់គ្រប់បែបយ៉ាងនៃការផ្តល់សំណង រួមមានសំណងសមូហភាពដែលមាននៅក្រោមបញ្ញត្តិក្នុងការផ្តល់សំណងក្នុងលក្ខន្តិកៈទីក្រុងរ៉ូម ។

តុលាការព្រហ្មទណ្ឌអន្តរជាតិត្រូវតែបង្កើតវិធាននីតិវិធីដ៏សំខាន់ថ្មីស្តីពីបញ្ហាផ្តល់សំណងមួយចំនួនចំពោះអ្វីដែលមិនធ្លាប់កើតឡើងពីមុន ជាពិសេសថាតើដំណើរការផ្តល់សំណងត្រូវត្រួតពិនិត្យនិងគ្រប់គ្រងដោយរបៀបណា ។ ទន្ទឹមពេលដែលដំណើរការនីតិវិធីផ្តល់សំណងនៅតែជាការទទួលខុសត្រូវរបស់តុលាការអង្គជំនុំជម្រះសាលាដំបូង បានផ្ទេរការទទួលត្រូវភាគច្រើនក្នុង ការបង្កើតនិងការអនុវត្តការផ្តល់សំណងដល់មូលនិធិសំណងជនរងគ្រោះ ។ ថ្វីបើមានការផ្ទេរការទទួលខុសត្រូវ ដំណើរការនោះនៅតែត្រូវអង្គជំនុំជម្រះត្រួតពិនិត្យ ។

***(នៅមានត)***

**គ្រីស្ទីន ប័រគ័រលី**

# ស្តាប់រឿងរ៉ាវប្រវត្តិសាស្ត្រតាមវិទ្យុ

មជ្ឈមណ្ឌលឯកសារកម្ពុជាមានកម្មវិធី “សំឡេងអំពើប្រល័យពូជសាសន៍ៈ យុត្តិធម៌ និងការអត់ឃ្លាន” ដែលចាក់ផ្សាយតាមស្ថានីយ៍វិទ្យុដូចខាងក្រោមរៀងរាល់ថ្ងៃអាទិត្យ ។

ប្រិយមិត្តដែលរស់នៅរាជធានីភ្នំពេញ និងនៅខេត្តអាចស្តាប់កម្មវិធីវិទ្យុសហគមន៍របស់យើងខ្ញុំតាមរយៈ ៖

◆ វិទ្យុជាតិកម្ពុជា FM 105.75 MHz រាជធានីភ្នំពេញ វេលាម៉ោង១ រសៀល និងម៉ោង៧និង៣០ នាទីល្ងាច ។

◆ វិទ្យុខេត្តកំពត FM 93.25 MHz វេលាម៉ោង៧ព្រឹក និងម៉ោង៧ល្ងាច ។

◆ វិទ្យុខេត្តព្រះវិហារ FM 99 MHz វេលាម៉ោង៧:៣០ ព្រឹក និងម៉ោង៨រសៀល ។

◆ វិទ្យុខេត្តបាត់ដំបង FM 103.25 MHz វេលាម៉ោង៨ព្រឹក និងម៉ោង៨រសៀល ។

សម្រាប់ព័ត៌មានលម្អិត សូមទាក់ទង ម៉ែន ពិចិត្រ តាមរយៈទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ឬ០៩២ ១៦៨ ៥៤៣ ។

# ស្វែងយល់អំពីគេហទំព័រឃ្លាំមើលការវិវឌ្ឍន៍របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា www.cambodiatribunal.org

គេហទំព័រឃ្លាំមើលការវិវឌ្ឍន៍របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា www.cambodiatribunal.org គឺជាប្រភពឈានមុខគេនៃសារព័ត៌មានដំណឹងវិវឌ្ឍន៍ថ្មីៗ ព្រមទាំងបទអត្ថាធិប្បាយរបស់អ្នកជំនាញជាច្រើនទៅលើដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាទាំងមូល ។ រយៈពេលកន្លងមកនេះព័ត៌មានយ៉ាងច្រើនត្រូវបានផ្សព្វផ្សាយ នៅលើគេហទំព័រនេះ ។ គេហទំព័រនេះបង្កលក្ខណៈងាយស្រួលបំផុតសម្រាប់សាធារណជនទាំងឡាយក្នុងការស្វែងយល់អំពីដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

សំណុំរឿងព្រហ្មទណ្ឌលេខ០០២ដែលទាក់ទិននឹងជនជាប់ចោទពីរនាក់ទៀតគឺ ខៀវ សំផន គណៈប្រធានរដ្ឋនៃរបបកម្ពុជាប្រជាធិបតេយ្យ និង នួន ជា អនុលេខាបក្សនិងជាប្រធានរដ្ឋសភានៃរបបកម្ពុជាប្រជាធិបតេយ្យបានចាប់ផ្តើមបើកសវនាការកាលពីខែវិច្ឆិកា ឆ្នាំ២០១១ និងបញ្ចប់សវនាការដេញដោលកាលពីខែតុលា ឆ្នាំ២០១៣ ។

ដើម្បីជួយកាត់បន្ថយចំនួនអ្នកខកខានមិនបានតាមដានដំណើរការដោយផ្ទាល់ឲ្យមកនៅត្រឹមកម្រិតតូចមួយ គេហទំព័រឃ្លាំមើលការវិវឌ្ឍន៍របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា www.cambodiatribunal.org ត្រូវបានបង្កើតដោយមានផ្នែកជាច្រើនទាក់ទិននឹងរបាយការណ៍ប្រចាំថ្ងៃអំពីសវនាការ វីដេអូសវនាការទាំងមូលនិងយោបល់ផ្សេងៗរបស់ជនរងគ្រោះទាក់ទងទៅនិងសវនាការ សារព័ត៌មានផ្សេងៗជុំវិញតុលាការ របាយការណ៍របស់តុលាការនិងអង្គការក្រៅរដ្ឋាភិបាល ដំណើរការនីតិវិធីផ្សេងៗនៃអង្គជំនុំជម្រះ ប្រវត្តិសាស្ត្រ ប្រវត្តិរបស់តុលាការនេះ និងបទអត្ថាធិប្បាយរបស់អ្នកជំនាញ ។

គេហទំព័រនេះនឹងជួយបង្កលក្ខណៈងាយស្រួលគ្រប់គ្រាន់សម្រាប់និស្សិតគ្រប់គ្រឹះស្ថានសិក្សាដែលមានបំណងចង់សិក្សាស្វែងយល់អំពីដំណើរនីតិវិធីអង្គជំនុំជម្រះវិសាមញ្ញដែលជាដំណើរការមានលក្ខណៈចម្រុះជាតិនិងអន្តរជាតិ ។ ឧទាហរណ៍ ការយកទ្រឹស្តីច្បាប់មួយដែលមានលក្ខណៈស្មុគស្មាញនិងចម្រូងចម្រាសមកអនុវត្តដោយអង្គជំនុំជម្រះវិសាមញ្ញគឺទ្រឹស្តី “សហកម្មឧក្រិដ្ឋកម្មរួម” ដែលភាសាអង់គ្លេសហៅថា “Join Criminal Enterprise” ដែលតាមរយៈទ្រឹស្តីនេះ ជនសង្ស័យអាចត្រូវបានដាក់ឲ្យទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌចំពោះបទក្រិដ្ឋទាំងឡាយដែលប្រព្រឹត្តឡើងទៅតាម “ផែនការឧក្រិដ្ឋរួម” ដែលភាសាអង់គ្លេសហៅថា “Common Criminal Plan” ។ ដូច្នេះ យើងអាចចូលទៅរកដំណើរការនីតិវិធីផ្សេងៗនៃអង្គជំនុំជម្រះឬបទអត្ថាធិប្បាយរបស់អ្នកជំនាញដើម្បីស្វែងយល់ថាតើចៅក្រមបានសម្រេចយ៉ាងដូចម្តេចចំពោះការដែលយកទ្រឹស្តីនេះមកអនុវត្តនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ តើមានភាគីផ្សេងទៀតដែរឬទេដែលមានយោបល់ទៅលើបញ្ហានេះ?

ប្រសិនបើមិនចង់ចំណាយពេលវេលាច្រើនដើម្បីមើលវីដេអូសវនាការដែលប្រព្រឹត្តឡើងពេញមួយថ្ងៃដែលអាចចំណាយពេលពី៦ទៅ៨ម៉ោងនោះ សាធារណជនអាចចូលទៅក្នុងផ្នែករបាយការណ៍ប្រចាំថ្ងៃអំពីសវនាការ ។ ក្នុងផ្នែកនេះ យើងមានអ្នកឃ្លាំមើលសវនាការម្នាក់ដែលត្រូវបានបញ្ជូនឲ្យទៅអង្គុយនៅក្នុងបន្ទប់សវនាការផ្ទាល់ បន្ទាប់មកអ្នកឃ្លាំមើលនេះសរសេររបាយការណ៍ខ្លីមួយដែលរៀបរាប់អំពីខ្លឹមសារសំខាន់ៗទាំងឡាយទាក់ទិននឹងសវនាការពេញមួយថ្ងៃនោះតែម្តង ។ របាយការណ៍បែបនេះមានជាភាសាខ្មែរដែរ ។

**វ៉ាន់ថាន់ ពៅដារ៉ា**

# អង្គជំនុំជម្រះសាលាដំបូងសម្រេចទទួលយកកំណត់ហេតុស្តាប់ចម្លើយ និងប្រតិចារិកចំនួន១៣៩៩ ជំនួសឱ្យការផ្តល់សក្ខីកម្មដោយផ្ទាល់មាត់

*កាលពីពាក់កណ្តាលខែសីហា អង្គជំនុំជម្រះសាលាដំបូង ចេញសេចក្តីសម្រេចចុងក្រោយស្តីអំពីភាពអាចទទួលបាននៃកំណត់ហេតុស្តាប់ចម្លើយ និងប្រតិចារិក ជំនួសឲ្យការផ្តល់សក្ខីកម្មដោយផ្ទាល់មាត់ ដែលជាបញ្ហាមួយមានវិវាទយូរមកហើយក្នុងសំណុំរឿង០០២/០១ នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ដោយបានកាត់បន្ថយជាច្រើននៃចំនួនឯកសារដែលធ្លាប់បានស្នើសុំឲ្យទទួលយកលើកមុន សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីស្នើសុំឲ្យទទួលយកកំណត់ហេតុស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណីចំនួន៥២០ឯកសារ ។ ចំណែកសហព្រះរាជអាជ្ញាស្នើសុំឲ្យទទួលយកកំណត់ហេតុស្តាប់ចម្លើយចំនួន១១០៩ ឯកសារ និងប្រតិចារិកក្នុងសំណុំរឿង០០១ ។ ក្រុមមេធាវីការពារក្តីជនជាប់ចោទ នួន ជា និង ខៀវ សំផន បានជំទាស់ចំពោះបញ្ជីឈ្មោះ វិសាលភាព និងភាពអាចជឿទុកចិត្តបាននៃឯកសារទាំងនោះ ។ ក្រុមមេធាវីការពារក្តីជនជាប់ចោទ នួន ជា ស្នើសុំស្តាប់សក្ខីកម្មដោយផ្ទាល់មាត់របស់សាក្សីជាងមួយរយនាក់ ដែលកំណត់ហេតុស្តាប់ចម្លើយរបស់សាក្សីទាំងនោះ គឺបញ្ជាក់អំពីការកំណត់មុខសញ្ញានៃមន្ត្រីសាធារណរដ្ឋខ្មែរ ដែលជាបញ្ហាមួយដ៏សំខាន់ទាក់ទងទៅនឹងលទ្ធភាពរបស់ជនជាប់ចោទក្នុងការទទួលខុសត្រូវចំពោះការសម្លាប់មនុស្សនៅទួលពោធិ៍ជ្រៃ ក្នុងអំឡុងពេលជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ។*

*យ៉ាងហោចណាស់មានកំណត់ហេតុស្តាប់ចម្លើយចំនួន២២០ ដោយរួមបញ្ចូលទាំងឯកសារភស្តុតាងពាក់ព័ន្ធត្រូវបានស្នើដាក់ដោយសហព្រះរាជអាជ្ញា ដើម្បីបង្ហាញអំពីអំពើ និងអាកប្បកិរិយារបស់ជនជាប់ចោទដូចដែលបានចោទប្រកាន់ ។ ក្រុមមេធាវីការពារក្តីជនជាប់ចោទ នួន ជា បានតវ៉ាថា យោងទៅលើបទដ្ឋានដែលអនុវត្តដោយតុលាការមិនអចិន្ត្រៃយ៍ផ្សេងៗទៀត (តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា និងអតីតប្រទេសយូហ្គោស្លាវី) អង្គជំនុំជម្រះត្រូវតែដកចេញនូវកំណត់ហេតុទាំងឡាយណាដែលត្រូវបានបញ្ចូលជាភស្តុតាង រួមទាំង "ភស្តុតាងដែលមានភាពជិតស្និទ្ធទៅនឹងជនជាប់ចោទ" ប្រសិនបើភស្តុតាងទាំងនោះជាប់ពាក់ព័ន្ធទៅនឹងគោលបំណងផ្សេងៗទៀត ។ យោងទៅលើក្រុមមេធាវីការពារក្តីជនជាប់ចោទ ខៀវ សំផន ឯកសារកំណត់ហេតុដែលត្រូវបានដកចេញត្រូវតែរួមបញ្ចូលទាំងឯកសារដែលពាក់ព័ន្ធទៅនឹង "បញ្ហាដែលកំពុងមានការចាប់អារម្មណ៍" របស់ភាគីទាំងអស់ដូចជា "រចនាសម្ព័ន្ធ អត្តិភាព និងគោលនយោបាយនៃសហឧក្រិដ្ឋកម្មរួម លក្ខខណ្ឌចាប់ផ្តើមនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការបម្លាស់ទីប្រជាជន" ។*

*នៅក្នុងសេចក្តីសម្រេចរបស់ខ្លួន អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ថាៈ*

> *"កំណត់ហេតុស្តាប់ចម្លើយជាលាយលក្ខណ៍អក្សរ ឬប្រតិចារិកដែលនឹងបង្ហាញអំពីអំពើ និងអាកប្បកិរិយារបស់ជនជាប់ចោទ ដែលបានចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ លើកលែងតែមានអញ្ញត្តកម្ម គួរចាត់ទុកថា "មិនអនុញ្ញាតឲ្យយកមកប្រើប្រាស់តាមផ្លូវច្បាប់ឡើយ" ...ហើយមិនអាចទទួលយកបានសម្រាប់គោលបំណងនេះទេ លើកលែងតែក្រុមមេធាវីការពារក្តី បានទទួលឱកាសសួរដេញដោលអ្នកដែលបានផ្តល់ចម្លើយទាំងនេះនៅក្នុងតុលាការ" ។*

*អញ្ញត្តកម្មនឹងត្រូវបានផ្តល់សម្រាប់កំណត់ហេតុទាំងឡាយណាដែលបានបំពេញជាបឋមនូវភាពពាក់ព័ន្ធ និងភាពអាចជឿទុកចិត្តបាន ដើម្បីជួយសម្រួលដល់បញ្ហាផ្សេងៗទៀត ជាពិសេសនៅ*

ពេលពុំមានឱកាសសួរតទល់ ដោយសារសាក្សីទទួលមរណភាព ឬមិនអាចរកឃើញ ឬភ័ស្តុតាងដែលស្នើសុំនោះទើបប្រមូលបាន ឬបានផ្តល់បរិបទនៃធាតុផ្សំអប្បបរមានៃឧក្រិដ្ឋកម្មអន្តរជាតិ ។

អង្គជំនុំជម្រះបានបញ្ជាក់ថា បទដ្ឋានស្តីអំពី «អំពើ និង អាកប្បកិរិយា» គឺ «អនុវត្តតែចំពោះកំណត់ហេតុ ឬប្រតិចារិកដែល "តាមលក្ខណៈនេះ" នឹងបង្ហាញអំពីអំពើនិងអាកប្បកិរិយាផ្ទាល់ខ្លួនរបស់ជនជាប់ចោទដែលត្រូវចោទប្រកាន់តែប៉ុណ្ណោះ» ហើយពុំពង្រីកទៅដល់បញ្ហា "ស្នូល" របស់សហព្រះរាជអាជ្ញា បញ្ហា "ដែលកំពុងមានការចាប់អារម្មណ៍" នៅក្នុងវិវាទ "អំពើនិងអាកប្បកិរិយានៃអង្គការ និងស្ថាប័នដែលជនជាប់ចោទធ្វើជាសមាជិកឬបុគ្គលទាំងឡាយដែលជនជាប់ចោទបានចូលរួមជាមួយ ឬបុគ្គលនៅក្រោមបង្គាប់ "ដែលនៅជិតស្និទ្ធបំផុត" បញ្ហាទាំងនោះនឹងត្រូវបានប្រើដើម្បីថ្លឹងថ្លែងអំពីភាពមិនអាចទទួលយកបាននៃឯកសារ ។ អង្គជំនុំជម្រះសាលាដំបូងបានច្រានចោលសំណើសុំឲ្យទទួលយកឯកសារកំណត់ហេតុចំនួន២៤ ដោយរកឃើញថាមានការជាប់ពាក់ព័ន្ធតែអំពើនិងអាកប្បកិរិយារបស់ជនជាប់ចោទដែលត្រូវបានចោទប្រកាន់ ហើយទទួលយកឯកសារចំនួន១១៤ ដោយរកឃើញថា "មានលក្ខណៈត្រួតគ្នាទៅវិញទៅមក និង/ឬភ័ស្តុតាងផ្សេងៗទៀត" និងបានបំពេញជាបឋមអំពីភាពពាក់ព័ន្ធទៅនឹងបញ្ហាផ្សេងៗទៀតនៅក្នុងសំណុំរឿង០០២/០១ ក្រៅពីអំពើ និងអាកប្បកិរិយារបស់ជនជាប់ចោទ ។

ចំពោះទំហំដែលឯកសារទាំងនោះបង្ហាញអំពីអំពើ និងអាកប្បកិរិយារបស់ជនជាប់ចោទអង្គជំនុំជម្រះ «នឹងមិនពឹងផ្អែកទៅលើព័ត៌មានទាំងនេះដើម្បីបង្ហាញអំពើឬអាកប្បកិរិយាផ្ទាល់ខ្លួនរបស់ជនជាប់ចោទដែលត្រូវបានចោទប្រកាន់នៅក្នុងសំណុំរឿង០០២/០១ឡើយ» ។ បន្ថែមលើនេះទៀតការជំទាស់ផ្សេងៗទៅនឹងភាពមិនអាចជឿទុកចិត្តបាននៃឯកសារទាំងនេះ ដោយហេតុថាស្ថិតនៅក្រោមកាលៈទេសៈ ដែលឯកសារទាំងនោះទទួលបាន ឬចំណាប់អារម្មណ៍របស់ស្ថាប័ន ដែលជាអ្នកធ្វើការសម្ភាសន៍ដូចជា សហព្រះរាជអាជ្ញា ឬមជ្ឈមណ្ឌលឯកសារកម្ពុជានឹងត្រូវបានពិចារណាក្នុងការវាយតម្លៃ ប្រសិនបើមាននៅក្នុងសាលក្រម ។

ទោះបីកំណត់ហេតុ និងប្រតិចារិកមួយចំនួនដែលស្នើដាក់ដោយសហព្រះរាជអាជ្ញាពាក់ព័ន្ធ តែអង្គហេតុស្ថិតនៅក្រៅវិសាលភាពដែលត្រូវជំនុំជម្រះនៅក្នុងសំណុំរឿង០០២/០១ក៏ដោយ ក៏សហព្រះរាជអាជ្ញានៅតែអះអាងថា ការទទួលយកឯកសារទាំងនោះគឺ «មានសារសំខាន់ដើម្បីបំពេញកាតព្វកិច្ចរបស់ខ្លួនក្នុងការបង្ហាញភ័ស្តុតាងទាក់ទងនឹងគោលនយោបាយសហឧក្រិដ្ឋកម្មរួម និង បរិបទដែលជាធាតុផ្សំនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ» ។ អង្គជំនុំជម្រះសាលាដំបូងបានធ្វើការកត់សម្គាល់ថា ជាទូទៅភ័ស្តុតាងទាំងនោះត្រូវតែពាក់ព័ន្ធនឹងគោលនយោបាយ និងទីតាំងឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់នៅក្នុងសំណុំរឿង០០២/០១ ។

ទោះបីជាយ៉ាងនេះក្តី ព័ត៌មានដែលស្ថិតនៅក្រៅវិសាលភាពនេះគប្បីត្រូវទទួលយកដែល "ជាទូទៅ" នៅពេលព័ត៌មាននោះបានផ្តល់ភ័ស្តុតាងពាក់ព័ន្ធដោយផ្ទាល់ និង/ឬទាក់ទងទៅនឹងផលប៉ះពាល់នៃឧក្រិដ្ឋកម្មទៅលើជនរងគ្រោះ» ។

អាស្រ័យហេតុនេះ អង្គជំនុំជម្រះដកចេញឯកសារចំនួន ១២២ ដោយរកឃើញថា ជាប់ពាក់ព័ន្ធទៅ នឹងការចោទប្រកាន់ទៅលើអង្គហេតុដែលពុំមាននៅក្នុងសំណុំរឿង០០២/០១ ។ អង្គជំនុំជម្រះសម្រេចថាឯកសារទាំងនោះ "ពុំមានសារសំខាន់" សម្រាប់សហព្រះរាជអាជ្ញា ដើម្បីបំពេញកាតព្វកិច្ច របស់ខ្លួនក្នុងការបង្ហាញភ័ស្តុតាង និងស្ទួនគ្នាជាមួយឯកសារផ្សេងៗទៀតដែលត្រូវបានទទួលយក» ។

សរុបសេចក្តីមក អង្គជំនុំជម្រះសាលាដំបូងសម្រេចទទួលយកកំណត់ហេតុស្តាប់ចម្លើយ និងប្រតិចារិកចំនួន១៣៩៩ឯកសារជំនួសឲ្យការមកផ្តល់សក្ខីកម្មដោយផ្ទាល់មាត់ ។ ក្រុមមេធាវីការពារក្តីជនជាប់ចោទ នួន ជា បានធ្វើការជំទាស់ជាយូរមកហើយ ដោយថា ប្រសិនបើអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាអនុម័តយកមធ្យោបាយក្នុងការទទួលយកភ័ស្តុតាង ដែលអនុវត្តដោយតុលាការមិនអចិន្ត្រៃយ៍ផ្សេងៗទៀត «នោះតម្រូវឲ្យមានការវាយតម្លៃម្តងមួយៗ ទៅលើកំណត់ហេតុនីមួយៗ មុននឹងសម្រេចទទួលយកកំណត់ហេតុនោះ» ។ សម្រាប់ហេតុផលនេះ ក្រុមមេធាវីការពារក្តីស្នើសុំឲ្យ "វាយតម្លៃមួយបន្ទាត់ម្តងៗ" នៃឯកសារភ័ស្តុតាងដែលមាននៅក្នុងកំណត់ហេតុដែលត្រូវបានទទួលយកនោះ ។ ទោះបីជាយ៉ាងនេះក្តី អង្គជំនុំជម្រះសាលាដំបូងពុំបានដោះស្រាយដោយផ្ទាល់

ចំពោះការតវ៉ានេះឡើយ អង្គជំនុំជម្រះបានសង្កត់ធ្ងន់ថា ក្នុងការអនុម័តយកបទដ្ឋាននៃការទទួលយកភស្តុតាងរបស់តុលាការមិនអចិន្ត្រៃយ៍ «វាពុំបាន...និងអនុម័តយកដោយពុំរើសមុខនូវបច្ចេកទេស និងលក្ខខណ្ឌតម្រូវលម្អិតឲ្យរបស់បទដ្ឋានទាំងនោះឡើយ» ។

អង្គជំនុំជម្រះសាលាដំបូងបានបដិសេធសំណើរបស់ក្រុមមេធាវីការពារក្តីជនជាប់ចោទ នួន ជា (ដោយផ្អែកទៅលើភាពដូចគ្នា ដែលត្រូវបានលើកឡើងនៅក្នុងសវនាការស្តាប់សក្ខីកម្មសាក្សីលើកមុន) សុំឲ្យកោះហៅសាក្សីចំនួន១១០រូប ដែលកំណត់ហេតុស្តាប់ចម្លើយរបស់សាក្សីទាំងនោះបានបញ្ជាក់អំពីការកំណត់មុខសញ្ញាទៅលើមន្ត្រីសាធារណរដ្ឋខ្មែរ ហើយត្រូវបានទទួលយក ។ សំណើសុំឲ្យកោះហៅសាក្សីមួយចំនួនដែលត្រូវបានបដិសេធចោលលើកមុន និងសាក្សីដែលនៅសេសសល់ ពុំត្រូវបានស្នើទាន់ពេលវេលា ។ អង្គជំនុំជម្រះបានសង្កត់ធ្ងន់ថា ក្រុមមេធាវីការពារក្តីជនជាប់ចោទ នួន ជា «ត្រូវបានជូនដំណឹងចាប់តាំងពីខែមេសា ឆ្នាំ២០១១» អំពីកំណត់ហេតុស្តាប់ចម្លើយដែលសហព្រះរាជអាជ្ញាស្នើសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះ ជំនួសឲ្យការផ្តល់សក្ខីកម្មដោយផ្ទាល់មាត់ដែលទោះបីជាទីតាំងខក្រិដ្ឋកម្មទួលពោធិ៍ជ្រៃ (ជាទីតាំងតែមួយគត់ដែលនិយាយអំពីការកំណត់មុខសញ្ញាទៅលើមន្ត្រីរបស់របបសាធារណរដ្ឋខ្មែរ) មិនត្រូវបានដាក់បញ្ចូលរហូតមកដល់ខែតុលា ឆ្នាំ២០១២ និងវិសាលភាពដែលត្រូវចោទប្រកាន់នៅក្នុងសំណុំរឿង០០២/០១ ទើបតែត្រូវកំណត់ជាស្ថាពរនៅខែមុនក៏ដោយ ។

ជាច្រើនថ្ងៃមុនពេលអង្គជំនុំជម្រះសាលាដំបូងចេញសេចក្តីសម្រេចនេះ ក្រុមមេធាវីការពារក្តីជនជាប់ចោទ នួន ជា តវ៉ាថាដោយសាររយៈពេលសម្រាប់ធ្វើសេចក្តីសន្និដ្ឋានបិទបញ្ចប់កំពុងខិតជិតមកដល់ការខកខានក្នុងការកំណត់ចំពោះឯកសារដែលត្រូវទទួលយកគឺបានបង្កើតនូវ «ការរំលោភសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីត្រៀមរៀបចំការពារខ្លួន» ។ បន្ថែមលើនេះទៀត សេចក្តីសម្រេចទាំងអស់ដែលត្រូវបានប្រកាស «ពេលវេលាដែលត្រូវការសម្រាប់ពិនិត្យមើលឲ្យសេចក្តីសម្រេចទាំងនោះ» ធ្វើឲ្យមេធាវីការពារក្តី នួន ជា ចំណាយពេលអស់ពីរសប្តាហ៍» ហើយនៅដំណាក់កាលនេះ «បានបង្កឲ្យមានភាពលម្អៀងយ៉ាងធ្ងន់ធ្ងរទៅលើលទ្ធភាពជនជាប់ចោទ នួន ជា ក្នុងការត្រៀមរៀបចំការពារខ្លួន» ។

ដូច្នេះ ក្រុម មេធាវីការពារក្តីស្នើសុំឲ្យបន្ថែមពេលវេលាសម្រាប់ធ្វើសេចក្តីសន្និដ្ឋានបិទបញ្ចប់មិនតិចជាងប្រាំមួយសប្តាហ៍ចាប់រាប់ពីកាលបរិច្ឆេទដែលសេចក្តីសម្រេចទទួលយកឯកសារនោះបានចេញ ។ សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងពុំបានដោះស្រាយចំពោះ សំណើសុំនេះឡើយ ។

**អាន ហាញូឌុល**

# ដំណឹងស្វែងរកបងប្អូន

ខ្ញុំបាទឈ្មោះ ញ៉ាន ស៊ី ស្នាក់នៅផ្ទះលេខ៤៧៦G សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ក្រុងភ្នំពេញ ប្រកាសស្វែងរកឈ្មោះ អៀវ ទៀងហាវ ភេទប្រុស កើតឆ្នាំ១៩៤៨ នៅភូមិក្រពាំងក្រឡឹង ឃុំតាំងស្យា ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ។ ពីមុន ទៀងហាវ គឺជាសាស្ត្រាចារ្យរូបវិទ្យា-គីមី នៅវិទ្យាល័យអង្គរ ទីរួមខេត្តសៀមរាប ។ នៅខែវិច្ឆិកា ឆ្នាំ១៩៧៥ ទៀងហាវ និងភរិយាឈ្មោះ គួច សាយទៀង ត្រូវខ្មែរក្រហមជម្លៀសទៅនៅភូមិកន្ទួត ឃុំណាំតៅ ស្រុកភ្នំស្រុក ខេត្តបាត់ដំបង ។

នៅខែធ្នូ ឆ្នាំ១៩៧៥ ខ្មែរក្រហមបានប្រមូលបញ្ញាវន្តនៅតាមភូមិឃុំ ក្នុងស្រុកភ្នំស្រុក ហើយបានបញ្ជូន ទៀងហាវ និងភរិយាទៅនៅភូមិប្រាសាទ ឃុំប្រាសាទ ស្រុកព្រះនេត្រព្រះ ខេត្តបាត់ដំបង (បច្ចុប្បន្នខេត្តបន្ទាយមានជ័យ) ។ ទៀងហាវ និងភរិយាបានបាត់ខ្លួននៅឆ្នាំ១៩៧៦ ។

ប្រសិនបើបងប្អូនណាបានឮឬស្គាល់ឈ្មោះដូចខាងលើសូមផ្តល់ដំណឹងមកខ្ញុំបាទតាមរយៈអាសយដ្ឋានក្រសួងរៀបចំដែនដីនរគនីយកម្ម និងសំណង់ ទូរស័ព្ទលេខ ០១២ ៩៥៨ ៥៨៦ ឬ អ៊ីមែល nhansy04@yahoo.com ។

***សូមអរគុណ!***




រូបគំនូរដោយអ្នកនិពន្ធ ឆាយ ស៊ីផាត្រ

**(តពីលេខមុន)**

ថ្ងៃមួយ មិត្ត ម៉ែន បានប្រាប់យើងឲ្យរៀបចំខ្លួនចេញដំណើរទៅស្តាប់ការខទ្ទេសនាមរបស់អង្គការថ្នាក់លើដែលមកពីភូមិភាគ ។ ព្រឹកឡើងយើងត្រូវដើរតាំងពីការដ្ឋានស្រែសម័យភ្នំអង្គទៅដល់ទំនប់តានៃ ប្រហែលជាងដប់គីឡូម៉ែត្រដើម្បីទៅស្តាប់បទខទ្ទេសនាមរបស់គណៈភូមិភាគ ។

នៅទីនោះ ខ្ញុំក៏បានជួបអតីតមិត្តរួមថ្នាក់ជានិស្សិតមកពីមហាវិទ្យាល័យនានា ហើយគឺជាអ្នកដែលរួចរស់មានជីវិតឆ្លងកាត់ជីវិតដ៏លំបាកកាលពីកន្លងទៅ ក៏ប៉ុន្តែយើងមិនមានពេលដើម្បីនិយាយគ្នាទេ ។ យើងមានគ្នាច្រើនណាស់ដែលមកពីគ្រប់ការដ្ឋាន

ក្នុងស្រុក១៤ និងគ្រប់ឃុំប្រហែលជា ៥០០០នាក់ ។

យើងទាំងអស់គ្នាសុទ្ធតែស្លៀកពាក់ពណ៌ខ្មៅថ្មីៗ ថែស ។ ម៉ោងប្រហែលពីរសៀល រថយន្តហ្ស៊ីបមួយគ្រឿងបានបើកចូលមក កម្មាភិបាលបង្គាប់ឲ្យយើងក្រោកឈរទះដៃទទួលសមមិត្តដែលមកពីអង្គការលើគឺជាបុរសពាក់កណ្តាលអាយុម្នាក់ដែលមានឈ្មោះថា "តាស៊ី" ជាគណៈភូមិភាគបស្ចិម ។ គាត់ស្លៀកពាក់ខ្មៅ និងពាក់ស្បែកជើងកង់ឡានបង់កក្រមាពណ៌ក្រហម អមដោយនីរសាពីរនាក់ ។ ខ្ញុំមើលទៅគាត់ដូចជាអស្ចារ្យខ្លាំងណាស់ ។ កម្មាភិបាលខ្ចបខ្ចាច ដូចកូនស្វាឃើញខ្លាធំ ។ តាស៊ី អង្គុយលើកៅអីដែលរៀបចំឲ្យ និងអ្នកដែលអង្គុយសងខាង "តាស៊ី" គឺស្ត្រីម្នាក់ដែលខ្ញុំមិនស្គាល់ឈ្មោះ រីឯម្នាក់ទៀតគឺ តាសារុន ជាគណៈតំបន់៣១ ខេត្តកំពង់ឆ្នាំង ។ តាស៊ី បានប្រើពេលប្រហែលមួយម៉ោងដើម្បីថ្លែងសរសើរពីស្មារតីយកចិត្តទុកដាក់របស់យុវជនកងចល័តដែលពង្រីងជំហរបដិវត្តន៍ខ្ពស់ សកម្មការងារ ដែលអង្គការបានដាក់ចុះ ។ តាស៊ី និយាយថា គាត់ជាអតីតសាស្ត្រាចារ្យនៅសង្គមរាស្ត្រនិយមជំនាន់សម្តេចឪ ។ តាស៊ី ពុំបាននៅយូរទេ ព្រោះគាត់ត្រូវទៅខេត្តនាមនៅកន្លែងផ្សេងទៀត ហើយទុកនាទីឲ្យ តាសារុន ថ្លែងសុន្ទរកថាបន្តទៀត ។ តាសារុន ជាមនុស្សដែលនិយាយម៉ាត់ៗ ហើយប្រើពាក្យអសុរោះយ៉ាងខ្លាំងចំពោះអ្នកដែលរស់នៅជាមួយរបប លន់ នល់ ។

បន្ទាប់មកទៀត ក៏មានការសម្តែងសិល្បៈតំបន់ដែលមកពីកំពង់ឆ្នាំង ។ អត្ថន័យនៃសិល្បៈគឺនិយាយតែលើកម្លាំងវណ្ណៈ ការប្រយុទ្ធ និងការងារបំពេញភារកិច្ចឥតនឿយហត់ឲ្យហើយសម្ភារដែលមកសម្តែងគឺកាំភ្លើង ញញួរ និងកណ្តៀវ ។

គាត់មិននិយាយពីភាពទន់ភ្លន់ ផ្អែមល្ហែម ឬសេចក្តីស្នេហាអ្វីទេ ព្រោះនោះជាកំអែលសង្គមចាស់ សក្តិភូមិ ពុករលួយដែលធ្វើឲ្យប្រឡាក់មន្ទិលដល់បដិវត្តន៍ដ៏ស្អាតស្អំភ្លឺស្វាង ។

ថ្ងៃនោះ អង្គការបានកាប់គោ ក្របី ជ្រូក ជប់លៀង យើងទាំងអស់គ្នាស៊ីបានតាមចិត្តចង់បានប៉ុន្មានក៏បានដែរ ក្នុងចានសម្លសុទ្ធតែសាច់ បាយឆ្អែត យើងស៊ីទាល់ហល់ចាក់ច្រាស ព្រោះថាជាងមួយឆ្នាំហើយ ទើបនឹងបានឆ្ងាញ់បានឆ្អែតម្តង មានអ្នកខ្លះទាល់ពោះ ក្អួត និងរាគមួល ។ នៅពេលយប់ អង្គការចែកបារីម៉ាកគួបី ក្នុងម្នាក់បានជប់ដើមសម្រាប់ជក់បង្អួយគ្នា ។

អង្គការបានចែកបន្ថែមផង គឺទឹកដោះគោខាប់មួយកំប៉ុងឲ្យទឹកក្តៅមួយខ្ទះហុកសិបលីត្រ លាយជាមួយស្ករត្នោត ។ យើងត្រូវឈរតម្រង់ជួរទទួលទឹកដោះគោមួយកែវម្នាក់ ។ សមមិត្ត ម៉ែន បានប្រាប់យើងថា បដិវត្តន៍គឺស្មើភាពនិងយុត្តិធម៌ សង្គមគ្មានអ្នកមាន គ្មានអ្នកក្រ អ្នកណាធ្វើការ អ្នកនោះបានហូប វណ្ណៈសក្តិភូមិនាយទុនត្រូវតែកម្ទេច ។ ម៉ែន បញ្ជាក់ទៀតថា កាលពីសង្គមចាស់គឺមានតែអ្នកសក្តិភូមិទេ ដែលមានទឹកដោះគោផឹក ក៏ប៉ុន្តែពេលនេះពេលណាចង់ផឹកទឹកដោះគោនោះ គឺយើងផឹកទាំងអស់គ្នា ។

ខ្ញុំស្តាប់ ម៉ែន និយាយបណ្តើរនឹកក្នុងចិត្តបណ្តើរ ។ គាត់និយាយតែសមភាព យុត្តិធម៌ ក៏ប៉ុន្តែនៅទីនេះ ខ្ញុំមិនដែលឃើញយុត្តិធម៌ទាល់តែសោះ ព្រោះពេលដែលគាត់នៅជិតចៅហ្វាយគាត់ម្តងៗ គាត់មិនដែលហ៊ានមើលមុខចំទាល់តែសោះ ហើយនៅពេលដែលចៅហ្វាយគាត់មក គាត់ញញើញញ័រខ្លាំងណាស់ ។

ពេលនេះ ជាលើកទីមួយហើយ ដែលយើងបានសម្រាកឥតធ្វើការ ហើយបានស៊ីឆ្អែតរយៈពេលពីរថ្ងៃ ។ ថ្ងៃនោះហើយដែលខ្ញុំបានឮពាក្យថា "បក្សកុម្មុយនីស្តកម្ពុជា" ។ ខ្ញុំមិនបានចាំថ្ងៃខែ ក៏ប៉ុន្តែមេក្រុបានប្រកាសយ៉ាងឧឡារិកថា ថ្ងៃខួបទី១៥ នៃការបង្កើតបក្សកុម្មុយនីស្តកម្ពុជា គឺចាប់ពីថ្ងៃនោះហើយដែលអង្គការឈប់ប្រើពាក្យថា"អង្គការ" ដោយប្រើពាក្យថា "បក្ស" ជំនួសវិញ ។

## ៤៣) ប៉ុល ពត

គឺថ្ងៃនោះហើយដែលវិទ្យុភ្នំពេញបានចាក់ផ្សាយបទខទ្ទេសនាមរបស់សមមិត្ត ប៉ុល ពត អគ្គលេខាធិការនៃគណៈកម្មាការមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា ហើយក៏ជាលើកទីមួយដែលខ្ញុំបានឮឈ្មោះ សមមិត្ត ប៉ុល ពត ។ មិនថាតែរូបខ្ញុំទេ សូម្បីតែកម្មាភិបាលថ្នាក់ទាបដូចជា ម៉ែន និង ផល ក៏ពុំដែលឮឈ្មោះនេះដែរ ។ បទខទ្ទេសនាមរបស់សមមិត្ត ប៉ុល ពត មានរយៈពេលប្រហែលពីរម៉ោងកន្លះ ។ ប៉ុល ពត និយាយច្រំដែលៗគឺគាត់លើកសរសើរពីបក្សដ៏មហាភ្លឺស្វាង មហាលោតផ្លោះ មហាអស្ចារ្យ ។ គាត់និយាយអំពីប្រវត្តិនៃការរៀបចំគណៈកម្មាធិការមជ្ឈិមបក្សនៅភ្នំពេញ អំពីមហាសន្និបាតរបស់បក្សដែលបានធ្វើឡើងនៅស្ថានីយអយស្ម័យយានកម្ពុជា ។ គាត់និយាយអំពីចលនាប្រឆាំង សីហនុ និងចលនាយុវជនសិស្ស និស្សិត ប្រឆាំងនឹងរាជានិយម ។ ប៉ុល ពត

ពន្យល់ទៀតថា កំហឹងវណ្ណៈប្រៀបដូចជាសំពត់ស ដែលត្រូវកំដៅនារដូវក្តៅគឺថាងាយ និងឆេះ ខ្លាំងណាស់គឺពេលនោះហើយដែលបក្សកុម្មុយនីស្តទទួលបានជោគជ័យក្នុងការដឹកនាំចលនាតស៊ូដោយសារមានការជិះជាន់ភាពអយុត្តិធម៌ដែលពួកសក្តិភូមិបានសង្កត់សង្កិនរាស្ត្រ ។ តាមការខទ្ទេសនាមនោះ ប៉ុល ពត សរសើរហើយសសើរទៀតអំពីបក្សខ្លួន ដូច្នេះដែរ ព្រោះថា គាត់នេះហើយជាអ្នកដឹកនាំជាអគ្គលេខាធិការ ។ និយាយទៅនិយាយមក គាត់និយាយតែពាក្យដដែលៗ ។

ក្រោយសុន្ទរកថាដ៏វែងរបស់ ប៉ុល ពត ក៏រៀបអាហារឲ្យយើងទាំងអស់គ្នាបរិភោគពេលថ្ងៃ រួចសម្រាកបន្តិច ។ ក្នុងខណៈដែលយើងកំពុងអង្គុយជជែកគ្នានារសៀលនោះ ក៏មានការចាក់សាឡើងវិញនូវសន្ទរកថារបស់ ប៉ុល ពត ។ លើកនេះអ្នកណាចង់ស្តាប់ក៏ស្តាប់ តែអ្នកណាដែលនិយាយគ្នា ក៏អាចនិយាយគ្នាបាន ។ ខ្ញុំឃើញ ម៉ែន ដើរសំដៅមកខ្ញុំ ហើយហុចទស្សនាវដ្តីមួយដែលមានអក្សរធំថា ទស្សនាវដ្តីកម្ពុជាប្រជាធិបតេយ្យ ។ ចូរឯងអានឲ្យមិត្តឯទៀតស្តាប់ផង! ខ្ញុំភ្ញាក់ព្រើតក្នុងចិត្តនឹកថា ម្តងនេះ ម៉ែនច្បាស់ជារករឿងទៀតហើយ ។ ខ្ញុំចាប់យកទស្សនាវដ្តីមកផ្ទៀងផ្ទួងមើលដោយយកចិត្តទុកដាក់ ។ នៅលើទស្សនាវដ្តី ឃើញរូបម្នាក់រាងធាត់មុខធំ កាត់សក់ខ្លី ពាក់កម្រងផ្កាដែលកុមារាកុមារីកូរ៉េខាងជើងបានបំពាក់ឲ្យ ។ ដោយឃើញកាយវិការញាក់ញ័ររបស់ខ្ញុំ ម៉ែនក៏ស្រែកគំហក មើលឲ្យពុទ្ធឡើង នរណាក៏ដឹងដែរថា ឯងជាបញ្ញាជន កុំធ្វើបុកខ្លាំងពេក ។

ខ្ញុំចាប់ផ្តើមអានទស្សនាវដ្តីពុទ្ធៗច្បាស់ពេលនោះហើយដែលខ្ញុំឃើញច្បាស់នូវរូប ប៉ុល ពត ដែលបានធ្វើទស្សនកិច្ចនៅកូរ៉េខាងជើង ។ គាត់ជាអគ្គលេខាធិការនៃគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្ត ។

## ៤៤) គម្រោងការក្បត់

មហាសន្និបាតបក្សកុម្មុយនីស្តបានបញ្ចប់ប្រកបដោយជោគជ័យ យើងឈប់ប្រើពាក្យថា អង្គការទៀតហើយ ។ ពេលនេះបក្សមានផែនការធំមួយ ។ គ្រប់ការដ្ឋានត្រូវចូលរួមបំពេញភារកិច្ចរបស់បក្សដើម្បីបុព្វហេតុបដិវត្តន៍ ។ បក្សតម្រូវឲ្យគ្រប់ការដ្ឋានបញ្ជូនកម្លាំងទៅកាន់ទំនប់ទឹក ភូមិភាគនៅពាមល្វានៅឃុំត្រពាំងជោរ តំបន់៣២ ។ តាមគោលការណ៍របស់បក្សត្រូវរក្សាសុទ្ធតែកម្លាំងទី១ ហើយកម្លាំងទី២ ត្រូវត្រឡប់ទៅស្រែសម័យវិញ ។

តាមធម្មតាខ្ញុំត្រូវបានចាត់ទុកជាកម្លាំងទីពីរ ប៉ុន្តែដោយសារតែ ម៉ែន មិនចូលចិត្តខ្ញុំនោះ ក៏ត្រូវ ម៉ែន ចុះឈ្មោះឲ្យទៅពាមល្វាជាមួយកម្លាំងទី១ដទៃទៀត ។ យើងចំនួន១៥នាក់ត្រូវបានបញ្ជូនឲ្យចូលរួមជាមួយយុវជនយុវនារីដទៃទៀត ។

នៅកងថ្មីនេះ មានយុវជនយុវនារី លាយចម្រុះគ្នាប្រហែលបួនរយនាក់ដែលឲ្យឈ្មោះថា កងវរសេនាប្រតិបត្តិការជួរមុខ ។ មេបញ្ជាការរបស់យើងឈ្មោះមិត្ត វុធ អាយុ៣៥ឆ្នាំ មេបញ្ជាការរងឈ្មោះ មិត្ត ទូន ជាមិត្តនារីអាយុ២៧ឆ្នាំ និង មិត្ត មុត មានអាយុប្រហែល៣០ឆ្នាំ ។

សមមិត្ត វុធ គឺជាបុរសមានចរិតស្ងប់ស្ងៀមនិងម៉ឺងម៉ាត់ ។ ចំណែក នារី ទូន គឺជាមនុស្សរួសរាយ គាត់ស្លៀកពាក់ពណ៌ខ្មៅ អាវឡេវច្រើនពណ៌ក្រហម ។ ទូន ស្រឡាញ់នាឡិកាដែលផលិតនៅប្រទេសជប៉ុន ។ ជាញឹកញយ យើងឃើញគាត់មើលកដៃខាងស្តាំដែលពាក់នាឡិកាដ៏ស្អាតនោះ ។ ចំពោះមិត្ត មុត គឺជាមនុស្សនិយាយពុទ្ធ និងច្រៀងពិរោះ ហើយចូលចិត្តនិយាយកំប្លែង ។

យើងធ្វើដំណើរកាត់ឃុំព្រៃជ្រៅ ស្រុកអមលាំងមកដល់ផ្លូវបំបែកគោងហោរុង និងស្រុកគងពិសី ដែលកាលសម័យនោះហៅថា តំបន់៣២ ។

ខ្ញុំត្រូវអង្គការចាត់តាំងឲ្យបររទេះគោដឹកអង្ករ ខ្លះនិងគ្រឿងឧបភោគបរិភោគផ្សេងទៀត ។ យើងដើរឆ្លងកាត់ព្រៃក្រាស់ដែលពេលខ្លះពុំមានពន្លឺថ្ងៃទៀតផង ។

នៅការដ្ឋានភូមិភាគទំនប់ទឹកពាមល្វា យើងធ្វើការចម្រុះគ្នាមានប្រុសមានស្រី ។ ការដ្ឋាននេះធំណាស់ គឺមានកម្លាំងប្រហែលប្រាំម៉ឺននាក់គឺដើម្បីទប់ស្ទឹងពាមល្វានៅត្រង់ភូមិលឹម តំបន់៣២ ដើម្បីយកទឹកស្រោចស្រពស្រែសម័យដែលមានផ្ទៃដី១៥០០០ ហិកតា ។ កម្លាំងទាំងអស់សុទ្ធតែជាយុវជន យុវនារីដែលនៅលីវមកពីគ្រប់ស្រុកនៃតំបន់៣១ កំពង់ឆ្នាំង ។ កងរបស់យើងបែកចែកជាប្រាំមួយអនុសេនាធំដែលមានកម្លាំង៧០នាក់ ។ ក្នុងមួយអនុសេនាធំមានបញ្ជាការម្នាក់ ។ មេបញ្ជាការបុរសត្រួតត្រាកងបុរស មេបញ្ជាការនារីត្រួតត្រាកងនារី ។

មេបញ្ជាការកងអនុសេនាធំរបស់យើងឈ្មោះ សមមិត្ត ជឿន ជាបុរសមានមាឌធំខ្ពស់ សក់រួញ សម្បុរខ្មៅ ។ គាត់មានអាយុប្រហែល២៧ឆ្នាំ ។ ទៅទីណា សមមិត្ត ជឿន ស្ពាយទ្រសោរបស់គាត់ជានិច្ច ។ ជឿន ក្លួងពិរោះណាស់ ។ សំឡេងទ្ររបស់គាត់លាន់ឮ ឲ្យនឹករឭកដល់ភូមិស្រុក ឪពុកម្ដាយ បងប្អូនធ្វើឲ្យយើងស្ទុងបាត់ក្នុងស្រមោលអតីតកាល ។

យើងជាយុវជន យុវនារី ចូលចិត្តសំឡេងទ្ររបស់ ជឿន ដែលលេងបទប្រពៃណីដែលស្ដាប់ហើយមានអារម្មណ៍លន្លង់លន្លោចខ្លោចផ្សារស្រក់ទឹកភ្នែក ។

នាថ្ងៃសម្ពោធការដ្ឋាន យើងបានមកជួបជុំគ្នានៅមាត់ស្ទឹងពាមលា្វ ដើម្បីស្ដាប់សេចក្ដីថ្លែងការណ៍របស់ តាស៊ី គណៈភូមិភាគបស្ចិម បន្ទាប់មក គឺមិត្ត វេង ជាសមាជិកគណៈកម្មាធិការភូមិភាគ និងជាសមាជិកសភាប្រជាជនកម្ពុជា ។

តាមរយៈសមមិត្ត វុធ ដែលជាបញ្ជាការកងវរសេនាពិសេសជួរមុខបានឲ្យដឹងថា មិត្ត វេង កើតចេញពីគ្រួសារកសិករក្រីក្រមួយ ។ គាត់មិនដែលចូលសាលារៀនទេ ហើយក៏ពុំចេះអក្សរដែរ ដោយសារតែគ្រួសារគាត់ពុំមានដីស្រែ គាត់ទាំងអស់គ្នារស់នៅដោយសារការស៊ីឈ្នួលគេដើម្បីចិញ្ចឹមជីវិត ។ អំឡុងសង្គ្រាមប្រាំឆ្នាំ រវាងសីហនុ និង លន់ នល់ សមមិត្ត វេង បានចូលរួមក្នុងចលនាបដិវត្តន៍តស៊ូប្ដូរផ្ដាច់ដើម្បីបុព្វហេតុវណ្ណៈអធន ។ វេង បានបូជាទាំងរូបកាយ និងទឹកចិត្តចំពោះបដិវត្តន៍ឥតមិនរាថយចំពោះឧបសគ្គ ។ គាត់តែងតែជឿជាក់លើការដឹកនាំរបស់បក្សដែលភ្លឺស្វាង មហាលោតផ្លោះ មហាអស្ចារ្យ ។ វេង គឺជាវីរបុរសដែលទទួលកិត្តិយសពីបក្សជាយុទ្ធជនដ៏អង់អាចក្លាហានដែលហ៊ានប្រយុទ្ធតទល់នឹងរថក្រោះដោយហ៊ានយកគ្រាប់បែកទៅបោកសម្លាប់សត្រូវនៅលើរថក្រោះទៀតផង ។

ការងារនៅទីនោះ មានភាពងាយស្រួលដោយយើងចាប់ផ្ដើមនៅម៉ោងប្រាំមួយ ហើយសម្រាកនៅម៉ោងដប់មួយ ។ យើងទទួលរបបអាហារបីពេលក្នុងមួយថ្ងៃ ដោយមានបន្ថែមម្ដងថ្ងៃអាទិត្យសម្រាកហើយ មិនមានធ្វើការយប់ទេ ។ នាថ្ងៃអាទិត្យ អង្គការអនុញ្ញាតឲ្យយើងដើរលេងឆ្លងពីដីរំមួយទៅកាន់ដីរំមួយទៀត ។ ខ្ញុំបានដើររហូតដល់មាត់ទំនប់ពាមលា្វ ។ ទំនប់នេះមានប្រវែងប្រហែល ៩គីឡូម៉ែត្រ រីឯទ្វារទឹកចាក់បេតុងអាម៉េ ហើយមានគ្រាក់ទ័រ និងគ្រឿងចក្រជាច្រើន ។ នៅទីនោះ ក៏ឃើញមានវិស្វករជនជាតិចិនជាច្រើននាក់ ។

ពេលដែលមានរបបអាហារគ្រប់គ្រាន់និងធ្វើការមានពេលសម្រាក អារម្មណ៍យុវជន យុវនារី ក៏បានពុះកញ្ជ្រោលក្នុងដួងមនោសញ្ចេតនាស្នេហាខ្លះៗដែរ ។ រីឯសាច់ឈាមក៏ស្រស់ថ្លា យើងនាំគ្នាច្រៀងបទចម្រៀងបដិវត្តន៍តែមានពេលខ្លះក៏មានលួចច្រៀងចម្រៀង ស៊ិន ស៊ីសាមុត ដែរ ។

អង្គការក៏បានចែកសម្លៀកបំពាក់ពណ៌ផ្សេងៗដូចជា ដីក្រហម ផ្កា និងមានស្បែកជើងម៉ាកជីបតុង ។ មួយអាទិត្យម្ដង មិត្ត វុធ បញ្ជាកងវរសេនាពិសេសជួរមុខបានបើកអង្គប្រជុំដើម្បីលើកទឹកចិត្តដើម្បីធានាកំណែទម្រង់នយោបាយរបស់បក្សនាពេលអនាគត ។ ទោះយ៉ាងណាក៏ក្ដី យើងមិនដែលមានយោបល់អំពីនយោបាយឬកំណែទម្រង់អ្វីទេ ព្រោះបារម្ភថានេះជាការស្ទាបស្ទង់គោលជំហររបស់បក្សចំពោះយើង ។

ជារៀងរាល់ថ្ងៃ រថយន្តដឹកស្បៀងដែលមានស្លាកបិទនៅជញ្ជាំងថា ស.ហ ភូមិភាគបស្ចិម ឬសេដ្ឋកិច្ច ហិរញ្ញវត្ថុភូមិភាគបស្ចិម បានបើកបរជាក្បួនហូរហែ ។

យើងពុំនឹកស្មានថា សេចក្ដីសប្បាយនេះមានរយៈពេលខ្លីដល់ថ្នាក់នេះសោះ គឺប្រហែលអំឡុងចុងឆ្នាំ១៩៧៦ ឬដើមឆ្នាំ ១៩៧៧ ដែលយើងកំពុងតែមានកម្លាំងរឹងមាំបានបន្តិចបន្ទាប់ពីការបាក់កម្លាំងនិងភាពហត់នឿយអស់រយៈពេលយ៉ាងយូរមក ។ ស្រាប់តែស្រមោលនៃឡានឡង់រ៉ូវែរពេជ្ឈឃាតបានតាមលងយើងសាជាថ្មី ។

លើកនេះឡានឡង់រ៉ូវែរ ពុំមែនសំដៅយើងទៀតទេ ។ ថ្ងៃដ៏គួរឲ្យរន្ធត់នោះគឺមិត្ត វើង គណៈការដ្ឋានទំនប់ពាមលា្វ និងកម្មាភិបាលជាន់ខ្ពស់ដទៃទៀតជាច្រើននាក់ត្រូវចងមុខ និងចាប់ដាក់ឡាន ។ រីឯសមមិត្តថ្នាក់ក្រោមបន្ទាប់ត្រូវចងស្លាបសេកដាក់ឡានទ្រុងបិទជិតបូលជិត ។ ថ្ងៃនោះ ខ្ញុំសង្កេតឃើញមានកម្មាភិបាលថ្នាក់វរសេនាតូច និងអនុសេនាប្រហែលជាងសែសិបនាក់ត្រូវបានចងបញ្ចូលឡានទ្រុង ដែលមានសមមិត្ត វុធ ដែរ ។

គណៈបញ្ជាការថ្មីបានមកជំនួសភ្លាមៗ ។ អ្នកទាំងនោះសុទ្ធ

តែមកពីភូមិភាគនិរតីដែលដឹកនាំដោយ តាម៉ុក ជាគណៈបញ្ជាការសេនាធិការរបស់បក្សកុម្មុយនីស្តកម្ពុជា ។ យោធាដែលបញ្ជូនមកពុំស្លៀកពាក់ពណ៌ខ្មៅទេ គឺសុទ្ធតែពណ៌ត្រីអ៊ីហើយមានអាយុក្មេងៗ មានខ្លះពុំទាំងចេះនិយាយភាសាខ្មែរផង ។ ក្មេងទាំងនោះសុទ្ធតែជាក្មេងជនជាតិព្នងមកពីរតនគិរី ។

មេបញ្ជាការថ្មីបង្គាប់ឲ្យយើងឈប់ធ្វើការដើម្បីបើកអង្គប្រជុំពិសេស ។ ពេលមកដល់ជំរំ មិត្ត រួន និង មិត្ត មុត ត្រូវចាប់ខ្លួនដាក់ឡានទៅបាត់អស់ហើយ អ្វីដែលខ្ញុំរន្ធត់បំផុតគឺ ទ្រូ មួកកន្ទឹបអាវ និងក្រមារបស់មិត្ត ជឿន តន្ត្រីដ៏ជាទីស្រលាញ់របស់យើងបានបន្សល់នៅលើជញ្ជាំងគួរឲ្យសង្វេគ ព្រោះម្ចាស់របស់ទ្រូនេះក៏ត្រូវបានចាប់ខ្លួនទៅបាត់ដែរ ។

អង្គការបានប្រាប់យើងទាំងអស់គ្នាថា តាស៊ី ដែលជាអតីតលេខាធិការគណៈភូមិភាគបស្ចិម និង វេង ជាគណៈការដ្ឋានទំនប់ទឹកពាមល្វា គឺជាជនក្បត់បក្សត្រូវចាប់ខ្លួនដឹកទៅភ្នំពេញតាមរថយន្តឡង់រ៉ូវែរ រីឯកម្មាភិបាលថ្នាក់បង្គាប់ដូចជា វ៉ុធ ទួន មុត និង ជឿន និងគណៈបញ្ជាការវរសេនាតូចនិងអនុសេនាដទៃទៀតត្រូវបានចាប់ខ្លួននឹងដឹកចេញពុំដឹងថាជាទៅទីណា ចំណែកយើងដែលជាប់និន្នាការជាមួយក្រុម ក្បត់ត្រូវរង់ចាំបញ្ជារបស់បក្ស ។

## ៨៥) អាយ៉ឹងយួន

ការចាប់ខ្លួនកម្មាភិបាលនោះគឺជាបន្សុទ្ធកម្មដាច់ខាតដែលដឹកនាំដោយតាម៉ុកដើម្បីស្វែងរកខ្មាំងស៊ីរូងផ្ទៃក្នុង ។ ប្រហែលជាងបីរយនាក់ដែលត្រូវចាប់ដាក់ឡានឡង់រ៉ូវែរនិងឡានយ្ហុប ។ យើងលែងបានពុស្ទួរចម្រៀងឬសំណើចទៀតហើយ ការភ័យខ្លាចខ្លាំងជាងនៅកងចល័តស្រែសម័យនៅភ្នំអង្គទៅទៀត ។ យោធាវ័យក្មេងជាច្រើនរយនាក់ដែលមកពីរតនគិរីគឺជាទាហានដ៏ស្មោះត្រង់របស់បក្សហើយពុំចេះស្តាប់ពាក្យអង្វរឡើយ ។ ពេលនោះ គ្រប់វរសេនាតូចត្រូវបំបែកជាក្រុមតូចៗក្នុងមួយក្រុមមានជាង២០នាក់ហើយត្រូវបានត្រួតត្រាដោយមេក្រុមម្នាក់ដែលយើងពុំដែលស្គាល់ ។

មេក្រុមថ្មីពុំបានពន្យល់អ្វីទាល់តែសោះ ប្រាប់យើងឲ្យចេញដំណើរ ហើយបានឲ្យខ្ញុំបរទេះគោដឹក ចានឆ្នាំង និងខ្ទះធំ ចាកចេញពីពាមល្វាទាំងព្រលឹម ។ មេក្រុមរបស់ខ្ញុំជិះសេះ រីឯជំនួយការរបស់គាត់ជិះកង់ ក្រុមយុវជនដទៃទៀតធ្វើដំណើរពីរថ្ងៃកាត់ព្រៃជ្រោះនិងភ្នំរាប់រយដោយមិនស្គាល់អ្វីទាំងអស់រហូតដល់ជួបភូមិ ស្រុកនិងសហករណ៍ទីបំផុតខ្ញុំបានស្គាល់ច្បាស់គឺភូមិព្រៃខ្មែរដែលជាភូមិកំណើតរបស់ខ្ញុំ ។ ស្ថិតតាមផ្លូវជាតិលេខប្រាំត្រង់បង្គោលគីឡូម៉ែត្រលេខ៨២ ។ យោធាទាំងនោះឲ្យយើងសម្រាកនៅទីនោះមួយយប់ ។ នៅទីនោះ ខ្ញុំរំឭកអនុស្សាវរីយ៍កាលពីក្មេងដែល ក្រោយមកត្រូវភ្លើងសង្គ្រាមប្រាំឆ្នាំ សីហនុ និង នល់ នល់ បានត្រូវបំផ្លាញខ្ទេចខ្ទីដោយគ្រាប់កាំភ្លើងធំដោយយន្តហោះទម្លាក់គ្រាប់បែកនិងដោយការដុតបំផ្លាញ ។

នាយប់នោះ ពេលសម្រាកនាភូមិព្រៃខ្មែរ ខ្ញុំដេកមិនលក់ទេ ខ្ញុំសួរខ្លួនឯងថាតើហេតុអ្វីបានជាខ្ញុំត្រូវមកទទួលកម្មពៀររបៀបនេះ ។ ខ្ញុំបន្ទោសសេនាប្រមុខ នល់ នល់ ដែលបានធ្វើរដ្ឋប្រហារទម្លាក់សម្តេចនរោត្តម សីហនុ នាថ្ងៃ១៨ មីនា ១៩៧០ ។ ខ្ញុំថ្កោលទោសចំពោះរបបសាធារណរដ្ឋខ្មែរដែលពុករលួយរហូតដល់ឈានទៅរកបរាជ័យសង្គ្រាមនាថ្ងៃ ១៧ មេសា ឆ្នាំ១៩៧៥ ។

ខ្ញុំក៏បានសួរខ្លួនឯងទៀតថា នៅថ្ងៃនោះ បើយើងមិនជឿថាអង្គការឲ្យយើងចាកចេញពីផ្ទះដើម្បីទៅទទួលសម្តេច ហើយបើសិនជាយើងប្រឆាំងនឹងការបណ្តេញចេញ តើលទ្ធផលវានឹងទៅជាយ៉ាងណា? ចំពោះឪពុករបស់ខ្ញុំដែលតែងតែគាំទ្រសម្តេចហើយប្រឆាំងជានិច្ចចំពោះសេនាប្រមុខ លន់ នល់ តើពេលនេះសម្តេចឪទ្រង់គង់នៅឯណា? តើទ្រង់យាងមកជួយពួកយើងដែរឬទេ? ឥឡូវនេះ ឪពុកម្តាយក៏បានចែកឋានទៅហើយ សល់តែកូនដែលរស់នៅយ៉ាងវេទនាបែបនេះ ។

ខ្ញុំបានចងចាំនូវសម្តីរបស់ឪពុកខ្ញុំដែលតែងតែសរសើរមិនដាច់ពីមាត់អំពីយុទ្ធជនរណសិរ្សរំដោះជាតិកម្ពុជាដែលស្លូតបូតសុភាពរាបសាប្រកបដោយឧត្តមគតិជាតិនិងប្រជាជនគឺជាយុទ្ធជនដែលមានន័យថ្លៃថ្នូរ ស្រឡាញ់ប្រជាជនចុះហេតុដូចម្តេចអ្នកទាំងនេះក្លាយជាសាហាវបែបនេះ ។ កាលក្នុងអំឡុងសង្គ្រាមប្រាំឆ្នាំ ពេលដែលកងទ័ពរណសិរ្សរំដោះជាតិទៅដល់ទីណាមានប្រជាជនទាំងភូមិ យកចំណី ចេកដូង អំបុក ល្ហុងយកទៅឲ្យដល់ទីនោះ ចុះឥឡូវនេះ? តើអ្នកទាំងនោះតបស្នងប្រជាជនវិញដោយរបៀបនេះឬ?

ស្អែកឡើងយើងបន្តដំណើរចាកចេញពីព្រៃខ្មែរកាត់តាមភូមិអណ្តូងស្វាយ គោកបន្ទាយ ឆ្ពោះទៅភូមិត្បែងប៉ាហ៊ីឆ្លងកាត់វាលចារ

រហូតដល់ម៉ោងបួនរសៀលទើបយើងមកដល់មាត់បឹងធំមួយ ។

នៅជិតក្បែរមាត់បឹងមានកម្មាភិបាលម្នាក់បញ្ជាឲ្យយើងអង្គុយដើម្បីចាប់ផ្តើមអង្គប្រជុំ ។ នៅទីនោះយើងបានឃើញយុវជនជាងដប់នាក់ មានទឹកមុខស្មេកស្មាំងនិងអស់កម្លាំងប្រហែលជាអ្នកទាំងអស់គ្នាមកទីឆ្ងាយដូចយើងដែរ ។

កម្មាភិបាលបានប្រជុំប្រាប់យើងថា ទីនេះជាជំរំដុសខាត់ខួរក្បាលចំពោះអ្នកដែលមានជំហរមិនច្បាស់លាស់ចំពោះមាគ៌ាបដិវត្តន៍ ។ ចំពោះអ្នកណាដែលមានជាប់និន្នាការខ្មាំងស៊ីរូងផ្ទៃក្នុងត្រូវលត់ដំអត្តចរិត និងគោលជំហរបដិវត្តន៍ ហើយត្រូវកសាងខ្លួនឲ្យបានល្អ ព្រោះថាទាំងអស់គ្នាគឺជាអាយ៉ងយួនប្តូក្បាលយួនខ្លួនខ្មែរ ។ សមមិត្តបានប្រាប់ថា បច្ចុប្បន្ននេះ ខ្មាំងយួនកំពុងចាត់តាំងចារកម្មផ្ទៃក្នុងឲ្យមកបំផ្លាញបដិវត្តន៍ ដូច្នេះបក្សត្រូវតែប្រយុទ្ធតបតវិញតាមគ្រប់វិធី ។ ក៏ប៉ុន្តែដោយសារមាគ៌ាដឹកនាំរបស់បក្សដ៏មហាអស្ចារ្យ មហាភ្លឺស្វាង ទើបបានជារកឃើញនូវបណ្តាញចារកម្មរបស់ខ្មាំងហើយកម្ទេចទាន់ពេលវេលា ។

សមមិត្តបានប្រាប់យើងថា តាស៊ី អតីតគណៈភូមិភាគបស្ចិមនិងបក្សពួកដូចជា តាវេង ព្រមទាំងអ្នកដទៃទៀតត្រូវបានបក្សកម្ទេចអស់ហើយ ។ សមមិត្តបានបញ្ចប់ដោយផ្តាំផ្ញើថា មិត្តទាំងអស់ត្រូវលត់ដំគោលជំហរឲ្យដូចជាដែកថែប ដើរតាមមាគ៌ាដឹកនាំរបស់បក្សឲ្យបានត្រឹមត្រូវ ។

**(នៅមានត)**

**ឆាយ ស៊ីឆាត្រ**

# ខ្សែភាពយន្តឯកសាររឿង «ក្បង់ទឹកទន្លេ»

“ក្បង់ទឹកទន្លេ” គឺជាខ្សែភាពយន្តឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលទទួលបានការគាំទ្រ និងទិដ្ឋាការពីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។ មកដល់ពេលនេះ ខ្សែភាពយន្ត “ក្បង់ទឹកទន្លេ” ទទួលបានពានរង្វាន់លំដាប់ពិភពលោកចំនួន១២ហើយ ។ “ក្បង់ទឹកទន្លេ” បង្ហាញនូវដំណើរជីវិតមួយដ៏វិសេសវិសាល និងមិនធ្លាប់មានពីមុនមក ដែលផ្តើមចេញពីតំបន់ជនបទ ចុងកាត់មាត់ញកព្រៃភ្នំ និងភូមិនេសាទនៅលើផ្ទៃទឹករបស់តួអង្គទាំងបី ។ ខ្សែភាពយន្តនេះបានចាក់បញ្ចាំងនៅសារមន្ទីរសិល្បៈទំនើប សហរដ្ឋអាមេរិក ចាប់ពីថ្ងៃទី១២ ដល់ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៣ និងប្រទេសអូទ្រីស បែលហ្ស៊ិក អាឡឺម៉ង់ កូរ៉េខាងត្បូង អ៊ីតាលី និងប្រទេសអង់គ្លេស ។ ខ្សែភាពយន្តឯកសារនេះ ក៏គ្រោងនឹងដាក់បញ្ចាំងតាមសាកលវិទ្យាល័យ និងភូមិចំនួន៦០ ទូទាំងប្រទេសកម្ពុជាដើម្បីបើកឲ្យមានការពិភាក្សាស្តីពីការផ្លាស់ប្តូរបរិស្ថាន ដើម្បីស្វែងរកដំណោះស្រាយ ។

ខ្សែភាពយន្តនេះក៏មានចាក់បញ្ចាំងជូនទស្សនារៀងរាល់ថ្ងៃសុក្រនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ។

ព័ត៌មានបន្ថែមសូមទាក់ទង កញ្ញា សា ហ្វាទីលី តាមរយៈទូរស័ព្ទលេខៈ ០១២ ៥១១ ៩១៤ ។

អ៊ីម៉ែល : *truthfatily.s@dccam.org* គេហទំព័រ : *www.ariverchangescourse.com*





# គ្រួសារឪពុកខ្ញុំពីឆ្នាំ១៩៧៥ដល់១៩៧៩

ខ្មែរក្រហមបានសម្លាប់ប្រជាជនប្រមាណជិតពីរលាននាក់ ដោយការធ្វើទារុណកម្មយ៉ាងព្រៃផ្សៃ ការបង្អត់អាហារ ការបង្ខំឲ្យធ្វើការងារហួសកម្លាំង ។ ទិដ្ឋភាពតក់ស្លុត ភ័យខ្លាចដែលមិនធ្លាប់កើតមានឡើងនេះបានដក់ជាប់ក្នុងអារម្មណ៍គ្រួសាររបស់ខ្ញុំ និងជាពិសេសប្រជាជនកម្ពុជាដែលធ្លាប់ឆ្លងកាត់របបនេះ ។ ប៉ុន្តែជារឿងសំណាងរបស់ខ្ញុំ ដែលមានឪពុកម្តាយ និងបងប្អូនរួចរស់ជីវិតពីរបបឃោរឃៅមួយនេះ ។ ខ្ញុំចង់ដឹងពីរបបនេះឲ្យកាន់តែច្បាស់ថែមទៀត ។ ការយល់ដឹងនិងការរៀនសូត្រពីរបបខ្មែរក្រហមបានធ្វើឲ្យខ្ញុំសម្រេចចិត្តសរសេរអត្ថបទអំពីជីវិតរបស់ឪពុកខ្ញុំក្នុងព្រឹត្តិការណ៍ឆ្នាំ១៩៧៥-១៩៧៩ ដែលប្រជាជនគ្រប់រូបហៅថា "របបខ្មែរក្រហម ឬ របបកម្ពុជាប្រជាធិបតេយ្យ" ។


នីកូឡា ថតជាមួយឪពុកម្តាយនៅខេត្តសៀមរាប (រូបថត គ្រួសាររបស់ នីកូឡា)

ឪពុករបស់ខ្ញុំឈ្មោះ យ៉ាន់ សំអូន ។ គាត់មានបងប្អូនទាំងអស់បីនាក់ ហើយគាត់ជាកូនច្បងនៅក្នុងគ្រួសារដែលមានជីតាឈ្មោះ យ៉ាន់ វិត និងយាយ នុត សំអុល ។ នៅពេលដែលយោធាខ្មែរក្រហមចូលមកដល់ទីក្រុងភ្នំពេញភ្លាម គ្រួសារឪពុកខ្ញុំត្រូវខ្មែរក្រហមជម្លៀសពីភូមិចំបក់ ឃុំសៀមរាប ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ឲ្យទៅរស់នៅភូមិទួលក្រូច ឃុំស្អាងភ្នំ ស្រុកស្អាង ខេត្តកណ្តាល ។ នៅពេលនោះ ជីតារបស់ខ្ញុំគឺជាអ្នករកស៊ីរត់ពន្ធទំនិញពីស្រុកមួយទៅស្រុកមួយទៀតមាន ដូចជា របស់របរប្រើប្រាស់ ចំណីអាហារ និងផ្លែឈើ ។ នៅទីនោះ ជីតាខ្ញុំបានជាប់គុកនៅវត្តទំពែកពីបទជាប់ពាក់ព័ន្ធជាមួយសេ.អ៊ី.អា របស់ លន់ នល់ ប្រមាណជាបីខែ ទើបកងរំដោះខ្មែរក្រហមដោះលែងគាត់វិញ ។

ក្រោយពីដោះលែងជីតាខ្ញុំ អ្នកយាមគុកនៅទីនោះ បានប្រាប់គាត់ឲ្យយកប្រពន្ធកូនចេញពីភូមិដែលកំពុងរស់នៅជាបន្ទាន់ ដោយឲ្យគាត់ត្រឡប់មករស់នៅភូមិកំណើត (ភូមិចំបក់) វិញ ។ បន្ទាប់មក ខ្មែរក្រហមក៏ចាប់ធ្វើជំរឿនតាមគ្រួសារនីមួយៗ ។ កុមារដែលមានអាយុប្រហែលប្រាំមួយឆ្នាំត្រូវខ្មែរក្រហមបញ្ជូនឲ្យទៅនៅកងកុមារ រីឯអ្នកដែលមានវ័យធំៗ អង្គការបានបញ្ជូលទៅកងយុវជនដើម្បីធ្វើការបម្រើអង្គការថ្នាក់លើ ។

ឪពុករបស់ខ្ញុំដែលទើបមានអាយុទើបតែ៦ឆ្នាំ ត្រូវអង្គការបញ្ចូលទៅកងកុមារនៅភូមិរាយដប ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល និងឲ្យស្នាក់នៅសាលារៀន រីឯប្អូនគាត់ទាំងពីរនាក់ទៀតដែលនៅតូចៗអង្គការមិនបានឲ្យធ្វើការងារទេ ។ យាយតាខ្ញុំលើកទំនប់ទឹកជីកប្រឡាយ និងលើកភ្លឺស្រែ ។ ចំណែកយាយទួតខ្ញុំនៅផ្ទះមើលថៅ ហើយតាទួតធ្វើការនៅរោងសិប្បកម្មធ្វើនង្គ័ល និងរនាស់រាស់ដី ។ បន្ទាប់ពីគ្រួសារឪពុកខ្ញុំធ្វើការមិនបានប៉ុន្មានខែផង ខ្មែរក្រហមចាប់ផ្តើមប្រកាសរកអ្នកចេះដឹងខ្ពង់ខ្ពស់ និងអ្នកដែលធ្លាប់ធ្វើការសម័យ លន់ នល់ ដើម្បីបម្រើអង្គការ ។ ប្រជាជនដែលខ្មែរក្រហមប្រមូលបាន ត្រូវយកទៅរៀនសូត្រនៅឯស្រុកផ្សេងទៀត ប៉ុន្តែ

តាំងពីពេលនោះមក ឪពុករបស់ខ្ញុំមិនដែលឃើញអ្នកទាំងនោះត្រឡប់មកវិញទេ ។

ក្រោយមក អង្គការបានឲ្យឪពុកខ្ញុំចូលមកធ្វើការនៅក្នុងសហករណ៍វិញ ។ អង្គការចែកបង្គី កណ្តៀវ កាំបិតពន្លាក ចបកាប់ ឲ្យទៅជីកអន្លង់ដើម្បីស្តុកជីធម្មជាតិ ហើយអ្នកខ្លះទៀត អង្គការបញ្ជាឲ្យធ្វើការងារផ្សេងៗ ។ ក្រៅពីនោះ ខ្មែរក្រហមបញ្ជាឲ្យគាត់ដកស្មៅក្នុងស្រែ នៅពេលដែលសន្ទូងបែកគុម្ព យាមសត្វនៅពេលដែលស្រូវចាប់ផ្តើមដាក់គ្រាប់និងកម្ចាត់សត្វទាំងឡាយណាដែលបំផ្លាញស្រូវ ដូចជា ដង្កូវ កណ្តូប ចាប និងកណ្តុរ ដែលសត្វទាំងនេះត្រូវបានចាត់ទុកជាខ្មាំងរបស់អង្គការ ។

ទន្ទឹមនឹងនេះដែរ ឪពុកខ្ញុំបានឃើញខ្មែរក្រហមដាក់ច្រវាក់ជើងបុរសម្នាក់ឲ្យនៅលើផ្ទះម្នាក់ឯងដោយបង្អត់អាហារ ហើយក៏គ្មាននរណាហ៊ានយកបាយទឹកឲ្យដែរព្រោះខ្លាចអង្គការចោទជាខ្មាំងទៀត ។ បុរសម្នាក់នោះឈ្មោះ ជ័យ ត្រូវបានអង្គការចោទប្រកាន់ថាជាមនុស្សខ្ជិលច្រអូស មិនធ្វើការងារ ហើយថែមទាំងខស្បារ៉ាប់ឈើទន្សាយជារឿយៗទៀតផង ។

មកដល់រដូវច្រូតស្រូវរួច អង្គការបានបញ្ជាឲ្យកុមារទាំងអស់ទៅរស់នៅក្បែរវត្តវិហារកំបោរ ភូមិកណ្តោក ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល និងបានបែងចែកជាក្រុម ដែលក្នុងមួយក្រុមមានសមាជិកដប់នាក់ ។ សមាជិកទាំងអស់ត្រូវហូបបាយជុំគ្នាតាមក្រុម ដោយអង្គការតែងតាំងឈ្មោះ ចិន ជាមេក្រុមដែលសមាជិកក្នុងកងទាំងអស់តែងហៅគាត់ថា “មិត្តបងចិន” ។

ការងាររបស់ឪពុកខ្ញុំ និងក្មេងៗទាំងអស់គឺកាប់ដើមទន្ទ្រានខែត្រ លើកភ្លឺស្រែ ។ ក្រោយពេលហូបបាយថ្ងៃត្រង់ គាត់ត្រូវមករៀនអក្សរនៅក្រោមដើមអំពិលធំមួយដែលមានគ្រូឈ្មោះ ឡោ ជាអ្នកបង្រៀន ។ ឪពុកខ្ញុំតែងតែអង្គុយរៀនបិទភ្នែកដោយសារ



នីកូឡា (ទីពីររាប់ពីស្តាំ) ថតជាមួយឪពុកម្តាយ និងប្អូនប្រុស នៅមុខប្រាសាទអង្គរវត្ត ក្នុងឆ្នាំ២០០៦ ។ (រូបថត គ្រួសាររបស់ នីកូឡា)

តែគាត់អស់កម្លាំង និងហូបមិនឆ្អែត ។ ពេលខ្លះខ្មែរក្រហមឲ្យកងរបស់ឪពុកខ្ញុំហូបបបរលាយជាមួយដំឡូងជ្វា ហើយពេលខ្លះបាយលាយគ្រាប់ពោត ដែលស្ទើរតែគ្មានគ្រាប់បាយទាល់តែសោះ ។

រៀងរាល់យប់ ឪពុករបស់ខ្ញុំតែងតែរត់ទៅរកយាយទូតខ្ញុំដើម្បីយកបាយក្តាំងមកហូប ពីព្រោះយាយទូតខ្ញុំគឺជាអ្នកចិញ្ចឹមជ្រូក ហើយគាត់តែងតែលាក់ទុកឲ្យឪពុកខ្ញុំនិងចៅៗផ្សេងទៀត ។ នៅទីនោះ ឪពុកខ្ញុំបានឃើញបុរសបីនាក់ត្រូវខ្មែរក្រហមចាប់ដាក់ច្រវាក់ជើងទុកក្នុងចេតិយ៍ ។ អ្នកទោសនោះបានស្រែកហៅប្រជាជនឲ្យយកទឹកឲ្យផឹក តែគ្មាននរណាម្នាក់ហ៊ានជួយទេដោយសារតែខ្លាចខ្មែរក្រហមឃើញ ។

ឪពុកខ្ញុំរៀបរាប់ថា ពេលគាត់ទៅជួបយាយតា និងយាយទូត គាត់តែងត្រឡប់មកវិញជាមួយបាយក្តាំង និងចែកឲ្យអ្នកនៅក្នុងក្រុមហូបជាមួយគ្នាដើម្បីឲ្យជួយលាក់ការណ៍ កុំឲ្យមិត្តបងចិនដឹង ។ អ្នកនៅក្នុងកងទាំងអស់លាក់ការណ៍បានល្អណាស់ ។

នៅយប់មួយ ឪពុកខ្ញុំបានទៅរកយាយទូតជាមួយមិត្តរបស់គាត់ឈ្មោះ ឈាង ។ នៅពេលត្រឡប់មកវិញ គាត់ក៏ឮសំឡេងខ្មែរក្រហមដើរឆ្លងកាត់ ដូច្នេះហើយគាត់ទាំងពីរនាក់ក៏លូនចូលទៅដេកក្នុងគុម្ពស្រូវអស់មួយយប់ ។ នៅពេលព្រឹកប្រហែលម៉ោងប្រាំជិតភ្លឺ ខ្មែរក្រហមក៏វាយជួងដើម្បីឲ្យសមាជិកទាំងអស់គ្នាទៅហូបបបរដើម្បីចេញទៅធ្វើការងារ ។ ឮដូច្នេះ ឪពុកខ្ញុំរត់ទៅពួននៅឯគុម្ពស្រូវ ជិតផ្លូវដើរដើម្បីបន្លំចូលជួរ ។ តែចៃដន្យនៅយប់នោះមិត្តបងចិន បានចុះទៅត្រួតពិនិត្យនៅតាមខ្ទម ហើយមិនបានឃើញឪពុកខ្ញុំទេ ។ មិត្តបងចិន បានវាយទាត់និងទះកំផ្លៀងឪពុកខ្ញុំ រួចព្រមានឪពុកមិនឲ្យធ្វើរឿងនេះជាលើកទីពីរ ។ នៅពេលនោះដែរ ជីតាខ្ញុំក៏បានឃើញឪពុកខ្ញុំត្រូវខ្មែរក្រហមវាយដែរ តែគាត់មិនហ៊ានជួយ ។

ក្រោយមកទៀត គណៈកងបានចោទឪពុកខ្ញុំថាខុសសីលធម៌ជាមួយមីងសុណារី នៅពេលគាត់ហុចត្រីឆ្អិនមួយឲ្យឪពុកខ្ញុំនៅក្រោមដើមអំពិលបារាំងក្បែរវត្តវិហារកំបោរ ។ ព្រមជាមួយនោះ គណៈកងចោទឪពុកខ្ញុំទៀតថា បានលួចគេចខ្លួនទៅរកយាយដើម្បីយកបាយក្តាំងស៊ី រត់គេចពីកងឈ្លបទៅដេកក្នុងវាលស្រែ ។

ដោយសារតែភាពស្រេកឃ្លានពេក ឪពុកខ្ញុំតែងរកឱកាសលួចទៅរកយាយទៀត ។ ជីតារបស់គាត់បានកាត់ស្បែកជើងកង់ឡានឲ្យឪពុករបស់ខ្ញុំពាក់ នៅពេលឪពុកខ្ញុំស្អាត់ទៅជួបគាត់ ។ ឪពុកខ្ញុំពាក់ស្បែកជើងរបស់គាត់បានមួយថ្ងៃ ក៏កូនកម្មាភិបាលម្នាក់ឈ្មោះ ម៉ុត ចោទគាត់ថាលួចស្បែកជើងរបស់គាត់ដែលបាត់ ។ ម៉ុត បានយកកាំបិតពន្លាកដេញកាប់ឪពុកខ្ញុំ តែចៃដន្យតារបស់គាត់ជួយទាន់ពេលវេលា ដោយគាត់យកដងពូថៅវាយ ម៉ុត ដែលធ្វើឲ្យ ម៉ុត ចាប់ផ្តើមមានគំនុំជាមួយឪពុករបស់ខ្ញុំកាន់តែខ្លាំង ។

លុះក្រោយមកខ្មែរក្រហមប្តូរឲ្យឪពុកខ្ញុំទៅភូមិស៊ីង ក្នុងឃុំព្រៃស្វា ព្រំប្រទល់ខេត្តតាកែវ ដោយឲ្យក្មេងៗដកស្មៅតាមវាលស្រែ ។ មកដល់ទីនេះ ឪពុកខ្ញុំក៏លួចហូបស្រូវដើម តែត្រូវបានកម្មាភិបាលខ្មែរក្រហមឈ្មោះមិត្តជីន លួចរាយការណ៍ទៅអង្គការ ។ ខ្មែរក្រហមក៏ចាត់ឈ្លបមកយកឪពុកខ្ញុំទៅកសាងទាំងកណ្តាលអាគ្រាត ប៉ុន្តែសំណាងល្អឈ្លបទាំងនោះមិនបានសម្លាប់គាត់ ។ កងឈ្លបបានដាក់ទារុណកម្មឪពុកខ្ញុំឲ្យរែកទឹកនៅត្រពាំងរលួសចម្ងាយរាប់រយម៉ែត្រពីសហករណ៍ ។ លើកទីពី ឪពុកខ្ញុំរើសផ្លែព្រីងយកមកហូបក៏ត្រូវខ្មែរក្រហមចោទថា គាត់ក្បត់សមូហភាព ហើយបានព្រមានគាត់មិនឲ្យប្រព្រឹត្តិលើកទីបីទៀត ។ ដោយសារតែការស្រេកឃ្លាន ឪពុកខ្ញុំបានដើរវាយកណ្តុរដែលជាខ្មាំងបំផ្លាញស្រូវ តែចៃដន្យគាត់ជុំក្លិនក្រអូបត្នោតទុំ ទើបឪពុកខ្ញុំសម្រេចចិត្តឡើងបេះ ។ ប៉ុន្តែជាអកុសល គាត់ធ្លាក់ពីលើដើមត្នោតដោយពោះរបស់គាត់មុតយ៉ាងជ្រៅជាមួយនឹងធាងត្នោត ។ ឪពុកខ្ញុំមិនសង្ឃឹមថានឹងរស់ទេ ហើយដោយខ្លាច មិត្តវ៉ាន់ រាយការណ៍រឿងនេះប្រាប់អង្គការ ទើបគាត់កុហកអង្គការថា គាត់ឡើងដើមត្នោតវាយកណ្តុរ ព្រោះឃើញកណ្តុរឡើងដើមត្នោត ។

ឪពុកខ្ញុំត្រូវខ្មែរក្រហមយកទៅព្យាបាល ហើយបន្ទាប់មកអង្គការបានចាប់ផ្តើមបើកអង្គប្រជុំ ។ អង្គការបានលើកឈ្មោះឪពុកខ្ញុំថា កុមារគំរូ ធ្វើការយ៉ាងសកម្ម ក្លាហាន ហ៊ានឡើងវាយខ្មាំងកណ្តុរដែលជាសត្រូវរបស់អង្គការ រហូតដល់មានរបួសខ្លួនឯងដូចនេះ សមមិត្តនេះមានស្នាដៃល្អត្រូវបានអង្គការឲ្យសម្រាកព្យាបាលនិងទទួលបានរបបអាហារមួយចំនួនសម្រាប់ហូបបន្ថែម ។

ក្រោយពីត្រឡប់មកពីប្រមូលផលស្រូវវិញ ឪពុកខ្ញុំក៏មករស់នៅវត្តវិហារកំបោរវិញ ។ ខ្មែរក្រហមចាប់ផ្តើមហាមមិនឲ្យ

ឪពុកខ្ញុំជួបជាមួយឪពុកម្តាយ និងបានបង្ហាត់គាត់ឲ្យដាំដំឡូង ។ ប៉ុន្តែទោះបីជាមានការហាមឃាត់យ៉ាងណា ក៏គាត់នៅតែទៅជួបយាយនៅឯកសិដ្ឋានចិញ្ចឹមជ្រូកដើម្បីយកបាយក្តាំងហូប ។ ឃើញដូច្នេះ អង្គការបានតាមដានដើម្បីចាប់គាត់យកដាក់ក្នុងចេតិយ៍ដូច ប៉ូវ៉ា និងជ័យ ។ សំណាងល្អ នៅពេលនោះ ឪពុកខ្ញុំបានជួបនឹងមិត្តភក្តិរបស់គាត់គឺ មិត្តឈាង និង មិត្តអិត ធ្វើឲ្យគាត់សប្បាយរីករាយយ៉ាងខ្លាំង ប៉ុន្តែទន្ទឹមនឹងនោះដែរ មិត្តភក្តិរបស់គាត់ទាំងពីរបានប្រាប់គាត់ឲ្យភៀសខ្លួនចេញពីកងកុមារជាបន្ទាន់ ។ ឪពុកខ្ញុំបានរត់ទៅរកតាទួតឲ្យជួយ ព្រោះគាត់មិនដឹងថាគេចខ្លួនទៅទីណាទេ ។

នៅអំឡុងឆ្នាំ១៩៧៨ តាទួតរបស់ខ្ញុំត្រូវខ្មែរក្រហមបញ្ជូនមកភ្នំពេញដើម្បីស្វែងរកកូនប្រុសរបស់គាត់ដែលចូលបំរើយោធាខ្មែរក្រហមជាមួយនឹងប្រជាជនមួយចំនួនទៀតតាមឡាន ។ ឪពុករបស់ខ្ញុំបានឱកាសរត់ឡើងឡានជាមួយតាទួតដើម្បីគេចចេញពីកងកុមារ ។

ពេលចូលមកដល់ផ្សារថ្មី ស្រាប់តែក្រឡាប់ឡានធ្វើឲ្យអ្នកជិះទាំងអស់ត្រូវរបួសគ្រប់ៗគ្នា ។ ឪពុកខ្ញុំ និងតារបស់គាត់ត្រូវយោធាខ្មែរក្រហមម្នាក់ឃើញមុខជីតារបស់ខ្ញុំដូចនឹងឪពុករបស់គេ ទើបគេបញ្ជូនទៅពេទ្យធំដើម្បីព្យាបាល ដោយពេលនោះយោធាផ្សេងបាននិយាយថា គាត់ទាំងពីរពិតជាសំណាងណាស់ដែលបានមកដេកនៅពេទ្យធំ ។ នៅទីនោះ ឪពុកខ្ញុំតែងតែដើរលេងតាមមាត់ទន្លេ ព្រោះគេចពីការចាក់ថ្នាំ ។ ថ្ងៃមួយគាត់បានឃើញកាណូតដឹកឡានទ្រុងជាច្រើនគ្រឿងដែលមានប្រជាជនជិះលើពេញមកចតនៅប្រាំងទន្លេ និងមានឡានហ្ស៊ីបទាហានបើកនាំមុខតាមមាត់ទន្លេមកទិសខាងត្បូង ហើយប្រជាជនទាំងនោះស្រែកទ្រហោយំគ្រប់គ្នា ។ ឪពុកខ្ញុំបានលួចមើលតាមគុម្ពោត បន្ទាប់មកគាត់ក៏ទៅសួរយោធាខ្មែរក្រហមដែលដេកក្នុងមន្ទីរពេទ្យថា ហេតុអ្វីបានជាប្រជាជនទាំងនោះស្រែកយំនៅពេលឡើងឡានទ្រុង តែយោធានោះមិនបានប្រាប់អ្វីទេ ។ ទាហាននោះបានប្រាប់ឪពុកខ្ញុំកុំឲ្យទៅទីនោះទៀត ។ ស្នាក់នៅពេទ្យធំនោះអស់មួយរយៈ ឪពុករបស់ខ្ញុំក៏ក្លាយជាគ្រូពេទ្យវ័យក្មេង ព្រោះគាត់នៅទីនោះជួយការងាររបស់ពេទ្យរហូតគាត់ដឹងពីវិធីព្យាបាលស្រាលៗ ។

ក្រោយមក ឪពុកខ្ញុំក៏ឮដំណឹងថាវៀតណាមនឹងវាយចូលភ្នំពេញក្នុងរដូវប្រូតកាត់ ។ ដូច្នេះ អង្គការបានជម្លៀសកម្មាភិបាលខ្មែរក្រហម ពេទ្យទាហាន និងអ្នកជំងឺទាំងអស់ចេញពីទីក្រុងភ្នំពេញ ។ ឪពុកខ្ញុំបានធ្វើដំណើរទៅតាមផ្លូវពោធិ៍ចិនតុង រួចបត់ទៅស្រុកកណ្តាលស្ទឹង ។ យាយតាខ្ញុំ និងអ្នកភូមិបានគិតថាឪពុកខ្ញុំស្លាប់បាត់ហើយ ព្រោះប្រជាជនប្រាប់គាត់ថា “អ្នកផ្សេងទៀតដែលជិះឡានដំណាលឪពុកខ្ញុំត្រូវអង្គការយកទៅសម្លាប់អស់ហើយ” ។

នៅពេលនោះ ឪពុករបស់ខ្ញុំ បានជួបមិត្តសម្លាញ់គាត់ឈ្មោះអិត ដែលទើបតែរត់គេចពីកងកុមារមកផ្ទះដើម្បីរកឪពុកម្តាយរបស់គាត់ ។ ឪពុកខ្ញុំដើរបណ្តើររត់បណ្តើរដើម្បីរួសរាន់ទៅប្រាប់បងប្អូននិងឪពុកម្តាយរបស់គាត់ទាំងពីរកុំឲ្យទៅហូបនំបញ្ចុកព្រោះគាត់ទទួលដំណឹងពីទាហានម្នាក់ថា ក្រោយពេលហូបនំបញ្ចុករួច ខ្មែរក្រហមនឹងយកទៅសម្លាប់ចោលទាំងអស់មិនខាន ។ នៅពេលរសៀល ពេលកំពុងដើរ ស្រាប់តែឪពុកខ្ញុំឮសំឡេងគ្រាប់ផ្លោងពីចម្ងាយនិងឃើញឡានដឹកយោធាខ្មែរក្រហមជាច្រើនមកពីផ្លូវជាតិលេខ២ចេញពីភ្នំពេញមកវិញ ។ ឡានទើបតែបើកផុតបន្តិច ក៏មានរថក្រោះបើកដេញពីក្រោយចេញពីវាលស្រែមកលើផ្លូវជាតិ ។ ឪពុកខ្ញុំភ័យយ៉ាងខ្លាំង ហើយក៏រត់សំដៅទៅរកជីតា ។ ឪពុកខ្ញុំរត់ទៅមុខរហូតទៅជួបប្រជាជននិងឪពុកម្តាយគាត់នៅក្នុងរណ្តៅគ្រាប់បែមួយនៅភូមិពោធិ៍ព្រៃ រីឯគ្រាប់បន្តផ្លោងតាមក្រោយគាត់រហូត ។ មនុស្សមួយចំនួនស្លាប់ និងបែកបាក់គ្រួសារនៅពេលនោះ ។

ឪពុកខ្ញុំរត់គេចខ្លួនអស់រយៈពេលពីរថ្ងៃ ទើបមកជួបជុំក្រុមគ្រួសារនៅស្រុកកំណើតវិញ ។ សព្វថ្ងៃឪពុករបស់ខ្ញុំនៅតែមានអារម្មណ៍ខ្លាចសង្គ្រាមនិងភាពអសន្តិសុខ ។ បច្ចុប្បន្ន យាយទួតខ្ញុំតែងតែយកបាយក្តាំងឲ្យឪពុកខ្ញុំ និងពូមីងខ្ញុំជានិច្ច ។ បាយក្តាំងក៏ជាអ្នករួមចំណែកធ្វើឲ្យឪពុកខ្ញុំរស់រានមានជីវិតរហូតដល់សព្វថ្ងៃដែរ ។ **យ៉ាន់ នីភូឡា**

- ◆ **និយាយពីការរស់នៅក្នុងសម័យខ្មែរក្រហម គឺនិយាយពីការផ្សះផ្សា អប់រំកូនចៅឱ្យអត់ឱន អធ្យាស្រ័យគ្នា**
- ◆ **រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ គឺរៀនពីការទប់ស្កាត់អំពើប្រល័យពូជសាសន៍**

# គំនិតក្មេងជំនាន់ក្រោយមួយរូបទាក់ទង នឹងសាលាក្តីខ្មែរក្រហម

នៅពេលមានការនិយាយអំពីការជំនុំជម្រះក្តីខ្មែរក្រហមម្តងៗ សំណួរជាច្រើនត្រូវបានលើកមកនិយាយដូចជា តើអ្វីជាភាពចាំបាច់របស់អង្គជំនុំជម្រះចំពោះអ្នកដែលរស់រានមានជីវិតក្រោយរបបខ្មែរក្រហមចំពោះប្រជាជនកម្ពុជា និងចំពោះជាតិទាំងមូល? ហើយថា តើការកាត់ក្តីនេះពិតជានាំមកនូវយុត្តិធម៌មែនឬទេ? បុគ្គលម្នាក់ៗតែងតែមានគំនិតផ្សេងៗគ្នា ។ តាមការយល់ឃើញជាប្រវត្តិសាស្ត្រនោះ រាល់អ្វីដែលបានកើតឡើង ហើយនឹងបន្តកើតឡើងនៅអង្គជំនុំជម្រះក្តីដើរតួនាទីយ៉ាងសំខាន់នៅក្នុងប្រវត្តិសាស្ត្រកម្ពុជាបច្ចុប្បន្ន ។

តុលាការខ្មែរក្រហម គឺពិតជាមានសារសំខាន់ ដោយសារតែតុលាការនេះនាំមកនូវការស្វែងរកការពិតជូនជាតិ ជនរងគ្រោះដើម្បីរំពុកអតីតកាល ធ្វើការផ្សះផ្សានិងព្យាបាល ។ ទាំងនេះជាអ្វីដែលតុលាការខ្មែរក្រហមធ្វើបាន ។ គួរបញ្ជាក់ដែរថា ករណីសំណុំរឿង០០១ បានបញ្ចប់ទៅដោយមានការដាក់ទោសឲ្យជាប់គុកមួយជីវិតចំពោះ កាំង ហ្គេចអ៊ាវ ហៅ ឌុច ដែលធ្លាប់កាន់កាប់នៅគុកទួលស្លែងឬមន្ទីរស-២១ ។ ការកាត់ទោសនេះ បើកចំហជាផ្លូវការដើម្បីឲ្យជនរួមជាតិទាំងអស់ស្វែងរកបាននូវយុត្តិធម៌នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដែលបានបំផ្លាញជីវិតរស់នៅរបស់ប្រជាជនកម្ពុជាទាំងមូល ។ ស្របពេលនេះដែរ ករណីសំណុំរឿង០០២រឹតតែមានសារសំខាន់ ដោយសារតែជនជាប់ចោទទាំង



ស្រីនាថ ភូល ថតនៅសហរដ្ឋអាមេរិក

អស់ពាក់ព័ន្ធដោយផ្ទាល់ទៅនឹងការអនុវត្តនូវគោលនយោបាយសម័យកម្ពុជាប្រជាធិបតេយ្យនាំឲ្យជួបវិបត្តិសម្រាប់មនុស្សប្រមាណជា១.៧លាននាក់ ។ ចំនួនទឹកប្រាក់ដែលបានចំណាយ ចាប់តាំងពីបង្កើតសាលាជំនុំជម្រះក្តីក៏បង្ហាញឲ្យឃើញថាមានចំនួនច្រើនដែរ ។ រហូតមកដល់ថ្ងៃនេះ ចំនួនទឹកប្រាក់សរុបដែលបានចំណាយមានជាង ២០៨លានដុល្លា ចាប់តាំងពីឆ្នាំ២០០៦ បង្ហាញឲ្យឃើញថា រាល់ភាគីទាំងអស់មានឆន្ទៈក្នុងការផ្តល់ជំនួយដល់សាលាជំនុំជម្រះក្តីដូច្នេះទើបអាចទទួលបាននូវយុត្តិធម៌ ។

ដោយសារតែបុគ្គលនីមួយៗមិនមានគំនិតដូចគ្នា ម្តាយរបស់ខ្ញុំយល់ឃើញចំពោះសាលាជំនុំជម្រះក្តីថា មិនមែនតែអ្នកធ្វើការនៅអង្គជំនុំជម្រះវិសាមញ្ញនោះទេដែលត្រូវការស្តាប់រឿងរ៉ាវទាំងអស់នេះ ។ ម្តាយរបស់ខ្ញុំក៏ជាជនរងគ្រោះម្នាក់នៅក្នុងរបបខ្មែរក្រហម ហើយគាត់គឺជាកូនស្រីតែម្នាក់ដែលមានអាយុតែប្រាំមួយឬប្រាំពីរឆ្នាំក្នុងរបបនោះ ហើយគាត់សំណាងដែលមិនត្រូវបានគេបំបែកចេញពីម្តាយ ដូចក្មេងៗដទៃទៀតជួបប្រទះនោះទេ ។

នៅក្នុងការសន្ទនាជាច្រើនជាមួយនឹងគាត់អំពីអង្គជំនុំជម្រះក្តី ម្តាយខ្ញុំបានប្រាប់ពីអារម្មណ៍ថា គាត់មិនសូវជាយកចិត្តទុកដាក់ចំពោះនឹងការជំនុំជម្រះក្តីនេះប៉ុន្មានទេ ។ គាត់ប្រាប់ខ្ញុំថា គាត់មិនបានដឹងអំពីសាលាជំនុំជម្រះក្តីខ្មែរក្រហម ហើយដោយសារហេតុនេះហើយបានជាគាត់មិនបានយកចិត្តទុកដាក់លើការកាត់ក្តីនេះ ។ ខ្ញុំសឹងតែមិនជឿលើអ្វីដែលគាត់បានប្រាប់ព្រោះថា ម្តាយរបស់ខ្ញុំតែងតែតាមដាននូវព័ត៌មានក្នុងតំបន់ចុះហេតុអ្វីបានជាគាត់បែរជាមិនដឹងអំពីការជំនុំជម្រះក្តីទៅវិញ ។ ទោះជាគាត់ប្រាប់ថាគាត់មិនបានតាមដានការជំនុំជម្រះក្តីក៏ដោយ តែគាត់ពិតជានិយាយថា គាត់មិនជឿថា ការជំនុំជម្រះក្តីពិតជានាំមកនូវលទ្ធផលដែលគួរចង់បាននោះទេ ។ ម្តាយខ្ញុំក៏ប្រាប់ខ្ញុំផងដែរថា យើងបានចំណាយពេលវេលាយូរពេកហើយចំពោះការជំនុំជម្រះក្តីនេះ ហើយយើងក៏បានចំណាយលុយច្រើនណាស់ដែរ តែមិនទាន់មានលទ្ធផលអ្វីគួរឲ្យពេញចិត្តសោះ ។ ដោយយល់ពីហេតុផលរបស់ម្តាយ ខ្ញុំក៏បន្តសួរគាត់ទៀតថា តើគាត់គិតថាយើងពិតជាអាចរកយុត្តិធម៌បានមកពីការជំនុំជម្រះក្តីនេះដែរទេ គាត់ឆ្លើយភ្លាមថា “មិនអាចទេ” ។ លោកយាយម្នាក់ ដែលត្រូវជាប្អូនរបស់លោកយាយខ្ញុំបង្កើតបានចែករំលែកនូវគំនិតខុសប្លែកពីគ្នាទៅកាន់ម្តាយរបស់ខ្ញុំ ។ សព្វថ្ងៃនេះ គាត់មានអាយុជាង៩០ឆ្នាំហើយ ហើយបទពិសោធន៍របស់គាត់នៅក្នុងរបបខ្មែរក្រហមបានបន្សល់ទុកនូវការសម្តែងពីអារម្មណ៍យ៉ាងជ្រាលជ្រៅ ។ មិនខុសប្លែកពីរឿងរ៉ាវរបស់ប្រជាជនមួយចំនួនដែលបានរៀបរាប់ លោកយាយរបស់ខ្ញុំត្រូវបានជម្លៀសទៅខេត្តក្រចេះ ហើយត្រូវបង្ខំឲ្យធ្វើស្រែ ជីកប្រឡាយ និងលើកទំនប់ ។ ជីវិតគឺពិតជាលំបាកខ្លាំង ជាមេរៀនដែលធ្វើឲ្យជីវិតរបស់គាត់ប្រែប្រួលរហូតមកដល់សព្វថ្ងៃនេះ ។

លោកយាយខ្ញុំជាបុគ្គលម្នាក់ដែលគួរឲ្យសរសើរដោយសារតែគាត់សកម្មនៅក្នុងឆាកនយោបាយ គាត់គាំទ្រខ្លាំងក្លាលើយុត្តិធម៌សង្គម ។ ចាប់តាំងពីថ្ងៃដំបូងនៃការបើកសំណុំរឿង០០១ គាត់បានតាមដានរហូតមក ។ គាត់ជឿជាក់ថា ការជំនុំជម្រះក្តីគឺមានសារសំខាន់ណាស់សម្រាប់គាត់ និងប្រទេសជាតិរបស់គាត់ ។ គាត់យល់ថា សាលាជំនុំជម្រះក្តីនេះមានតួនាទីត្រួសត្រាយផ្លូវទៅរកយុត្តិធម៌ជូនប្រទេសជាតិ ។ ផ្ទុយទៅវិញ ដូចនឹងអ្វីដែលម្តាយរបស់ខ្ញុំបានលើកឡើងនៅខាងដើម លោកយាយរបស់ខ្ញុំគិតថា ដំណើរការរបស់សាលាក្តីនេះដើរយឺតពេកហើយ ហើយជនជាប់ចោទក៏កាន់តែចាស់ពីមួយថ្ងៃទៅមួយថ្ងៃ និងខិតចូលសេចក្តីស្លាប់ជាបណ្តើរៗ ។ គាត់បញ្ជាក់ពីការខកចិត្តពាក់ព័ន្ធនឹងការស្លាប់របស់ អៀង សារី និងការបញ្ឈប់ការដេញដោលចំពោះ អៀង ធីរិទ្ធិ ដោយយោងតាមលក្ខខណ្ឌផ្លូវចិត្តរបស់គាត់ ប៉ុន្តែគាត់បញ្ជាក់ដែរថា ដំណើរការនេះមិនអាចប្រញាប់ ប្រញាល់បានទេដោយសារតែពាក់ព័ន្ធនឹងដំណើរការច្បាប់ ។ តែគាត់នៅតែមានៈ ហើយពោលថា ការជំនុំជម្រះក្តីនេះមិនអាចផ្តល់យុត្តិធម៌១០០ភាគរយដល់គាត់ និងប្រជាជនកម្ពុជានោះទេ ។ ទោះបីជាអញ្ចឹងក៏ដោយ គាត់សង្ឃឹមថា ជនរងគ្រោះទាំងអស់នឹងមានសន្តិភាពផ្លូវចិត្តបានខ្លះ ហើយពេញចិត្តនឹងការសម្រេចរបស់តុលាការឆ្លុះបញ្ចាំងពីឧក្រិដ្ឋកម្មដែលជនជាប់ចោទបានប្រព្រឹត្ត ។ ការកាត់ទោស ឲ្យជាប់គុកអស់មួយជីវិតគឺជាអ្វីដែលគាត់សង្ឃឹមថាជនជាប់ចោទនឹងទទួល ។ ការជំនុំជម្រះក្តីដែលបន្សល់ទុកនូវអតីតមេដឹកនាំខ្មែរក្រហមពីររូបគឺមានសារសំខាន់ខ្លាំងណាស់សម្រាប់រូបគាត់ ប៉ុន្តែនេះគឺមិនទាន់គ្រប់គ្រាន់នោះទេ ។

គាត់ចង់ឲ្យសាលាជំនុំជម្រះក្ដីបន្ដការស៊ើបអង្កេតអ្នកដែលពាក់ព័ន្ធផ្ទាល់ទៅនឹង ការសម្លាប់មនុស្សនៅក្នុងតំបន់ក៏ដូចជាសហគមន៍ ។ គាត់ក៏ផ្ដល់ជាតម្រុយថាឲ្យនាំយកមកកាត់ទោសរាល់អ្នកពាក់ព័ន្ធទាំងអស់ ទោះជាអ្នកមានអំណាចក៏ដោយ ។ សារនេះគឺជាគន្លឹះមួយដែលរារាំងមិនឲ្យឧក្រិដ្ឋជនគេចផុតពីអំពើឃោរឃៅដែលខ្លួនបានប្រព្រឹត្ត និងជាគំរូដល់អ្នកដឹកនាំជំនាន់ក្រោយមិនឲ្យប្រព្រឹត្តអំពើព្រៃផ្សៃដូច្នេះ ដោយសារតែមានមធ្យោបាយផ្សេងៗនៅក្នុងការដាក់ទោសអ្នកដែល ប្រព្រឹត្តឧក្រិដ្ឋកម្ម ។

ជីតារបស់ខ្ញុំក៏បានចែករំលែកនូវមតិយោបល់ស្រដៀងទៅនឹងយាយរបស់ខ្ញុំដែរ ។ នៅពេលដែលខ្ញុំស្នើគាត់ឲ្យរៀបរាប់ពីគំនិតរបស់គាត់ គាត់ប្រាប់ខ្ញុំថា គាត់គាំទ្រយ៉ាងពេញទំហឹងចំពោះសាលាក្ដីខ្មែរក្រហម ហើយដូចជនរងគ្រោះផ្សេងទៀតក្នុងរបបខ្មែរក្រហមក៏ចង់ឃើញជនដែលធ្វើឲ្យគាត់រងទុក្ខវេទនាសក្ដិសមនឹងទទួលខុសត្រូវនូវអ្វីដែលអ្នកនោះបានប្រព្រឹត្ត ។

ខ្ញុំយល់ថា រឿងរ៉ាវរបស់តាខ្ញុំគួរតែត្រូវចែករំលែកដល់សាធារណជន ។ គាត់មានស្រុកកំណើតនៅខេត្តស្វាយរៀង ហើយគាត់បានផ្លូវទីលំនៅមកកាន់ទីក្រុងភ្នំពេញនៅទសវត្សរ៍៥០ តាមឪពុកម្ដាយរបស់គាត់ដើម្បីរកការងារធ្វើ ។ តារបស់ខ្ញុំរៀនបានជ្រៅជ្រះណាស់ ទោះបីជាពេលនោះគាត់មកពីគ្រួសារដែលមិនសូវធូរធារក៏ដោយ ប៉ុន្ដែគាត់បានបំពេញការសិក្សានៅគ្រប់កម្រិតទាំងអស់ដែលសាលាមាន ។ បន្ទាប់មក គាត់បម្រើការងារនៅស្ថានទូតអាមេរិកក្នុងឋានៈជាមន្ដ្រីលេខាធិការ រហូតដល់ពេលដែលសម្ដេចព្រះ នរោត្ដម សីហនុ បញ្ចប់រាល់ទំនាក់ទំនងជាមួយនឹងសហរដ្ឋអាមេរិក ។ គាត់ត្រលប់មកបម្រើការងារនៅស្ថានទូតម្ដងទៀតនៅពេលមានទំនាក់ទំនងឡើងវិញ ។ លើកនេះ គាត់បម្រើការជាអ្នកកាន់វិទ្យុទាក់ទងខាងពលទាហាន ។ គ្រាមួយ គាត់ប្រាប់ខ្ញុំថាគាត់ធ្វើការនិងត្រួតពិនិត្យលើឃ្លាំងទំនិញរបស់ទ័ពអាមេរិកនៅក្នុងតំបន់អន្លង់វែង ដែលជាផ្នែកមួយនៃជំនួយសហប្រតិបត្តិការ ក្រុមប្រឹក្សាទ័ព ។

ជីតារបស់ខ្ញុំឆ្លាតនិងមានសំណាង ។ នៅក្នុងរបបខ្មែរក្រហម គាត់គួរតែជាមនុស្សម្នាក់ដំបូងគេដែលត្រូវខ្មែរក្រហមសម្លាប់ ដោយសារតែគាត់មានសមត្ថភាព និងមានទំនាក់ទំនងជាមួយនឹងសហរដ្ឋអាមេរិក ។ ពេលនោះ គាត់ត្រូវបានកម្មាភិបាលខ្មែរក្រហមចាប់ដាក់គុក និងបង្ខំឲ្យធ្វើការធ្ងន់ ។ រយៈពេលមួយខែក្រោយមក អង្គការដោះលែងគាត់ដោយសារគាត់បង្ហាញថា គាត់គឺជាមនុស្សធម្មតា ។ លើកទីពីរនោះ កម្មាភិបាលខ្មែរក្រហមបានយកគាត់ទៅឆ្ងាយពីភូមិនៅពេលដែលកម្លាំងទ័ពវៀតណាមចូលមកប្រទេសកម្ពុជា ។ អង្គការត្រូវការមនុស្សបន្ថែមដើម្បីចម្អិននិងនាំយកអ្នករបួស និងអ្នកស្លាប់ពីសមរភូមិ ។

ជារៀងរាល់ថ្ងៃ ជីតារបស់ខ្ញុំតាមដានព័ត៌មានជាតិនិងសារព័ត៌មានអន្ដរជាតិដែលបានចាក់ផ្សាយជាប្រចាំអំពីហេតុការណ៍ដែលបានកើតឡើងនៅជុំវិញពិភពលោក ។ គាត់អានឯកសារនានាដែលទាក់ទងទៅនឹងខ្មែរក្រហមដើម្បីព្យាយាមសិក្សាអំពីអ្វីដែលធ្លាប់បានកើតឡើងនិងស្វែងរកព័ត៌មានថ្មី ។ នៅចុងបញ្ចប់ តាមការសន្ទេបសន្ទនាជាមួយគាត់ គាត់ប្រាប់ខ្ញុំថា ដំណើរការជំនុំជម្រះក្ដីខ្មែរក្រហមគឺជាមធ្យោបាយមួយសម្រាប់រក្សាតម្លាភាពរបស់អតីតមេដឹកនាំខ្មែរក្រហមនិងដាក់ទណ្ឌកម្មចំពោះបទឧក្រិដ្ឋរបស់មេដឹកនាំទាំងនោះតាមផ្លូវច្បាប់ ។ មិនខុសពីជីដូនរបស់ខ្ញុំប៉ុន្មានទេ ជីតាខ្ញុំយល់ឃើញថា ដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញរបស់តុលាការកម្ពុជាគឺពិតជាយឺតពេកហើយ ហើយគាត់សង្ឃឹមថា ដំណើរការនឹងលឿនជាងនេះព្រោះថាអតីតមេដឹកនាំខ្មែរក្រហមកាន់តែចាស់ទៅៗហើយ ។ ដោយឡែកគាត់នៅតែចង់ឃើញអតីតមេដឹកនាំខ្មែរក្រហមត្រូវបានកាត់ទោសឲ្យជាប់គុកអស់មួយជីវិតទោះបីជាមេដឹកនាំទាំងនោះមិនអាចរស់នៅបានយូរប៉ុន្មានក៏ដោយ ។ សម្រាប់ជីតារបស់ខ្ញុំ ការកាត់ទោសបែបនេះតំណាងឲ្យភាពយុត្តិធម៌ ។ គាត់ជឿជាក់ទៀតថា ការជំនុំជម្រះក្ដីនេះក៏ជាផ្លូវមួយដែលបង្ហាត់បង្រៀនដល់ក្មេងៗជំនាន់ក្រោយពីអ្វីៗដែលបានកើតឡើង ក៏ដូចជារំឭកដល់អ្នកដឹកនាំនៅពេលអនាគតអំពីអំពើអាក្រក់ដែលបានកើតឡើង និងកេរដំណែលផ្សាភ្ជាប់តមកដែលនឹងបង្រៀននិងរារាំងក្មេងជំនាន់ក្រោយមិនឲ្យដើរតាមផ្លូវដដែលនាពេលអនាគត ។

ខ្ញុំក៏ជាក្មេងម្នាក់ក្នុងចំណោមអ្នកដែលបានកើតទាន់សម័យចុះហត្ថលេខាលើកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ។ នៅពេលដែលខ្ញុំរស់នៅក្នុងប្រទេសកម្ពុជា ខ្ញុំសឹងតែមិនដឹងអ្វីទាំងអស់ពីរបប

ខ្មែរក្រហម ។ អ្វីទាំងអស់ដែលខ្ញុំធ្លាប់ដឹងគឺសម័យ ប៉ុល ពត គឺអាក្រក់ តែខ្ញុំមិនច្បាស់ថា ប៉ុល ពត គឺជាមនុស្សឬជាអ្វីផ្សេងនោះទេ ។ មិនយូរប៉ុន្មាន នៅពេលដែលខ្ញុំទៅរស់នៅសហរដ្ឋអាមេរិក ខ្ញុំសិក្សាពីអ្វីដែលបានកើតឡើងនៅក្នុងប្រទេសកម្ពុជា ។ ដំបូងពិតជាគួរឲ្យរន្ធត់ណាស់ដែលសិក្សាពីអំពើព្រៃផ្សៃទាំងនេះ ហើយប្រវត្តិសាស្ត្រនេះហាក់ដូចជាមិនគួរឲ្យជឿទាល់តែសោះ ។ តែបន្ទាប់ពីបានសិក្សាកាន់តែលម្អិតពីភាពឈឺចាប់គ្រប់យ៉ាង ការបំផ្លិចបំផ្លាញនៅក្នុងរបបខ្មែរក្រហមញាំញីប្រទេសកម្ពុជា និងបានយល់ដឹងបន្ថែមពីក្រុមគ្រួសារខ្ញុំចាប់ផ្តើមជឿជាក់ថា សម័យខ្មែរក្រហមគឺពិតជាមានសារសំខាន់ខ្លាំងណាស់ ព្រោះប្រវត្តិសាស្ត្រនេះជួយឲ្យមនុស្សជាតិចាប់ផ្តើមសិក្សាពីអតីតកាល និងជំរុញឲ្យមានការពិភាក្សា ដើម្បីរកមធ្យោបាយផ្សះផ្សាជាមួយនឹងអតីតកាលការព្យាបាល និងការរីកលូតលាស់ ទៅមុខនាពេលអនាគត ។ ខ្ញុំក៏យល់ឃើញដូចជាម្តាយរបស់ខ្ញុំដែរ ខ្ញុំគិតថា ដំណើរការរបស់សាលាក្តីខ្មែរក្រហមពិតជាយឺតណាស់ ហើយខ្ញុំមានអារម្មណ៍ក្រេវក្រោធចំពោះដំណើរការនេះ ដោយក្តីបារម្ភចំពោះអតីតមេដឹកនាំខ្មែរក្រហមនឹងស្លាប់មុនពេលទទួលបានការកាត់ទោស លើសពីនេះ ខ្ញុំក៏មានកំហឹងលើការអនុវត្តគោលនយោបាយដែលអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាជួបប្រទះដូចជាដំណើរការរបស់អង្គការសហប្រជាជាតិលើការជំនុំជម្រះក្តីដែលនៅតែបន្តភាពយឺតយ៉ាវ ។ ផ្ទុយទៅវិញ ទាំងនេះគឺមិនមែនជាបញ្ហាចម្បងសម្រាប់ខ្ញុំទេ ទុកឲ្យតុលាការបន្តការស៊ើបអង្កេតឲ្យបានទូលំទូលាយនូវអ្វីដែលបានកើតឡើងចន្លោះឆ្នាំ១៩៧-១៩៧៩ ។ ការរំពឹងទុករបស់ខ្ញុំនេះសង្ឃឹមថាតុលាការនឹងព្យាយាមក្រឡេកមើលបញ្ហាជាសកលនិងរក្សានូវទំនួលខុសត្រូវជនដែលពាក់ព័ន្ធ ។ ខ្ញុំគិតថា អតីតមេដឹកនាំខ្មែរក្រហមមិនមែនជាមនុស្សតែម្នាក់ដែលទទួលខុសត្រូវការជំនុំជម្រះក្តីនោះទេ មានជនដែលជាប់ពាក់ព័ន្ធជាច្រើនទៀតដែលបានប្រព្រឹត្តខុសក្នុងការបណ្តោយឲ្យរបបនេះកើតឡើង ។ រហូតមកដល់ពេលនេះ ជនរួមជាតិទាំងអស់កំពុងតែរង់ចាំនូវការប្រកាសសាលក្រមលើសំណុំរឿង០០២ជាមួយនឹងការរំពឹងទុកផ្សេងៗគ្នា ។ តាមការយល់ឃើញរបស់ខ្ញុំការកាត់ទោសមិនអាចសម្រេចបានឆាប់ៗនោះទេ ដោយសារការអូសបន្លាយនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ហើយក៏ប្រហែលជាមិនទទួលបាននូវយុត្តិធម៌នោះទេ ។ **ស្រីនាថ ភួល**

# ដំណឹងស្វែងរកគ្រួសារ



ខ្ញុំបាទឈ្មោះ ញ៉ាន ស៊ី ធ្វើការនៅក្រសួងដែនដី នគររូបនីយកម្ម និងសំណង់ សូមប្រកាសរកឈ្មោះ អៀវ អៀង ភេទប្រុស អាយុ៨២ឆ្នាំ កើតឆ្នាំ១៩៣៣ នៅភូមិត្រពាំងក្រឡឹង ឃុំតាំងស្យា ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ។ មុនឆ្នាំ១៩៧៥ អៀង ជានាវិក បម្រើការងារនៅកប៉ាល់ក្រុមហ៊ុនមួយនៅប្រទេសសិង្ហបុរី ។ ក្រោយមក អៀង បានមករស់នៅសង្កាត់លេខ៣ ក្រុងភ្នំពេញ ។ អៀង បាត់ខ្លួនក្រោយថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ នៅស្រុកកំពង់ត្រាច ខេត្តកំពត ។ តាមដំណឹងពីប្រជាជនថា អៀង បានត្រឡប់ចូលមកប្រទេសកម្ពុជាវិញ ព្រោះបានប្រទះឃើញគាត់នៅតាមផ្លូវក្នុងស្រុកកំពង់ត្រាចខេត្តកំពត ។ ក្រោយឆ្នាំ១៩៧៩ ប្រពន្ធ និងកូន អៀង បានទៅរស់នៅប្រទេសអាល្លឺម៉ង់រហូតមកដល់សព្វថ្ងៃនេះ ។ ប្រសិនបើបងប្អូនណាបានស្គាល់ ឬឮឈ្មោះ អៀង សូមទាក់ទងមកខ្ញុំបាទតាមរយៈអាសយដ្ឋានលេខ៨៧៦G មហាវិថីព្រះមុនីវង្ស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ ទូរស័ព្ទលេខ ០១២ ៩៥៨ ៥៤៦ អ៊ីម៉ែលៈ nhansy04@yahoo.com ឬទាក់ទងមកមជ្ឈមណ្ឌលឯកសារកម្ពុជា ផ្ទះលេខ៦៦ ផ្លូវព្រះសីហនុ ក្រុងភ្នំពេញ ។ ***សូមអរគុណ!***

# ម្តាយខ្ញុំចាំមិនភ្លេចសម័យបីឆ្នាំ ប្រាំបីខែ ម្ភៃថ្ងៃ

ថ្ងៃមួយក្នុងខែមេសា ឆ្នាំ១៩៧៥ ពេលកំពុងបរិភោគអាហារថ្ងៃត្រង់ ម្តាយរបស់ខ្ញុំនិងក្រុមគ្រួសារត្រូវបានក្រុមយោធាខ្មែរក្រហមជម្លៀសចេញពីទីក្រុង ដោយប្រើពាក្យកុហកបោកប្រាសថាឲ្យចេញទៅតែបីថ្ងៃនឹងត្រឡប់មកវិញ ។ ដោយសារតែពាក្យកុហកនេះ ម្តាយរបស់ខ្ញុំ លោកតាលោកយាយ និងបងប្អូនមីងមាទាំងអស់ត្រូវរៀបចំបង្វិចខោអាវចាកចេញពីផ្ទះ ។



ម៉ៅ ច័ន្ទដាលី

គ្រួសារម្តាយខ្ញុំធ្វើដំណើរដោយថ្មើរជើងចាកចេញទៅស្រុកកំណើតស្ថិតនៅខេត្តកំពង់ចាម ។ ក្រោយមក ម្តាយរបស់ខ្ញុំនិងក្រុមគ្រួសារបានដឹងថាគាត់ចាញ់បោកពាក្យកុហករបស់ក្រុមខ្មែរក្រហម ហើយក្នុងអំឡុងពេលធ្វើដំណើរជាច្រើនថ្ងៃមកនោះ ។ ម្តាយរបស់ខ្ញុំបានជួបប្រទះរឿងជាច្រើនដូចជា ការសម្លាប់ខ្លួនរបស់ក្រុមគ្រួសារអ្នកមានដោយបានបើកឡានចូលក្នុងទន្លេ ការចាប់ខ្លួនមន្ត្រីយោធាដើម្បីយកទៅសម្លាប់ និងឃើញសាកសពជាដើម ។

មកដល់ភូមិព្រែកពោធិ៍ ស្រុកស្រីសន្ធរ ម្តាយរបស់ខ្ញុំ និងបងប្អូនទាំងដប់នាក់របស់គាត់ បានទៅស្នាក់នៅផ្ទះអ៊ំខាងម្តាយខ្ញុំ ។ រយៈពេលដប់ថ្ងៃក្រោយមក មេភូមិមកកត់ឈ្មោះរួចសរសេរលិខិតបញ្ជូនឲ្យទៅនៅកន្លែងប្រជាជនថ្មី ឬប្រជាជន១៧មេសា ។ នៅទីនោះ ម្តាយរបស់ខ្ញុំ និងបងប្អូនរបស់គាត់ត្រូវចេញទៅស្ទូងស្រូវ ។ នៅពេលដែលស្រូវទុំ គាត់ត្រូវច្រូតកាត់ ហើយតែងតែយកឡានមកដឹកប្រជាជនថ្មីនៅពេលយប់ដើម្បីផ្លាស់ទៅកន្លែងថ្មីដើម្បីកសាងខ្លួន ។

នៅទីនោះ អង្គការបានបែងចែកកម្លាំង ដោយមនុស្សចាស់ត្រូវមើលកូន យុវជននិងយុវនារីដែលមានកម្លាំងពេញត្រូវចេញទៅលើកទំនប់ ជីកប្រឡាយ និងដកស្ទូង ។ ហេតុតែធ្វើការសកម្មម្តាយខ្ញុំដែលជាកូនទីបីក្នុងគ្រួសារ និងមានអាយុទើប១៨ឆ្នាំ ត្រូវបានអង្គការបញ្ជូនឲ្យទៅកំពង់ថ្ម ខេត្តកំពង់ធំ ។ ក្រោយពីម្តាយខ្ញុំចាកចេញបាត់ទៅ បងប្រុសទីពីរបានស្លាប់ដោយសារកង្វះជីវជាតិ ចំណែកប្អូនស្រីពៅបានស្លាប់ដោយសារកើតពិសក្នុងមាត់ ។

មិនយូរប៉ុន្មាន យាយតារបស់ខ្ញុំក៏ត្រូវបានអង្គការចាប់យកទៅវាយចោលជាមួយនឹងកូនប្រុសស្រីចំនួនបួននាក់ទៀត ដោយចោទថាជានាយទុន ។ ចុងក្រោយ ម្តាយរបស់ខ្ញុំនៅសល់តែប្អូនប្រុសស្រីពីរនាក់ប៉ុណ្ណោះ ។ នៅក្នុងកងចល័តនារី ម្តាយរបស់ខ្ញុំត្រូវក្រោកតាំងពីម៉ោងបួនព្រឹកទៅជីកប្រឡាយ ទំនប់ និងធ្វើស្រែ ។ ពេលនោះមានមេកងនារីម្នាក់បានមកសួរម្តាយខ្ញុំថា តើមានយកខោអាវមកច្រើនដែរឬទេ ។ គ្រាន់តែឮពាក្យនេះភ្លាម ម្តាយខ្ញុំដឹងថាមានរឿងមិនល្អកើតឡើងចំពោះក្រុមគ្រួសារគាត់ ហើយអ្វីដែលគាត់នឹកស្មានមិនដល់នោះគឺសមាជិកគ្រួសារគាត់ស្លាប់ស្ទើរតែទាំងអស់ ។ ប៉ុន្តែដើម្បីបន្តរស់រានមានជីវិត ម្តាយរបស់ខ្ញុំហាក់ធ្វើជាមិនដឹងរឿងអ្វីទាំងអស់ ។

បន្ទាប់ពីរបបកម្ពុជាប្រជាធិបតេយ្យដួលរលំ ម្តាយខ្ញុំបានមកជួបជុំជាមួយប្អូនប្រុសស្រីដែលនៅសេសសល់ រួចហើយក៏ត្រឡប់មករស់នៅភ្នំពេញ ។ ក្នុងរយៈពេលបីឆ្នាំ ប្រាំបីខែ ម្ភៃថ្ងៃគឺជាពេលវេលាដ៏ជូរចត់ដែលម្តាយខ្ញុំមិនបំភ្លេចបាន ។ **ម៉ៅ ច័ន្ទដាលី**

# សៀវភៅរំឭកវិញ្ញាណក្ខន្ធអ្នកដែលបានស្លាប់
# នៅក្នុងរបបខ្មែរក្រហម










មជ្ឈមណ្ឌលឯកសារកម្ពុជា គ្រោងនឹងបោះពុម្ពផ្សាយនូវសៀវភៅមានកត់ត្រាឈ្មោះរបស់អ្នកដែលស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម ។ កន្លងមក មជ្ឈមណ្ឌលឯកសារកម្ពុជាបានចងក្រងនូវឈ្មោះអ្នកដែលស្លាប់ជាង១លាននាក់រួចមកហើយ ។ ប្រសិនបើលោកយាយ លោកតា អ៊ំ ពូ មីង ប្រាថ្នាចង់ឲ្យឈ្មោះសមាជិកក្រុមគ្រួសារដែលបានស្លាប់បាត់បង់ជីវិតមាននៅក្នុងសៀវភៅនេះ សូមទាក់ទងមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈ អេង កុកថាយ ទូរស័ព្ទលេខ ០១២ ៩៥៥ ៨៥៨ ឬ អ៊ីម៉ែល ៖ truthkokthay@dccam.org ឲ្យបានឆាប់រហ័សតាមពេលវេលាដែលអាចធ្វើទៅបាន ។

**សូមផ្តល់ព័ត៌មានដូចខាងក្រោម៖**

១) ឈ្មោះអ្នកប្រកាសប្រាប់, ២) តើមានបងប្អូនបង្កើតរួមទាំងឪពុកម្តាយស្លាប់ប៉ុន្មាននាក់នៅក្នុងសម័យខ្មែរក្រហម? ៣) ឈ្មោះអ្នកស្លាប់, ៤) ភេទអ្នកស្លាប់, ៥) អាយុអ្នកស្លាប់ (បើអាចចាំបាន), ៦) ត្រូវជាអ្វីនឹងអ្នកប្រកាស (ឧទាហរណ៍៖ ឪពុក ម្តាយ បងប្រុស ប្អូនប្រុស បងស្រី ឬប្អូនស្រី), ៧) សាច់រឿងទាក់ទងនឹងការស្លាប់ (ឧទាហរណ៍ ៖ ស្លាប់នៅទីណា? មូលហេតុអ្វី?), ៨) វត្ថុតាងទាក់ទងនឹងអ្នកស្លាប់ (ឧទាហរណ៍៖ រូបថត ឯកសារ ឬវត្ថុផ្សេងៗ), ៩) ព័ត៌មានសម្រាប់មជ្ឈមណ្ឌលទាក់ទង (ឧទាហរណ៍៖ លេខទូរស័ព្ទ អាសយដ្ឋាន) ។

**ប្រសិនបើចង់ស្វែងរកអ្នកដែលបាត់ខ្លួនសូមផ្តល់ព័ត៌មានខាងក្រោម៖**

១) ឈ្មោះអ្នកបាត់ខ្លួន, ២) ភេទ, ៣) អាយុ, ៤) ត្រូវជាអ្វី, ៥) សាច់រឿងទាក់ទងនឹងការបែកគ្នា, ៦) វត្ថុតាងទាក់ទងនឹងអ្នកបាត់ខ្លួន (ឧទាហរណ៍៖ រូបថត ឯកសារ ឬវត្ថុផ្សេងៗ) ។

ដើម្បីយុត្តិធម៌និងការចងចាំ
ដែលជាមូលដ្ឋានដ៏សំខាន់ក្នុងការផ្សះផ្សាជាតិ


ឧបត្ថម្ភការបោះពុម្ពផ្សាយដោយ ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិ សហរដ្ឋអាមេរិក (USAID)
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មានលេខ ០២៩១ពម.៩៩ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**
ផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ ៖ (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារ ៖ (៨៥៥) ២៣ ២១០ ៣៥៨

DC-Cam/PIR : #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ Fax: (855) 23 210 358 ◆ dccam@online.com.kh ◆ www.dccam.org.
A magazine of the Documentation Center of Cambodia: Searching for the truth. ◆ Number 167, November 2013 ◆ Funded by USAID.
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No.0291 P.M/99, 2 August 1999.